# ព្រះពុទ្ធសាសនាក្នុងជីវិតខ្មែរ

# Buddhism in Khmer life

សិតសំរាំង និងចងក្រងដោយ ខ្លូត ធីតា

Selected Reading *KHLOT THYDA*

LIBRARY
BUDDHIST INSTITUTE

www.budinst.gov.kh www.elibraryofcambodia.org

## ស្នាដៃនេះ

កើតឡើងពីកិច្ចសហការគ្នា រវាង
**ពុទ្ធសាសនបណ្ឌិត្យ** និង **បណ្ណាល័យអេឡិចត្រូនិចខ្មែរ**
ក្នុងគោលបំណងយ៉ាងមុតមាំដើម្បីថែរក្សា ការពារ កុំឲ្យបាត់បង់តទៅទៀត
ព្រមទាំងផ្សព្វផ្សាយស្នាដៃ-ឯកសារទាំងនេះ
សម្រាប់សាធារណជនប្រើប្រាស់ដោយមិនគិតកម្រៃ។

សូមថ្លែងអំណរគុណដល់
**អង្គការរីហ្សូ កូស៊ី-កៃ  វិទ្យាស្ថានបើកទូលាយ**
**ករុណាខ្មែរ និង មូលនិធិខ្មែរសម្រាប់ការសិក្សា**
ដែលបានគាំទ្រគម្រោងការស្នាដៃនេះ សម្រាប់ទុកក្នុងបណ្ណាល័យអេឡិចត្រូនិច។

Buddhist Institute of Ministry of Cult and Religion and eLibrary of Cambodia have made a cooperative effort to digitalize books and manuscripts in order to preserve our Cambodian literary heritage. This will promote and provide easy, instant access, free of charge to the public and future generations to come.

A sincere thank you to our generous supporters: Rissho Kosei-Kai, Open Institute, Karuna Cambodia and Cambodian Education Excellence Foundation, who made this endeavor possible.

www.budinst.gov.kh    www.elibraryofcambodia.org

២១០.៥៧

Buddhism in Khmer life

# សំរិតសំរាំង និងចងក្រងដោយ ខ្លុត ធីតា (បណ្ឌិត)

Selected Reading: KHLOT THYDA (P.h.D)
Vice director
PHILOSOPHY DEPARTMENT



BUDDHIST INSTITUTE LIBRARY
៤៦២៥/២០០០

សាកលវិទ្យាល័យភូមិន្ទភ្នំពេញ ខែសីហា ឆ្នាំ១៩៩៩

*Royal University of Phnom Penh August 1999*

www.budinst.gov.kh www.elibraryofcambodia.org

# មាតិការឿង


ទំព័រ

**អារម្ភកថា** ១

**សេចក្តីផ្តើម** ២

**ផ្នែកទី១ : ចាស់នៅឥណ្ឌាថ្មីនៅខ្មែរ** ៣

ជំពូកទី១ : ព្រះពុទ្ធសាសនាជាអ្វី ? ៣

ជំពូកទី២ : ប្រវត្តិសង្ខេបព្រះពុទ្ធសាសនានៅឥណ្ឌា ២២

ជំពូកទី៣ : អំពីបញ្ហាបួស ២៥

ជំពូកទី៤ : ព្រះពុទ្ធសាសនា នៅខ្មែរ ៤០

**ផ្នែកទី២ : ការរីកចំរើននៃព្រះពុទ្ធសាសនាក្នុងជីវិតខ្មែរ** ៦២

ជំពូកទី១ : វិស័យអប់រំព្រះពុទ្ធសាសនានៅកម្ពុជា ៦២

ជំពូកទី២ : ព្រះពុទ្ធសាសនា និង ច្បាប់រដ្ឋធម្មនុញ្ញ ៧៤

ជំពូកទី៣ : ព្រះពុទ្ធសាសនា ផ្នែកហិនយាន ៧៥

ព្រះសក្យមុនីចេតិយ៍ ៧៥

ប្រវត្តិព្រះឧបោសថរតនារាម ( ព្រះវិហារព្រះកែវមរកត ) ៨១

អំពីវត្តខ្ទមតាយ៉ង ឬវត្តបទុមវតីរាជវរារាម ៨២

ព្រះបដិមាករស្រការលេញ ៩២

ប្រវត្តិពុទ្ធសករាជ ៩២

**ផ្នែកទី៣ : ទស្សនៈអ្នកនិពន្ធ** ៩៥

**សន្និដ្ឋាន** ១០៥


www.budinst.gov.kh www.elibraryofcambodia.org

# កថាមុខ

ជាកិត្តិយសមួយដ៏ប្រពៃណាស់ដែលនាងខ្ញុំបានខិតខំសរសេរសៀវភៅទាំងពានេះបានសំរេច ទោះមិនសូវល្អក្តីក៏ល្អខ្លះក្តី កន្លែងខ្វះខាតចំណុចក្តី កន្លែងខ្វះវិភាគ ក៏នាងខ្ញុំមិនដែលគិតពីការនឿយហត់ម្តងណាទេ ក្នុងការចងក្រងសៀវភៅនេះក៏ដូចក្នុងសៀវភៅមុនៗមួយចំនួន រួមទាំងសៀវភៅដឹកនាំនិស្សិតសរសេរបរិញ្ញាពាំងពីឆ្នាំ ១៩៩៦ មកជាបន្តបន្ទាប់ ។

នាងខ្ញុំបានខិតខំធ្វើការស្រាវជ្រាវទាក់ទងជាមួយក្រសួងធម្មការ សាសនា ពុទ្ធសាសនបណ្ឌិត តាមវត្តអារាម តាមអង្គការព្រះពុទ្ធសាសនាក្រៅរដ្ឋាភិបាលមួយចំនួនថែមទៀត ។

- ◆ ប្រភពទីមួយគឺ "ពុទ្ធប្រវត្តិ" តាមការបកស្រាយនៃព្រះត្រៃបិដក និងការសិក្សាផ្នែកហីនយាន ។
- ◆ ប្រភពទីពីរគឺ " ពុទ្ធប្រវត្តិ " តាមការសិក្សាផ្នែកមហាយាន ។
- ◆ ប្រភពទីបីគឺ " ពុទ្ធប្រវត្តិ " តាមការសិក្សាផ្នែកព្រះពុទ្ធសាសនា ដោយអ្នកប្រាជ្ញខាងបស្ចឹមប្រទេស និងបូព៌ា ប្រទេស។

ទោះបីមានការខ្វះខាត ឬ ឆ្គាំឆ្គងខ្លះ ខាងផ្នែកអក្ខរាវិរុទ្ធក្តី ផ្នែកឃ្លាប្រយោគក្តី សៀវភៅនេះជាវិភាគទានមួយ ។ៗ

នាងខ្ញុំបាននឹកឃើញនូវចំណាររបស់ព្រះមហាសុមេធាធិបតី "ជួនណាត់ជោតញ្ញាណោ" មួយប្រយោគថា " ធម្មតាការងារអ្វីទាំងអស់ក្នុងលោក តែងតែមានភ្លាំងភ្លាត់ខ្លះ បើមិនច្រើនក៏តិចតួចមិនខាន នេះជាទំលាប់នៃការងារបថុជន ព្រោះ ត្រូវជាតូត្រា និងខុស ប៉ុន្តែបើមានត្រូវច្រើន មានខុសតែបន្តិចបន្តួចក៏គង់អាចប្រើការគិត គ្រាន់បើជាងគ្មានសោះទៅដែរ "[១]។

សៀវភៅទាំងបីដែលកើតមានជាបន្តបន្ទាប់ក្នុងឆ្នាំតែមួយនេះមានសារៈសំខាន់បី:

១ - ចំពោះពុទ្ធសាសនិកជនទូទៅ សៀវភៅនេះជាគម្ពីរបង្ហាញប្រវត្តិផ្លាស់ប្តូរព្រះពុទ្ធសាសនា ប្រវត្តិពុទ្ធកិច្ច ប្រវត្តិ មនុស្សជំនាន់មុន ភារកិច្ច កាតព្វកិច្ច ស្នាដៃមនុស្សជំនាន់មុន ។

២ - ចំពោះអ្នកសិក្សាស្រាវជ្រាវផ្នែកវប្បធម៌ សាសនា ទស្សនវិជ្ជា សង្គមវិជ្ជា ចិត្តសាស្ត្រវិទ្យា សៀវភៅនេះជាមូលដ្ឋាននៃចិត្តមនុស្សជាតិផង ជាគោលចារឹកនៃការសិក្សាផ្លូវចិត្ត ចេះថ្លឹងថ្លែងជំនឿរបស់មនុស្សផង ស្គាល់ផ្លូវនាំទំនាស់និងបន្ថយទំនាស់ផងទៀត ។

៣ -ចំពោះអ្នកដឹកនាំសង្គមជាតិសៀវភៅទាំងនេះអាចចាត់ទុកជាក្បួនមគ្គុទេសន្តែនាំទៅរកសុភមង្គលវិបុលសុខដោយយកគុណធម៌និងគតិធម៌មានព្រហ្មវិហារធម៌និងទស្សនិទានធម៌ជាដើមតទ្រូង ។

១-ទឹង ជាន់ សុផុន :ព្រះសមណគោត្តមភាគទី១ សហរដ្ឋអាមេរិច ១៩៩៥ ទំព័រកថាមុខ

# សេចក្តីថ្លែងអំណរគុណ

នាងខ្ញុំសូមថ្លែងអំណរគុណចំពោះ

- ឯកឧត្តម ម៉ឹក ផន និងលោកជំទាវ ម៉ឹក ណារណ្ណា ដែលឯកឧត្តម និងលោកជំទាវបានផ្តល់បច្ច័យបោះពុម្ព ចំនួន១០០ដុល្លា អាមេរិក

- លោកឧកញ៉ា ស៊ិន សុខា និងលោកជំទាវ ឆាន់ ថល្លី ដែលលោកឧកញ៉ា និងលោកជំទាវបានផ្តល់បច្ច័យបោះពុម្ព ចំនួន១០០ដុល្លា អាមេរិក អ្នកស្រី ឌី រដ្ឋា ប្រធានសមាគមឥន្ទ្រទេវីបានផ្តល់បច្ច័យ ៥០ USD

- ក្រុមគ្រួសារខ្ញុំផ្ទាល់ ដែលខិតខំជំរុញដល់ការចងក្រងសៀវភៅនេះ :

**សៀវភៅ**

១- ព្រះពុទ្ធសាសនាក្នុងជីវិតខ្មែរ ( Buddhism in Khmer life )

២- ជំនឿសាសនាលើពិភពលោក ( The beliefs religion in the world )

៣- ទិដ្ឋភាពទូទៅនៃគំនិតខ្មែរ ( Aspect general of Khmer thought )

អំពីនាងខ្ញុំ ខ្លូត ធីតា

www.budinst.gov.kh www.elibraryofcambodia.org

វាយកុំព្យូទ័រដោយ :

១- និស្សិត នួន សោភ័ណ្ឌ ជានិស្សិតទស្សនវិជ្ជាឆ្នាំទី៤ ជំនាន់ទី១៦

២- និស្សិត ជា មុនីឫទ្ធិ ជានិស្សិតទស្សនវិជ្ជាឆ្នាំទី៤ ជំនាន់ទី១៧

៣- និស្សិត គិន ណារ៉ុម ជានិស្សិតទស្សនវិជ្ជាឆ្នាំទី៤ ជំនាន់ទី១៧

៤- និស្សិត ខេង គីមវ៉ៃ ជានិស្សិតទស្សនវិជ្ជាឆ្នាំទី៤ ជំនាន់ទី១៧

សូមជំរាបមិត្តអ្នកស្រាវជ្រាវថា :

១- សៀវភៅ **ព្រះពុទ្ធសាសនាក្នុងជីវិតខ្មែរ** .បោះពុម្ពលើកទី១ : ក្បាលភាគ១ និងភាគ២ចំនួន ១២០ក្បាល នាឆ្នាំ១៩៩៧ ។

បោះពុម្ពលើកទី២.: ១០០ក្បាលរួមធ្វើតែមួយ នា ចុងឆ្នាំ១៩៩៩ ។

២- សៀវភៅ **ជំនឿទូទៅនៃសាសនាលើពិភពលោក** បោះពុម្ពលើកទី១ចំនួន១០០ក្បាល

សូមរង់ចាំអានសៀវភៅទិដ្ឋភាពទូទៅនៃគំនិតខ្មែរក្នុងពេលឆាប់ៗនេះ !

៣- សៀវភៅ **ទិដ្ឋភាពទូទៅនៃគំនិតខ្មែរ** បោះពុម្ពលើកទី១នៅក្រៅប្រទេស គឺនៅសហរដ្ឋអាមេរិកនាដើមឆ្នាំ១៩៩៩មិនទាន់បានទទួលដំណឹងពីចំនួនបោះពុម្ពទេ។ ចុងឆ្នាំ១៩៩៩នេះ នាងខ្ញុំត្រៀមបោះពុម្ពលើកទី២ចំនួន១០០ក្បាលនៅពេលដំណាច់ឆ្នាំ១៩៩៩ ឬដើមឆ្នាំ២០០០។

សូមអរព្រះគុណ និងអរគុណ !

**ខ្លូត ធីតា**

www.budinst.gov.kh www.elibraryofcambodia.org

# ជូនចំពោះលោកអ្នកអាន

កម្រងអត្ថបទទាំងឡាយ ដែលមានក្នុងសៀវភៅ "**ព្រះពុទ្ធសាសនាក្នុងជីវិតខ្មែរ**" គឺជាលទ្ធផលនៃការ ខិតខំប្រឹងប្រែង សិក្សាស្រាវជ្រាវអស់រយៈពេលយ៉ាងយូររបស់នាងខ្ញុំ និងរៀបរៀងដើម្បីស្វែងរកវិធានការនានា ព្រមទាំងបទពិសោធន៍ល្អៗរបស់ចាស់ទុំខ្មែរក្នុងការស្ថាបនាសីលធម៌ពិតស្ថិតស្ថេរយូរអង្វែង។ នេះមិនគ្រាន់តែជា មូលភាពទ្រឹស្តីទេ តែគឺជាតថភាពជាក់ស្តែង ដែលបុព្វបុរសដូនតាខ្មែរ លោកធ្លាប់បានយកមកធ្វើជារូបមន្តសំរាប់ការ ស្ថាបនាសេចក្តីសុខស្ងប់ និងសន្តិភាពមាតុភូមិក្នុងអតីតកាល។ គឺជាការចាំបាច់ណាស់ ដែលប្រជាជាតិខ្មែរត្រូវទទួលស្គាល់ និងប្រកាន់យកគតិបណ្ឌិតវប្បធម៌ និងទស្សនវិជ្ជារបស់ដូនតាខ្លួនសំរាប់ការស្ថាបនាសីលធម៌ល្អរបស់ជាតិឱ្យ ស្ថិតស្ថេរយូរអង្វែងតាមរយៈព្រះពុទ្ធសាសនា។

នាងខ្ញុំជាអ្នកនិពន្ធ និងរៀបរៀងកំរងអត្ថបទ "**ព្រះពុទ្ធសាសនាក្នុងជីវិតខ្មែរ**" យល់ច្បាស់ថា ដើម្បីសន្តិភាពមួយរឹងមាំនៅលើទឹកដីនៃមាតុភូមិកម្ពុជា ដើម្បីស្តារ និងធ្វើឱ្យរស់ឡើងវិញនូវសីលធម៌ និងគុណធម៌ខាងផ្លូវចិត្តគំនិតរបស់ប្រជាពលរដ្ឋខ្មែរ គឺមានតែមធ្យោបាយនេះទេដែលអាចជួយឱ្យខ្មែរគេចផុតពីជម្លោះបែកបាក់ និងសង្គ្រាមវិនាសកម្មបាន។ ជាការពិតណាស់សីលធម៌ល្អពិតរមែងចាប់ផ្តើមពីក្នុងចិត្តគំនិតរបស់បុគ្គលម្នាក់ៗ ហើយវាក៏រីកសាយភាពដល់សមាជិកគ្រួសារ ភូមិស្រុក ខេត្តខ័ណ្ឌ និងសង្គមជាតិទាំងមូល។

ដូច្នេះប្រសិនបើខ្មែរម្នាក់ៗជំរុះអស់នូវគំនុំសងសឹក សេចក្តីខឹងក្រោធ ការស្អប់ខ្ពើម សេចក្តីលោភលន់កេងប្រវ័ញ្ច និងការឈ្នានីស បៀតបៀនគ្នា នោះហើយទើបជនជាតិខ្មែរគ្មានអ្វីត្រូវព្រួយបារម្ភដល់ការស្រុតចុះសីលធម៌ទៀតឡើយ។ ផ្ទុយទៅវិញបើយើងនៅតែប្រកាន់យកការសងសឹក និងគំនុំព្យាបាទរវាងគ្នានិងគ្នា នោះជនជាតិយើង ពិតជាមិនអាចរកឃើញជីវភាពសុខដុមរម្យនាបានយូរអង្វែងឡើយ។ សុខ និងទុក្ខរបស់ប្រជាជាតិខ្មែរ គឺវាអាស្រ័យដោយចិត្តគំនិត និងការប្រព្រឹត្តរបស់ប្រជាជាតិខ្មែរខ្លួនឯងម្នាក់ៗ ព្រោះតាមព្រះពុទ្ធសាសនាថា "**ចិត្ត**" គឺជាប្រភពនៃបញ្ហា និងរឿងហេតុទាំងឡាយ។ កាលណាគេព្រួតព្រា និងគ្រប់គ្រងចិត្តបានប្រកបដោយគុណធម៌ និងគតិបណ្ឌិត ហើយនោះ អ្វីៗទាំងអស់នឹងបានសុខស្រួល និងស្ងប់រំងាប់។ សន្តិភាពពិតប្រាកដរបស់ប្រទេសជាតិ គឺវាចំណុះទាំងស្រុងទៅលើគុណភាពចិត្តគំនិត និងការប្រព្រឹត្តរបស់ជនជាតិយើងម្នាក់ៗ។ គឺមានតែការខិតខំអប់រំចិត្តគំនិតខ្មែរឱ្យប្រកបដោយគុណធម៌ និងគតិបណ្ឌិតទេ ដែលអាចប្រាសចាកការគុំគួន ឈ្នានីស សេចក្តីស្អប់ខ្ពើម ការលោភលន់កេងប្រវ័ញ្ច និងអំពើហឹង្សាគ្រប់បែបយ៉ាង។

ទាំងអស់នេះ គឺជាគោលទស្សនៈ និងខ្លឹមសារនៃកម្រងអត្ថបទដែលជាទស្សនាទានផ្ទាល់របស់នាងខ្ញុំ និងរៀបរៀងក្រោយពីបានខិតខំសិក្សាស្រាវជ្រាវអស់រយៈពេលជាច្រើនឆ្នាំ ដើម្បីរួមចំណែកបញ្ចេញមតិយោបល់របស់ខ្លួនសំរាប់ការស្ថាបនាកសាងចិត្តគំនិតថ្មីៗរបស់ខ្មែរយើងតាមរយៈគោលធម៌ព្រះពុទ្ធសាសនា។

នាងខ្ញុំសង្ឃឹមថា ព្រះតេជព្រះគុណ លោក និងមិត្តអ្នកអានពិតជាអធ្យាស្រ័យចំពោះការខ្វះខាតដោយអចេតនា និងជួយផ្តល់មតិរិះគន់កែលំអ ស្ថាបនា ដើម្បីធ្វើឱ្យអត្ថបទនេះបំរើ បានល្អដល់មាតុភូមិយើង។

រាជធានីភ្នំពេញ, ថ្ងៃទី៣ ខែធ្នូ ឆ្នាំ១៩៩៩

**ខ្លូតធីតា**
នាយករងដេប៉ាតឺម៉ង់ទស្សនវិជ្ជា
(សាកលវិទ្យាល័យភូមិន្ទភ្នំពេញ)

www.budinst.gov.kh www.elibraryofcambodia.org

# អារម្ភកថា

ដើម្បីឱ្យស្គាល់ច្បាស់ពីសង្គមខ្មែរ មនុស្សខ្មែរ យើងគួរតែស្វែងយល់ឱ្យបានច្បាស់ពី ព្រះពុទ្ធសាសនានៅប្រទេសខ្មែរជាមុនសិន ។

ដោយផ្អែកលើមូលដ្ឋានគំនិតខាងលើនេះ យើងខ្ញុំបានខិតខំប្រមូលឯកសារ ដែលពាក់ព័ន្ធនឹងព្រះពុទ្ធសាសនា នៅកម្ពុជាជាច្រើន មកចងក្រងជាអត្ថបទថ្មីមួយ ដោយមានការថែរក្សាអត្ថបទចាស់ខ្លះចំណងជើងថា " ព្រះពុទ្ធសាសនាក្នុងជីវិតខ្មែរ " " Buddhism in Khmer Life " ។

សៀវភៅនេះ យើងខ្ញុំពុំមានបំណងចង់ប្រកែកនូវនាទី និងឥទ្ធិពលអ្វីទេ គឺមានបំណងត្រឹមតែបន្តវេនកុំឱ្យតំណែលវប្បធម៌ដែលមានមក ហើយត្រូវបាត់បង់ទៅវិញនោះទេ ។ ជាងនេះទៅទៀត ដោយយើងខ្ញុំជាអ្នកចូលចិត្តសិក្សាស្រាវជ្រាវព្រះពុទ្ធសាសនាផង ខ្ញុំចង់រួមចំណែកជួយពង្រីកចំណេះដឹងដល់មិត្តអ្នកអាន អ្នកស្រាវជ្រាវបន្ថែមអំពីស្ថានភាពព្រះពុទ្ធសាសនាពីអតីតកាលរហូតបច្ចុប្បន្នថែមទៀត ។

យើងខ្ញុំសូមរង់ចាំការទិតៀនដោយចំហរ ពីសំណាក់មិត្តអ្នកអាន អ្នកសិក្សាស្រាវជ្រាវដោយក្តីរីករាយជាទីបំផុត ។

អ្នករៀបរៀង : ពេជ្រ ខ្លួន ធិតា (សាស្ត្រាចារ្យទស្សនវិជ្ជាផ្នែកសាសនា )

នាយិការង ( ព្រឹទ្ធបុរសរង ) មហាវិទ្យាល័យទស្សនវិជ្ជា

( មហាវិទ្យាល័យសង្គមសាស្ត្រ_មនុស្សសាស្ត្រ សាកលវិទ្យាល័យភូមិន្ទភ្នំពេញ ) ។

បោះពុម្ពលើកទី២



www.budinst.gov.kh www.elibraryofcambodia.org

# សេចក្តីផ្តើម

មនុស្សជាតិលើពិភពលោក តែងមានបំណងចង់ឱ្យខ្លួន ឱ្យប្រទេសជាតិខ្លួនបានលូតលាស់ តាមការអភិវឌ្ឍសង្គម តាមសង្វាក់វប្បធម៌ អរិយធម៌ថែមទាំងចង់ផ្សារភ្ជាប់ជាមួយប្រទេសក្នុងតំបន់ ប្រទេសលើពិភពលោកទៀតផង។ ដើម្បីសំរេចនូវបំណងល្អខាងលើនេះ គេត្រូវឆ្លងកាត់មធ្យោបាយច្រើនបែបយ៉ាងណាស់។ គេអាចឆ្លងតាមវប្បធម៌ ទំនៀមទំលាប់ ជំនឿ សាសនា វិទ្យាសាស្ត្រនិងមានចំណែកតាមរចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋ។

ក្នុងនោះ នៅប្រទេសខ្មែរយើង ប្រជាជនប្រហែល ៩៥ % បានគោរពស្រលាញ់ព្រះពុទ្ធសាសនា បានយកសីលធម៌ព្រះពុទ្ធសាសនារសំយោគជាមួយច្បាប់រដ្ឋសំរាប់ជីវិតគេ ព្រោះព្រះពុទ្ធសាសនា ជាសាសនារបស់រដ្ឋយូរណាស់មកហើយ ហើយក៏ស្ថិតក្នុងចារចនាជាតិទៀតផង។ ម្យ៉ាងវិញទៀត លោក Arnold Toynbee លោកជាអ្នកប្រាជ្ញមួយរូប ដែលបានប្រើប្រាស់អស់១០ វ៉ុលម (Ten Volumes) ដើម្បីស្វែងយល់ពី "ប្រវត្តិមនុស្ស" (History of Man) ។ ការស្រាវជ្រាវរបស់លោក លោកយកសាសនាជាគន្លឹះ (Center)។ គាត់បាន ពោលថា "I have came back to a belief that religion holds the key to mystery of excistence" ( Y Masih : A comparative study of religions, Delhi in 1990, chapter I ) ។ នៅក្នុងលក្ខខណ្ឌនេះ "ព្រះពុទ្ធសាសនានៅក្នុងជីវិតខ្មែរ" គ្រាន់តែ ជាពាក្យដែលមនុស្សជំនាន់ក្រោយបានឮសំរាប់ជាមូលវិចារណ៍ មិនអាចខ្វះបានឬ ? ឬមកពី **បញ្ញាវប្បធម៌**( Culture Intellectuel ) ឬមកពី **សីលវប្បធម៌** ( Culture Morale ) ? " ។ ទន្ទឹមនឹងការអន់ថយ ការវិវត្តរីកចំរើន ឬដើម្បីឱ្យផលប្រយោជន៍ ដែលបានទទួល ក៏ដូចជា ផលប្រយោជន៍ ដែលកំពុងទទួល យើងអ្នកសិក្សាស្រាវជ្រាវគួរខិតខំយ៉ាងណា ដើម្បីជៀសវាងកំហុសឆ្គងបានខ្លះៗ ឬមួយ ក៏នៅតែបណ្តែតបណ្តោយ ឬអាងឆ្លើយថា : មកពីភ័យចក់ស្បាត ភ័យជ្រុះអស់មូលធម៌ គុណធម៌ដដែលនោះ ? ហេតុនេះ នាងខ្ញុំ នឹងសំរាយជូនខ្លះៗនូវបញ្ហាទាំងនេះនាជំពូកខាងក្រោយជាបន្តបន្ទាប់ៗ។

www.budinst.gov.kh www.elibraryofcambodia.org

## ផ្នែកទី១

# ចាស់នៅឥណ្ឌា ថ្មីនៅខ្មែរ

# ANCIENT IN INDIA TO MODERN IN CAMBODIA

### ព្រះពុទ្ធសាសនាជាអ្វី ? ប្រវត្តិសង្ខេបព្រះពុទ្ធសាសនានៅឥណ្ឌា ព្រះពុទ្ធសាសនានៅខ្មែរ

## ជំពូកទី ១

### ព្រះពុទ្ធសាសនាជាអ្វី ?

ដើម្បីឆ្លើយនឹងសំណួរនេះដំបូងយើងគួរយល់ដូចម្តេចដែលហៅថា "**សាសនា**" ជាមុនសិន ?

***សាសនា*** ជាពាក្យក្លាយមកពីពាក្យបាលី និងពាក្យសំស្ក្រឹតថា សាសនៈ (ឝាសនៈ) ដែលវចនានុក្រមរបស់សម្តេចសង្ឃរាជ **ជួន ណាត** បានពន្យល់ថាពាក្យបណ្តាំ ពាក្យផ្តាំផ្ញើ ពាក្យប្រៀនប្រដៅ ការប្រៀនប្រដៅលទ្ធិ ពាក្យបង្គាប់ ការបង្គាប់បញ្ជា ដំណឹង សំបុត្រ ពាក្យប្រកាស ការប្រកាសប្រាប់ ការជឿស្តាប់ ការដាក់ទណ្ឌកម្ម ការផ្ចាល់ទោសការ កែសំរួល ការគ្រប់គ្រង ការត្រួតត្រា ... ។

ពាក្យសាសនៈមានន័យច្រើនដូចខាងលើនេះ។ ប៉ុន្តែ ក្នុងពេលនេះ យើងសូមលើកយក តែន័យត្រឹមពាក្យបណ្តាំ ពាក្យប្រៀនប្រដៅ ឬការប្រៀនប្រដៅប៉ុណ្ណោះ ដើម្បីឱ្យស្មើគ្នានឹងពាក្យសាសនា ដែលត្រូវនឹងពាក្យបារាំងថា Religion ។

យើងអាចឱ្យនិយមន័យថា សាសនា គឺជាពាក្យបណ្តាំ ឬការទូន្មានប្រៀនប្រដៅរបស់គ្រូអាចារ្យណាមួយនៅក្នុងលោក។ នៅលើសកលលោកនេះ មានសាសនាច្រើនណាស់ដូចជា :

- សាសនាព្រាហ្មណ៍ មានដើមកំណើតនៅប្រទេសឥណ្ឌា
- សាសនាព្រះពុទ្ធ មានដើមកំណើតនៅប្រទេសឥណ្ឌា
- សាសនាគ្រឹស្ត មានដើមកំណើតនៅប្រទេសស៊ីរី
- សាសនាអ៊ីស្លាម មានដើមកំណើតនៅប្រទេសអារ៉ាប់
- សាសនាតៅ មានដើមកំណើតនៅប្រទេសចិន
- សាសនាស៊ិន្តូ មានដើមកំណើតនៅប្រទេសជប៉ុន
- សាសនាជេន មានដើមកំណើតនៅប្រទេសឥណ្ឌា ។ល។

www.budinst.gov.kh www.elibraryofcambodia.org

ក្រៅពីសាសនាខាងលើ មានលទ្ធិផ្សេងៗទៀត ដែលមានប្រភពដើមចេញពីទស្សនវិជ្ជាផ្សេងៗ តែការគោរពប្រតិបត្តិ និងជំនឿជាក់របស់គេ មានលក្ខណៈប្រហាក់ប្រហែលនឹងសាសនាដែរ ។

- **ព្រះពុទ្ធសាសនា** គឺជាពាក្យទូន្មាន ប្រៀនប្រដៅរបស់ព្រះសម្មាសម្ពុទ្ធ ដែលព្រះអង្គបានរកឃើញនូវមោក្ខធម៌ ដើម្បីដឹកនាំមនុស្សសត្វទៅរកខានរំងាប់ទុក្ខ ។

ដើមឡើយព្រះពុទ្ធសាសនា មានលក្ខណៈជាទស្សនវិជ្ជាមួយដែលបង្កើតឡើងដោយព្រះពុទ្ធអង្គ ហើយគាត់មានប្រភពចេញពីមនុស្សសុទ្ធសាធ ពុំមែនជាអាទិទេពដូចសាសនាដទៃទៀតឡើយ ។ តែក្រោយមកការអនុវត្ត និងការគោរពបូជារបស់ព្រះពុទ្ធសាសនិកជនចំពោះព្រះអង្គ ព្រះពុទ្ធអង្គក៏មានតួនាទី និងលក្ខណៈប្រហាក់ប្រហែល ដូចជាអាទិទេព ដូចជាក្នុងពេលធ្វើបុណ្យមានផ្សេងៗ ពុទ្ធសាសនិកជន សុទ្ធតែបួងសួងសុំឱ្យព្រះពុទ្ធជួយផ្តល់នូវ សេចក្តីសុខចំរើនដល់ខ្លួនឬនៅពេលដែលលាចាកលោកនេះទៅ សូមឱ្យជួបនឹងព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ។ អាស្រ័យហេតុនេះ យើងអាចនិយាយថា : ព្រះពុទ្ធសាសនា ជាទស្សនវិជ្ជាផងនិងជាសាសនាផង ។

## ១. ប្រវត្តិដើម [១]

### ក. កំណើត និងការចេញនៅសាងផ្នួសរបស់ព្រះពុទ្ធអង្គ

ព្រះពុទ្ធអង្គ ជាព្រះរាជបុត្ររបស់ព្រះបាទ **សុទ្ធោទនៈ** ក្នុងត្រកូលរាជវង្ស គោត្តម ជារាជានៃសម្ព័ន្ធសាក្យ : សោយរាជ្យនៅនគរ កបិលពស្តុ នៅឥណ្ឌាប៉ែកខាងជើង គឺប្រទេសណេប៉ាល់សព្វថ្ងៃនេះ ។

ព្រះមាតាព្រះនាម សិរិ មហាមាយាជាបុត្រីមហាក្សត្រ នៃបក្សសម្ព័ន្ធកោឡុ នៅនគរទេវទហៈ នៅជាប់ព្រំដែនកបិលពស្តុ ។ ព្រះពុទ្ធអង្គទ្រង់ប្រសូត្រនៅថ្ងៃសុក្រ ១៥កើត ពេញបូណ៌មី ខែពិសាខ ឆ្នាំច នៅក្រោមដើមសាលព្រឹក្សក្នុងព្រៃលុម្ពិនិ ស្ថិតនៅចន្លោះព្រំដែន នៃរដ្ឋកបិលពស្តុ និងទេវទហៈ ។

ក្រោយពេលប្រសូត្របាន៥ថ្ងៃ មានព្រាហ្មណ៍ ៨នាក់ បានថ្វាយព្រះនាមចំពោះព្រះរាជកុមារថា **សិទ្ធត្ថៈ** ដែលមានន័យថា : "អ្នកសំរេចប្រយោជន៍គ្រប់យ៉ាង" ។ ក្នុងពេលនេះព្រាហ្មណ៍៧នាក់ បានលើកម្រាមដៃពីរដែល ទាយថា : "បើព្រះរាជកុមារស្ថិតនៅជាក្សត្រ នឹងក្លាយទៅជាស្តេចចក្រពត្តិ តែបើចេញទៅសាងផ្នួស នឹងត្រាស់ដឹងជាព្រះពុទ្ធ គឺបានសំរេចសម្មាសម្ពោធិញ្ញាណ" ។ ប៉ុន្តែ មានព្រាហ្មណ៍ម្នាក់ទៀតឈ្មោះ **កោណ្ឌញ្ញ** ដែលនៅក្មេងជាងគេបានលើកតែម្រាមដៃមួយហើយទាយថា : "ព្រះរាជកុមារពិតជាបានត្រាស់ដឹងជាព្រះពុទ្ធមិនខាន" ។

ក្រោយពេលប្រសូត្របាន៧ថ្ងៃ ព្រះនាងសិរិ មហាមាយាជាព្រះមាតា ទ្រង់សោយទិវង្គត់ចោលព្រះ **សិទ្ធត្ថៈ** ឯព្រះរាជកុមារក៏បានព្រះមាតុច្ឆា របស់ព្រះអង្គព្រះនាម មហាបជាបតិគោត្តមី បីបាច់ថែរក្សា មតរៀងមក ។

ព្រះជន្មបាន១៦ព្រះវស្សា ព្រះសិទ្ធាថ៌ ត្រូវរៀបអភិសេកជាមួយព្រះនាង ពិម្ពាយសោធរា ។ ព្រះបិតាបានបញ្ជាឱ្យគេសាងសង់ប្រាសាទ៣ ថ្វាយព្រះអង្គគង់ប្រចាំទៅតាមរដូវទាំងពាគឺ : ប្រាសាទមួយសំរាប់រដូវក្តៅ ប្រាសាទមួយ

---

[១] លោក ទាវ ណៃហុក : វប្បធម៌អរិយធម៌ខ្មែរ ៣ភ្នា

www.budinst.gov.kh www.elibraryofcambodia.org

ទៀតសំរាប់រដូវរងា និងប្រាសាទមួយទៀតសំរាប់រដូវរំហើយ ។

ព្រះជន្មបាន២៩ព្រះវស្សា ព្រះនាងពិម្ពាយសោធារា ប្រសូតរាជឱរសមួយអង្គ នាម រាហុលកុមារ ។

ក្រោយមកព្រះអង្គទ្រង់ជួបប្រទះនៅទេពនិម្មិត៤យ៉ាង ដែលធ្វើឱ្យព្រះអង្គអផ្សុកយ៉ាងខ្លាំង បានធ្វើឱ្យស្ដេចយាងទៅក្រសាលក្នុងឧទ្យាន ដែលស្ថិតនៅព្រះបរមរាជវាំង ។ ក្នុងពេលចេញទៅក្រសាលទាំង៤លើក ព្រះអង្គបានទតឃើញទេពនិម្មិត៤យ៉ាងគឺ :

- លើកទី ១ ព្រះអង្គទតឃើញមនុស្សជរា
- លើកទី ២ ព្រះអង្គទតឃើញមនុស្សឈឺ
- លើកទី ៣ ព្រះអង្គទតឃើញមនុស្សស្លាប់
- លើកទី ៤ ព្រះអង្គទតឃើញអ្នកបួស

ដោយសារទេពនិម្មិតទាំង៤យ៉ាងនេះ ព្រះសិទ្ធាថ៌ មានការត្រិះរិះពិចារណា និងមានក្ដីសង្វេគចំពោះបញ្ហាជីវិតរបស់សត្វលោកហើយចុងក្រោយនៅរាត្រីស្ងាត់ នាថ្ងៃព្រហស្បត្តិ៍ ១៥ ខែអាសាធ ឆ្នាំថោះ ព្រះអង្គត្រូវតែចាកចោលរាជសម្បត្តិ មហេសី ចាកចោលព្រះរាជបុត្រព្រះនាម **រាហុលកុមារ** ដ៏ជាទីស្រលាញ់ របស់ព្រះអង្គចេញទៅសាងផ្នួស ក្នុងព្រះជន្ម២៩ព្រះវស្សា នៅមាត់ស្ទឹង **អនោមា** ចំងាយ៣០យោជន៍ គឺប្រហែល៤០០ គ.ម ពីព្រះរាជវង្សរបស់ព្រះនគរ ។ ក្រោយពេលបានដឹងថា ព្រះសិទ្ធាថ៌ យាងទៅបួសក្នុងព្រៃមក កោណ្ឌញ្ញព្រាហ្មណ៍និងកូនព្រាហ្មណ៍ឯទៀត៤នាក់ មានសទ្ធាជ្រះថ្លាទៅបួសដែរ ហើយបានតាមបំរើព្រះអង្គ។ អ្នកបួសទាំង៥អង្គនេះ ហៅថា **បញ្ចវគ្គីយ** គឺ **កោណ្ឌញ្ញ វប្បៈ ភទ្ទិយៈ មហានាមៈ** និង **អស្សជិ** ។

លុះបួសរួចព្រះអង្គបានសិក្សារៀនសូត្រ ក្នុងសំណាក់តាបសពីររូប ដែលបានសំរេចឈានជាន់ខ្ពស់ គឺឧទកតាបស និងអាឡារតាបស តែពុំអាចរកឃើញនូវសច្ចធម៌ ដែលជាមាគ៌ារំលត់ទុក្ខសោះឡើយ ។ដូចនេះ ព្រះអង្គសុំលាតាបសទាំងពីររូបចេញទៅស្វែងរកសិក្សាស្រាវជ្រាវដោយព្រះអង្គឯងវិញ ។

### ៦. អំពីការព្យាយាម និងត្រាស់ដឹង

ព្រះអង្គបានខិតខំព្យាយាមតស៊ូស្វែងរក **មោក្ខធម៌** ដែលជាមាគ៌ារំលត់ទុក្ខ អស់រយៈពេល៦ឆ្នាំ លុះត្រាតែទ្រង់បានសំរេចសម្មាសម្ពុទ្ធិញ្ញាណ ។ តែក្នុងដំណាក់កាលដំបូង ព្រះអង្គបានសាកល្បងក្នុងមាគ៌ា ប្រតិបត្តិ ដោយធ្វើឱ្យកាយលំបាកវេទនាយ៉ាងក្រៃលែង ។ ហើយបន្ថយរាបារម្ដងបន្តិច១ រហូតដល់ទ្រង់សោយអាហារប៉ុនផ្លែពុទ្រាក្នុងមួយថ្ងៃ ដើម្បីធ្វើឱ្យព្រះកាយពលរបស់ព្រះអង្គចុះទ្រុឌទ្រោម ស្គមស្គាំង នៅសល់តែរាងឆ្អឹងទៅតាមការប្រព្រឹត្តិយោគ: ធ្វើចិត្តឱ្យបរិសុទ្ធដោយផ្ដាច់ចិត្តចោលពីរូបកាយ ដែលជាមាគ៌ារំលត់ទុក្ខរបស់ព្រាហ្មណ៍តាបសទាំងឡាយធ្លាប់បានប្រព្រឹត្តិកន្លងមក ។ ព្រះសាមណគោតម្ម ទ្រង់ស្ម័យភ្ញាក់រឭកពិចារណាឃើញថា ទុក្ខកិរិយាក្នុងមាគ៌ា **អត្តកិលមថ** ថា **ឧបយោគ** តាមលទ្ធិព្រាហ្មណ៍ គឺជាមាគ៌ា ប្រតិបត្តិឥតប្រយោជន៍ពុំមែនជាវិធីរំដោះឱ្យរួចពីរាងកាយ

www.budinst.gov.kh www.elibraryofcambodia.org

ពីជាតិ ជរា ព្យាធិ មរណៈ របស់សត្វលោកបានឡើយ។ ដូចនេះ ព្រះសមណគោត្តម ទ្រង់ចាប់ផ្ដើមសោយអាហារបិណ្ឌបាត ដោយអនុវត្តតាមមាគ៌ា មជ្ឈិមាបដិបទា កើនឡើងបន្តិចម្ដងៗ ពីមួយថ្ងៃទៅមួយថ្ងៃ រហូតដល់កំរិតជាធម្មតា ញ៉ាំងឱ្យព្រះកាយពលរបស់ព្រះអង្គរីកចំរើនឡើងវិញ។ ប្រការនេះធ្វើឱ្យបញ្ចវគ្គីតាបសអស់ជំនឿដោយយល់ថា ព្រះសមណគោត្តម ពុំអាចរកសម្មាសម្ពុទ្ធិញ្ញាណឃើញទើបនាំគ្នាចេញទៅឆ្ងាយពីសមណគោត្តម។

ក្នុងព្រះជន្ម៣៥ព្រះវស្សា ព្រះសមណគោត្តម ទ្រង់គង់តែម្នាក់ព្រះអង្គឯង ហើយប្រតិបត្តិតាមមាគ៌ាមជ្ឈិមាបដិបទា គឺផ្លូវកណ្ដាលរវាងកាមសុខល្លិកានុយោគ និងអត្តកិលមថានុយោគ។

នៅថ្ងៃពេញបូរមី ខែពិសាខ ព្រះសមណគោត្តម ទ្រង់តាំងសមាធិនៅក្រោមដើមពោធិ៍ព្រឹក្សក្បែរមាត់ស្ទឹងនេរញ្ជរា តាំងពីពេលរសៀលជិតដល់ពេលព្រលប់នាថ្ងៃពេញបូរមីនោះ។ ព្រះសមណគោត្តម បានផ្ចាញ់កិលេសមារដែលកើតក្នុងនិមិត្តនៃសតិអារម្មណ៍របស់ព្រះអង្គ។ ព្រះអង្គទ្រង់កំចាត់បង់នៅពលមារាធិរាជ ដែលតែងមកញាំញីព្រះអង្គ។ រាត្រីបូរមី ខែពិសាខ ព្រះអង្គគង់លើរតនបល្លង្កក្រោមដើមពោធិ៍ព្រឹក្ស :

- ក្នុងបឋមយាម "ពីម៉ោង ១៨០០ ដល់ម៉ោង ២២.០០" ព្រះអង្គបានជ្រួតជ្រាបដឹងច្បាស់នូវបុព្វេនិវាសានុស្សតិញ្ញាណរំឭកនឹកឃើញនូវជាតិរបស់ព្រះអង្គ។
- ក្នុងមជ្ឈិមយាម "ពីម៉ោង ២២.០០ ដល់ម៉ោង ០២.០០" ទ្រង់សំរេចបាននូវចតូបបាតញ្ញាណ ដែលជាទិព្វចក្ខុមើលឃើញច្បាស់នូវមូលហេតុ ដែលជាបច្ច័យទាក់ទងទៅនឹងការកើត ស្លាប់របស់សត្វលោក។
- ក្នុងបច្ឆិមយាម "ពីម៉ោង ០២.០០ ដល់ម៉ោង ០៦.០០ព្រឹក" ព្រះអង្គទ្រង់សំរេចនូវអាសវក្ខយញ្ញាណដោយសារទ្រង់បានពិចារណាបដិច្ចសមុប្បាទញ្ញាណ។

**គ. ព្រះពុទ្ធសាសនា**

ព្រះពុទ្ធសាសនា គឺពុទ្ធដីការទាំងអស់ដែលព្រះពុទ្ធទ្រង់បានសំដែងហើយ អស់រយៈពេល៤៥ព្រះវស្សា ចាប់ពីថ្ងៃដែលព្រះអង្គបានត្រាស់ដឹង។ ពុទ្ធដីការដ៏សំខាន់នោះគឺ បឋមទេសនា ដែលព្រះអង្គទ្រង់បានសំដែងជាដំបូងប្រោសបញ្ចវគ្គិយភិក្ខុ ក្នុងឥសិបតនមិគទាយវ័នក្បែរក្រុងពារាណសី។ បឋមទេសនានោះគឺ :

ធម្មចក្កប្បវត្តនសូត្រ ដែលសំដែងអរិយសច្ចៈ៤យ៉ាង :

- ទុក្ខអរិយសច្ចៈ សេចក្ដីពិតដ៏ប្រសើរអំពីទុក្ខ
- ទុក្ខសមុទយអរិយសច្ចៈ សេចក្ដីពិតដ៏ប្រសើរអំពីផ្លូវដែលនាំឱ្យកើតទុក្ខ គឺតណ្ហា
- ទុក្ខនិរោធអរិយសច្ចៈ សេចក្ដីពិតដ៏ប្រសើរអំពីការរំលត់ទុក្ខ
- ទុក្ខនិរោធគាមិនីបដិបទាអរិយសច្ចៈ សេចក្ដីពិតដ៏ប្រសើរអំពីផ្លូវសំរាប់ប្រតិបត្តិដើម្បីឆ្ពោះទៅរកសេចក្ដីរំលត់ទុក្ខ។

www.budinst.gov.kh www.elibraryofcambodia.org

ព្រះត្រៃបិដកបាលី-ខ្មែរ ដែលខ្មែរយើងធ្វើការបោះពុម្ពហើយទាំង១១០ភាគក៏ពុំមានធម៌ដទៃអំពីគំនិតដែលមានមកហើយក្នុងអរិយសច្ចៈទាំង៤នេះហើយ។

អរិយសច្ចៈទាំង៤ នេះជាធម៌ប្រាប់នូវបញ្ហាផង នូវហេតុដែលនាំឱ្យមានបញ្ហាផង នូវដំណោះស្រាយផង នូវមធ្យោបាយអនុវត្តន៍លុតបញ្ហាដើម្បីសុខសន្តិភាពសំរាប់មនុស្សសត្វទាំងអស់គ្នា។

១. **ទុក្ខអរិយសច្ចៈ** ព្រះពុទ្ធទ្រង់បានឃើញច្បាស់ថា "លោក" នេះឬ "សង្សារ" នេះពោរពេញដោយភាពមិនទៀងទាត់ មិននឹងនរ មិនគ្រប់គ្រាន់ មិនមានខ្លឹមសារ ដែលនិយាយឱ្យខ្លីមកថា ពោរពេញដោយទុក្ខ គឺ

- ជាតិទុក្ខ ទុក្ខព្រោះការកើត
- ជរាទុក្ខ ទុក្ខព្រោះការចាស់គ្រាំគ្រា ប្រែប្រួល
- ព្យាធិទុក្ខ ទុក្ខព្រោះជំងឺតម្កាត់
- មរណទុក្ខ ទុក្ខព្រោះការស្លាប់
- អប្បិយេហិ សម្បយោគទុក្ខ ទុក្ខព្រោះជួបប្រទះនូវសង្ខារដែលមិនជាទីស្រលាញ់ពេញចិត្ត
- បិយេហិវិប្បយោគទុក្ខទុក្ខព្រោះជួបព្រាត់ប្រាស់សង្ខារជាទីស្រលាញ់ពេញចិត្ត
- យម្បិច្ឆំនលភតិតម្បិទុក្ខទុក្ខព្រោះប្រាថ្នាវត្ថុណាហើយមិនបានសំរេចតាមសេចក្តីប្រាថ្នា
- សង្ខិត្តេនបញ្ចុបាទានក្ខន្ធទុក្ខា និយាយសង្ខេបមកបញ្ចក្ខន្ធ គឺសង្ខារទាំងអស់ជាតួនៃសេចក្តីទុក្ខ។ សង្ខារ គឺអ្វីៗទាំងអស់ដែលកើតមកហើយ ទាំងមនុស្ស ទាំងសត្វ ទាំងវត្ថុតែងស្ថិតនៅក្នុងភាព អនិច្ចំ ទុក្ខំ អនត្តា។

ការដឹងច្បាស់អំពីទុក្ខមាន ជាតិទុក្ខ ជរាទុក្ខ ជាដើមសំខាន់ណាស់ ព្រោះថា លុះណាយល់ច្បាស់អំពីទុក្ខទើបរកសុខបាន។ ទុក្ខព្រោះតែការប្រែប្រួលមិនតាំងនៅដដែលនៃស្ថានភាពអ្វីមួយដែលជាទីពេញចិត្ត សុខហើយទៅជាទុក្ខ សប្បាយហើយប្រែជាលែងសប្បាយ ក្លាយជាទុក្ខ ព្រោះអ្វីៗទាំងអស់ កើតរលត់ រកអ្វីជាខ្លឹមសារគ្មានសោះ។ ការពិតលោកទាំងមូលយ៉ាងដូច្នេះឯង។ ការពិត ជាពិតអរិយសច្ចៈ ការពិតជាន់ខ្ពស់ដែលមានគ្រប់សម័យ គ្រប់ទីកន្លែង នៅក្រោមច្បាប់ធម្មជាតិតែមួយដូចគ្នា។

២. **ទុក្ខសមុទយៈ** ហេតុនាំឱ្យមានទុក្ខ គឺតណ្ហា។ តណ្ហា គឺសេចក្តីប្រាថ្នា។ សេចក្តីប្រាថ្នានឹងឯងគឺនាំឱ្យមានទុក្ខ បើអស់ប្រាថ្នាលែងមានទុក្ខ បើនៅតែជាខ្ញុំកញ្ជះតណ្ហា សេចក្តីទុក្ខមានច្រើន។ មនុស្សដែលទៅជាចៅហ្វាយនាយ ជាម្ចាស់ខ្លួនឯង ជាម្ចាស់លើអ្វីៗទាំងអស់ ទើបលែងមានទាសៈនៃតណ្ហា។។ ពោលម្យ៉ាងទៀត គឺអកុសលមូល លោភៈ ទោសៈ មោហៈ នោះឯង ដែលជាមូលហេតុនាំឱ្យមានទុក្ខ។ ហើយប្រព្រឹត្តធ្វើអំពើខុសនាំឱ្យមានវិបត្តិតាំងពីតូចតាចរហូតដល់សង្គ្រាម ហេតុវាមានតែមួយគឺ លោភៈ ទោសៈ មោហៈ ។

និយាយឱ្យខ្លី ឱ្យចំតែម្តង មិនខ្លាចច្រឡំ វិបត្តិទំនាស់ សង្គ្រាមក្នុងប្រទេសណាក៏ដោយ សម័យណាក៏ដោយ

www.budinst.gov.kh www.elibraryofcambodia.org

គឺអកុសលមូលទាំង៣នេះឯងជាហេតុ ។

**៣. ទុក្ខនិរោធ** បើរកឃើញហេតុហើយក៏អាចរកឃើញការរំលត់បញ្ចប់ទុក្ខ គឺនរោធ វិមុត្តិ ការរួចនោះហៅថា សេរីភាពពិតប្រាកដ រួចផុតពីទុក្ខ លែងធ្វើអំពើអាក្រក់ លែងលង់ក្នុងកិលេស គ្រឿងសៅហ្មង លោភៈ ទោសៈ មោហៈនេះឯងហៅថា វិមុត្តិការរួចជាន់ខ្ពស់ ការរំដោះខ្លួនថ្នាក់ខ្ពស់ ជាទីស្ងប់ ជាត្រើយនាយ ជាកន្លែងរំលត់ទុក្ខ ជាកន្លែងអស់ទៅនៃតណ្ហា គឺព្រះនិព្វាន នោះឯងនេះជាសច្ចៈធម៌ទី៣ ។

**៤. ទុក្ខនិរោធគាមិនីបដិបទា** ដើម្បីដល់នូវនិរោធ ដើម្បីអស់ទៅនៃតណ្ហា លោភៈ ទោសៈ មោហៈ ពុទ្ធបរមគ្រូនៃយើងទ្រង់ដាក់ចុះនូវវិធីប្រតិបត្តិ៨យ៉ាង "អរិយមគ្គ(ផ្លូវដ៏ប្រសើរ)" ឬ អដ្ឋង្គិកមគ្គ (ផ្លូវប្រកបដោយអង្គ៨) ដែលហៅថា មជ្ឈិមបដិបទា គឺផ្លូវប្រតិបត្តិជាកណ្តាលបនដល់ :

- សម្មាទិដ្ឋិ ការយល់ត្រូវ
- សម្មាសង្កប្បៈ ការត្រិះរិះត្រូវ
- សម្មាវាចា ការនិយាយត្រូវ
- សម្មាកម្មន្ត ការងារត្រូវ
- សម្មាអាជីវៈ ការចិញ្ចឹមជីវិតត្រូវ
- សម្មាវាយាមៈ ព្យាយាមត្រូវ
- សម្មាសតិ ការនើកត្រូវ
- សម្មាសមាធិ ការតាំង ឬតំកល់ចិត្តត្រូវ

អរិយមគ្គទាំង៨ នេះចែកជា៣គឺ :

- សម្មាទិដ្ឋិ និងសម្មសង្កប្បៈចាត់ជា *បញ្ញាសិក្ខា*ការអប់រំខាងបញ្ញា(អភិវឌ្ឍន៍បញ្ញា)
- សម្មាវាចា សម្មាកម្មន្តៈ និងសម្មាអាជីវៈ ចាត់ជា *សីលសិក្ខា* អប់រំកាយវាចារឱ្យមានសណ្តាប់ធ្នាប់ល្អ កុំឱ្យច្រឡំសបើស ច្រឡាងខាម ឱ្យមានសីលធម៌នៅក្នុងសង្គម មានសុខចំរើន(អភិវឌ្ឍន៍កាយវាចា) ។
- សម្មាវាយាមៈ សម្មាសតិ និងសម្មាសមាធិ ចាត់ជាសម្មាធិសក្ខាអប់រំផ្លូវចិត្ត (អភិវឌ្ឍន៍ចិត្ត) ឱ្យរួចចាកឧបក្កិលេស គឺតណ្ហា លោភៈ ទោសៈ មោហៈ ដែលជាគ្រឿងសៅហ្មងនាំឱ្យបន្តនូវសង្សារ ដែលជាហេតុឱ្យជួបប្រទះ គេចមិនផុតពីទុក្ខសោកគ្រប់បែបយ៉ាង ។

ការប្រតិបត្តិមាគ៌ាទាំង៨ (អដ្ឋង្គិកមគ្គ) ជាហេតុធ្វើឱ្យដល់ឆាប់នូវការអស់ទៅនៃតណ្ហា លោភៈ ទោសៈ មោហៈ ហើយទទួលបាននូវសុខសន្តិភាពសំរាប់ខ្លួនផង សំរាប់មនុស្ស សត្វទាំងអស់គ្នាផង ។

www.budinst.gov.kh www.elibraryofcambodia.org

☆សីលសិក្ខា ដើម្បីមានសីល ត្រូវមានព្រហ្មវិហារធម៌ទាំង៤គឺ :

១- មេត្តា ស្រឡាញ់ រាប់អាន មិនរើសអើង

២- ករុណា អាណិត អាសូរគ្នាជួយសង្គ្រោះគ្នា ជួយដោះទុក្ខធុរៈគ្នា

៣- មុទិតា ជួយត្រេកអរ អនុមោទនា ចំពោះសេចក្តីសុខរបស់អ្នកដទៃ

៤- ឧបេក្ខា រៀនដាក់ចិត្តនៅកណ្តាល មិនរំភើបញាប់ញ័រ ចំពោះលោកធម៌ទាំងពួង មិនលំអៀង ដោយអគតិទាំង៤ គឺ :

- ឆន្ទាគតិ លំអៀង ព្រោះស្រលាញ់ ព្រោះប្រាថ្នាប្រយោជន៍ផ្ទាល់ខ្លួន
- ទោសាគតិ លំអៀង ព្រោះស្អប់ ព្រោះខឹង
- មោហាគតិ លំអៀង ព្រោះវង្វេង ព្រោះល្ងង់ មិនយល់ការពិត
- ភយាគតិ លំអៀងព្រោះខ្លាច

ព្រហ្មវិហារធម៌ទាំង៤យ៉ាងនេះឯង នាំឱ្យមានសម្មាវាចា (វាចាត្រូវ) សម្មាកម្មន្តៈ (ការងារត្រូវ) សម្មាអាជីវៈ (ការចិញ្ចឹមជីវិតត្រូវ)។ នឹងមានព្រហ្មវិហារធម៌ទៅបាន យើងត្រូវតែធ្វើការប្រៀបធៀបខ្លួនយើងទៅនិងអ្នកដទៃ (អត្តានំ ឧបមំ កត្វា) យើងចង់បានសុខ ចង់បានសេចក្តីស្រឡាញ់រាប់អាន អាណិតអាសូរ ចង់មានសេរីភាពសិទ្ធិប្រយោជន៍យ៉ាងណា អ្នកដទៃក៏ចង់បានដូច្នោះដែរ។

☆សមាធិសិក្ខា បណ្តុះចិត្តឱ្យនឹងធឹង អប់រំចិត្តឱ្យស្ថិតនៅក្នុងអារម្មណ៍តែមួយដោយវិធីចំរើនភាវនា។ មនុស្សដែលមានចិត្តអប់រំត្រឹមត្រូវឃើញអ្វីតែងឃើញពិត(យថាភូតំ បជានាតិ)។

☆បញ្ញាសិក្ខា ការដឹងនូវសភាវពិត តាមពិតនេះឯងហើយ ហៅ បញ្ញា។ ប៉ុន្តែ ត្រូវដឹងថាបញ្ញាជាលោកិយគឺចំណេះដឹងទូទៅរបស់ បថុជ្ជន បើខ្វះសីលធម៌ ខ្វះព្រហ្មវិហារធម៌នឹងទៅជាការចេះដឹងរឹងមានះបើមានតែសីលធម៌ ព្រហ្មវិហារធម៌ ប្រាសចាកបញ្ញា នឹងទៅជាមនុស្សចិត្តល្អ តែមិនដឹងអ្វី។ ដូច្នេះ មនុស្សត្រូវបណ្តុះឱ្យកើតមានក្នុងសណ្តាននូវសីលធម៌ ព្រហ្មវិហារធម៌ផងនូវបញ្ញាផង មុនជាងអ្វី១ទាំងអស់ ព្រោះអ្វី១ទាំងអស់ ត្រូវបានមនុស្សជាអ្នកបង្កើតឡើង គឺថាបើគេបានអប់រំមនុស្សដោយ (កាយវាចាចិត្ត) ឱ្យបានល្អហើយ ការអភិវឌ្ឍក្នុងគ្រប់វិស័យដទៃទៀតនឹងបានសំរេចផលល្អយ៉ាងពិតប្រាកដ។

បញ្ញាដែលកើតមានពីការអប់រំបន្ទំចិត្ត តាមរយៈការចំរើនសម្មាធិវិបស្សនា ចាត់ជាបញ្ញាដ៏ខ្ពង់ខ្ពស់បំផុត។ "ព្រះពុទ្ធសាសនាបង្រៀនមនុស្សឱ្យសង្កត់ធ្ងន់លើសតិបញ្ញា ក្នុងមាគ៌ារបស់ជីវិត។ ឱ្យចេះកំចាត់សេចក្តីទុក្ខដោយពិចារណាងាយឃើញដើមហេតុរបស់ទុក្ខ ហើយធ្វើកំណែ និងសំរាយឱ្យត្រឹមត្រូវតាមសេចក្តីពិត មិនឱ្យជឿ ឬប្រកាន់យកផ្លូវដោះស្រាយធូរ១ ងាយ១ ប្រាសចាកហេតុផល" អង់គ្លេសថា "Intelligence"។

ពាក្យ "**សតិ និង បញ្ញា**" ប្រែមកពីពាក្យថា Intelligence នោះ ប្រសិនបើយើងចង់ប្រើពាក្យពុទ្ធ

www.budinst.gov.kh www.elibraryofcambodia.org

សាសនាសុទ្ធ យើងប្រើតែបញ្ញាមួយក៏បានណាស់ទៅហើយ ព្រោះបញ្ញាល្អឬបញ្ញាពិតៗដែលអភិធម្មយើងឱ្យឈ្មោះថា "សោភណចេតសិក" នោះត្រូវមានសតិទៅក្នុងនោះផងដែរ ដែលលោកឱ្យឈ្មោះម្យ៉ាងទៀតថា "បញ្ញាជាសហគតៈជាមួយនិងសតិ" ។ ធម្មតាជាទូទៅនៃពុទ្ធសាសនាមិនមានធម្មៈណាស្ដីដល់ជំនឿ ហើយគ្មានស្ដីដល់បញ្ញាផងទេ ។ សទ្ធា និងបញ្ញាត្រូវតែជាប់ទាក់ទងជាមួយគ្នាយ៉ាងណា សតិ បញ្ញាក៏ត្រូវបានជាសហគតៈធម៌និងគ្នាយ៉ាងនោះដែរ ព្រោះធម៌ទាំងអស់នេះត្រូវបានចាត់ចូលក្នុងសោភណចេតសិកដូចគ្នា ។

**ពុទ្ធឱវាទ** (SACRED APHORISM)

សេចក្ដីស្អប់មិនអាចបញ្ចប់ដោយសេចក្ដីស្អប់បានជាដាច់ខាត មានតែសេចក្ដីស្រឡាញ់ទេ ដែលអាចបញ្ចប់សេចក្ដីស្អប់បាន ។ នេះជាច្បាប់ពីបុរាណ ។

ដំបូន្មានរបស់ព្រះពុទ្ធដែលហៅថា "ពុទ្ធសាសនា ឬពុទ្ធវចនៈ ឬក៏ពុទ្ធឱវាទ" មានច្រើនណាស់ ក្នុងគម្ពីរបានពោលថាមានដល់ទៅ៨៤.០០០ព្រះធម្មខន្ធ តែបើនិយាយចោះយកតែគោលសំខាន់ៗ មានត្រឹមតែ៣ប្រការគឺ :

- កុំប្រព្រឹត្តិអំពើបាប
- ចូរសាងព្រួសបណ្ដុះអំពើល្អ
- ចូរធ្វើចិត្តឱ្យបានបរិសុទ្ធ

ពុទ្ធឱវាទទាំង៣ប្រការនេះ ប្រដៅសង្កត់ធ្ងន់លើសច្ចធម៌ ចង់ឱ្យអ្នកសិក្សា ដឹងច្បាស់ ឃើញច្បាស់ តាមហេតុផល តាមហេតុផលនៃការគិតទាំងឡាយ និងប្រដៅក្នុងគោលសំខាន់ សំរាប់ធ្វើជីវភាពឱ្យប្រព្រឹត្តិទៅបានស្រួលដោយឱ្យចេះដឹងដោយខ្លួនឯង ហើយនិងប្រដៅឱ្យចេះស្គាល់អធ្យាស្រ័យអ្នកដទៃ ធ្វើខ្លួនឱ្យចូលនិងអ្នកដទៃបានស្រួល ជាធម៌ដែលមនុស្សគ្រប់វ័យ គ្រប់ភេទ ក្នុងសង្គមនាំយកទៅបដិបត្តិគ្រប់ពេលវេលា ។

ជាការពិត ព្រះពុទ្ធសាសនាប្រដៅមនុស្សឱ្យស្គាល់ហេតុ ស្គាល់ផល ស្គាល់ប្រមាណ ស្គាល់កាលៈទេសៈ និងស្គាល់បរិស័ទ ស្គាល់បុគ្គល នេះជាសេចក្ដីចំរើន នេះជាសេចក្ដីវិនាស នេះគួរធ្វើ នេះមិនគួរធ្វើ ដូច្នេះជាដើម ។ ក្នុងគម្ពីរធម្មបទ មានពុទ្ធគាថាជាង៣០០ ដែលព្រះអង្គទ្រង់សំដែងទាក់ទងនិងបុគ្គល ឬសង្គមមនុស្ស :

- វាបានជេរអញ វាបានចំអកឡកឡឺយឱ្យអញ វាបានវាយអញ ។ ដរាបណា បុគ្គលនៅតែរក្សាគំនិតបែបនេះ កំហឹងរបស់គេនឹងមិនចប់ទេ ។

ដរាបណាគំនុំនៅតែមានក្នុងចិត្ត កំហឹងក៏នៅតែមានដែរ ។ ប៉ុន្តែ បើកាលណា គំនុំវិនាសអស់ហើយ នោះកំហឹងក៏វិនាសអស់ដែរ ។

ផ្ទះដែលដំបូលធ្វើមិនល្អ ធ្លុះធ្លាយដោយអន្ទើ ទឹកភ្លៀងនឹងលេចចូលទៅក្នុងផ្ទះ ។ ដូចគ្នានេះដែរ ចិត្តដែលបង្ហាត់មិនបានល្អ ហើយដែលមិនអាចត្រួតត្រាបាននោះ គំនិតលោភលន់នឹងចូលទៅញាំញីបានមិនខានឡើយ ។

ការនៅទំនេរស្ងៀម ជាផ្លូវទៅកាន់សេចក្ដីស្លាប់ ។ ការឧស្សាហ៍រៀសរវៃ ជាផ្លូវសំរាប់ជីវិតរស់នៅ ។ បុគ្គល

www.budinst.gov.kh www.elibraryofcambodia.org

ឆ្កួតលីលាទៅទំនេរស្មៀម ចំណែកបុគ្គលល្អជាបណ្ឌិតមានការឧស្សាហ៍ ភ្ញាក់រ វៃ ។

អ្នកធ្វើព្រួញខំធ្វើព្រួញឱ្យបានត្រង់ ។ ដូចគ្នានេះ បុគ្គលជាបណ្ឌិតខំរក្សាចិត្តគេឱ្យបានត្រឹមត្រង់ ។

ចិត្តសៅហ្មងកំរើកជានិច្ច លោតពីទី១ ទៅទី១ពិបាកគ្រប់គ្រងណាស់ ។ ផ្ទុយទៅវិញ ចិត្តស្ងប់មានភាពស្ងប់ ។ ដូច្នេះ ការរក្សាចិត្តឱ្យបាននៅស្ងប់ ជាគតិបណ្ឌិត ។

ពុំមែនសត្រូវទេ គឺពិតជាចិត្តរបស់ខ្លួនផ្ទាល់តែម្តង ដែលដឹកនាំទៅកាន់ផ្លូវអាក្រក់ ។

បុគ្គលដែលចេះការពារចិត្តរបស់ខ្លួន ទប់ទល់និងសេចក្តីលោភលន់ សេចក្តីខឹងក្រោធ អំពើអាក្រក់ នឹងបានប្រកបសេចក្តីស្ងប់ពិតប្រាកដមិនចេះចប់ ។

- មានវាចាល្អ តែមិនធ្វើតាម អាចប្រៀបបានទៅនឹងផ្កាមានពណ៌ស្រស់ល្អ តែឥតក្លិនក្រអូប ។

គន្ធពិដោរនៃផ្កា មិនក្រអូបបញ្ច្រាស់ខ្យល់ទេ ។ តែកេរ្តិ៍ឈ្មោះល្អរបស់មនុស្ស ទើបអាចផ្សព្វផ្សាយគ្រប់ទិសទីបញ្ច្រាស់ខ្យល់បាន ។

រាត្រីកាលហាក់ដូចជាយូរណាស់ ចំពោះអ្នកដេកមិនលក់ ផ្លូវដើរហាក់ដូចជាឆ្ងាយណាស់ ចំពោះអ្នកធ្វើដំណើរដោយលំបាក ។ ដូចគ្នានេះ ពេលវេលានៃការយល់ច្រឡំ និងទុក្ខព្រួយហាក់ដូចជាវែងឆ្ងាយណាស់ ចំពោះអ្នកមិនយល់សិក្ខាបទពិតប្រាកដ ។

កាលណាគេធ្វើដំណើរ គេគួរតែដើរជាមួយ និងមិត្តម្នាក់ ដែលមានសតិបញ្ញាស្មើនិងគេឬខ្ពស់ជាងគេ ។ តែគេគួរដើរម្នាក់ឯង ល្អជាជាងដើរជាមួយមនុស្សឆ្កួតលីលា ។

គេខ្លាចសត្វសាហាវ តែគេគួរខ្លាចមិត្តអាក្រក់ច្រើនជាងសត្វសាហាវ ។ សត្វសាហាវបណ្តាលឱ្យមានរបួសត្រឹមតែរូបកាយ តែមិត្តអាក្រក់បណ្តាលឱ្យមានរបួសដល់បេះដូង ។

ដរាបណាគេមិនអាចគ្រប់គ្រងចិត្តរបស់គេបាន គេមិនអាចបោះបង់គំនិតថា "នេះជាកូនរបស់អញ" ឬ "នេះជាទ្រព្យសម្បត្តិរបស់អញ" បានទេ ។ បុគ្គលល្ងង់ខ្លៅរងទុក្ខនិងគំនិតរបៀបនេះ ។

"ល្ងង់ហើយដឹងខ្លួនថាល្ងង់ វាប្រសើរជាងល្ងង់ហើយនឹកស្មានថាខ្លួនជាបណ្ឌិត ។

ស្លាបព្រាមិនអាចដឹងរសជាតិនៃម្ហូប ដែលដួសឡើងនោះទេ ។ ដូចគ្នានេះ បុគ្គលល្ងង់ ( ឆ្កួត ) មិនអាចយល់គតិបណ្ឌិតរបស់អ្នកប្រាជ្ញបណ្ឌិតបានឡើយ ទោះបីបុគ្គលនោះរស់នៅជាមួយអ្នកប្រាជ្ញបណ្ឌិតនោះក៏ដោយ ។

ពាមធម្មតា ដូចជាទឹកដោះស្រស់ ដែលមិនងាយនឹងកករ៉ឹងភ្លាមៗ អំពើអាក្រក់មិនផ្តល់ហេតុផលភ្លាមៗទេ ។ អំពើអាក្រក់ដូចជារងើកភ្លើងដែលកប់ក្នុងផេះ ហើយដែលនៅទីបំផុតឆេះឆ្អៅឡើង ។

ការសង្វាតរកប្រយោជន៍ឯកសិទ្ធ រកឋានន្តរសក្តិ រកកំរៃ រកកិត្តិយស ជាការឆ្កួត ។ ការប្រាថ្នាទៅលើវត្ថុទាំងនោះ មិនអាចនាំមកនូវសុភមង្គលបានទេ ផ្ទុយទៅវិញគឺរឹតតែបន្ថែមទុក្ខព្រួយ ។

មិត្តល្អដែលបង្ហាញសេចក្តីយល់ច្រឡំ និងកំហុសរបស់អ្នក ដល់អ្នកដែលស្តីប្រដៅអ្នកអំពីអំពើអាក្រក់របស់

www.budinst.gov.kh www.elibraryofcambodia.org

អ្នក គួរជាទីគោរព បីដូចជាមិត្តនោះបានប្រាប់ទីលាក់កំណប់មួយដល់អ្នក ។

- បុគ្គលដែលសប្បាយរីករាយនិងការទូន្មានល្អ អាចដេកលក់ដោយសុខស្ងប់ ព្រោះចិត្តរបស់គេត្រូវបានលាងស្អាតហើយ ។

ជាងធ្វើផ្ទះខំធ្វើធ្នឹមផ្ទះឱ្យបានត្រង់ល្អ ។ អ្នកធ្វើព្រួញខំធ្វើព្រួញឱ្យបានត្រឹមត្រូវតាមកំហិត ។ អ្នកជីកប្រឡាយបង្ហូរទឹកបញ្ចូលស្រែ ខំធ្វើយ៉ាងណាឱ្យទឹកបានហូរស្រួល ។ ដូចគ្នានេះ បុគ្គលជាបណ្ឌិតខំគ្រប់គ្រងចិត្តរបស់គេឱ្យមានដំណើរស្រួល ឱ្យមានភាពត្រឹមត្រង់ ។

ដុំថ្មធំមិនអាចរញ្ជួយដោយសារខ្យល់ទេ ។ ដូចគ្នានេះ ចិត្តរបស់បុគ្គលជាបណ្ឌិត មិនអាចរញ្ជួយដោយសារកិត្តិយស ឬការប្រមាថមើលងាយឡើយ ។

ជំនះខ្លួនឯងបាន ជាមហាជោគជ័យមួយធំជាងឈ្នះសត្រូវមួយពាន់នាក់ ក្នុងលានប្រយុទ្ធទៅទៀត ។

រស់តែមួយថ្ងៃហើយបានស្តាប់ឮសេចក្តីប្រៀនប្រដៅវិសុទ្ធល្អ ប្រសើរជាជាងរស់មួយរយឆ្នាំ ហើយពុំបានស្តាប់ឮសេចក្តីទូន្មានល្អវិសុទ្ធ ។

បើស្រឡាញ់ខ្លួនតែងតែឃ្លាំមើលវាជានិច្ច កុំឱ្យវាធ្លាក់ទៅក្នុងចំណង់អាក្រក់ ។

លោកនេះជាភ្លើងឆេះជានិច្ច ឆេះដោយភ្លើងលោភលន់ ភ្លើងកំហឹង ភ្លើងល្ងង់ខ្លៅ ។ តែងតែរត់គេចពីគ្រោះថ្នាក់ទាំងនេះជាបន្ទាន់ ។

លោកនេះដូចជាពពុះទឹក ដូចជាសរសៃសំបុកពីងពាង ដូចជាក្អែលនៃក្អមកខ្វក់ ។ បុគ្គលរាល់រូបតែងតែរក្សាការពារភាពបរិសុទ្ធរបស់ខ្លួនជានិច្ច ។

- ចូរជៀសវាងអំពើអាក្រក់ទាំងអស់ ចូរស្វែងរកអំពើល្អ ចូររក្សាចិត្តឱ្យបានបរិសុទ្ធ ។ ទាំងនេះហើយជាសេចក្តីទូន្មានរបស់ព្រះពុទ្ធ ។

សេចក្តីអំនត់ ជាវិន័យមួយក្នុងចំនោមវិន័យដែលពិបាកបំផុតវាងតេបង្អស់ ។ ប៉ុន្តែ មានតែអ្នកមានអំណត់ទេ ដែលត្រូវទទួលជោគជ័យជាសំរេច ។

កាលណាគេកើតមានគំនុំ គេត្រូវតែកំចាត់គំនុំនោះចោល ។ កាលណាគេមានចិត្តបាក់ទៅលើសេចក្តីលោភលន់ គេត្រូវតែកំចាត់សេចក្តីលោភលន់នោះចោល ។ ដើម្បីរស់នៅក្នុងជីវភាពប្រកបដោយសប្បុរសធម៌ ត្រូវតែមើលមកខ្លួនឯងថា គ្មានអ្វីទាំងអស់ដែលជាកម្មសិទ្ធរបស់ខ្លួន ។

មានសុខភាពល្អ ជាអត្ថប្រយោជន៍ធំមួយ ។ សប្បាយរីករាយនឹងឃើញគេឯទៀតមានធនវាប្រសើរជាជាងមានសម្បត្តិស្តុកស្តម្ភផ្ទាល់ខ្លួន ។ ធ្វើឱ្យអ្នកឯទៀតមានការទុកចិត្ត ជាសញ្ញាមិត្តភាពពិតប្រាកដ ។ បានសំរេចពន្លឺត្រាស់ដឹង ជាសុភមង្គលខ្ពស់បំផុត ។

កាលណាគេបានវៀរចាកអំពើអាក្រក់ កាលណាគេបានប្រកបអារម្មណ៍ស្ងប់ កាលណាគេបានមានចិត្តរីក

វាយនិងបាននទទួលយកដំបូន្មានល្អ គេនឹងបានចាកផុតពីក្តីបរម្ភខ្វាច ។

ចូរកុំជំពាក់ចិត្តនិងអ្វីៗដែលអ្នកចូលចិត្ត ចូរកុំរុញច្រានអ្វីៗដែលអ្នកមិនចូលចិត្ត ។ សេចក្តីព្រួយសេចក្តីខ្លាច និងសេចក្តីជាប់ជំពាក់ទាំងនេះ មកអំពី ការចូលចិត្ត និងការមិនចូលចិត្តនេះឯង ។

- ច្រែះកើតមកអំពីដែក ហើយស៊ីទំលុះដែក ។ ដូចគ្នានេះអំពើអាក្រក់កើតចេញអំពីចិត្តហើយទំលុះស៊ីចិត្តវិញ ។

សៀវភៅដែលគេមិនដែលបើកមើលជារឿយៗ ឆាប់ជាប់ធូលី ។ ផ្ទះដែលគេមិនជួលជុលឱ្យទាន់ពេលវេលា មុខជាទ្រុឌទ្រោមបាក់បែក ។ ដូចគ្នានេះបុគ្គលដែលរស់នៅក្នុងភាពទំនេរខ្ជិល នឹងទៅជាអសោជមួយរំពេច ។

អំពើអាស់អាភាសនាំអោយខូចដល់កិត្តិនាមនារី ។ ការកំណាញ់ស្វិតនាំខូចទាយជ្ជទាន ។ ដូចគ្នានេះអំពើអាក្រក់នាំឱ្យខូចជីវិតបច្ចុប្បន្ននិងជីវិតអនាគត ។

មន្ទិលសៅហ្មងដែលគួរឱ្យខ្លាចជាងគេបង្អស់ គឺមន្ទិលសៅហ្មងនៃសេចក្តីល្ងង់ខ្លៅ ។ គេមិនអាចសង្ឃឹមនឹងធ្វើខ្លួនហើយនឹងចិត្តរបស់គេ ឱ្យបានបរិសុទ្ធទេដរាបណាគេមិនកំចាត់សេចក្តីល្ងង់ខ្លៅចេញ ។

ការរអិលធ្លាក់លើអំពើឥតអៀនខ្មាស់ ឡើងចិត្តគេឃ្លើន ការឡើងឡឹតក្រអឺតក្រអោងដូចមាន់គក ការប្រព្រឹត្តអាក្រក់ទៅលើអ្នកដទៃ ដោយគ្មានចិត្តចេះគិតស្តាយក្រោយ ជាការងាយស្រួលណាស់ ។ ប៉ុន្តែការធ្វើខ្លួនឱ្យបានសុភាពរាបសារ ការចេះគោរព និងផ្តល់កិត្តិយសដល់អ្នកដទៃ ការមិនជាប់ជំពាក់ចិត្ត ការរក្សាគំនិត និងអំពើរបស់ខ្លួនឱ្យបានបរិសុទ្ធការធ្វើខ្លួនឱ្យបានជាបណ្ឌិត ជាការលំបាក ។

ការមើលឃើញកំហុសអ្នកដទៃជាការងាយស្រួល ក៏ប៉ុន្តែការមើលឃើញកំហុសរបស់ខ្លួនជាការពិបាក ។ គេប្រកាសកំហុសអ្នកដទៃយ៉ាងលើវំពង តែគេលាក់កំហុសរបស់របស់គេផ្ទាល់ ដូចជាអ្នកលេងបៀលាក់សន្លឹកបៀ ។

មេឃាមិនទុកដានទៃសត្វបក្សាបក្សី ដាននៃផ្សែង ឬដាននៃខ្យល់ព្យុះទេ ។ សេចក្តីទូន្មានអាក្រក់មិនដឹកនាំទៅកាន់ពន្លឺត្រាស់ដឹងទេ ។ នៅក្នុងលោកនេះគ្មានអ្វីដែលមិនប្រែប្រួលនោះទេ ។ ប៉ុន្តែ អ្នកបានទទួលពន្លឺត្រាស់ដឹងនិងបានស្ថិតនៅក្នុងសេចក្តីស្ងប់ឥតប្រែប្រួលរហូត ។

- ដូចជាឆ្មាំដែលយាមរក្សាទ្វារវាំងប្រាសាទ បុគ្គលរាល់រូបត្រូវតែរក្សាការពារចិត្តរបស់ខ្លួនទប់ទល់សត្រូវទាំងខាងក្រៅ និងទាំងខាងក្នុង ហើយកុំប្រហែសវាអោយសោះ ។

យើងជាម្ចាស់លើខ្លួនយើង យើងទីពឹងលើខ្លួនយើង ។ ហេតុនេះយើងតែងតែគ្រប់គ្រងខ្លួនយើងផ្ទាល់ ។

ជំហានទីមួយក្នុងការរំដោះវិញ្ញាណឱ្យរួចផុតពីច្រវាក់ និងចំណងលោកិយត្រូវតែគ្រប់គ្រងចិត្តរបស់ខ្លួនចៀសវាងការនិយាយច្រើនឥតប្រយោជន៍ ត្រូវតែមានស្មារតីប្រុងប្រយ័ត្ន ។

ព្រះអាទិត្យបំភ្លឺលោកនៅពេលថ្ងៃ ព្រះច័ន្ទធ្វើអោយរាត្រីមានសម្រស់ អាវក្រោះធ្វើអោយទាហ៊ានរឹតតែខ្លាំង ។ ដូចគ្នានេះការចំរើនភាវនាដោយស្ងប់ជាកិច្ចសំគាល់អ្នកដែលស្វែងរកពន្លឺត្រាស់ដឹង ។

www.budinst.gov.kh www.elibraryofcambodia.org

បើកាលណាគេមិនបានរក្សាការពារវិញ្ញាណទាំង៥របស់គេ ពោលគឺ ភ្នែក ត្រចៀក ច្រមុះ អណ្ដាតនិងរូបទាំង៥ហើយចេះគ្រប់គ្រងចិត្ត បុគ្គលនោះអាចព្យាយាមចិត្តប្រកបដោយជោគជ័យដើម្បីសំរេចពន្លឺត្រាស់ដឹងបាន ។

- បើកាលណាគេលុងក្នុងអំណាចនៃការចូលចិត្ត និងការមិនចូលចិត្ត គេមិនអាចយល់ឱ្យបានត្រឹមត្រូវអំពីន័យនៃកាលៈទេសៈទេ ហើយដោយហេតុនេះគេតែងតែខំដណ្ដើមយកឈ្នះចាញ់ ។ បើកាលណាគេចាកផុតពីការជំពាក់ចិត្ត គេនឹងយល់យ៉ាងត្រឹមត្រូវអំពីកាលៈទេសៈ ហើយអាស្រ័យហេតុនេះគេនឹងឃើញថាវត្ថុទាំងអស់នឹងប្រែប្រួល ។

សុភមង្គលតាមក្រោយទុក្ខព្រួយ ទុក្ខព្រួយតាមក្រោយសុភមង្គល ។ ប៉ុន្តែ បើកាលណាគេមិនធ្វើការវែកញែករវាងទុក្ខព្រួយ និងសុភមង្គល រវាងល្អ និងអាក្រក់នោះ គេមិនអាចបានស្គាល់នៅសុខសេរីពិតប្រាកដទេ ។

ព្រួយបារម្ភនិងអនាគត ហើយស្ដាយស្រណោះនៅអតីត ប្រដូចបាននឹងដើមប្របេសដែលគេកាត់បាលស្ងួត ។

សេចក្ដីជាអាថ៌ ដើម្បីសុខសួស្ដីនៃរូបកាយវិញ្ញាណ គឺមិនសោកស្រណោះនៅអតីតមិនព្រួយបារម្ភអំពីអនាគតជាធម្មតា ។

ចូរកុំគិតទាក់ទាមពីអតីត ចូរកុំរង់ចាំអនាគត កិច្ចតែមួយគឺ ត្រូវរស់នៅប្រកបដោយចិត្តនឹងនក្នុងបច្ចុប្បន្នកាលនេះឯង ។

ការបំពេញកិច្ចបច្ចុប្បន្នឱ្យបានល្អ ជាការប្រសើរមួយ ចូរកុំទីកខំចៀសវាងកិច្ចបច្ចុប្បន្ន ឬទុកវាទៅថ្ងៃស្អែក បើអ្នកបំពេញកិច្ចបច្ចុប្បន្ននេះឱ្យបានសមរម្យល្អបាន គឺអ្នករស់នៅដោយសប្បាយរីករាយបានមួយថ្ងៃ ។

គ្មានអ្នកបំភ្លឺណាប្រសើរជាងអ្នកគតិធម៌ទេ គ្មានមិត្តណាប្រសើរជាងគំនិតជ្រះថ្លាទេ ។ បុគ្គលទាំងឡាយតែងវត់គេចចេញអន្ធពាលនៃសេចក្ដីល្ងង់ខ្លៅ និងទុក្ខព្រួយ ហើយខំស្វែងរកពន្លឺត្រាស់ដឹង ។

កាលណាគេគ្រប់គ្រងកាយ និងចិត្តគេបាននេះជាសញ្ញានៃអំពើប្រកបដោយគុណធម៌ នេះជាករណីកិច្ចខ្ពង់ខ្ពស់បំផុត ។ ពេលនោះជំនឿជ្រះថ្លានិងបានជាសម្បត្តិសេចក្ដីស្មោះត្រង់ និងផ្ដល់រស់ជាតិផ្អែមត្រជាក់ហើយការប្រមូល សន្សំកុសលផលបុណ្យនេះនឹងបានជាករណីកិច្ចនេះប្រសើរបំផុត ។

ក្នុងដំណើរនៃជីវិតជំនឿជ្រះថ្លា ជាចំណីអាហារ គុណធម៌ជាទីជំរក គតិធម៌ជាពន្លឺនៅពេលថ្ងៃ ការចេះប្រុងប្រយ័ត្ន ដ៏ត្រឹមត្រូវ គឺជាសំភារៈការពារនៅពេលយប់ ។ បុគ្គលណាចេះរស់នៅក្នុងជីវិតស្អាតបរិសុទ្ធគ្មានអ្វី អាចមកបំផ្លាញបានឡើយ ។ បុគ្គលណាបានឈ្នះសេចក្ដីលោភលន់គ្មានអ្វីអាចកំណត់ព្រំដែននៃសេរីភាពរបស់គេបានទេ ។

គេតែងតែបំភ្លេចខ្លួនគេដើម្បី សេចក្ដីស្នេហាដល់គ្រួសារ ។ គេតែងតែលះបង់គ្រួសាររបស់គេដើម្បីសេចក្ដីស្នេហាភូមិស្រុកគេ ។ គេតែងតែបំភ្លេចភូមិស្រុកគេ ដើម្បីសេចក្ដីស្នេហាប្រទេសជាតិរបស់គេ ។ ជាសំរេចគេតែងបំភ្លេចអ្វីៗទាំងអស់ដើម្បីបំពេញសេចក្ដីត្រាស់ដឹង ។

www.budinst.gov.kh www.elibraryofcambodia.org

អ្វី១ទាំងអស់សុទ្ធតែប្រែប្រួលអ្វី១ទាំងអស់កើតឡើងតែងវិនាសទៅវិញជាធម្មតា គ្មានសេចក្តីសុខសព្វត់ទេ ដរាបណាគេមិនបានឆ្លងកាត់ដំណាក់កាលប្រែប្រួលនៃការរស់ និងការស្លាប់នេះ ។

ព្រះពុទ្ធសាសនាបានបង្រៀនឱ្យសង្កត់ធ្ងន់លើសតិ បញ្ញាលើទង្វើរបស់ជីវិត ។ ឱ្យគេកំចាត់សេចក្តីទុក្ខដោយពិចារណាឱ្យឃើញដើមហេតុនៃទុក្ខ ហើយធ្វើកំណែ និងសំរាយឱ្យបានត្រឹមត្រូវ តាមសេចក្តីពិតមិនឱ្យជឿប្រកាន់យកផ្លូវដោះស្រាយយ៉ាងធូរងាយ១ប្រាសចាកហេតុផល ។

ពាក្យថា "សតិ និងបញ្ញា" ប្រែពីពាក្យថា **Intelligience** នោះបើយើងចង់ប្រើពាក្យព្រះពុទ្ធសាសនាគឺយើងប្រើតែពាក្យបញ្ញាមួយក៏បានណាស់ទៅហើយព្រោះបញ្ញាល្អ ឬបញ្ញាពិត១ដែលគម្ពីរអភិធម្មយើងបានអោយឈ្មោះថា : "សោភណចេតសិក" នោះត្រូវត្រូវមានសតិទៅក្នុងនោះផងដែរ ដែលឱ្យឈ្មោះថាបញ្ញាជាសហគតៈជាមួយនិងសតិ ។

បញ្ញាដែលគេយល់ថាលំបាក ឬមានសេចក្តីស្មុគ្រស្មាញនោះវាពិតជាអញ្ចឹងមែនហើយព្រោះរឿងនេះវាធ្លាប់មានការប្រឆាំងប្រទាំងទើសគ្នាយូរមកហើយ តែបើគេយល់ពុទ្ធចិន្តាថាជាធាតុមានលក្ខណៈជាវិទ្យាសាស្ត្រ ឬមានលក្ខណៈប្រកបដោយហេតុផល នោះភាពលំបាក និងភាពស្មុគ្រស្មាញរបស់គេក្នុងរឿងនេះ វាពុំអាចប្រព្រឹត្តទៅបានទៀតទេពុទ្ធសាសនាបង្រៀនមនុស្សតាមបែបយ៉ាងប្រជាធិបតេយ្យ ឬបង្រៀនគំនិតជាប្រជាធិបតេយ្យ ឬ បង្រៀនមានលក្ខណៈជាប្រជាធិបតេយ្យនោះ គេមិនត្រូវបំភ្លេចធាតុជាប្រជាធិបតេយ្យរបស់ព្រះពុទ្ធសាសនា គឺជាប្រជាធិប-តេយ្យនៅក្នុងក្របខ័ណ្ឌនៃសីលធម៌ ឬនិយាយម្យ៉ាងទៀតថា គឺជាប្រជាធិបតេយ្យដែលមានលក្ខណៈជាប្រជាធិបតេយ្យពិត១ផង មានលក្ខណៈជាប្រជាធិបតេយ្យធម្មាផង ។ ជាពិសេសប្រជាធិបតេយ្យដែលមានធម្មាធិបតេយ្យជាមូលដ្ឋាន ។ គឺមតិភាគច្រើនបានដាក់ជាគោលគំនិតនៃការអនុម័ត ឬការវិនិច្ឆ័យ នៅក្នុងលក្ខខណ្ឌនៃធម៌វិន័យ ឬច្បាប់ រដ្ឋទើបយកជាបានការ ប្រសិនគំនិតភាគច្រើនមិនប្រកាន់យក ធម្មវិនិច្ឆ័យ ឬច្បាប់រដ្ឋ ជាបន្ទាត់នៃការអនុម័តមិនអាចអនុវត្តកើត ពុំអាចយកជាបានការឡើយ ។ ដោយអាស្រ័យហេតុនេះទើបព្រះពុទ្ធសាសនាកាលណាមានសម័យប្រជុំលោកតម្រូវអោយស្នើរញត្តិ ឬស្ម័យោបល់ ដោយសូត្រប្រកាសឱ្យបានច្រើន ដើម្បីទុកឱ្យសមាជិកប្រជុំមានពេលត្រិះរិះពិចារណាឱ្យឆ្លើយល្មមមុននឹងចេញមតិថា "ទេ" "ឬ" "អើ" យ៉ាងណាក៏ដោយចុះមតិភាគច្រើនត្រូវតែមានភាពត្រឹមត្រូវមានប្រសិទ្ធិភាពជាងមតិភាគតិច ។ ដូចនេះទើបព្រះសម្មាសម្ពុទ្ធព្រះអង្គបដិសេធមតិបុគ្គល ឬគណៈ ហើយយកមតិសង្ឃជាមតិវិនិច្ឆ័យដាច់ខាត ។ ព្រោះអ្វី ? ព្រោះមតិភាគច្រើនទោះជាម្តេចម្តាក៏គង់មានប្រសិទ្ធិភាពជាងមានពន្លឺជាងមតិភាគតិចជានិច្ច ។ បើសិនអង្គប្រជុំមានសមត្ថភាពប្រហែលគ្នា តែបើភាគច្រើនមានសមត្ថភាពខ្សោយជាងភាគតិចនោះបញ្ហាមុខជាមិនឈប់ចោទទេ ។ ដោយអាស្រ័យហេតុនេះទើបព្រះពុទ្ធសាសនាទាញស្មារតីអ្នកវិនិច្ឆ័យឱ្យលះបង់អគតិធម៌ ៤ ។ ខ្ពស់ជាងនេះ គឺហាមជនល្ងង់មិនឱ្យធ្វើការតំណាងជាតិ ។

ចំនុចមួយទៀតព្រះពុទ្ធសាសនាបានសរសើរមនុស្សដែលមានការសិក្សាច្រើន មានបញ្ញាវាងវៃពីកំណើត

www.budinst.gov.kh www.elibraryofcambodia.org

មានការពិសោធន៍ក្នុងការងារមានគំនិតប្រកបដោយពន្លឺក្នុងគតិលោកគតិធម៌ មានចម្បាស់ក្នុងការអនុវត្តមានលទ្ធផលល្អច្រើនលើកច្រើនគ្រាមកហើយមានជីវិតរស់នៅក្នុងព្រហ្មវិហារយូរមកហើយ ។ ជាមួយគ្នានេះខ្លួនយើងជាមនុស្សរស់នៅលើបង្អែកនៃគំនិតជាក់លាក់ច្បាស់លាស់ ។

ពុទ្ធភាសិតថា " **ធីរិយេន ទុក្ខ មច្ចេតិ** " គេឆ្លងអន្លង់ទុក្ខបានដោយអាស្រ័យព្យាយាមដែលមានបញ្ញាជាដៃគូនោះ ។ពុទ្ធភាសិតនេះបានសង្កត់ធ្ងន់លើកំហឹង និងពន្លឺ ប្រសិនបើយើងអនុវត្តភាសិតនេះបាន ប្រជាធិបតេយ្យក្តី ធម្មាធិបតេយ្យក្តីនឹងមានវឌ្ឍនភាពដល់ទិសដៅរបស់មនុស្សជាមិនខាន ដរាបណាគេខំស្រាវជ្រាវសាកល្បងពិសោធន៍ឱ្យឃើញសេចក្តីខ្លួនឯងជារឿយៗលុះត្រាបានជួបសេចក្តីពិត ឬការភ្លឺស្វាងដោយខ្លួនឯង ។ ដរាបនោះ ទើបគេមានជំនឿមួយបែបដែលមិនចាំអាស្រ័យការគោលដៅ ឬស្តាប់សេចក្តីបំភ្លឺអ្នកដទៃ ។ នេះជាគុណសម្បត្តិរបស់ពិសេសរបស់មនុស្សដែលពុទ្ធសាសនាត្រូវការចង់បាន ។ តែអស់រយៈកាលយូរណាស់មកហើយមនុស្សបែបនេះនៅតែមានមិនច្រើនដដែល ។ តើដល់ពេលណាទៅទើបខ្មែរយើងមានប្រជាធិបតេយ្យ និងធម្មាធិបតេយ្យសំបូរបាន ។

## **ប្រជាធិបតេយ្យ** Democracy

ព្រះពុទ្ធសាសនារបស់យើងជាតួយ៉ាងនៃលទ្ធិប្រជាធិបតេយ្យបរមបុរាណរបស់ពិភពលោក មានគោល និងពិធីកម្មយ៉ាងទាន់សម័យ តាំងពីកាលនោះ របួតដល់សព្វថ្ងៃនេះ ។

ជាដំបូងនេះយើងត្រូវស្គាល់ថា ពាក្យ *ប្រជាធិបតេយ្យ* ដែលគេបានប្រែពីភាសាអង់គ្លេសថា Democracy នោះមានអត្ថន័យដូចម្តេច រួចហើយយើងត្រូវពិចារណាទៅទៀតថា ព្រះពុទ្ធសាសនាដែលរាប់ថាជាតួយ៉ាងនៃលទ្ធិប្រជាធិបតេយ្យយ៉ាងមានចំណាស់ជាទីបំផុតរបស់ពិភពលោកចុះនេះមានគោលការណ៍អ្វីខ្លះ និងពិធីកម្មទាន់សម័យដូចម្តេចខ្លះ ?

ពាក្យថា *ប្រជាធិបតេយ្យ* យើងត្រូវញែកជាពីរបទគឺ *ប្រជា* និង *ធិបតេយ្យ* ។ *ប្រជា* គឺប្រជាជន *ធិបតេយ្យ* គឺភាពធំ ។ ដូចនេះ *ប្រជាធិបតេយ្យ* ប្រែថា ប្រជាជនមានភាពធំ ពាក្យនេះមានន័យប៉ុនគ្នា ឬជិតតែនឹងស្មើគ្នានិងពាក្យរបស់អង់គ្លេសហើយ ។ គឺពាក្យអង់គ្លេសថា Democracy មកពីពាក្យក្រិចថា Demokratia ពាក្យនេះញែកបានជាពីរ Demo = ប្រជាជន, Kratia = អំណាច ។ កាលបើប្រើរួមគ្នាមានសេចក្តីត្រូវនឹងពាក្យអង់គ្លេសថា People's Power ( អំណាចរបស់ប្រជាជន ) ។

ពាក្យនិយាមរបស់ពាក្យប្រជាធិបតេយ្យយ៉ាងខ្លីថា " ប្រជាធិបតេយ្យ គឺជារូបនៃការគ្រប់គ្រង ឬរបបគ្រប់គ្រងដែលប្រជាពលរដ្ឋគ្រប់ជាន់ថ្នាក់មានអំណាចខ្ពង់ខ្ពស់បំផុត ព្រមទាំងប្រើអំណាចនោះតាមអ្នកតំណាងរបស់ខ្លួនអ្នកនោះ គឺជាអ្នកតំណាងរាស្ត្រ ។

Democracy is a form of government in which the People retain supreme power and exercise their power through representative.

www.budinst.gov.kh www.elibraryofcambodia.org

ប្រទេសក្រិចត្រូវបានអ្នកប្រវត្តិសាស្ត្រឱ្យឈ្មោះថា ប្រទេសដែលឱ្យកំណើតនៃលទ្ធិប្រជាធិបតេយ្យមុនគេក្នុងពិភពលោក។ ព្រោះហេតុដូចនេះ ពាក្យអង់គ្លេសដែលមានន័យត្រូវគ្នានឹងពាក្យបាលីថា ប្រជាធិបតេយ្យដូចបានពោលមក ទើបត្រូវជាពាក្យដែលមានឫសគល់មកពីភាសាក្រិចនឹងឯង។

កាលណាគេត្រួតពិនិត្យមើលប្រវត្តិសាស្ត្រក្នុងចំនុចថា ប្រជាធិបតេយ្យរបស់ក្រិចចាប់ផ្តើមកើតមានឡើងនៅក្នុងពេលណា អ្នកណាជាអ្នកបង្កើត។ គេនឹងបានឃើញនូវពាក្យជជែកគ្នានៃពួកអ្នកប្រវត្តិសាស្ត្រ ដែលមានការមិនស្របយោបល់គ្នាជាច្រើន។ អ្នកខ្លះថា *សូឡូន* (Solon) អ្នកមានកំណើតប្រមាណ៥៣៨ឆ្នាំមុនគ្រឹស្តសករាជ ក្នុងរយៈវេលាស្របពេលនិងព្រះពុទ្ធបានត្រាស់។ បុគ្គលនេះត្រូវបានគេដាក់ឈ្មោះថា *ជាបិតានៃប្រជាធិបតេយ្យរបស់ក្រិច* អ្នកខ្លះថា *គ្លីសាធេនីស* (Gleisthenes) ដែលកើតក្រោយសូលូនប្រមាណ១០០ឆ្នាំជាអ្នកបង្កើត និងត្រូវបានគេលើកតំកើងថា *ជាបិតានៃប្រជាធិបតេយ្យរបស់ក្រិច* ។ តែដោយគេទទួលស្គាល់ទាំងអស់គ្នានូវសេចក្តីរីកចំរើននៃលទ្ធិនេះរបស់ក្រិចវិញ គឺក្នុងសម័យរបស់*ប៉េរីសគ្លីស*(Pericles) ជាសម័យផងគ្នានឹងសូក្រាត(Socrates) និងប្លាតូ(Plato) ទាំងអស់គ្នានេះសុទ្ធតែជាទស្សនវិទូមានកេរ្តិ៍ឈ្មោះល្បីល្បេចរបស់ជនជាតិក្រិច ដែលគេប៉ាន់ស្មានថាមានរយៈវេលាបន្តបន្ទាប់គ្នាមកពីសម័យនៃគ្លីសធេនីសមិនដល់១០០ឆ្នាំ។

គេអាចនឹងមើលបានដោយញែករយៈវេលាស្របពេលគ្នា ឬឃ្លាតឆ្ងាយពីគ្នាមិនដល់១០០ឆ្នាំ គឺ :

១- រយៈដំបូង កាលពី៥៩៤ឆ្នាំមុនគ្រឹស្តសករាជ សម័យដែលសូលូនកែប្រែរដ្ឋធម្មនុញ្ញរបស់ក្រិច ជាគ្រាទី១ ដែលមានសភាប្រជាជន (Popular Assembly) ។

២- រយៈជាបន្ទាប់ កាលពី៥០៩ឆ្នាំមុនគ្រឹស្តសករាជ សម័យគ្លីសធេនីស កែប្រែរដ្ឋធម្មនុញ្ញរបស់ក្រិចម្តងទៀតដោយឱ្យប្រជាជនបានទទួលសិទ្ធិសេរីភាពកាន់តែមានចំនួនច្រើនឡើងជាងមុន។

៣- រយៈចុងក្រោយ កាលពី៤៦១ឆ្នាំមុនគ្រឹស្តសករាជ ដែលរាប់ថាជាសុវណ្ណយុគ្គរបស់ក្រិច គឺជាយុគ្គដែលប៉េរីសគ្លីស អ្នកប្រកាន់យកយ៉ាងខ្ជាប់ខ្ជួននូវគោលការណ៍ប្រជាធិបតេយ្យតាមបែបគ្លីសធេនីស បានស្ថាបនាពង្រីកបន្ថែមឱ្យលទ្ធិប្រជាធិបតេយ្យរបស់គ្លីសធេនីសរីកចំរើនដល់ថ្នាក់ទីបំផុតក្នុងយុគ្គនោះ។

ទាំង៣រយៈនេះ មានវេលាជិតៗគ្នាក្នុងចំនួន៣០០ឆ្នាំប៉ុណ្ណោះ។ រយៈដំបូង ជារយៈស្របពេលគ្នានឹងពុទ្ធកាល ចំណែករយៈទី២ ក្រោយពុទ្ធកាល ឬក្រោយពុទ្ធបរិនិព្វាន ព្រះសម្មាសម្ពុទ្ធនិព្វានកាលពី៥០៧ឆ្នាំមុនគ្រឹស្តសករាជ។

ដើម្បីឱ្យអ្នកអានឆាប់ចូលចិត្តរឿងនេះឲ្យាស់លាស់ ខ្ញុំសូមផ្តល់គំនិតជាថ្មីទៀតចំពោះដំណើរប្រព្រឹត្តទៅនៃព្រឹត្តិការណ៍ដែលជាប់ទាក់ទងគ្នាជាមួយលទ្ធិប្រជាធិបតេយ្យរបស់ក្រិចទាំង៣រយៈកាល។ ដើម្បីងាយស្រួលដល់ការប្រៀបធៀបគ្នារវាងប្រជាធិបតេយ្យរបស់ក្រិច និងប្រជាធិបតេយ្យដែលព្រះសម្មាសម្ពុទ្ធប្រទានទុកមក។ តែយើងទាំងអស់គ្នាមិនត្រូវភ្លេចថា ប្រជាធិបតេយ្យរបស់ក្រិច ជានយោបាយប្រើបានទាំងផ្នែកកុសល ទាំងផ្នែកអកុសល។ ចំណែកប្រជាធិបតេយ្យរបស់ព្រះពុទ្ធ ជាធាតុនយោបាយប្រើបានតែខាងផ្នែកកុសល។ ធាតុទាំងពីរយ៉ាងនេះយើង

www.budinst.gov.kh www.elibraryofcambodia.org

មិនអាចចាត់ទុកថាដូចគ្នាទាំងអស់បានទេ ចំនុចដែលយើងត្រូវធ្វើសេចក្តីកត់សំគាល់នូវភាពត្រូវគ្នា និងភាពប្លែកគ្នា នៃធាតុទាំងឡាយ ( ប្រជាធិបតេយ្យរបស់ក្រិច និងប្រជាធិបតេយ្យរបស់ពុទ្ធសាសនា) នោះមិនមែនផ្អែកទៅលើរបស់អ្វីដទៃក្រៅពីគោលការណ៍នៃធាតុទាំងអស់នេះទេ ។

ក្នុងសម័យសូឡូនកែប្រែរដ្ឋធម្មនុញ្ញរបស់ក្រិចនោះ វាជាហេតុមួយ លើកតំកើងឱ្យខ្លួនគាត់បានទទួលកិត្តិយស ថាជាបិតានៃប្រជាធិបតេយ្យរបស់ក្រិច ។ គឺក្នុងសម័យដែលប្រទេសក្រិចកំពុងមានការគ្រប់គ្រងបែបអភិជនាធិបតេយ្យ (Aristocracy) គឺមានបទជនដែលគេទុកដាក់ថាមានជីវិតរស់នៅក្នុងថ្នាក់ជាន់ខ្ពស់ មានភាពជាធំ គឺជាអ្នកកាន់អំណាចទូទៅក្នុងប្រទេស ហើយដែលគេហៅម្យ៉ាងទៀតថាជនកើតក្នុងត្រកូលខ្ពស់ហ្នឹងឯង ។ គឺមានតែជនពួកទាបថោកទាំងអស់នេះសុទ្ធតែជាកូនបំណុលរបស់ជនថ្នាក់ខ្ពស់ស្ទើរតែគ្មានសល់ម្នាក់ឡើយ ។ កូនបំណុលទាំងឡាយប្រសិនបើគ្មានសមត្ថភាពរកប្រាក់សងម្ចាស់បំណុលតាមពេលដែលគេកំណត់ទុកឱ្យនោះទេ ។ ទាំងអស់គ្នាគេចមិនផុតពីត្រូវគេរឹបអូសយកខ្លួនទៅធ្វើជាទាសៈឡើយ ។ ទោះជាបំណុលនោះត្រូវកើតមានឡើងម្តងម្កាល តាមការចាំបាច់ដែលតំរូវឱ្យខ្ចី ឬចងការក៏ដោយ ។ ការចាំបាច់ ឬពេលចាំបាច់របស់អ្នកក្រីក្រនោះមានជាអាទិ៍ ពេលច្រូតកាត់ផលស្រូវ ពេលផ្តើមប្រកបរបរដំណាំ ពេលមានគ្រោះថ្នាក់ដោយមិនដឹងខ្លួនជាមុន ។ សូឡូន ជាអ្នកអារកាត់សម្រេចសេចក្តីលើកចោលច្បាប់ជំពាក់បំណុល មិនយល់ព្រម ឬមិនអនុញ្ញាតឱ្យម្ចាស់បំណុលរឹបអូសយកកូនបំណុលទៅធ្វើជាទាសៈរបស់ខ្លួន ឬយកទៅលក់ឱ្យធ្វើជាទាសៈអ្នកដទៃ ។ យ៉ាងណាក៏ដោយចុះ ការកែប្រែរដ្ឋធម្មនុញ្ញរបស់សូឡូននាសម័យនោះ ក៏នៅពុំទាន់មានប្រសិទ្ធភាពសម្រាប់មនុស្សលោកពេញលេញនៅឡើយ ។ សូឡូនខ្លួនឯង នៅតែចែកមនុស្សជា៤ថ្នាក់គឺ : អ្នកមានធំ អ្នកមានមធ្យម អ្នកមានតិច និងអ្នកទីទ័លក្រ ។ នៅក្នុងន័យនេះមានតែពួកអ្នកមានស្តុកស្តម្ភមួយពួកប៉ុណ្ណោះទេ ដែលមានសិទ្ធធ្វើនយោបាយដោយគ្មានកំនត់ក្របខ័ណ្ឌ មនុស្សដែលគេទុកដាក់ថាមានធំ មានមធ្យម មានតិច និងទីទ័លក្រនោះ គេមានកំនត់បរិមាណ ឬចំនួនយ៉ាងទៀងទាត់ពីប៉ុននេះទៅប៉ុននោះ ត្រូវបានធ្វើជាអ្នកមានធំ ។ល។ ប្រហាក់ប្រហែលគ្នានឹងប្រទេសឥណ្ឌាក្នុងជំនាន់ព្រះពុទ្ធបានត្រាស់ គេបានកំនត់ចំនួនទ្រព្យសំរាប់អ្នកមានតាមថ្នាក់ជាន់អញ្ចឹងដែរ ។ អ្នកមានគួរធ្វើសេចក្តីកំនត់សំគាល់ និងសេចក្តីចងចាំថា មនុស្សដែលជាកម្មករ ឬទីទ័លក្រនោះ ត្រូវបានគេចាត់ទុកក្នុងប្រភេទទី៤ ( ប្រភេទទន់ខ្សោយបំផុត ) ។

នៅក្នុងសម័យជាមួយគ្នានេះ ព្រះសម្មាសម្ពុទ្ធបានបញ្ញត្តិវិន័យឱ្យភិក្ខុសង្ឃមានអំណាចគ្រប់គ្រងពួកគណៈ ( ទិត្ថប្រតិបត្តិ ) មានសិទ្ធិបញ្ចេញមតិបដិសេធចោលនូវច្បាប់ណាដែលខ្លួនមិនយល់ស្របផង ។ ទាំងអស់នេះភិក្ខុសង្ឃធ្វើបានដោយមិនមានព្រំដែន គឺគ្មានកំនត់ថាភិក្ខុណាកើតក្នុងត្រកូលខ្ពស់ ឬទាបឡើយ ។ នៅក្នុងន័យនេះព្រះសម្មាសម្ពុទ្ធបានធ្វើសេចក្តីបញ្ជាក់ថា ភិក្ខុទាំងឡាយតាមតែចេញចាកត្រកូលណាក៏ដោយ ស្តុកស្តម្ភ ឬខ្សត់ខ្សោយ កាលណាមកបួសជាភិក្ខុសាមណេរ ឬប្រគល់កាយថ្វាយខ្លួនជាមួយ និងចិត្តញ្ញាណ ហើយរស់នៅជាគ្រហស្ថប្រតិបត្តិធម៌វិន័យក្នុងសាសនាតថាគត អ្នកទាំងអស់គ្នានេះត្រូវមានសិទ្ធិសេរីភាពស្មើគ្នាតាមកំពស់នៃធម៌ដែលខ្លួនរស់នៅ ។សូម្បី

www.budinst.gov.kh www.elibraryofcambodia.org

( សេចក្ដីប្រកាន់រឹងត្អឹង) ឱ្យមានកំលាំងកាន់តែច្រើនឡើងៗ ហើយផលវិបាកនៃការប្រកាន់យកខុសនេះ វាជាប្រភពនៃជម្លោះតាំងពីតូចៗ រហូតដល់ធំជាទីបំផុត ដែលគេនិយមហៅថា ចំបាំងជូចសព្វថ្ងៃនេះ ។

ព្រះសម្មាសម្ពុទ្ធពិតជាបានប្រទានសមត្ថភាព ឬភាពស្មើគ្នាដល់ពុទ្ធសាសនិកទាំងឡាយ ។ ជាពិសេស គឺភិក្ខុសង្ឃមែន តែសមភាពនោះពុំមែនជាសមភាពគ្មានព្រំដែនទេ គឺមានព្រំដែនជាក់លាក់ថា រស់នៅក្នុងយុត្តិធម៌ស្មើគ្នា រស់នៅក្នុងសិក្ខាបទស្មើគ្នា មានសិទ្ធិបញ្ចេញមតិបានដូចគ្នា រស់នៅក្នុងធម្មវិន័យស្មើគ្នា មានសិទ្ធិគិតគូរបានដូចគ្នា ។ល។ តែត្រូវរស់នៅក្នុងការគោរពគ្នាតាមចំនួនវស្សា តាមលំដាប់អាយុធម៌ដែលខ្លួនប្រព្រឹត្តប្រតិបត្តិ តាមឋានៈគ្រូ និងសិស្ស មាតាបិតា ។ល។ នេះគឺជាសិទ្ធិស្ដីពីសមភាពរបស់ពុទ្ធសាសនា។។

ក្នុងសម័យបន្ទាប់ពីសួលូនមិនដល់១០០ឆ្នាំ អ្នកប្រវត្តិសាស្ត្របានជួបប្រជាធិបតេយ្យថ្មីមួយទៀត មានលក្ខណៈទូលំទូលាយគួរជាទីពេញចិត្ត គឺសម័យរបស់ក្លីសធេនីស ។ ទស្សនវិទូរូបនេះ ត្រូវបានគេទទួលស្គាល់ជាមួយនឹងការលើកតំកើងថាជាអ្នកបានបណ្ដេញបំបរបង់លទ្ធិអភិជនាធិបតេយ្យអស់ពីក្រុងអាតែនរបស់ក្រិច ហើយបានស្ថាបនាបង្កើតឱ្យមានលទ្ធិប្រជាធិបតេយ្យ និងរដ្ឋធម្មនុញ្ញថ្មីមួយទៀតឡើង ។

តួយ៉ាងប្រជាធិបតេយ្យដែលមានសូត្រស្មើញត្តិមួយដង សូមសេចក្ដីយល់ស្របមួយដងដែលហៅថា**ញត្តិទុតិយកម្ម** ក្នុងទីនេះស្ដីចំពោះតែរឿងឱ្យសំពត់កឋិនមួយដែលមានចែងក្នុងវិន័យបិដក ដើម្បីទុកជាគំរូដល់គំនិតរបស់អ្នកអានដូចនេះ :

*" លោកដ៏ចំរើន ! សូមសង្ឃស្ដាប់ពាក្យរបស់ខ្ញុំ សំពត់កឋិននេះកើតឡើងហើយដល់សង្ឃ បើសេចក្ដីព្រមព្រៀងរបស់សង្ឃមានក្នុងទីនេះហើយ សង្ឃគប្បីប្រគល់ឱ្យនូវសំពត់កឋិននេះ ដល់ភិក្ខុមានឈ្មោះដូចនេះដើម្បីក្រាលកឋិននេះជាញត្តិ "* ។

*" លោកដ៏ចំរើន ! សូមសង្ឃស្ដាប់ពាក្យរបស់ខ្ញុំ សំពត់កឋិននេះកើតឡើងហើយដល់សង្ឃ សង្ឃឱ្យសំពត់នេះដល់ភិក្ខុមានឈ្មោះដូចនេះ ដើម្បីក្រាលកឋិន ការឱ្យសំពត់នេះដល់ភិក្ខុសង្ឃមានឈ្មោះដូចនេះ ដើម្បីក្រាលកឋិន ( ទង្វើនេះរបស់សង្ឃ) បើភិក្ខុសង្ឃណាមានសេចក្ដីយល់ស្រប ភិក្ខុរូបនោះគប្បីស្ថិតនៅក្នុងឥរិយាបទស្ងៀម បើមិនពេញចិត្តដល់ភិក្ខុរូបណាភិក្ខុរូបនោះគប្បីឆ្លើយមក ។សំពត់កឋិននេះ សង្ឃបានប្រគល់ឱ្យហើយដល់ភិក្ខុមានឈ្មោះដូចនេះ ដើម្បីក្រាលកឋិន ការឱ្យនេះមានការយល់ស្របពីសង្ឃហើយ ហេតុនេះទើបសង្ឃស្ងៀមស្ងាត់គ្មានចំលើយ ខ្ញុំសូមធ្វើសេចក្ដីកត់សំគាល់នូវសេចក្ដីសំរេចចិត្តរបស់សង្ឃដោយប្រការដូចនេះ* ([២])

ចំណុចខាងលើនេះបានបញ្ជាក់ឱ្យឃើញថា ព្រះពុទ្ធសាសនាជាគំរូនៃលទ្ធិប្រជាធិបតេយ្យ ដោយឥតប្រកែកបានឡើយ ។

---

២ លោក ឌិន ខែម កម្ពុជសុរិយា ពោធិពុទ្ធសាសនបណ្ឌិត ភ្នំពេញ ឆ្នាំ១៩៩៧ ទំព័រ ១៥-២៧

www.budinst.gov.kh www.elibraryofcambodia.org

**ឃ. ធម្មទេសនា**

ក្រោយពេលព្រះពុទ្ធអង្គទ្រង់បានត្រាស់ព្រះសម្មាសម្ពុទ្ធ ទ្រង់បានយាងទៅធ្វើធម្មទេសនា អប់រំទូន្មានសត្វលោកឱ្យធ្វើអំពើល្អគ្រប់បែបយ៉ាង ។

ដំបូងព្រះអង្គ យាងទៅសំដែងធម្មចក្កប្បវត្តនសូត្រប្រោសបញ្ចវគ្គីភិក្ខុ នៅក្នុងព្រៃឥសិបតនមិគទាយវ័ន "សារនាថ" នៅជិតក្រុងពារាណសី ។ ភិក្ខុបញ្ចវគ្គីបានសំរេចអរហន្តផល ។ ។ ការសំដែងធម្មទេសនាជាបន្តបន្ទាប់ របស់ព្រះពុទ្ធអង្គបានធ្វើឱ្យមនុស្សជាច្រើនគ្រប់ស្រទាប់វណ្ណៈ ចូលបួសជាភិក្ខុ ភិក្ខុនី ក្នុងសំណាក់ព្រះអង្គ ។

ចាប់ពីពេលដែលព្រះអង្គ បានត្រាស់រហូតដល់ព្រះពុទ្ធអង្គបរិនិព្វាន ព្រះអង្គតែងបានគោរពអនុវត្តកម្មវិធីពុទ្ធកិច្ចជាប្រចាំក្នុងមួយថ្ងៃៗ ។

- ពេលព្រឹក ព្រះអង្គទ្រង់និមន្តបិណ្ឌបាត្រ
- ពេលរសៀល ព្រះអង្គទ្រង់សំដែងធម្មទេសនាប្រោសឧបាសក ឧបាសិកា
- ពេលព្រលប់ ព្រះអង្គទ្រង់ប្រទានឱវាទសិក្ខាវិន័យដល់ភិក្ខុ ភិក្ខុនី សាមណេរ សាមណេរី ទាំងឡាយ ។
- ពេលអាធ្រាត ព្រះអង្គទ្រង់ដោះស្រាយប្រស្នាទាំងឡាយ
- ពេលជិតភ្លឺ ព្រះអង្គទ្រង់ពិចារណាប្រមើលមើលឧបនិស្ស័យរបស់មនុស្សដែលព្រះអង្គ នឹងត្រូវយាងទៅប្រោស ។ ព្រះអង្គទ្រង់យាងទៅប្រោសមនុស្ស សត្វ ដែលមានឧបនិស្ស័យនៅគ្រប់ទិសទីដោយព្រះបាទផ្ទាល់ ។

ទ្រង់បានប្រោសតាបសឧរុវេលកស្សបៈ នទីកស្សបៈ គយាកស្សបៈ និងសិស្សគណៈ របស់តាបស ទាំងបីនោះមានចំនួន១០០០នាក់ ហើយបានបួសជាភិក្ខុ ដែលបានសំរេចអរហន្តផល ។

ទ្រង់បានប្រោសព្រះបាទពិម្ពិសារ ឱ្យក្លាយទៅជាឧបាសកពុទ្ធសាសនូបត្ថម្ភ ដែលបានចាត់ចែងសាងសង់ព្រះវិហារនៅក្នុងព្រៃវេឡុវ័នថ្វាយចំពោះព្រះពុទ្ធព្រះធម៌ ព្រះសង្ឃ ។

ទ្រង់បានប្រោសសារីបុត្រ និងមោគ្គល្លាន ព្រមទាំងសិស្ស២៥០នាក់ របស់សញ្ជ័យជក ទ្រង់បានបបួសជា **ឯហិភិក្ខុ** សំរេចអរហន្តផល ។ សារីបុត្តត្ថេរនិងមោគ្គល្លានត្ថេរបានសំរេចអរហន្តបដិសម្ភិទាញ្ញាណ ។

ទ្រង់បានយាងទៅប្រោសពុទ្ធបិតា និងពុទ្ធញាតិនៅក្រុង **កបិលពស្តុ** សំរេចមគ្គផល ។

ទ្រង់បានយាងទៅប្រោសពុទ្ធមាតានៅ **ស្ថានតាវត្តិង្ស** ដោយទ្រង់សំដែងនូវបរមត្ថអភិធម្ម ហើយឱ្យពុទ្ធមាតា និងទេវតារាប់កោដិសំរេចសោតាបត្តិផល ។

ព្រះអង្គទ្រង់បានចាត់តាំងរចនាសម្ព័ន្ធគ្រប់គ្រងសង្ឃ ដែលរួមមានអគ្គសាវកពីរអង្គ គឺសារីបុត្តត្ថេរ មោគ្គល្លានត្ថេរ និងមហាសាវ័ក ៨០អង្គ គឺព្រះទាំងភិក្ខុអរហន្ត ភិក្ខុនីអរហន្តនី សាមណេរ សាមណេរី ខីណាស្រពរាប់ម៉ឺនអង្គ ។

www.budinst.gov.kh www.elibraryofcambodia.org

### ខ. ព្រះឥរិយាបថរបស់ព្រះពុទ្ធ ក្នុងសម័យដែលព្រះអង្គទ្រង់គង់ព្រះជន្មនៅឡើយ ([៣])

ព្រះសម្មាសម្ពុទ្ធបរមគ្រូនៃយើងទាំងឡាយ ចាប់ដើមតាំងអំពីព្រះអង្គបានត្រាស់ដឹងឡើង ទៅទល់នឹងបរិ - និព្វានទៅ ព្រះអង្គមិនដែលបានសំរេចព្រះឥរិយាបថគង់នៅចាំវស្សាក្នុងវត្តណាមួយ ឬកន្លែងណាមួយជាប់ជានិច្ច រហូតដល់បរិនិព្វានទេ ។ជួនកាល ព្រះអង្គទ្រង់គង់នៅចាំវស្សាក្នុងវត្តជិតទីក្រុងដែលគេកសាងថ្វាយក៏មាន ជួនកាលទ្រង់គង់នៅចាំវស្សាក្នុងព្រៃ ឬលើភ្នំ ឬក៏ក្នុងស្រុកក៏មាន ដោយព្រះអង្គទ្រង់យល់ឃើញថា ទីណាដែលមានប្រយោជន៍ច្រើនដល់សត្វលោក ទ្រង់តែងយាងទៅគង់នៅទីនោះ ដូចសេចក្តីដែលបានលើកយកពិពណ៌នាតទៅនេះគឺ :

- វស្សាទី១ ទ្រង់គង់នៅនា **ឥសិបតនមិគទាយវ័ន** ជិតក្រុងពារាណសី ជាមួយនឹងព្រះអរហន្តថ្មី១៦០អង្គ។
- វស្សាទី២-៣-៤ ទ្រង់គង់នៅក្នុងវត្ត **វេឡុវ័ន** ក្រុងរាជគ្រឹះ។
- វស្សាទី៥ ទ្រង់គង់នៅក្នុង **កូដាគារសាលា** នាមមហាវ័នជិតក្រុងវេសាលី ។
- វស្សាទី៦ ទ្រង់គង់នៅនា **មកុលបព៌ត** ក្នុងដែនមគធៈ។
- វស្សាទី៧ ទ្រង់គង់នៅក្នុង **តាវត្តិំសទេវលោក** លើបណ្ឌុកម្ពលសិលាសនៈ ទ្រង់ប្រទានសត្តប្បករណាភិធម្ម ប្រោសព្រះមហាមាយាទេវបុត្ត ( ជាពុទ្ធមាតា)
- វស្សាទី៨ ទ្រង់គង់នៅក្នុង **ភេសកឡាវ័ន** ក្នុងភគ្គរាជជនបទ។
- វស្សាទី៩ ទ្រង់គង់នៅក្នុងព្រៃ **បារិលេយ្យកៈ**។
- វស្សាទី១០-១១ ទ្រង់គង់នៅក្នុងដងព្រៃ ជិតស្រុកព្រាហ្មណ៍ឈ្មោះ **សាលេយ្យគ្រាម** ។
- វស្សាទី១២ ទ្រង់គង់នៅក្រោមដើម **ស្តៅដែលនឡេរុយក្ខយក្ស**។
- វស្សាទី ១៣ ទ្រង់គង់នៅនា **បារិលេយ្យកបព៌ត** ។
- វស្សាទី ១៤ ទ្រង់គង់នៅក្នុងវត្ត **ជេតពន** ជិតក្រុងសាវត្ថី ។
- វស្សាទី ១៥ ទ្រង់គង់នៅវត្ត **និគ្រោធារាម** ជិតក្រុងកបិលព័ស្តុ។
- វស្សាទី ១៦ ទ្រង់គង់នៅក្នុងស្រុក **អាឡវី** ។
- វស្សាទី ១៧-១៨-១៩ ទ្រង់គង់នៅក្នុងវត្ត **វេឡុវ័ន** ក្រុងរាជគ្រឹះ។
- វស្សាទី ២០ ដល់ទី ២៩ ទ្រង់គង់នៅក្នុងវត្ត **ជេតពន** ជិតក្រុងសាវត្ថី។

---

[៣] ព្រះគ្រូសាសនមុនី **គីម ទុះ** វត្តឧណ្ណាលោម

www.budinst.gov.kh www.elibraryofcambodia.org

- វស្សាទី ៣០ ដល់ទី ៣៥ ទ្រង់គង់នៅក្នុងវត្ត **បុព្វារាម** ជិតក្រុងសាវត្ថី ។
- វស្សាទី ៣៦ ដល់ ៤៤ ទ្រង់គង់នៅក្នុងវត្ត **ជេតពន** ជិតក្រុងសាវត្ថី ។
- វស្សាទី ៤៥ ទ្រង់គង់នៅនាស្រុក **វេឡុវគ្រាម** ។

ព្រះសម្មាសម្ពុទ្ធ ទ្រង់ចូលបរិនិព្វានក្នុងព្រះជន្មាយុ ៨០ ឆ្នាំគត់ នៅថ្ងៃអង្គារ ១៥ កើត ពេញបូណ៌មី ខែពិសាខ ឆ្នាំម្សាញ់នព្វស័ក ក្រោមដើមសាលព្រឹក្សទាំងគូ ក្នុងឧទ្យាននៃមល្លក្សត្រិយ៍ជិតកុសិនារារាជធានី ។

**៦. បរិនិព្វាន**

នាថ្ងៃ ១៥ កើត ពេញបូណ៌មី ខែមាឃ ឆ្នាំម្សាញ់ ពេលចេញវស្សាទី៤៥ ព្រះទាំងអង្គ ទ្រង់ដាក់អាយុសង្ខារ របស់ព្រះអង្គថា ព្រះអង្គនឹងចូលបរិនិព្វានក្នុងរវាង៣ខែទៀត ។

ពុទ្ធសាវ័កទាំងឡាយ ជាពិសេសអានន្ទ កាលបើដឹងថា ព្រះពុទ្ធអង្គបានដាក់កំរិតអាយុសង្ខាររួចទៅ ហើយពុំអាចកែប្រែបាន ក៏សោយសោកអាឡោះអាល័យស្តាយព្រះពុទ្ធអង្គដោយមិនចង់ឱ្យព្រះពុទ្ធអង្គចូលបរិនិព្វាន ឡើយ ។

ព្រះអង្គបានយាងទៅដល់នគរ **កុសិនារា** ហើយទ្រង់យាងចូលទៅកាន់សាលវ័ន ទ្រង់ត្រាស់ឱ្យអានន្ទ រៀបចំគ្រែថ្វាយព្រះអង្គផ្ទំ ។

ព្រះអង្គផ្ទំផ្ទៀងទៅស្តាំ ព្រះបាទឆ្វេងត្រួតលើព្រះបាទស្តាំ ។ នៅបច្ឆិមរាត្រី ព្រះអង្គទ្រង់ត្រាស់ដល់ភិក្ខុទាំងឡាយថា " ម្នាលភិក្ខុទាំងឡាយ ឥឡូវនេះតថាគត ហៅអ្នកទាំងឡាយមកប្រាប់ថា អ្វីដែលកើតឡើងហើយ ដែលមានហើយ ដែលផ្សំផ្គុំ ហើយតែងមានធម៌ភាព និងរលត់ទៅវិញជាការធម្មតា ។ អ្នកទាំងឡាយត្រូវញុំាងប្រយោជន៍ឱ្យសំរេចដោយកិរិយាមិនធ្វេសប្រហែសចុះ " ។ ព្រះអង្គមានពុទ្ធដីការតែប៉ុណ្ណេះ ទ្រង់ក៏រលត់សង្ខារនៅពេលនោះទៅ គឺនៅថ្ងៃ ១៥ កើត ពេញបូណ៌មី ខែពិសាខ ឆ្នាំម្សាញ់ មុនគ្រិស្តសករាជ ៥៤៣ឆ្នាំ ក្នុងព្រះជន្ម ៨០ព្រះវស្សា ។

## ជំពូកទី ២

## ប្រវត្តិសង្ខេបព្រះពុទ្ធសាសនាមហាយាន

នៅក្នុងរវាងរាជកនិស្ក មានកើតហេតុជាធំមួយក្នុងពុទ្ធសាសនាមានបំបែកពួកសង្ឃជាពីរពួក គឺ **ហីនយាន** និង **មហាយាន** ។

**១. អំពីយាន** ([៤])

មហាយាន គឺជាពួកធម៌ថ្មី ដែលគេប្តូរគ្នាជាគំរូ បដិបក្ខនិង ហីនយាន ឬពុទ្ធសាសនា ដើម្បីពួកនេះ ប្រហែលជាមានបែបផែនមកពី **នាគារ្ជុន** ដែលកើតក្នុងពាក់កណ្តាលគ្រិស្តសករាជ ២០០ ខាងដើម ឯលក្ខណៈមហាយាន

---

[៤] Louis Finot អំពីពុទ្ធសាសនា ភ្នំពេញ ១៩៦៤ ទំព័រ ១៨៨

www.budinst.gov.kh www.elibraryofcambodia.org

ដែលប្លែកពីហីនយាននោះមានសេចក្តីដូចខាងក្រោម ៖

១- ហីនយានសំដែងថា មនុស្សយើងត្រូវប្រាថ្នាយកព្រះអរហន្ត និងព្រះនិព្វាន ឯមហាយានវិញសំដែងថា មនុស្សត្រូវប្រាថ្នាយកពោធិសត្វ ដែលមានពោធិញ្ញាណជាទីបំផុត ។

២- តាមហីនយានថា ព្រះនិព្វាននោះបានដោយបុញ្ញកិរិយាវត្ថុ គឺទានសីល និងភាវនា ឯខាងមហាយានវិញថា បានដោយសទ្ធា និងសេចក្តីជ្រះថ្លាក្នុងព្រះពុទ្ធ មានព្រះពុទ្ធ អមិតាភជាដើម ។

៣- តាមហីនយានថា ទីព្រះអរហន្តនោះបានដល់តែភិក្ខុទេ ឯមហាយានថា ទៅជាយពរាវាសក៏គង់បានដល់ទីពោធិសត្វដែរ ។

៤- ហីនយានសំដែងថា ខ្លួនត្រូវទីពឹងខ្លួន គឺជាកុសលដែលអ្នកណាម្នាក់បានធ្វើ នឹងនាំអ្នកនោះឱ្យបានរួចចាកទុក្ខ ឯមហាយានវិញថា កុសលរបស់ខ្លួនអាចនឹងផ្សាយដល់អ្នកដទៃឯទៀតបាន ។

៥- ក្នុងគំនិតពួកមហាយានថា ព្រះពុទ្ធទាំងឡាយ ជារូបមិនមែនធម្មតា អាស្រ័យដោយការឈានទៅកាន់គ្រប់កន្លែងក្នុងឱកាស ប្រៀបដូចជាព្រះពុទ្ធ **ភៃសជ្យគុរុ** និងព្រះពុទ្ធ **អមិតាភ** ឯព្រះពុទ្ធ **អមិតាភ** នេះស្ថិតនៅទិសខាងលិចក្នុងឋានសួគ៌ឈ្មោះ **សុខាវតី** ។

៦- ព្រះពុទ្ធមួយអង្គមានកាយ៣ កាយមួយហៅថា **ធម៌កាយ** គឺកាយព្រះធម៌ បានដល់ពោធិ ឬនិព្វាន កាយមួយទៀតហៅថា **សម្ភោគកាយ** គឺកាយដែលប្រកបដោយសិរីសួស្តី ជ័យមង្គលដែលព្រះពុទ្ធស្ថិតនៅក្នុងឋានសួគ៌ និងកាយទី៣មានឈ្មោះថា **និម៌ាណកាយ** គឺកាយជាមនុស្ស ។

៧- មានពោធិសត្វធំៗជាច្រើន ដែលមិនចូលនិព្វាន ហើយនៅក្នុងលោកយើងនេះ ដើម្បីសង្គ្រោះដល់សត្វ ។ ឯពោធិសត្វទាំងនេះមាន **អវលោកិតេស្វរ** ឬ **វជ្របាណី** ឬ **លោកេស្វរ** ជាដើម គឺជាពោធិសត្វសង្គ្រោះ ដែលផ្តល់សេចក្តីសុខសប្បាយ ។ **មញ្ជុស្រី** គឺពោធិសត្វដែលត្រួតត្រាខាងផ្លូវយុត្តិធម៌ គង់នៅលើរូបសីហ ហើយកាន់សៀវភៅមួយ និងព្រះខ័នមួយ ។ **សមន្តភទ្រ** គឺពោធិសត្វអាណាព្យាបាលអ្នកកាន់សាសនា ដែលគេធ្វើជារូបគង់នៅលើដំរីប្រែ ។ **មេត្រេយ** គឺ ទៅអនាគតជាព្រះពុទ្ធទ្រង់នៅចាំរក្សាសាសនា ដែលព្រះសមណគោតមបានផ្សាយ ។ **ក្សិតិគភ៌** គឺពោធិសត្វដែលស្រង់មនុស្សពីស្ថាននរក ។ **វជ្របាណី** គឺពោធិសត្វដែលមានវជ្រ គឺរន្ទះជាអាវុធក្នុងដៃ ដើម្បីការពារសាសនាលោកេស្វរ មានភរិយាឈ្មោះ **តារា** គឺជាអ្នកស្រោចស្រង់ប្រាជ្ញាបារមី គឺប្រាថ្នាយ៉ាងឧត្តម ដែលគេសន្មត់ឱ្យមានរូបរាងឡើងក៏ទៅជាតួនាងទេវធីតាមួយទៅ ។

៨- មហាយានមានគម្ពីរផ្សេងៗជាច្រើន គឺសទ្ធម៌បុណ្ឌរីកសូត្រ អមិតាភសូត្រ សុវណ្ណ ប្រភាសលង្កាវតារ ។ ។ល។

៩- ពួកគេមានសេចក្តីជឿទៅក្នុងកិរិយា គោរពរាប់អានដល់រូបនិម្មិត ក្នុងបុណ្យផ្សេងៗ ក្នុងការសូត្រធម៌ និងក្នុងពិធីវេទមន្ត ។

www.budinst.gov.kh www.elibraryofcambodia.org

ធម៌អាចារ្យរបស់មហាយាននោះ កើតមានជាយូរអង្វែងណាស់មកហើយ ព្រមទាំងបានផ្សាយទូទៅក្នុងតំបន់ទិសពាយ័ព្យនៃស្រុកឥណ្ឌា ក្នុងរាជស្តេច **កនិស្ក**។ ប៉ុន្តែ ប្រហែលជានាគាជ៌ុន បានបង្កើតបែបផែនជាដំបូងនាគាជ៌ុននេះ បានបង្កើតពួកមាធ្យមិក ហើយបានផ្សាយធម៌ក្នុងមហាប្រាជ្ញាបារមិតាសាស្ត្រ ដែលមានតែជាភាសាចិន ក្នុងនោះមាធ្យមិកសូត្រ ( អ្នកផ្សាយឈ្មោះ **ឡាចារ៉ី ឡេព្វូស្សាំង** ក្នុងសៀវភៅរឿងពុទ្ធសាសនា) ។

ពួកអ្នកប្រាជ្ញទាំងនេះ កើតឡើងក្នុងរជ្ជកាល **កុសណ** ដែលគ្រងរាជតពីស្តេច **កនិស្ក** ក្នុងរវាងគ្រិស្តសករាជ ១៥០ ដល់ ២២០។

## ២. អំពីសេចក្តីវិនាសព្រះពុទ្ធសាសនាក្នុងប្រទេសឥណ្ឌា (៥)

សេចក្តីវិនាសព្រះពុទ្ធសាសនា ចាប់ផ្តើមឡើងតាំងពីឆ្នាំ៧០០ ហើយវិនាសយ៉ាងឆាប់ តាំងពីឆ្នាំ ៨០០តទៅ ហើយចាប់ពីនេះក៏កាន់តែបាត់បង់បន្តិចម្តងៗ។

សេចក្តីវិនាសមានហេតុពីរយ៉ាងគឺ : ហេតុខាងក្នុង និងហេតុខាងក្រៅ

### ក. អំពីហេតុខាងក្នុង

ហេតុយ៉ាងធំដែលនាំឱ្យព្រះពុទ្ធសាសនាវិនាសនោះមកអំពីសេចក្តីបង្កើតនៅវិធីហួសខ្នាត និងមន្តអាគមផ្សេងៗរបស់ពួកមហាយាន។ ឯកិរិយាប្រើនូវវិធីដេញខ្មោច និងប្រើយាននោះមិនខុសឆ្ងាយពីបែបសាសនាចាស់ឡើយ។ ប៉ុន្តែ ព្រមទាំងប្រកាន់យកនូវផ្លូវចង្អៀតពេក ហើយធ្វើកាន់តែហួសតៗមកទៀត។

ក្នុងឆ្នាំ៧០០ គេបានពិនិត្យឃើញមានប្រើបែបធរណី ឯវិធីនេះ កើតមានឡើងជាបែបបទនៅក្នុងឆ្នាំ៦៥០ ដែលបានឱ្យឈ្មោះថា **វជ្រយាន** គឺរទេះថ្មីមួយសំរាប់នាំទៅកាន់ស្ថាននិញ្វន។

### ខ. អំពីហេតុខាងក្រៅ

ការលុកលុយរបស់ពួក **ហ៊ុន** នាំឱ្យវិនាសដល់ព្រះពុទ្ធសាសនាក្នុងស្រុក **បញ្ចាប** មានព្រះវិហារជាច្រើនដែលបោះបង់ចោលហើយបាននិយាយនៅក្នុងចារឹករបស់អ្នកដំណើរក្នុងឆ្នាំ៧០០ គឺនៅមានតែស្រុក **ឧទ្យាន** ប៉ុណ្ណោះ ដែលបណ្តាលឱ្យអ្នកស្រុកមានការកោតខ្លាច ការគោរពប្រតិបត្តិព្រះពុទ្ធសាសនាចាស់។ តពីនោះមក ពួក **មហាម៉ាត់** បានញាំញីអស់ទៅទៀត។

នៅស្រុក **កស្មីរ** ព្រះពុទ្ធសាសនាវិនាសទៅដោយពួក **ហិណ្ឌូ** ក្នុងឆ្នាំ៦០០។ អ្នកបួសសុទ្ធតែមានប្រពន្ធទាំងអស់ តមករាជស្តេច **លលីតាទិត្យ** គឺពីឆ្នាំ៧៣៣ ដល់ឆ្នាំ៧៦៩ ស្តេចទាំងអស់ដែលគ្រងរាជជាបន្តបន្ទាប់ សុទ្ធតែជាពួកអ្នកកាន់សាសនាព្រះឥសូរទាំងអស់។

ស្រុក **សិន្ធុ** ពួក **អារ៉ាប់** វាយយកបានក្នុងឆ្នាំ៧១២។ ក្នុងស្រុកទាំងឡាយដែលនៅត្រើយសមុទ្រខាងលិចគឺស្រុក **គុជរ៉ាតមហារាស្ត្រគោន្ត** នោះពួក **សម្មិតិយ** ថ្កុំថ្កើងរុងរឿងក្នុងឆ្នាំ៧០០ ព្រះពុទ្ធសាសនាស្ថិតនៅក្នុងទីនោះ

[៥] Louis Finot អំពីពុទ្ធសាសនា ភ្នំពេញ ១៩៦៤ ទំព័រ ១៥០

www.budinst.gov.kh www.elibraryofcambodia.org

លុះដល់ឆ្នាំ១២០០។

ក្នុងតំបន់ខាងត្បូង មានព្រះវិហារប្រាសាទធំ១ មានព្រះវិហារនៅអមរាវតី ( ឆ្នាំ ១៥០ ) និងនៅអជន្តា ( ១០០ឆ្នាំមុនគ្រិស្តសករាជ មកដល់ ៦០០ឆ្នាំក្រោយគ ស ) ។ ប៉ុន្តែ ព្រះពុទ្ធសាសនានៅទីនោះបានតតាំងនិងខ្លាំង សត្រូវយ៉ាងពូកែពីរគឺ សាសនា ហិណ្ឌូនិងសាសនា ជេន ហើយអន្តរាយអស់រលីងក្នុងឆ្នាំ១៥០០ ។

ទីក្រុងចាស់របស់ស្តេច**មាសិ** តាំងនៅទន្លេគង្គខាងលើ ឆ្នាំ៨០០ បានក្លាយទៅជាក្រុង**ព្រះរាជ**វិញ។ ព្រះពុទ្ធសាសនាបានស្ថិតស្ថេរជាយូរអង្វែងក្នុងតំបន់ឥណ្ឌាខាងទិសឥសាន្ត គឺនៅស្រុក**បង់ក្លាទ្និវិស្ស** និងនេប៉ុល ដោយមានការឧបត្ថម្ភនៃពួកស្តេចដែលជារាជវង្ស **បាល** នៅទីក្រុងដែលបាលបានកសាងក្នុងឆ្នាំ ៧៣០។ ពួកនេះរស់នៅតបាន ៤៥០ឆ្នាំហើយការគោរពសាសនាពីពួកស្តេចទាំងនោះឥតមានប្រួលប្រែឡើយ។ ចំពោះសាសនាហិណ្ឌូវិញក៏ឥតធ្វើទុក្ខ ធ្វើបាបអ្វីដែរ គឺបណ្តោយអោយនៅសុខសាន្តទៅ កោបាលបានសាងព្រះវិហារនៅ**ឧទ្ទន្តបុរះ** ។ ឯធម៌បាល .( ឆ្នាំ៨០០) បានសាងវិជ្ជមសិលាជាជំនួយ**នាលន្ទ** ដើម្បីជាកន្លែងបង្ហាត់បង្រៀនខាង ផ្លូវសាសនា ក្នុងរាជមហិបាល (ឆ្នាំ៩៧៨ ដល់ ១០៣០) ពួកបួសទាំងឡាយនៅក្នុងស្រុកបង់ក្លល បានយកពុទ្ធ សាសនាមកផ្សព្វផ្សាយនៅស្រុក**ទីបេត៍** ព្រះពុទ្ធសាសនានៅស្រុកនេះ អន្តរាយទៅដោយការលុកលុយក្នុងឆ្នាំ ១០០០។

**៣. អំពីការផ្សព្វផ្សាយ ព្រះពុទ្ធសាសនា** ( [៦] ) :

ពីដើម **អសោក**គ្រាន់តែស្ម័គ្រចូលក្នុងព្រះពុទ្ធសាសនាជាឧបាសក លុះសេចក្តីជ្រះថ្លានេះចំរើនឡើង ក៏បានចូលទៅកាន់យកនូវសំលៀកបំពាក់ ជាភិក្ខុគ្រាន់តែជាឧបនិស្ស័យទៅមុខ ក្នុងរវាងជាង ២ ឆ្នាំខ្លួនខ្ញុំធ្វើជាឧបាសកមួយមិនខ្នះខ្នែងឱ្យពេញបរិបូរ តាំងពីជាង ៦ ឆ្នាំ ហើយខ្ញុំបំពេញផ្នួសជាសង្ឃ ហើយខ្ញុំបានយកចិត្តទុក្ខដាក់ជាខ្លាំង ។

ប្រកាស ( ក អា ៨ ) ព្រះពុទ្ធសម្តេចព្រះចៅ **បិយទេស្សី** ១០ឆ្នាំក្រោយរាជាភិសេក បានយាងទៅកាន់កន្លែងដែលព្រះសម្ពុទ្ធបរមាភិសម្ពោធិញ្ញាណ។ ដូចច្នេះព្រះបាទ**អសោក** បានចូលទៅកាន់ពុទ្ធសាសនានៅវេលា៩ឆ្នាំក្រោយដែលបានរាជភិសេក គឺឆ្នាំ ២៥៤ មុន គ ស ហើយបានបំពេញភ្នួសនៅក្នុងរវាង ដាច់ឆ្នាំទី ១១ គឺឆ្នាំ ២៥២។

នៅឆ្នាំ១៤ ក្រោយរាជាភិសេក គឺឆ្នាំ ២៤៥ ព្រះអង្គបញ្ញត្តដល់សង្ឃធ្វើជាប្រកាសនៅតំបន់**ឡា** គឺក្នុងឆ្នាំនោះហើយ តាមពង្សាវតាអ្នកស្រុក**លង្កា**ថា ទ្រង់បានលើកតតិយសង្គាយនា តែក្នុងចារឹកនានា មិនឃើញមានយោបល់សេចក្តីឱ្យឃើញសោះ។ ដោយ**អសោក**នេះ កាន់ពុទ្ធសាសនាយ៉ាងមាំមួន ហើយពេលនោះក៏មានពួកផ្សេង១ បន្លំចូលផង ពួកដែលបន្លំទាំងនោះបានប្រព្រឹត្តបំពានដល់លក្ខណៈបញ្ញត្តទាំងឡាយនៃព្រះវិន័យ។ ដើម្បីជាប្រយោជន៍បានត្រឹមត្រូវឡើងវិញនោះ បានតាំងលើកតតិយសង្គាយនាក្នុងគ្រានោះ។ សង្គាយនានោះបានកំណត់៩ ខែនៅក្រុង **បាតលីបុត្រ** នៅក្នុងអសោករាមដោយមានតិស្ស **មោគ្គលីបុត្រថេរ** ជាប្រធានដែលបានសំដែងនូវគម្ពីរ

[៦] Louis Finot អំពីពុទ្ធសាសនា ភ្នំពេញ ១៩៦៨ ទំព័រ ១៩១

www.budinst.gov.kh www.elibraryofcambodia.org

កថាវត្ថុជាដំបូងបង្អស់ សាលាដែលសំរាប់បង្រៀននូវពុទ្ធិវិជ្ជាដ៏ពិតប្រាកដនោះគឺសាលាវិ **ភជ្ជវាទ** ហើយបានបំពេញនូវពកអ្នកដ៏ទៃដែលចូលមកបន្ថំញាំញីពុទ្ធសាសនាចេញទាំងអស់។

វេលាដែលសង្គាយនាស្រេចហើយ បានចាត់ទុកព្រះអរហន្តជាច្រើនឱ្យចេញទៅប្រទេសផ្សេងៗ ដើម្បីផ្សាយព្រះពុទ្ធសាសនា។

ទៅគន្ធារ គឺបញ្ជាប់ខាងជើងនោះគឺ**មជ្ឈន្តិក (បា.មជ្ឈន្តិកថេរ)**

ទៅមហិសមណ្ឌល ( គិរីសៅរ៍ )នោះគឺមហាទេវថេរ។

ទៅវនវាសសព្វថ្ងៃហៅ កនរនោះគឺរក្ខិ ( បា.រក្ខិតថេរ ) ។

ទៅអបរាន្តតិ គជ៌រតខាងជើង និងកច្ឆ្យាវារ៍និងសន្ធ៍តិធម៌រក្ខិតយវន ឬយោនក ធម្មរក្ខិតថេរ។

ទៅមហារាស្ត្រ( បា.មហារដ្ឋ )គឺឥណ្ឌាកណ្ដាលនោះគឺ មហាធម៌រក្ខិត។

ទៅប្រទេសនៃពួកយវន គឺយោនកលោកឬយោនវិសយសព្វថ្ងៃហៅអ័ហ្វយនិស្តង់ គឺមហារក្ខិត។

ទៅក្នុងតំបន់ហិមាល័យ គឺមធ្យម ឬ( មជ្ឈិម ) ដោយមានទុន្ទុភិស្វរ ( ឬទន្ទុស្សរ ) ទៅជាមួយផង គឺសហទេវនិងទូលកទេវ។

ទៅសុវណ្ណភូមិ ( ស្រុកមន ) គឺសោណនិងឧត្តរថេរ។

ទៅលង្កា សព្វថ្ងៃហៅស៊ីឡង់គឺមហិន្ទជាបុត្រសសោក។

សេចក្ដីពិតប្រាកដអំពីការចាត់ចែងព្រំអរហន្តទាំងឡាយនោះមានកំណត់ដោយកោដ្ឋពាដែលគេរកឃើញនៅសោនវិតិស្រុកភិល្សសព្វថ្ងៃមួយអន្ទើនិងចារឹកដែលមានសញ្ញាចុះនាម**អរហន្ត** ដែលមានអដ្ឋិក្នុងកោដ្ឋនោះផង។

១. សបុរិសស គោតិបុតស ហេមវតស ទទភិសរ ទាយាទស "ឆ្អឹងនៃព្រះអរហន្តគោតិបុត្ត នៅហិមល័យតពី ទទភិសរថេរ"

២. សបុរិសសគោតីបុតស ដាសបគោតស សវហេមវតាចរិយស "អដ្ឋិនៃព្រះអរហន្តកោតីបុត្ត ជាត្រកូលកាសប ហើយជាសាវ័កគ្រូគទូទៅក្នុងតំបន់ហិមាល័យ"

៣. សបុរិសសមជ្ឈិមស កោទិនិបុតស "អដ្ឋិនៃព្រះអរហន្ត មជ្ឈិមកោទិបុក"

ដូចនេះ កោដ្ឋទាំងនោះបានប្រាប់ពិតក្នុងរឿងរ៉ាវនៃអរហន្ត ២អង្គដែលជាអ្នកធ្វើ តតិយ សង្គាយនគឺ :

- ទទភិសរៈ ហៅថា ទុន្ទុភិស្វរ។
- មជ្ឈិម កោទតិនិបុត ហៅថា មធ្យមកោទីនី។

www.budinst.gov.kh www.elibraryofcambodia.org



១ កាលព្រះសម្មាសម្ពុទ្ធនៅជាពោធិសត្វកំពុងធ្វើទុក្ករកិរិយា ៦ ឆ្នាំ នៅក្នុងព្រៃឧរុវេឡា ព្រះអង្គស្គមនៅតែស្បែកនិងឆ្អឹង រូបនេះគេធ្វើពីថ្ម រកឃើញនៅខាងជើងប្រទេសឥណ្ឌា ក្នុងស្រុកគន្ធារ គេសាងក្នុងរវាងពុទ្ធសករាជ ៧០០ ទៅ ៨០០ ឆ្នាំ —

www.budinst.gov.kh www.elibraryofcambodia.org



៤ [illegible]

[illegible] ៨០០ ជាតំណាងព្រះសម្មាសម្ពុទ្ធបរិនិព្វាន ៚—

www.budinst.gov.kh www.elibraryofcambodia.org

## ជំពូកទី ៣

## អំពីបព្វជ្ជា បួស

**បុព្វកថា :** ពាក្យ បួស ជាពាក្យមានតំលៃល្អប្រសើរ។ មនុស្សដែលបានបួសក្នុងព្រះពុទ្ធសាសនាគឺជាមនុស្សមានតំលៃល្អប្រសើរជាងអ្នកមិនបានបួស។ អ្នកកាន់ព្រះពុទ្ធសាសនាគេនិយមថា អ្នកបួសគឺជាមនុស្សល្អ ដឹងខុស ដឹងត្រូវ ដឹងទោស ដឹងបុណ្យ ដឹងបាប ។ល។ឬកែគំនិតមាយាទនិតស្មារតីពិអាក្រក់ថោកទាបឱ្យមកជាល្អខ្ពង់ខ្ពស់បាន ដោយអាស្រ័យការប្រព្រឹត្តិតាមធម៌វិន័យរបស់ព្រះពុទ្ធក្នុងភេទបួល ។

បុព្វជិតភាវោ ទុល្លភោៈភាពនៃបុព្វជិត គេរកបានដោយកំរ។ កាបានបួសជាភិក្ខុក្តី ជាសាមណេរក្តី បួសហើយដាច់ចិត្តចេញមកប្រព្រឹត្តិប្រត្តិបត្តិធមសថកម្មដ្ឋានឬវិបស្សនាកម្មដ្ឋានក្តី បានឈ្មោះថាជារបស់រកបានដោយកម្រ ក្នុងចំនាន់ដើម ។

ចំណែកភិក្ខុ-សាមណេរបច្ចុប្បនេះដែលបានបួសត្រឹមត្រូវហើយ ខិតខំរៀនសូត្រធម៌វិន័យសិក្ខាចំរើនសមថកម្មដ្ឋានវិបស្សនាកម្មដ្ឋានរឿយៗឈ្មោះថាជាជួបប្រទះនឹងរបស់ដែលគេរកបានដោយកម្រណាស់។ សូម្បីតែគ្រហស្ថដែលបានស្ម័ខ្លួនជាឧបាសកឧបាសិកាបានបួសកាយវាចាចិត្ត របស់ខ្លួនសុខចិត្តលះបង់នូវសេចក្តីសុខបន្តិចបន្តួចត្រឹមតែត្រួសារប៉ុណ្ណោះសង្ឃឹមប្តូរយកសុខធំទូលំទូលាយ ហើយនាំគ្នាមកធ្វើរាងកាយដែលជារបស់បដិកូល គួរខើមរអើមនេះឱ្យទៅជារបស់ស្អាត់ មានក្លិនក្រអូបដោយសិលសមាធិបញ្ញាទៅវិញសុទ្ធតែរកបានដោយក្រ។ តាមន័យនេះអ្នកស្លៀកពាក់ខ្មៅ ដណ្តប់ខ្មៅ ស្លៀកសដណ្តប់ស ពានាសក្តី ក៏ឈ្មោះថាអ្នកនាំគ្នាមកបួសបានដែរ( តាមបែបចែតនាកម្ម) ឬហៅថាភិក្ខុក៏បាន ព្រោះសំដៅយក "អ្នកឃើញភ័យក្នុងវដ្តសង្សា" ដូចពាក្យអដ្ឋកថាចារ្យពោលថា

យោ ច ឥមំ បដិបត្តិំ បដិបជ្ជតិ

សោ ភិក្ខុ នាម ហោតិ

អ្នកណាប្រតិបត្តិតាមឧប្រតិបត្តិនេះ អ្នកនោះឈ្មោះថា "ភិក្ខុ"

បដិបន្នកោ ហិ ទេវោ វា ហោតិ

មនុស្សោ វា ភក្ខុតិ សង្ខយំ គច្ឆតិយេវ

ពិតមែនអ្នកដែលចំរើនវិបស្សនានោះ ទោះជាទេវក្តី មនុស្សក្តី បានឈ្មោះថា "ភិក្ខុ" ទាំងអស់។

ហេតុនេះ អស់លោកជាឧបាសក ឧបាសិកា គប្បីចូលចិត្តចាំថា បើទុកណាជាយើងនៅមិនទាន់មានឱកាសបួស។ ស្លៀកដណ្តប់ពណ៌អម្ពត់ ( តាមបែបបញ្ញត្តិកម្ម) ក៏ដោយ បើបានប្រតិបត្តិខ្លួនឱ្យចំរើនដោយគុណធម៌យ៉ាងនេះ ហើយក៏ចាត់ទុកថាបាននៅក្នុងចំនែកនៃការបួស ( តាមបែបចេតនាកម្ម) ហើយរាប់បានថាជារបស់រកបានដោយក្រក្រៃលែង។

www.budinst.gov.kh www.elibraryofcambodia.org

ដោយហេតុទៅ សូម្បីអ្នកបួសបែបគោត្រភូសង្ឃ ព្រះសង្ឃតវង្សត្រកូល គឺអ្នកបួសក្នុងសម័យលង្វែកព្រះពុទ្ធសាសនា បួសហើយប្រតិបត្តិឃ្លៀងឃ្លាតចាកធម៌វិន័យស្ទើរតែទាំងអស់ គ្រាន់តែមានភេទជាអ្នកបួសឥតក្លែងក្លាយ ឬក៏រង្កៀសសង្ស័យឡើយ ។ សូម្បីនៅត្រឹមតែយកសំពត់ជ្រលក់ពណ៌អម្ចត់មកចងកខ្លះ សៀតនឹងត្រចៀកខ្លះប៉ុណ្ណោះដោយបានប្ដេជ្ញាសំគាល់ខ្លួនថាជាអ្នកបួសដោយពិត ឥតមានសង្ស័យ ពីព្រោះធ្លាប់បានទទួលផ្នួសអំពីគ្រូអាចារ្យត១មក យ៉ាងនេះក៏ហៅថាអ្នកបួសដែរ ( បែបចេតនាកម្ម ) ។

## បួសមានពីរប្រភេទ

### ក. ប្រភេទបួសបែបបញ្ញត្តិកម្ម ៤យ៉ាងគឺ :

១. បួសចង់ធ្វើឱ្យខ្លួនស្អាតបរិសុទ្ធចេញផុតចាកចំណងកាមគុណ

២. បួសតាមជំនឿថា មានតែដើរតាមមាគ៌ាព្រះពុទ្ធតែមួយគត់ទើបរើខ្លួនឱ្យរួចចាកពីទុក្ខបាន

៣. បួសប្រាថ្នាធ្វើឱ្យជាក់ច្បាស់នូវព្រះនិព្វានជាទីរួចផុតស្រឡះចាកវដ្ដទុក្ខ

៤. ដោយភ្ញាក់រលឹកចង់បន្តវង្សព្រះសង្ឃបញ្ញត្តិកម្មមានយូរអង្វែងគ្រប់ប្រាំពាន់ព្រះវស្សា

ប្រភេទបួសបែបបញ្ញត្តិកម្មទាំង៤នេះ ត្រូវមានឧបជ្ឈាយ៍ ជាប្រធាន និងគ្រូសូត្រស្ដាំ-ឆ្វេង ព្រមទាំងការកសង្ឃជាប្រធានផង ។

ប្រភេទបួសបែបបញ្ញត្តិកម្មដែរ ប៉ុន្តែច្រើនប្រព្រឹត្តិពាយងាយទុព្ភូជាពិក: មាន៤ពួកគឺ :

- បួសចាស់ព្រាំគ្រាទុរន់ទុរា មានទោស៥យ៉ាងគឺ :
  - ១. ទុល្លភោ និបុណោ ក្របានជាមនុស្សល្អិតល្អន់ទន់ភ្លន់
  - ២. ទុល្លភោ អកប្បសម្បន្នោ ក្របានជាមនុស្សមានមាយាទត្រឹមត្រូវល្អ
  - ៣. ទុល្លភោ ពហុស្សុតោ ក្របានជាពហុស្សូត្រ អ្នកចេះដឹងច្រើន
  - ៤. ទុល្លភោ ធម្មកថិកោ ក្របានជាធម្មកថិកជំនាញ
  - ៥. ទុល្លភោ វិនយធរោ ទ្រទ្រង់វិន័យដោយលំបាកពេក
- បួសបែបថោកទាបមាន៤យ៉ាងគឺ :
  - ១. បួសព្រោះក្រទ្រព្យសម្បត្តិ ឬខ្ទាចអស់ទ្រព្យសម្បត្តិ ( បួសសន្សំទ្រព្យ )
  - ២. បួសព្រោះចាស់ជរា ពីការ ធ្វើការងារអ្វីមិនកើត
  - ៣. បួសព្រោះអស់ញាត្តិសន្តាន ( ប្រពន្ធស្លាប់ ឬគេរត់ចោល )
  - ៤. បួសអាស្រ័យការចិញ្ចឹមជីវិតងាយស្រួល
- បួសបែបបុព្វជិតមាន៦ពួកគឺ :
  - ១. ឧបវិជិកាបួសអាស្រ័យកាចិញ្ចឹមជិត
  - ២. ឧបចិណ្ណិកាបួសសន្សំទ្រព្យ

www.budinst.gov.kh www.elibraryofcambodia.org

៣. ឧបកីឡិកា បួសសំរាប់តែលេងល្បែង

៤. ឧបទុសិកា បួសសំរាប់តែប្រទូសរាយគេ

៥. ឧបមុយ្ហិកា បួសហើយល្ងង់គ្មានរៀនសូត្រអ្វី

៦. ឧបនិស្សរណា បួសប្រាថ្នារើរលាស់ខ្លួនចេញចាកវដ្តទុក្ខ

បួសទាំង៦ពួកនេះបួសប្រាថ្នាលាមកមាន២ គឺបួសប្រាថ្នាចិញ្ចឹមជីវិត១ បួសសន្សំទ្រព្យ១។ បួសដោយភ្លេចខ្លួន (ប្រមាថ) មាន៣គឺបួសសំរាប់តែដើរលេង១ គិតតែប្រទូសរាយគេ១ ល្ងិតល្ងង់មិនខំរៀនអោយចេះ ដឹង១ បួសដោយភ្ញាករលឹករើ ខ្លួនចេញចាកវដ្តទុក្ខគ្រប់យ៉ាងមានតែ ១គត់ដែលកំនត់ថាបួសត្រឹមត្រូវ។

- បួសប្រតិបត្តិបំបែកផ្លូវដើរផ្ទុយពីមាគ៌ាព្រះពុទ្ធ

បព្វជិតរូបណាមួយក៏ដោយទោះជាភិក្ខុក្តីសាមណេរក្តីបួសហើយប្រព្រឹត្តិប្រតិបត្តិអាស្រ័យដោយលាភសក្ការៈតែ១ប៉ុណ្ណោះ ផ្ទុយពីមាគ៌ារបស់ព្រះពុទ្ធហើយ ឥតបានសំរេចប្រយោជន៍អ្វីក្នុងភេទផ្នួសនោះទេ។ ព្រះអង្គទ្រង់សំដែងថា :

អញ្ញា ហិលាភូបនិសា អញ្ញានិព្វានគាមិនី
ឯវមេតំ អភិញ្ញាយ ភិក្ខុ ពុទ្ធស្ស សាវកោ
សក្ការំ នាភិនន្ទេយ្យ វិវេកមនុព្រូហយេ

សេចក្តីប្រតិបត្តិអាស្រយ័លាភ ជាផ្លូវដាច់ដោយឡែក ទៅព្រះនិព្វាន ជាផ្លូវដាច់ដោយឡែក (ឥតជាប់ពាក់ពន្ធ័គ្នាឡើយ) ភិក្ខុជាសាវក័របស់ព្រះពុទ្ធ កាលបើដឹងនូវហេតុការនេះច្បាស់ហើយ មិនគប្បីត្រេកអរនិងលាភសក្ការៈទេ គួរគប្បីស្វះស្វែងចំរើននូវវិវេកជាទីស្ងប់ស្ងាត់វិញ។

**ខ. បួសបែបចេតនាកម្ម**

បួសដែលពុំចាំបាច់មានឧបជ្ឈាយ៍ត្រឹមត្រូវ មិនទាក់ទងដោយដោយពុទ្ធបញ្ញត្តិ និងពុទ្ធានុញ្ញត្តិ គឺអាស្រ័យលើចេតនាតែម្យ៉ាង ហៅចេតនាកម្មមាន៤យ៉ាងគឺ :

១. បួសរក្សាប្រពៃណី គឺខ្មែរច្រើនមានជំនឿលើប្រពៃណីថា បើមានកូនប្រុស ត្រូវតែឱ្យបួសអាយុ១២ឆ្នាំ បួសជាសាមណេរដើម្បីសងគុណមាតា ពីព្រោះមាតាមានគុណ១២ អាយុ២១ឆ្នាំបួសជាភិក្ខុដើម្បីសងគុណឪពុក ពីព្រោះឪពុកមានគុណ២១ ម្លោះហើយប្រពៃណីនេះគេមិនប៉ានកន្លងទេ។ ការបួសនេះទៀតសោត ពុំសូវប្រាកដទេ ជួនកាលជាបញ្ញត្តិកម្មជួនកាលជាចេតនាកម្ម។

២. បួសខ្លាចធ្លាក់ក្នុងនរក គឺខ្មែរយើងខ្លះ ពួកពុទ្ធនិយមមានជំនឿលើសាស្ត្រាបុរាណមួយផ្នែកអក្សរសិល្ប៍ ហៅថាសាស្ត្រាសុបិន (រឿងយល់សប្តិ)។ សាស្ត្រានោះបានចែងថា មានកូន

www.budinst.gov.kh www.elibraryofcambodia.org

ប្រុសចង់បួសុំលាម្ដាយ ម្ដាយឃាត់មិនឱ្យបួស ទោសព្រោះតែឃាត់កូនមិនឱ្យបួស ទើបយមបាលចាប់ម្ដាយទាំងរស់បោះទៅក្នុងខ្ទះដែលមានទឹកកំពុងពុះកញ្ជ្រោលដោយអណ្ដាតភ្លើង។

៣. បួសលាបំណន់ បួសប្រភេទនេះកើតឡើងដោយមានភ័យ ឬបំណងអ្វីមួយទើបបន់ លុះបានសំរេចហើយ ទើបបួសលា កុំឱ្យជំពាក់បំណន់តទៅទៀត។

៤. បួសមុខភ្លើង បួសប្រភេទនេះក៏នៅក្នុងលក្ខណៈសងគុណដែរ

បួសទាំង៤ពួកនេះសុទ្ធតែមានលោកភិក្ខុជាឧបជ្ឈាយ៍ បំបួស មានស្បង់ ចីពរ អង្សក់ វត្ថពទ្ធ ពណ៌អម្ចត់ កោរសក់ កោរពុកមាត់ រោមចិញ្ចើម ទទួលត្រៃ សរណគមន៍ សមាទានសិក្ខាបទ១០ ប្រហាក់ប្រហែលបែបបព្វជ្ជាកម្មខ្លះដែរ ប៉ុន្តែគេបួសមិនយូរទេខ្លះបានតែមួយភ្លែត បុរាណហៅថា មួយសំកាំងដំរី ខ្លះបួសបាន ១-២-៣-៤-៥-៦-៧ ថ្ងៃយ៉ាងយូរ ក៏លាចាកសិក្ខា (សឹក) ហើយទៅគ្រប់គ្រងកាមគុណវិញទៅ ពីព្រោះគេគ្មានចេតនាចេញចាកកាម។

បួសបែបបព្វជ្ជាកម្មព្រះសម្មាសម្ពុទ្ធទ្រង់ហាមកុលបុត្រ៣២ជំពូក មិនឱ្យចូលបព្វជ្ជាទេ គឺ :

| | |
|---|---|
| ១. ហត្ថច្ឆិន្ន | មនុស្សកំបុតដៃ |
| ២. បាទច្ឆិន្ន | មនុស្សកំបុតជើង |
| ៣. ហត្ថបាទច្ឆិន្ន | មនុស្សកំបុតទាំងដៃទាំងជើង |
| ៤. កណ្ណច្ឆិន្ន | មនុស្សកំបុតត្រចៀក |
| ៥. នាសច្ឆិន្ន | មនុស្សកំបុតច្រមុះ |
| ៦. កណ្ណនាសច្ឆិន្ន | មនុស្សកំបុតទាំងត្រចៀកទាំងច្រមុះ |
| ៧. អង្គុលិច្ឆិន្ន | មនុស្សកំបុតម្រាមដៃ |
| ៨. អឡច្ឆិន្ន | មនុស្សកំបុតម្រាមជើង |
| ៩. កណ្ឌរច្ឆិន្ន | មនុស្សដាច់សរសៃធំ |
| ១០. ផណហត្ថក | មនុស្សម្រាមដៃជាប់គ្នា |
| ១១. ខុជ្ជ | មនុស្សគម |
| ១២. វាមន | មនុស្សតឿ |
| ១៣. គលគណ្ឌិក | មនុស្សពក ក |
| ១៤. លក្ខណាហត | មនុស្សដែលគេបៀតបៀនឱ្យមានស្លាកស្នាម |
| ១៥. កសាហត | មនុស្សដែលគេវាយដោយរំពាត់ |
| ១៦. លិខិតក | មនុស្សដែលរាជការព្យួរទោសទុក |
| ១៧. សិបទី | មនុស្សជើងស្ពក់ |

www.budinst.gov.kh www.elibraryofcambodia.org

| | |
|---|---|
| ១៨.បាបរោគី | មនុស្សមាន អាក្រក់ |
| ១៩.បរិសទូសក | មនុស្សប្រទូស្តនឹងបរិស័ទ |
| ២០.កាណោ | មនុស្សទើបនឹងខ្វាក់ |
| ២១.កុណី | មនុស្សក្ងែងដៃជើង |
| ២២.ខញ្ជ | មនុស្សខ្វិក |
| ២៣.បក្ខហត | មនុស្សស្លាប់កាយម្ខាង |
| ២៤.ឆិន្នរិយាបថ | មនុស្សខ្វិន |
| ២៥.ជរាទុព្វល | មនុស្សខ្សោយកំលាំង ព្រោះជរា |
| ២៦.អន្ធ | មនុស្សខ្វាក់ |
| ២៧.មូគ | មនុស្សគ |
| ២៨.ពធិរ | មនុស្សថ្លង់ |
| ២៩.អន្ធមូគ | មនុស្សទាំងខ្វាក់ទាំងគ |
| ៣០.អន្ធពធិរ | មនុស្សទាំងខ្វាក់ទាំងថ្លង់ |
| ៣១.មូគពធិរ | មនុស្សទាំងគទាំងថ្លង់ |
| ៣២.អន្ធមូគពធិរ | មនុស្សទាំងខ្វាក់ទាំងគទាំងថ្លង់ |

កុលបុត្រទាំង៣២ជំពូកនេះ បើចេះសតែបួស បានជាសាមណេរដែរ ប៉ុន្តែ លោកណាធ្វើឧបជ្ឈាយ៍បំបួស ភាគ នោះត្រូវអាបត្តិទុក្កដ។

កាលបើយ៉ាងនេះ សូមឧបជ្ឈាយ៍អ្នកបំបួស និងកុលបុត្រអ្នកសុំបួសពិនិត្យមើលឱ្យត្រឹមត្រូវផង (៩)។

## សតិជាគូ និងបញ្ញា

ដូចបានពោលរួចមកហើយក្នុងសប្បុរិសធម៌ (ធម៌មនុស្សល្អ) កប្រងធម៌នេះ មានសតិ និងបញ្ញាទៅជាមួយគ្នា ឬជាគូនិងគ្នា។ ខ្មែរយើងខ្លះចូលចិត្តថា ការមានតែសតិ គឺមានតែចាំ ក្មានចេះ ការមានតែបញ្ញា គឺមានតែចេះ តែក្មានចាំ។ អ្នកខ្លះមានមតិថា សតិសម្បជញ្ញៈមិនមែនជាធម៌អ្វីដទៃទេ គឺសតិ និងបញ្ញាបូកគ្នានឹងឯង។

**១. បញ្ញា ៤** (១០)

១- ស្គាល់ទុក្ខ

២- ស្គាល់ហេតុនៃទុក្ខ

---

៩ សម្ដេចព្រះមង្គលទេពាចារ្យ អ៊ុំ ស៊ុំ សប្បុរិសធម៌ ពុទ្ធសាសនបណ្ឌិត្យ ឆ្នាំ ១៩៩៨ ទំព័រ ២៧-៣៤

១០ ព្រះគ្រូធម្មបាល ខៀវ ជុំ **សារគុណធម៌** ភ្នំពេញ ១៩៧២ ទំព័រ ៤៥៦

www.budinst.gov.kh www.elibraryofcambodia.org

៣- ស្គាល់ភាពរលត់ទុក្ខ

៤- ស្គាល់ផ្លូវប្រតិបត្តិឱ្យដល់ភាពរលត់ទុក្ខ

ប៉ុន្តែព្រះពុទ្ធសាសនាពុំបានប្រកាសយកបញ្ហា ដែលមានមកពីកំណើតដែលយើងធ្លាប់ហៅថា សេចក្តីវៃឆ្លាត ទុកជាបញ្ហាជាន់ខ្ពស់ តែប្រកាន់យកបញ្ហា ដែលគេបានធ្វើឱ្យកើតដោយអាស្រ័យការគិត ការសិក្សា និងការប្រតិបត្តិធម៌ ឬការអនុវត្តទុកជាបញ្ហាជាន់ខ្ពស់បំផុត ដែលអាចជួយចំលងមនុស្សឱ្យផុតទុក្ខបាន។ ដូចនេះ ព្រោះអ្វី ? ព្រោះសេចក្តីវៃឆ្លាតរបស់មនុស្សយើងមាននោះមានភាពមិនដូចគ្នាទេ។ ចំណែកបញ្ហាប្រភេទដែលគេអប់រំឱ្យកើតបាននោះ ជាធាតុដែលមនុស្សរាល់រូបមានសិទ្ធ សិក្សារៀនសូត្រស្រាវជ្រាវ ប្រតិបត្តិ ឬអនុវត្តឱ្យមាន ឱ្យកើតស្រេចតែសេចក្តីត្រូវការរបស់ខ្លួន។ បញ្ហា ឬសេចក្តីវៃឆ្លាតពីកំណើត ដែលមិនអាចប្រើការបានជាស្ថាពរ ឬគ្មានភាពស្ថិតអស់រយៈចិរកាលនោះ ក៏មានទំនាក់ទំនងមិនខុសគ្នានឹងភ្លើងធម្មជាតិទាំងឡាយ មានភ្លើងព្រៃជាដើម ដែលគេមិនអាចនឹងប្រើភ្លើងនេះឱ្យបានប្រយោជន៍គ្រប់ពេលវេលាដែលត្រូវការបានឡើយ។ ដោយអាស្រ័យភាពមិនស្ថិតស្ថេរនៃភ្លើងទាំងឡាយនេះហើយ ទើបបានជាមនុស្សយើងបង្កើត ឈើគូស ដែកភ្លើងរហូតដល់អគ្គិសនី និងគ្រឿងឧបករណ៍របស់អគ្គិសនី ដើម្បីយកភ្លើងប្រើឱ្យបានគ្រប់ឱកាសដែលត្រូវការ។ សូម្បីបញ្ញាញាណនៃព្រះសម្មាសម្ពុទ្ធព្រះអង្គឯងក៏ពុំមែនបានមកដោយទទើផ្សងព្រេងឡើយ គឺកើតឡើងដោយសេចក្តីព្យាយាម និងការតស៊ូយ៉ាងប្ដូរផ្ដាច់ ទើបបានសំរេចក្នុងទីបំផុត។ "ពុទ្ធសាសនាមិនបានបង្រៀនមនុស្សឱ្យដេកចាំទទួលតែសេចក្តីសុខដែលផ្តល់ដោយធម្មជាតិ ឬដោយអាទិទេព ឬរង់ចាំជោគវាសនា ដែលឫក្សយាម ថ្ងៃ ខែ ឆ្នាំ ល្អផ្តល់ឱ្យឡើយ។ ពុទ្ធសាសនាបង្រៀនមនុស្សឱ្យធ្វើការគ្រប់យ៉ាងនៅក្នុងក្របខ័ណ្ឌនៃគំនិតបញ្ហា ឬក្របខ័ណ្ឌនៃហេតុផល ដើម្បីទទួលយកផលដែលមានគុណភាពខ្ពស់ សមតាមសេចក្តីត្រូវការរបស់ខ្លួន។ ពុទ្ធសាសនាមិនបានបង្រៀនមនុស្សឱ្យផ្ញើរជោគវាសនារបស់ខ្លួនលើគ្នាឯង ឬលើពួកទេពណាមួយឡើយ" ។ មតិនេះមិនសំអាងលើគម្ពីរអដ្ឋកថា ទុក្ខនិបាត អង្គុត្តរនិកាយ ក្នុងចំនុចថា ការខ្វះសតិសម្បជញ្ញៈក៏គ្មានញាណ ឬបញ្ញា។

## ២. ការប្រើបញ្ញាដំណោះទុក្ខ

ពុទ្ធសាសនាមានជំនឿថា ដំណោះទុក្ខជាបញ្ហាសំខាន់ ហើយជាទិសដៅយ៉ាងខ្ពស់បំផុតរបស់បុគ្គល អ្នកឃើញទោសនៃសេចក្តីទុក្ខ។ ចំពោះបញ្ហានេះអ្នកផងស៊ីងបានឃើញហើយថាទ្រឹស្តីអរិយសច្ចៈ៤ប្រការ គឺជាទ្រឹស្តីដំណោះទុក្ខយ៉ាងធំ១ តែជាទ្រឹស្តីមានភាពចំឡែកជាងធម្មតា។ គឺទ្រឹស្តីធម្មតាវាជារឿងនៃគំនិតប្រកាន់យក ឬទង្វើសាកល្បង និងរៀបចំឱ្យមានគោលការណ៍មុន ទើបធ្វើការពិសោធជាក្រោយ។ ទ្រឹស្តីអរិយសច្ចៈរបស់ព្រះសម្មាសម្ពុទ្ធ មិនមែនជាគំនិតយល់សប្តិ ឬគំនិតត្រិះរិះគ្នាន់គ្នេ ហើយប្រកាន់យក ឬអនុវត្តទេ គឺព្រះអង្គបានប្រើជីវិតរបស់ព្រះអង្គឯងជាដើមធាតុក្នុងការសាកល្បងស្រាវជ្រាវ លុះត្រាបានសំរេចផល បានរួចចាកទុក្ខទាំងពួងពិតប្រាកដហើយ ទើបបានប្រកាសទ្រឹស្តីនេះចេញមក ព្រមគ្នានេះបានធ្វើសេចក្តីថ្លែងការបញ្ជាក់ថា ដរាបណាព្រះអង្គមិនបាន

www.budinst.gov.kh www.elibraryofcambodia.org

រកឃើញសេចក្ដីពិត ឬប្រតិបត្តិធម៌មិនបានសំរេចដោយខ្លួនឯង ព្រះអង្គនឹងមិនធ្វើសេចក្ដីប្ដេជ្ញាជាដាច់ខាតថា ព្រះអង្គបានត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិញ្ញាណឡើយ ។

ព្រោះហេតុនេះ ការពិចារណាដល់កំណើត ឬដំណោះនៃសេចក្ដីទុក្ខ តាមលំអាននៃព្រះពុទ្ធសាសនា យើងត្រូវពិចារណាដោយត្រង់ៗ ចំៗ ទៅលើអរិយសច្ចមួយចំនែក ។ ជាមួយគ្នានេះគេត្រូវប្រើគោលការណ៍ និងគំនិតនៅក្រោមខ្សែបន្ទាត់នៃអរិយសច្ចៈ ដើម្បីចំអិនបញ្ហាជារឿយៗ ប្រកបដោយការព្យាយាមយ៉ាងក្លាហានមោះមុត ។

**ក. កំណែទុក្ខតាមគំនិតអរិយសច្ចៈ**

១- មុនដំបូងឱ្យស្គាល់អ្វីជាភាពទុក្ខ ពេលខ្លះគេមូលចិត្តត្រឡប់ត្រឡិន ឃើញទុក្ខថាជាសុខ ។ ដូចនេះទើបគេប្រកាន់យកគោលការណ៍ថាទុក្ខមាន៤បែប គឺទុក្ខប្រចាំបានដល់ សេចក្ដីកើត សេចក្ដីចាស់ សេចក្ដីឈឺ និងសេចក្ដីមរណៈ ។ ទុក្ខ បានដល់សេចក្ដីខ្សឹកខ្សួល សេចក្ដីមិនសប្បាយចិត្ត-កាយ សេចក្ដីចង្អៀតចង្អល់ ។ល។

២- ឱ្យស្គាល់ថាអ្វីជាដើមហេតុនៃទុក្ខ ឬធ្វើកំណែទុក្ខ ។ តែកំណែរបស់គេពុំបានធ្វើដល់ដើមហេតុនៃទុក្ខត្រឡប់ជាវេរីវាយទៅធ្វើលើផលនៃទុក្ខទៅវិញ ។ ដូចនេះ ទើបកំណែរបស់គេវាទៅជាគ្មានផល បានប្រយោជន៍ធ្វើ គឺវានៅជាទុក្ខ ជាព្រួយដដែល ។ល។

៣- ឱ្យស្គាល់ភាពរលត់ទុក្ខថា បានដល់អ្វី ឬមានអ្វីជាធាតុសំរាប់រំលត់ទុក្ខ ។ ពុទ្ធសាសនាបានបង្ហាញថាការរំលត់ទុក្ខ មិនមែនរំលត់ផលទេ គឺត្រូវរំលត់ហេតុ ។ បើរំលត់តែផល ហេតុនៅដដែល ទុក្ខនឹងកើតឡើងទៀត ។ ដូចនេះការរំលត់ទុក្ខក្នុងទីនេះ គឺត្រូវរលត់ហេតុ បានដល់តណ្ហាពាឱ្យបានដាច់ខាត ។

៤- ឱ្យស្គាល់ថា ភាពរំលត់ទុក្ខមិនអាចនឹងកើតបានស្រួលៗ ធូរៗទេ ត្រូវបានការប្រតិបត្តិនាំឱ្យរំលត់ទុក្ខ ។ សេចក្ដីប្រតិបត្តិនោះគេហៅថា **មជ្ឈិមបដិបទា** ។

ចំពោះរឿងសេចក្ដីស្នេហា ព្រះសម្មាសម្ពុទ្ធបានមានព្រះតម្រាស់ថា ស្នេហាមួយមានទុក្ខមួយ ស្នេហាមួយរយមានទុក្ខមួយរយ ។ល។ អ្នកណាថាមិនពិត ឬមានហេតុផលជំទាស់នឹងព្រះពុទ្ធឱវាទ នេះក៏ស្រេចតែក្បាលចិត្តរបស់គេចុះ គំនិតខ្ញុំឃើញថា ពុទ្ធតម្រាស់នេះបើទុកដាក់ជាគហេតសាស្ត្រក៏បាន ព្រោះខាងគហេតសាស្ត្រតែងតែមានស៊ុំ មានសង ឬបើទុកដាក់ជាគ្រឿងប្រដាប់សម្រាប់ទប់ សម្រាប់ភ្លោមក៏បាន ព្រោះបើគ្មានគ្រឿងប្រដាប់ភ្លោមកង់ កង់ក៏មិនយេចវិល រថយន្តក៏មិនឈប់បុក ឬភ្លូក ។ ចំណែកចិត្តមនុស្សវិញ បើគ្មានធម្មៈសំរាប់ទប់ សំរាប់ភ្លោម សេចក្ដីស្នេហាក៏មិនឈប់កើត ទុក្ខក៏មិនលេចបំបាន ។ បើសេចក្ដីស្នេហាមនុស្សកាន់តែដើរហួសព្រំដែន ម្នាក់ណាក៏ដូចម្នាក់ណា ពិភពលោកក៏ត្រូវតែឆេះដោយ **រាគគ្គិ** នៃប្រជាសត្វជាមិនខាន ។ ពុំទាលនេះត្រូវចំរើនលើពុទ្ធសុភាសិតថា ៖ "គ្មានភ្លើងណាមានកំដៅជាងភ្លើងស្នេហាគ្មានព្រំដែន គ្មានស្ងប់ ។ គ្មានកំហុសណាមានពិសកំណាចជាងកំហុសនៃកំរើង ។ គ្មានសំណាញ់ណាមានជំទាប់មាំមួនជាងសំណាញ់នៃក្រឡៀ ។ គ្មានស្ទឹងណាហូរជាប់ឥតឈប់ដូចស្ទឹងនៃ

www.budinst.gov.kh www.elibraryofcambodia.org

សេចក្តីស្នេហាទេ”។ “**នត្ថិ រាគ សមោ អគ្គិ នត្ថិ ទោសសា សមោគហោ នត្ថិ មោហ សមំ ជាលំ នត្ថិតណ្ហា សមា នទី**” មួយទៀតគ្មានភ្លើងណាមានកំដៅខ្លាំងក្លាជាងសេចក្តីស្នេហាអត់មានចប់ អត់មានព្រំដែន គ្មានកំហុសភ្លាំងភ្លាត់ណាត្រូវបង្កើតគ្រោះថ្នាក់ស្មើដោយទោសៈ គ្មានទុក្ខណាញាំញីកំទេចមនុស្សស្មើដោយខន្ធ៥ គ្មានស្ទឹងណាហូរជាប់រសាត់អសាតជានិរន្តរ៍ស្មើដោយស្ទឹងនៃសេចក្តីស្នេហាគ្មានទីបញ្ចប់ គ្មានទីបំផុត“**នត្ថិ រាគ សមោ អគ្គិ នត្ថិ ទោសសា សមោ កលិ នត្ថិ ខន្ធា សមា ទុក្ខា**” ។ ជីវិតទោសៈនៃសេចក្តីស្នេហា (តណ្ហា) ឃើញពិភពលោកមានទំហំតូច មានភាពចង្អៀត។ ជីវិតសន្តោស (ស្កប់ចិត្ត) ឃើញពិភពលោកមានទំហំធំ មានសភាពទូលំទូលាយ។ ពិភពលោកកើតសង្គ្រាមដោយភ្លើងរាគៈ ទោសៈ មោហៈ ដែលអាស្រ័យនៅក្នុងចិត្តមនុស្ស ឬដែលមានចិត្តសត្វលោកជាជើងក្រាន។ ពិភពលោកមានសន្តិភាពដោយអាស្រ័យសេចក្តីសន្តោសមានព្រំដែន ដែលមាននៅក្នុងចិត្តមនុស្ស ឬដែលមានចិត្តសត្វលោកជាលំនៅឋាន។ ពិភពលោកមានសេចក្តីរុងរឿងដោយអ្នកសាសនា និងអ្នកវិទ្យាសាស្ត្រមានចិត្តជាកុសល ឬរស់នៅក្នុងព្រហ្មវិហារធម៌។ ពិភពលោកវិនាសដោយសារអ្នកសាសនា និងអ្នកវិទ្យាសាស្ត្រគ្មានសីលធម៌ គ្មានអនុវត្តព្រហ្មវិហារធម៌ គ្មានមេត្តាដល់គ្នាទៅវិញទៅមក មានសេចក្តីដូចនេះ :

បុគ្គលណាមានស្មារតីមនុស្សជាតិ ចំរើនមេត្តាធម៌គ្មានកំណត់ព្រំដែន បុគ្គលនោះបានឈ្មោះថា ឃើញធម៌ជាទីអស់ទៅនៃកិលេស រមែងមានកិលេសជាគ្រឿងទាក់ចងថយចំនួនចុះ។ បុគ្គលមានចិត្តមិនប្រទូស្ត ផ្សាយមេត្តាធម៌ដល់សត្វ សូម្បីមានខ្លួនតែមួយ ទង្វើនេះរបស់គេជាទង្វើមានកុសល។ បើគេមានចិត្តអនុគ្រោះក្នុងសត្វទាំងពួង ទង្វើគេនេះក៏ត្រូវបានឈ្មោះថា ជាទង្វើប្រសើរ ជាទង្វើបានបុណ្យយ៉ាងច្រើន ជាទង្វើដែលសប្បុរសទាំងឡាយលើកតំកើងជាកំពូលដូចព្រះច័ន្ទ ជាកំពូលនៃផ្កាយទាំងឡាយ ។ល។

## ខ. ហេតុផលក្នុងការខ្វះការសំលាប់សត្វ

ពុទ្ធសាសនាមិនបានបង្រៀនមនុស្សឱ្យគិតតែពីសត្វ បៀតបៀនសត្វ មិនបានបង្រៀនឱ្យឃើញតែប្រយោជន៍ផ្ទាល់ខ្លួន ជាងតម្លៃជីវិតឃោរឃៅសាហាវអ្នកដទៃ។ បង្រៀនឱ្យដឹកដល់ចិត្តគេចិត្តយើង ឆ្វេងគេឆ្វេងយើង។ ដរាបណាយើងឃើញតែប្រយោជន៍ផ្ទាល់ខ្លួន កាលណាមានធាតុអ្វីមួយមកខ្ទាស់ទើសប្រយោជន៍របស់យើង យើងក៏កំទេចចោលភ្លាម យើងគ្មានជំនឿក្នុងការប្រតិកម្មធម្មៈរបស់ពុទ្ធសាសនា ព្រោះយើងមានគំនិតថា បើមនុស្សទាំងពិភពលោកគេគិតតែប្រយោជន៍ផ្ទាល់ខ្លួនជាធំទៅហើយ តែយើងគិតប្រយោជន៍អ្នកដទៃ ដែលដឹកនាំដោយពុទ្ធសាសនានោះ យើងនឹងប្រកាន់យកដូចម្តេចបាន។ គំនិតនេះក៏ត្រូវបរ្យាងដែរ តែបើមនុស្សលោកមានគំនិតយ៉ាងដូចនេះដូចគ្នាទាំងអស់ តើការប្រកាន់ប្រជែង ទំរើជិះជាន់ អង្វើកាត់ប្រកាក់ ទង្វើមល្បាំង ។ល។ វាអាចចប់ដែរឬទេ ? សន្តិភាពនៃពិភពលោកដែលជាទីត្រូវការរបស់សកលមនុស្ស វាអាចមានបានឬពុំបានទេ ? ព្រះសម្មាសម្ពុទ្ធពុំដែលបានបង្រៀនឱ្យសំពីងឃើញតែប្រយោជន៍ផ្ទាល់ខ្លួននៃមនុស្សម្នាក់ៗដល់ម្តងណាទេ ព្រះអង្គតែងតែបង្រៀនឱ្យគិតយើងមើល

ប្រយោជន៍អ្នកដទៃផង ។ ព្រោះអ្វី ? គឺព្រោះប្រយោជន៍របស់ខ្លួន បើគ្មានអ្នកដទៃទោះជាយើងខំប្រឹងធ្វើយ៉ាងណាក៏កើតមិនបានដែរ ។ ក្នុងទីណាក៏ដោយបើគ្មានការយកចិត្តគេមកដាក់ក្នុងចិត្តរបស់យើងហើយក្នុងទីនោះគេមិនអាចនឹករកសេចក្តីសុខស្ងប់បានឡើយ ។ តាមគោលការណ៍នឹកដល់ទ្រូងគេទ្រូងយើង ។ ទង្វើនេះអាចពង្រីកចេញទៅជាគំនោលសីលធម៌ខាងព្រះពុទ្ធសាសនាជនសាមញ្ញ ដែលហៅថា បញ្ចសីល បញ្ចធម៌ គឺ : សីល៥ ធម៌៥ ។

**គ. បញ្ចសីលបញ្ចធម៌**

សីលដៅយកការវៀរចាកទង្វើអាក្រក់ ធម៌សំដៅយកដល់ការបណ្តុះបំប៉នទង្វើល្អ មួយដែកជា៥ ជាគូៗនឹងគ្នាដូចនេះ :

១- វៀរចាកសំលាប់សត្វ និងមនុស្ស ជាសីលទីមួយ មានមេត្តាករុណាចំពោះមនុស្ស និងសត្វ ជាធម៌ទី១ ។

២- វៀរចាកលួចទ្រព្យសម្បត្តិ ជាសីលទី២ ប្រកបសម្មាអាជីព និងមានចិត្តអ្វើពើធ្វើអំណោយផ្សាយសេចក្តីសុខចម្រើនដល់អ្នកដទៃ ជាធម៌ទី២ ។

៣- វៀរចាកទង្វើប្រព្រឹត្តិខុសក្នុងប្រពៃណីកាម ជាសីលទី៣

៤- វៀរចាកនិយាយកុហក ជាសីលទី៤ និយាយពាក្យពិត ជាធម៌ទី៤

៥- វៀរចាកផឹកសុរា មេរយៈ ឬគ្រឿងស្រវឹងទាំងឡាយដែលជាទីតាំងនៃសេចក្តីប្រមាថ ជាសីលទី៥ មានសតិស្មារតីនឹងនរ ជាធម៌ទី៥ ។

**ឃ. ព្រះពុទ្ធសាសនាជាមួយនឹងសង្គមសង្គ្រោះ**

ពុំនោះថា : ពុទ្ធសាសនាបង្រៀនឱ្យធ្វើសង្គមកិច្ច ជំនួសទង្វើសំលាប់សត្វ បៀតបៀនសត្វ គឺសំលាប់សត្វបូជាយញ្ញ នោះ ។យើងគួរដឹងថាសង្គមកិច្ចរបស់ព្រះពុទ្ធសាសនាយ៉ាងដូចម្តេចខ្លះ ។

គោលការណ៍សង្គមសង្គ្រោះដែលត្រូវនឹងពាក្យអង់គ្លេសថា (Social Work) នោះសំដៅដល់សង្គ្រោះនូវមនុស្សដែលគ្នាគ្មានមធ្យោបាយជួយខ្លួនឯងបាន ដើម្បីឱ្យគ្នាមានសមត្ថភាពជួយខ្លួនឯង ដោយគ្មានប្រាថ្នាយកកំរៃជំនួសវិញ ។ ទង្វើនេះត្រូវតែធ្វើដោយមានការពិនិត្យ សាកសួរដេញដោលជាមុន ដោយហេតុថាបញ្ហានេះមិនមែនធូរស្រួលងាយធ្វើទេ ព្រោះមានមនុស្សមួយពួកខ្ជិលធ្វើការដើម្បីរស់ គិតតែពឹងផ្អែករស់លើអ្នកដទៃតែម្តង ។ ពួកមួយខំធ្វើការដើម្បីរស់ខ្លួនឯង តែខ្វះមធ្យោបាយរកធ្វើមិនចេញ ។ មនុស្សទាំងពីរពួកនេះព្រះពុទ្ធសាសនាក្តី អ្នកសង្គមសាស្ត្រក្តីបង្រៀនឱ្យយើងធ្វើសង្គមកិច្ច ។ ចំនែកមនុស្សខ្ជិល ព្រះអង្គមិនត្រឹមតែមិននិយាយឱ្យជួយប៉ុណ្ណឹងទេ ព្រះអង្គព្រមទាំងពុំនោលបញ្ជីថា មនុស្សបែបនេះគេកើតមកត្រឹមតែជាដង្កត់ ឬជាភក់ជល់ជើងកប់កង់នៃសេចក្តីចំរើនរបស់ពិភពលោក (**ឧសិយា សោក ទឡ្ហនា**) ([១២]) ។ ដូច្នេះហើយ បានជាក្នុងធម្មៈដែលមានឈ្មោះថា "**ទាន**"

[១២] ព្រះភិក្ខុធម្មបាល ខៀវ ជុំ **សារគមនវិទ្យា** ភ្នំពេញ ១៩៧២ ទំព័រ ទំព័រ ៦៣៤

www.budinst.gov.kh www.elibraryofcambodia.org

ព្រះអង្គ បានបញ្ជាក់ហើយបញ្ជាក់ទៀតថា អ្នកធ្វើអំណោយជាមនុស្សមានគុណធម៌ល្អហើយ តែគេត្រូវធ្វើអំណោយចំពោះ មនុស្សណាមានរូបកាយអន់ ខ្វះមធ្យោបាយគ្រប់បែបយ៉ាង។ ចំនែកមនុស្សដែលមាន សុខភាពល្អ រូបកាយរឹងប៉ឹងមាំមួន ដៃជើងធំៗ ហើយខ្ជិលធ្វើការមិនត្រូវឱ្យទេត។ បើនៅតែចចេសឱ្យ សង្គមមនុស្សនឹងអស់មនុស្សធ្វើការហើយ។ មានតែមនុស្សសុំទានពេញផែនដីទាំងមូល។ ទង្វើសុំទាន ទង្វើគ្មានមនុស្សធ្វើការ ទង្វើធ្វើការមិនគ្រប់ម៉ោង ទង្វើធ្វើការមិនគ្រប់មនុស្ស ឬអ្នកធ្វើការមានចំនួនតិច អ្នកមិនធ្វើការមានចំនួនច្រើន។ល។ ទង្វើទាំងឡាយនេះជាទង្វើសេចក្តីមរណៈមកឱ្យស្រុក ប្រទេស ឬពិភពលោក។ នេះគឺជាសេចក្តីយល់ឃើញរបស់អ្នកសេដ្ឋកិច្ចដែលស្រប នឹងយោបល់ពុទ្ធសាសនាដល់កំរិតមួយរយភាគរយឥតប្រកែកកើត។

ព្រះពុទ្ធសាសនាមានគំនោលធម្មៈបង្រៀនឱ្យសង្គ្រោះមនុស្សដោយសេចក្តីមេត្តា ករុណា គ្មានប្រាថ្នាកកំរៃតបស្នងវិញ គឺសង្គ្រោះដោយទឹកចិត្តល្អបរិសុទ្ធ។ ចំនែកការត្រួតពិនិត្យ ការសាកសួរដើម្បីដឹងមិនឱ្យអ្នកមកសុំទាន ឬសុំជំនួយបោកបញ្ឆោតនោះ ក៏ជាទង្វើមួយទៀតរបស់អ្នកធ្វើអំណោយ ដែលត្រូវតែប្រើបញ្ញាពិចារណារកហេតុផលឱ្យឃើញថា ស្មូមនោះត្រូវការដើម្បីក្រពះ ឬដើម្បីសេដ្ឋកិច្ច ឬដើម្បីសប្បាយប៉ុកប៉ាក់ហ៊ឺហា។ ព្រោះអ្វី ? ព្រោះថាទង្វើគ្រប់យ៉ាងព្រះពុទ្ធសាសនាបានបង្រៀនឱ្យយកបញ្ញាធ្វើជាបង្អែក មិនមែនឱ្យធ្វើដោយកំឡៅឡើយ។ ការធ្វើទានមានស្រួល មានមិនស្រួលដែរ ធ្វើដល់មនុស្សទន់ខ្សោយពិតៗស្រួលហើយឈ្មោះថា បានបំពេញមនុស្សធម៌យ៉ាងប្រសើរ ធ្វើដល់អ្នកបោកប្រាស់មិនស្រួលទេ។ ខាងផ្លូវធម៌គេថាព្រះពុទ្ធសាសនាបានប្រព្រឹត្តនូវទង្វើមិនល្អ គឺធ្វើឱ្យមនុស្សលែងចេះពឹងខ្លួនឯងដែលព្រះពុទ្ធសាសនាធ្លាប់បានបង្រៀនឱ្យមនុស្សពឹងខ្លួនឯង កុំឱ្យពឹងអ្នកដទៃ។ ឯខាងផ្លូវសេដ្ឋកិច្ចជាតិ គេថាមនុស្សរស់ដោយសារអំណោយយូរៗទៅ ជាតិស្លាប់។ គេឱ្យសេចក្តីប្រៀបថា ដូចអ្នកស្រែយកពស់វែកថ្លាក់ទឹកមកកៀកអោបនឹងដើមទ្រូងរបស់ខ្លួន ដើម្បីចែកកំដៅដល់វា លុះវាបានកំដៅគ្រប់គ្រាន់ វាចឹកអ្នកស្រែស្លាប់ទៅ យ៉ាងណាមិញប្រទេសជាតិក៏អញ្ចឹងដែរបើមានតែអ្នករស់ដោយសារអំណោយ គ្មានអ្នកធ្វើការងារបង្កើតផលទេ ប្រទេសជាតិក៏ត្រូវស្លាប់ដោយសារតែអ្នកសុំទានយ៉ាងដូចនោះដែរ។ យោបល់ខ្ញុំក្នុងរឿងនេះថាការធ្វើកំណែនៃសេចក្តីកំណាញ់របស់អ្នកមានស្តុកស្តម្ភដោយធ្វើអំណោយ និងការធ្វើកំនែអ្នកក្រខ្សត់ខ្សោយ អត់ឃ្លានដោយទទួលអំណោយនោះ ទង្វើនេះវាគ្រាន់ជាប្រពៃណីចាស់សំរាប់មនុស្សកំឡៅប៉ុណ្ណោះទេ។ ចំណែកទង្វើមានហេតុផល ឬកំនែស្របក្បួនសេដ្ឋកិច្ច គឺរកមធ្យោបាយយ៉ាងណាឱ្យមនុស្សមានការធ្វើគ្រប់គ្នា ទើបស្រាយបញ្ហាសេដ្ឋកិច្ចសង្គមរួច។ នេះឯងគឺជាពុទ្ធតម្រាស់មួយក្នុងចំនុចមួយថា "សប្បុរសលោកធ្វើទានដល់មនុស្សណាដែលគួរធ្វើ គួរឱ្យ។ មនុស្សណាខ្លះដែលគួរធ្វើ គួរឱ្យ គឺមនុស្សខ្វះមធ្យោបាយ ធ្វើខ្លួនឱ្យរស់ ឬរស់នៅដោយខ្លួនឯងមិនកើត មានជាអាទិ៍ មនុស្សបាក់ដៃ ជើង មនុស្សខ្វាក់ភ្នែក មានជំងឺរ៉ាំរ៉ៃក្នុងខ្លួន ឬខ្វះខាតដើមទុនពិតៗ។ល។

www.budinst.gov.kh www.elibraryofcambodia.org

**ខ. គោលធម៌ក្នុងការធ្វើសង្គ្រោះដែលមានឈ្មោះថាសង្គហវត្ថុ៤ ([១៣])**

មនុស្សគ្រប់មជ្ឈដ្ឋានទោះជាអ្នករាជការដែលរដ្ឋឱ្យតំណែងខ្ពស់ក្តី កណ្តាលក្តី ទាបក្តី។ ប្រជារាស្ត្រ ឬប្រជាពលរដ្ឋទោះជាអ្នកមានក្តី កណ្តាលក្តី ក្រក្តី ។ល។ ត្រូវតែនាំគ្នារស់នៅក្នុងសង្គហធម៌ទាំង៤នេះ ទើបជាតិរស់ សាសនាចំរើនបាន ព្រះសម្មាសម្ពុទ្ធបានឱ្យឈ្មោះសង្គហធម៌៤នេះថា ជាកងធម៌កង់សម្រាប់បង្វិលមនុស្សទៅកាន់សេចក្តីចំរើនគ្រប់ប្រការ ថាជាប្រភពនៃសាមគ្គីធម៌ផង។

**គ. ការធ្វើបុណ្យតាមន័យរបស់ព្រះពុទ្ធសាសនា**

ពាក្យថាបុណ្យក្នុងព្រះពុទ្ធសាសនាមានន័យ៣យ៉ាងគឺ :

១- ពុំនោលដោយសភាវៈ បានដល់គុណជាតិសំរាប់ជំរះសណ្តានចិត្តសត្វឱ្យស្អាតផូរផង់ ព្រោះ បុណ្យប្រែថាជំរះ ឬលាង គឺលាងជំរះមន្ទិលសៅហ្មងដែលមាននៅក្នុងចិត្ត។

២- ពុំនោលដោយហេតុ បានដល់ការធ្វើគុណល្អផ្សេងៗ ឬទង្វើល្អនានា

៣- ពុំនោលដោយផល បានដល់សេចក្តីសុខចំរុងចំរើន

ជនភាគច្រើនមានចំនួលចិត្តថា ទង្វើបុណ្យត្រូវមានលុយកាក់ទើបធ្វើបាន ព្រោះគេមានយោបល់ថា មានតែការបរិច្ចាកទ្រព្យប៉ុណ្ណោះទើបមានឈ្មោះថាធ្វើបុណ្យ។ បើដូចគំនិតនេះពិត បុណ្យគេទិញដោយប្រាក់ ឬដូរដោយទ្រព្យសម្បត្តិទើបបានបុណ្យ។ តែបើយើងស្គាល់ន័យរបស់បុណ្យថា បុណ្យបានដល់ទង្វើឱ្យជំរះចិត្តបរិសុទ្ធ យើងនឹងចូលចិត្តបានភ្លាមថា ប្រភពសំភារៈឱ្យកើតបុណ្យមានច្រើនបែប ច្រើនប្រការណាស់ អ្នកក្រខ្សត់ខ្សោយអាចធ្វើបុណ្យបានច្រើនជាងអ្នកមានស្តុកស្តម្ភទៅទៀតក៏មានដែរ បើសិនបើគេមានចិត្តចង់ធ្វើ ឬចាំបាច់ត្រូវធ្វើ គេចេះតែធ្វើកើតមិនខានឡើយ ព្រោះព្រះពុទ្ធសាសនាជាសាសនាដែលបង្រៀនឱ្យប្រកាន់យកធម្មៈ គឺភាពត្រឹមត្រូវតាមហេតុផលជាប្រមាណដែលហៅថា ធម្មាធិបតេយ្យ។ មិនបង្រៀនឱ្យប្រកាន់យកខ្លួនឯងជាធំ។ គំនោលបង្រៀនក្នុងចំនុចថាអ្នកណាមើលឃើញធម្ម អ្នកនោះឈ្មោះថាឃើញព្រះសម្មាសម្ពុទ្ធ។ គំនោល គឺបង្រៀនអាមិសបូជា បដិបត្តិបូជា និងការតែងតាំងធម្មវិន័យទុកជាគ្រូអាចារ្យ ឬបរមសាស្ត្រាចារ្យជំនួសព្រះសម្មាសម្ពុទ្ធ។ ជាទង្វើបង្រៀនបែបធម្មាធិបតេយ្យ។

[១៣] ព្រះភិក្ខុធម្មបាល ខៀវ ជុំ **សាគរធម៌** ភ្នំពេញ ១៩៧២ ទំព័រ ៦៦៥

www.budinst.gov.kh www.elibraryofcambodia.org

**ខ. គោលធម៌ក្នុងការធ្វើសង្គ្រោះដែលមានឈ្មោះថាសង្គហវត្ថុ៤** ([១៣])

មនុស្សគ្រប់មជ្ឈដ្ឋានទោះជាអ្នករាជការដែលរដ្ឋឱ្យតំណែងខ្ពស់ក្តី កណ្តាលក្តី ទាបក្តី ។ ប្រជារាស្ត្រ ឬប្រជាពលរដ្ឋទោះជាអ្នកមានក្តី កណ្តាលក្តី ក្រក្តី ។ល។ ត្រូវតែនាំគ្នារស់នៅក្នុងសង្គហធម៌ទាំង៤នេះ ទើបជាតិរស់ សាសនាចំរើនបាន ព្រះសម្មាសម្ពុទ្ធបានឱ្យឈ្មោះសង្គហធម៌៤នេះថា ជាកងធម៌កង់សម្រាប់បង្វិលមនុស្សទៅកាន់សេចក្តីចំរើនគ្រប់ប្រការ ថាជាប្រភពនៃសាមគ្គីធម៌ផង ។

**គ. ការធ្វើបុណ្យតាមន័យរបស់ព្រះពុទ្ធសាសនា**

ពាក្យថាបុណ្យក្នុងព្រះពុទ្ធសាសនាមានន័យ៣យ៉ាងគឺ :

១- ពុំនោលដោយសភាវៈ បានដល់គុណជាតិសំរាប់ជំរះសណ្តានចិត្តសត្វឱ្យស្អាតផូរផង់ ព្រោះ បុណ្យប្រែថាជំរះ ឬលាង គឺលាងជំរះមន្ទិលសៅហ្មងដែលមាននៅក្នុងចិត្ត ។

២- ពុំនោលដោយហេតុ បានដល់ការធ្វើគុណល្អផ្សេងៗ ឬទង្វើល្អនានា

៣- ពុំនោលដោយផល បានដល់សេចក្តីសុខចំរុងចំរើន

ជនភាគច្រើនមានចំនួលចិត្តថា ទង្វើបុណ្យត្រូវមានលុយកាក់ទើបធ្វើបាន ព្រោះគេមានយោបល់ថា មានតែការបរិច្ចាគទ្រព្យប៉ុណ្ណោះទើបមានឈ្មោះថាធ្វើបុណ្យ ។ បើដូចគំនិតនេះពិត បុណ្យគេទិញដោយប្រាក់ ឬដូរដោយទ្រព្យសម្បត្តិទើបបានបុណ្យ ។ តែបើយើងស្គាល់ន័យរបស់បុណ្យថា បុណ្យបានដល់ទង្វើឱ្យជំរះចិត្តបរិសុទ្ធ យើងនឹងចូលចិត្តបានភ្លាមថា ប្រភពសំភារៈឱ្យកើតបុណ្យមានច្រើនបែប ច្រើនប្រការណាស់ អ្នកក្រខ្សត់ខ្សោយអាចធ្វើបុណ្យបានច្រើនជាងអ្នកមានស្តុកស្តម្ភទៅទៀតក៏មានដែរ បើសិនបើគេមានចិត្តចង់ធ្វើ ឬចាំបាច់ត្រូវធ្វើ គេចេះតែធ្វើកើតមិនខានឡើយ ព្រោះព្រះពុទ្ធសាសនាជាសាសនាដែលបង្រៀនឱ្យប្រកាន់យកធម្មៈ គឺភាពត្រឹមត្រូវតាមហេតុផលជាប្រមាណដែលហៅថា ធម្មាធិបតេយ្យ ។ មិនបង្រៀនឱ្យប្រកាន់យកខ្លួនឯងជាធំ ។ គំនោលបង្រៀនក្នុងចំនុចថាអ្នកណាមើលឃើញធម្ម អ្នកនោះឈ្មោះថាឃើញព្រះសម្មាសម្ពុទ្ធ ។ គំនោល គឺបង្រៀនអាមិសបូជា បដិបត្តិបូជា និងការតែងតាំងធម្មវិន័យទុកជាគ្រូអាចារ្យ ឬបរមសាស្ត្រាចារ្យជំនួសព្រះសម្មាសម្ពុទ្ធ ។ ជាទង្វើបង្រៀនបែបធម្មាធិបតេយ្យ ។

[១៣] ព្រះភិក្ខុធម្មបាល ខៀវ ជុំ **សាសនវិទ្យា** ភ្នំពេញ ១៩៧២ ទំព័រ ៦៦៩

## ព្រះពុទ្ធអង្គ

(ស.វទី៥ – ៦ នៃគ.ស)



ព្រះពុទ្ធអង្គសិរីទ្រង់ឈរ

ស្រុកកងទឹក, ខេត្តកញ្ចនៈបុរី (សៀមសព្វថ្ងៃ)

www.budinst.gov.kh www.elibraryofcambodia.org

ឆ្នាំ៥០០ - ៥៥០ គ.ស





រកឃើញនៅចេតិយបឋម , នគរបឋម

ព្រះពុទ្ធអង្គទ្រង់ឈរ សំរិទ្ធ និង ថ្ម

រូបភាពទី១ : សម័យនគរភ្នំ មុនការបង្កើតនគរមន ទ្វារវតី.ស.វ ៦ គ.ស

រូបភាពទី២ : ខេត្តស៊ុភាគ ធានី ស.វទី៦ ថៃ [illegible]

www.budinst.gov.kh www.elibraryofcambodia.org



ព្រះពុទ្ធអង្គទ្រង់បង្រៀន

អង្គបុរី,ខេត្តតាកែវ,ស.វ.ទី៦ នៃគ.ស



ព្រះពុទ្ធអង្គថ្ម , ទ្រង់ឈរ

រូបភាពទី ១៖ ទួលតាហ៊ិយ , កំពង់ស្ពឺ ស.វ.ទី ៦ គ.ស

២–៣៖ វត្តរំលោក , អង្គបុរី , តាកែវ ស.វ.ទី ៦ គ.ស

www.budinst.gov.kh www.elibraryofcambodia.org

# ជំពូកទី ៤

## ព្រះពុទ្ធសាសនានៅខ្មែរ

### ១. កម្ពុជា

#### ក. ទីតាំង

ប្រទេសកម្ពុជាស្ថិតនៅទ្វីបអាស៊ីភាគអាគ្នេយ៍ ត្រង់ភាគខាងត្បូងនៃឧបទ្វីបឥណ្ឌូចិន ចន្លោះខ្សែស្របទី១០ និងទី១៥ នៃរយៈទទឹងខាងជើង និងចន្លោះខ្សែបណ្តោយទី១០២ និងទី១០៨នៃរយៈបណ្តោយខាងកើត។ ដូចនេះ កម្ពុជានៅក្នុងតំបន់ត្រូពិច ត្រង់អឌ្ឍគោលខាងជើង ដែលជាតំបន់ដីមានជីជាតិ ហើយអំណោយផលដល់ការលូតលាស់នៃរុក្ខជាតិ និងដំណាំផ្សេងៗគ្រប់ប្រភេទ។ កម្ពុជាមានរាងជាពហុកោណស្ទើរស្មើជ្រុង មានព្រំប្រទល់ខាងជើងជាប់ប្រទេសថៃ ហើយមួយភាគធំជាប់នឹងប្រទេសឡាវ ខាងកើត និងខាងត្បូងមួយភាគជាប់នឹងប្រទេសវៀតណាម ខាងត្បូងមួយភាគទៀតជាប់នឹងឈូងសមុទ្រថៃ ខាងលិចជាប់នឹងឈូងសមុទ្រថៃ ហើយមួយភាគទៀតជាប់នឹងប្រទេសថៃ។

#### ខ. ផ្ទៃដី

ប្រទេសកម្ពុជាមានផ្ទៃក្រឡា ១៨១.០៣៥ ត.ម$^{2}$ ។

#### គ. ប្រជាជន

ចំពោះប្រជាជននៅកម្ពុជា តាមអ្នកប្រាជ្ញខាងជាតិពន្ធុវិទ្យាបានសន្និដ្ឋានថាពួក **អូស្ត្រាឡូអ៊ីត** និងពួក **មេឡាណេស៊ី** សម្បុរខ្មៅបានមកនៅឥណ្ឌូចិនតាំងពីច្រើនស.វមុនគ.សមកម្ល៉េះ។ បន្ទាប់មកមានពួកឥណ្ឌូនេស៊ី ជាជនជាតិស្បែកលឿងចូលមកនៅលាយឡំនឹងប្រជាជនចាស់បង្កបង្កើតឡើងជាជាតិសាសន៍ **មន-ខ្មែរ** ។ ក្រោយមកមានពួកឥណ្ឌាជាអ្នកជំនួញ ជាអ្នកភៀសខ្លួនពីសង្គ្រាម និងជាអ្នកផ្សាយសាសនាបានមករស់នៅលាយឡំជាមួយនឹងម្ចាស់ស្រុកដើមបង្កបង្កើតបានជាអរិយធម៌មួយ។ តែមានពួកកុលសម្ព័ន្ធខ្លះពុំព្រមទទួលយកនូវបញ្ហាទាំងនេះ ពួកគេក៏ទៅរស់នៅតំបន់ដាច់ពីគេ ហើយមានសេសសល់រហូតដល់សព្វថ្ងៃនេះ។ ក្រោយមកទៀតមានជាតិសាសន៍ផ្សេងៗបានមករស់នៅជាបន្តបន្ទាប់ដូចជាជាតិថ្មា ព្រាហ្មណ៍ (ស.វទី៨) ជាតិចិន (ស.វទី១៣) វៀតណាម ឡាវ ចាម ភូមា ជាដើម។ ហេតុនេះបានជាគេឃើញមានមនុស្សផ្សេងៗគ្នាជាច្រើនរស់នៅលើទឹកដីកម្ពុជា។ ស្ថិតិប្រជាជនកម្ពុជាក្នុងឆ្នាំ ១៩៦២ មានចំនួន ៥.៧២៨.៧៧១នាក់ ក្នុងនោះមានជនជាតិខ្មែរប្រហែលជា ៥ ភាគ ៦ ([១៤]) ។

---

១៤ លោក គាត់ ម៉ម ស្គាល់ **ដឹងប្រជាជនពិភពលោក** ភ្នំពេញ ១៩៧៤ ទំព័រ ៤៥

www.budinst.gov.kh www.elibraryofcambodia.org

### ឃ. ជនជាតិផ្សេងៗក្រៅពីជនជាតិខ្មែរមាន

- ពួកកុលសម្ព័ន្ធ មានច្រើនក្រុមដូចជាពួកពរ៍ ស្ទូច សំរែ កួយ ស្មៀង ព្នង ។ ពួកគេរស់នៅដាច់ស្រយាលពីគេ ។ ប្រកបអាជីវកម្មប្រមាញ់ នេសាទ និងកសិកម្មលើដីព្រៃដុត ។

- ពួកចំណូលស្រុក ឬខ្មែរដូលជាតិ ជាប្រជាជនដែល មករស់នៅក្នុងប្រទេសកម្ពុជាយូរយារណាស់មក ហើយមានសិទ្ធិ និងកាតព្វកិច្ចដូចខ្មែរដែរ ។ ជនជាតិទាំងនេះមាន ចាម ជ្វា ឡាវ វៀតណាម និងភូមា... ។

## ២. តើខ្មែរមកពីណា ?

ជាយូរយារណាស់មកហើយ អ្នកធ្វើការសិក្សាស្រាវជ្រាវខ្មែរបានខិតខំដោះស្រាយនូវបញ្ហាកំណើតខ្មែរនេះ ។ ពួកគេបានបញ្ចេញយោបល់ប្លែកៗគ្នា ហើយជូនកាលផ្ទុយស្រឡះតែម្តង ។ ប៉ុន្តែ យោបល់ទាំងនោះអាចចែកជាពីរក្រុម គឺ :

### ក. យោបល់ទី១

ពួកគេទទួលថាជាតិខ្មែរ ជាជាតិប្រវេសន៍ (Race Immigrée) ចេញពីប្រទេសឥណ្ឌា ហើយបានលុកលុយដណ្តើមយកទឹកដីរបស់ជាតិដើមមួយ (Race Autochone) គឺជនជាតិក្នុងអំបូរម៉ាឡាយូប៉ូលីណេស៊ីយ៉ែន (Race Malayopolynésiene) នេះឯង ។ ទស្សនៈនេះត្រូវបានបង្កើតឡើងមុនគេដោយលោក Hendricke Kerne ។ បន្ទាប់មកទៀតក៏មានអ្នកស្រាវជ្រាវខ្លះយល់ស្របតាមដូចជាលោក Adhenard Leclére និងលោក Pierre Gourou ជាដើម ។ លោក Pirre Gourou បានបញ្ជាក់ថា ជនជាតិខ្មែរប្រហែលជាត្រូវពួក **ទ្រាវិឌ** ឬពួក **អារ្យ** ច្រានចេញពីឥណ្ឌាហើយដោយមានសេសសល់ក្រុមខ្លះ ដូចជាពួកមណ្ឌបានមកលុកលុយប្រទេសភូមា ប្រទេសសៀម និងប្រទេសកម្ពុជា ។ លោក Etieme Aymonier ដែលយល់ថាក្រុម **មន-ខ្មែរ** ។ មុណ្ឌមានតាំងពីដើមនៅជើងភ្នំទីបេ ហើយក្រោយមកបានបំបែកជាពីរក្រុម គឺ **មន-ខ្មែរ** ចូលមកតាំងនៅភូមិភាគអាស៊ីអាគ្នេយ៍ ឯមួយក្រុមទៀត គឺ **មុណ្ឌ** ចូលទៅនៅក្នុងប្រទេសឥណ្ឌារហូតដល់សព្វថ្ងៃ ។

### ខ. យោបល់ទី២

ទទួលស្គាល់ថា ជនជាតិខ្មែរជាជនជាតិមួយស្ថិតនៅក្នុងក្រុម **មន-ខ្មែរ** ហើយបានកើតឡើងនៅភូមិភាគអាស៊ីអាគ្នេយ៍នេះតាំងពីបុរាណមក ។ នេះគឺជាយោបល់របស់លោក Bernard Philiffe Groslier បណ្ឌិតប្បទ្ទជាអភិរក្សអង្គរ និងលោក Macel Talahot ជាដើម ។

លោកទាំងពីរនេះបានយល់ឃើញថា ក្នុងសម័យ **មុន** ប្រវត្តិសាស្ត្រដ៏យូរលង់មកហើយ មានមនុស្សជាច្រើនក្រុមបានធ្វើដំណើរពីខាងជើងចុះមកភាគអាស៊ីអាគ្នេយ៍ដូចពួក **អូស្ត្រាឡូអ៊ីដ** (Australoides) **មេឡាណេស៊ីយ៉ាង** (Mélanésiens) និង **ឥណ្ឌូណេស៊ីយ៉ាង** (Indonésiens) ។ អំបូរ **មន-ខ្មែរ** បានកើតឡើងដោយការកាត់ផ្សំរវាងពួកឥណ្ឌូណេស៊ីយ៉ាង និងមេឡាណេស៊ីយ៉ាង ហើយបានរស់នៅរាយប៉ាយលើទឹកដី ដែលលាតសន្ធឹងពីឥណ្ឌូចិនជ្រោយម៉ាឡាយូរហូតដល់ព្រំប្រទល់ប្រទេសឥណ្ឌា ។

www.budinst.gov.kh www.elibraryofcambodia.org

គួរកត់សំគាល់ថា យោបល់នៃក្រុមទាំងពីរនេះមានលក្ខណៈស្របទៅនឹងទស្សនៈរបស់ខ្មែរ ពីព្រោះបើយើងសំអាងទៅលើរឿងព្រេងខ្មែរ ដោយសារតែមាន **នាងនាគ** នៅស្រុកខ្មែរនេះឯងទើប **ព្រះថោង** ដែលគេថាមកពីស្រុកឥណ្ឌាបានជួបប្រភពគ្នា ហើយបានគ្រប់គ្រងស្រុក **គោកធ្លក** នេះឯង។ បានសេចក្តីថា លុះត្រាតែមានជនជាតិខ្មែរនៅលើកោះគោកធ្លកនេះដែរ ទើបឥណ្ឌាអាចផ្សាយអរិយធម៌របស់ខ្លួនបានខ្លះចូលក្នុងស្រុកខ្មែរ។

សេចក្តីក្នុងរឿងព្រេងនេះសរឱ្យយើងឃើញថា ចំពោះខ្មែរយើង ជាតិខ្មែរមានប្រភពនៅក្នុងស្រុកខ្មែរនេះឯង។ ចំពោះបញ្ហាដើមកំនើតនៃជាតិសាសន៍ខ្មែរនេះ អ្នកប្រាជ្ញអន្តរជាតិបានបញ្ចេញសម្មតិកម្មច្រើនបែបយ៉ាងណាស់។ តែលោកបានស្របយោបល់គ្នាត្រង់ចំនុចដែលថា ខ្មែរជាជនជាតិមួយស្ថិតនៅក្នុងអំបូរពិសេសមួយ គឺអំបូរ **មន-ខ្មែរ ឬ ខម** នេះឯង ([15])។

ថ្មីៗនេះ លោកបណ្ឌិត **ម.ត្រាណេរ** លោកជាអ្នកស្រាវជ្រាវវប្បធម៌ខ្មែរ ស្នាដៃរបស់លោកសមស្របជាមួយមតិទី២ គឺលោកបានបញ្ជាក់ថា ខ្មែរមានជីវិតនៅលើទឹកដីខ្មែរតាំងពី ៦៨០.០០០ឆ្នាំមុនគ.ស មកដល់ស.វទី១ នៃគ.ស។ សម័យនេះ ជាសម័យថ្មគ្រួសបំបែក ដែលមានអាយុ ៦៨០.០០០ ឆ្នាំដល់ ១២០.០០០ឆ្នាំមុនគ.ស។ យុគនេះអាចជាការចាប់ផ្តើមនៃអារ្យធម៌ខ្មែរ ហើយការចងក្រងទំព័រ ប្រវត្តិសាស្ត្រកម្ពុជា ត្រូវស្ថិតនៅលើសំភារៈវប្បធម៌កម្ពុជាដំបូងបង្អស់ជាមូលដ្ឋាន ([16])។

វប្បធម៌ អរិយធម៌ខ្មែរ ដូចបានបញ្ជាក់ជូនខាងលើក៏អាចបង្ហាញឱ្យអ្នកសិក្សាស្រាវជ្រាវអាចវិភាគបានពីប្រភពព្រះពុទ្ធសាសនានៅកម្ពុជាដែរ។

## ៣. ប្រភព និងកាលបរិច្ឆេទព្រះពុទ្ធសាសនានៅប្រទេសកម្ពុជា

ដូចយើងបានបញ្ជាក់ខាងលើមកហើយថា ព្រះពុទ្ធសាសនាមានដើមកំនើតនៅប្រទេសឥណ្ឌា ហើយត្រូវផ្សព្វផ្សាយនៅលើបណ្តាប្រទេសនានានៅលើពិភពលោក ជាពិសេសនៅលើបណ្តាប្រទេសមួយចំនួននៃភូមិភាគអាស៊ីអាគ្នេយ៍យើងនេះ។

ប្រទេសកម្ពុជាយើង ព្រះពុទ្ធសាសនាបានចូលមកដល់តាំងពីយូរអង្វែងណាស់មកហើយ ហើយមានការរីកចំរើនយ៉ាងខ្លាំងក្លា ព្រមទាំងជះឥទ្ធិពលយ៉ាងជ្រាលជ្រៅទៅក្នុងក្រអៅបេះដូងនៃចិត្តគំនិត ទំនៀមទំលាប់ ប្រពៃណី សិល្បៈ វប្បធម៌នៃមនុស្សខ្មែរយើង។

ចំពោះការបរិច្ឆេទនៃការចូលមកដល់ ឬវត្តមាននៃព្រះពុទ្ធសាសនាកម្ពុជា ជាបញ្ហាមួយដែលអ្នកសិក្សាប្រវត្តិសាស្ត្រក៏ដូចជាអ្នកសិក្សាអក្សរសាស្ត្រ និងវប្បធម៌ទូទៅតែងតែចោទសួរថា ៖ តើព្រះពុទ្ធសាសនាបានចូលមកដល់ប្រទេសកម្ពុជាតាំងពីពេលណា ?

---

[15] លោកស្រី ត្រឹង ងា **អរិយធម៌ខ្មែរ** ភ្នំពេញ ទំព័រ៧

[16] លោក ម. ត្រាណេរ **មុនប្រវត្តិសាស្ត្រ** ភ្នំពេញ ១៩៨៧

www.budinst.gov.kh www.elibraryofcambodia.org

បញ្ហាបរិច្ឆេទនៃការចូលមកដល់នៃលទ្ធិព្រះពុទ្ធសាសនានេះយើងគួរសិក្សាឱ្យបានច្បាស់លាស់ ព្រោះបញ្ហានេះវាបានឆ្លុះបញ្ចាំងទៅលើការរីកចំរើនរបៀបរបបរស់នៅ និងទិន្នាការរបស់សង្គមខ្មែរយើងនៅគ្រប់ដំណាក់កាលប្រវត្តិសាស្ត្ររបស់ខ្លួនរយៈកាលកន្លងមក។

បញ្ហានេះ អ្នកសិក្សាជាច្រើនបានស្រាវជ្រាវឃើញកាលបរិច្ឆេទខុសៗគ្នា :

- មានអ្នកសិក្សាខ្លះបកស្រាយថា ព្រះពុទ្ធសាសនាបានចូលមកដល់ប្រទេសកម្ពុជាយើងតាំងពីស.វទី៣ ឬទី២ មុនគ.ស ដោយសំអាងទៅលើប្រវត្តិសាស្ត្រនៃព្រះបាទ **ធម្មាសោក** នៃប្រទេសឥណ្ឌាដែលព្រះអង្គជាមហាពុទ្ធសាសនិកជនមួយរូបគោរពព្រះពុទ្ធសាសនា **ថេរវាទ** បានបញ្ជូនសមណទូតពីរអង្គ **សោណត្ថេរ** និង **ឧត្តរត្ថេរ** មកផ្សព្វផ្សាយព្រះពុទ្ធសាសនានៅលើដែនដីសុវណ្ណភូមិ។

បញ្ជាក់ដោយ សម្តេចមហាសុមេធាធិបតី **ហួត តាត** វជិរប្បញ្ញោ ព្រះអង្គនាយកគណៈមហានិកាយ ព្រះអង្គ ទ្រង់បានសរសេរក្នុងស្នាព្រះហស្ថរបស់ព្រះអង្គ "**ព្រះពុទ្ធសាសនានៅកម្ពុជាសង្ខេប**" បោះពុម្ពលើកទី២ នៅគ.ស ១៩៧០ ទំព័រទី១ ថា "ព្រះពុទ្ធសាសនាផ្សាយចូលមកប្រទេសកម្ពុជាមុនដំបូងតាមគម្ពីរពុទ្ធសាសនា សមន្តបាសាទិកាអដ្ឋកថាវិន័យបិដក ជាភាសាបាលីបានប្រាប់ពត៌មានថា កាលក្រោយពេលដែលធ្វើតតិយសង្គាយនារួចហើយ នៅក្នុង **ជម្ពូទ្វីប** គឺប្រទេសឥណ្ឌាក្នុងព.សទី៣ ព្រះមហាថេរមួយអង្គព្រះនាមព្រះមហា មោគ្គលិបុត្តតិស្សៈបានចាត់ចែងបញ្ជូនព្រះថេរពីរអង្គ គឺព្រះសោណត្ថេរ និងព្រះឧត្តរត្ថេរឱ្យចេញពីជម្ពូទ្វីប (ឥណ្ឌា) មកផ្សាយព្រះពុទ្ធសាសនានៅសុវណ្ណភូមិ ក្នុងព្រះបរមរាជូបត្ថម្ភនៃព្រះមហាក្សត្រនាម ធម្មាសោក "។

- អ្នកសិក្សាខ្លះទៀតបានរកឃើញ ព្រះពុទ្ធសាសនាបានចូលមកដល់ប្រទេសខ្មែរយើងនៅស.វទី២ នៃគ.ស ទៅវិញ។ បញ្ហានេះអ្នកស្រី**ត្រឹង ងា** បានសរសេរនៅក្នុងស្នាដៃអរិយធម៌ខ្មែរ បោះពុម្ពនៅឆ្នាំ ១៩៧៣ ទំព័រ៨០ ថា "តាមសិលាចារឹកវ៉ូ **កាញ់** (នៅវៀតណាមខាងត្បូង) ទំនងជាព្រះពុទ្ធសាសនាចូលមកប្រតិស្ឋានក្នុងស្រុកខ្មែរនៅស.វទី២ នៃគ.សក្នុងរជ្ជកាលព្រះបាទ **ស្រីមារៈ** ឬ **ហ្វាន់ចេម៉ាន់** ។ ទស្សនៈបែបនេះគេបានពន្យល់ថា ព្រះពុទ្ធសាសនាមានកំណើតក្រោយព្រហ្មញ្ញសាសនា ប្រហែលនឹងអាចចូលមកដល់ប្រទេសកម្ពុជាក្រោយការចូលមកដល់នៃលទ្ធិសាសនាព្រាហ្មណ៍ ពោលគឺក្រោយស.វទី១ នៃគ.ស ដែលជាកាលកំណត់នៃការចូលមកដល់លទ្ធិព្រាហ្មណ៍សាសនា។

- មានអ្នកខ្លះឱ្យយោបល់ថា ព្រះពុទ្ធសាសនា និងព្រហ្មញ្ញសាសនាបានចូលមកដល់ប្រទេសកម្ពុជាយើងក្នុងដំណាក់កាលប្រហាក់ប្រហែលគ្នា ឬមុនក្រោយបន្តិចបន្តួចប៉ុណ្ណោះ។ គេបានពន្យល់ថា បញ្ហានេះគ្មានឯកសារណាមួយបញ្ជាក់ឱ្យបានច្បាស់លាស់ទេ ព្រោះគេហាក់ដូចជាពុំទាន់មានជំនឿ ចំពោះទស្សនៈរបស់អ្នកសិក្សាឯទៀតដែលយល់ថា សាសនានេះ ឬសាសនានោះមកដល់មុន។

យោបល់ស្តីពីវត្តមាននៃការចូលមកដល់នៃលទ្ធិព្រះពុទ្ធសាសនាមានច្រើនដូចខាងលើ ដែលយើងពិបាកនឹងកំនត់ឱ្យបានច្បាស់លាស់ពេក។ ប៉ុន្តែ ពិនិត្យជារួមទោះបីយ៉ាងណាក៏ដោយ ក៏មតិយោបល់ទាំងអស់នោះ ជាពន្លឺនៃ

www.budinst.gov.kh www.elibraryofcambodia.org

ការសិក្សារបស់យើង។ យើងពិនិត្យឃើញថា យោបល់ទាំងអស់ហាក់ដូចជាមានការឯកភាពគ្នាមួយនៅត្រង់ព្រះពុទ្ធសាសនាក៏ដូចជាព្រហ្មញ្ញសាសនា បានចូលមកដល់ប្រទេសកម្ពុជាយើងតាំងពីយូរយារណាស់មកហើយ។

ផ្អែកលើទស្សនៈឯកសារខាងលើ យើងជាអ្នកសិក្សាស្រាវជ្រាវ គួរតែត្រិះរិះពិចារណារកហេតុផលឱ្យមានលក្ខណៈច្បាស់លាស់ និងសមស្របដើម្បីកំណត់ពីបញ្ហានេះ។ យើងគួរលើកយកពីប្រវត្តិសាស្ត្រនៃព្រះបាទធម្មាសោក ដែលឱ្យពត៌មានថា "ព្រះពុទ្ធសាសនាបានផ្សព្វផ្សាយចូលមកដែនដីសុវណ្ណភូមិនៅស.វទី៣ ឬទី២មុនគ.ស" យកមកត្រិះរិះពិចារណា ដើម្បីកំណត់កាលបរិច្ឆេទនៃការចូលមកដល់របស់លទ្ធិព្រះពុទ្ធសាសនា នៅកម្ពុជាយើង។ បញ្ហាចោទនោះគឺដែនដីសុវណ្ណភូមិជាដែនដីរបស់ប្រទេសណា ? ជាប្រទេសខ្មែរយើង ឬជាប្រទេសណាទៀត ?

ដែនដីសុវណ្ណភូមិនេះ ត្រូវបានគេយល់ឃើញដោយឡែកៗ ហើយម្នាក់ៗសុទ្ធតែអះអាងថា ដែនដីសុវណ្ណភូមិជាដែនដីរបស់ខ្លួនម្នាក់ៗ។ ឧទាហរណ៍ដូចជា ខ្លះថាដែនដីនេះជាដែនដីរបស់ភូមា ខ្លះថាជាដែនដីឥណ្ឌូនេស៊ី ខ្លះថាម៉ាឡេស៊ី ខ្លះថាកម្ពុជា ខ្លះថាថៃ ខ្លះថាចាម ខ្លះថាវៀតណាម... ។ល។

យោបល់ដោយឡែកៗខាងលើរបស់ជនជាតិនីមួយៗ សុទ្ធតែមានអំណះអំណាង ព្រមទាំងប្រកាន់យកនូវមហិច្ឆតាជាតិរបស់ខ្លួនជានិច្ច។ មកដល់ត្រឹមនេះ យើងជាជនជាតិខ្មែរ ក៏ពុំទាន់ហ៊ានអះអាងថាដែនដីសុវណ្ណភូមិ ជាដែនដីរបស់យើងឡើយ។ តែយើងត្រូវចោទសួរបន្តទៀត តើបណ្ដាប្រទេសនៅអាស៊ីអាគ្នេយ៍នេះ ប្រទេសណាដែលបានទទួល និងគោរពព្រះពុទ្ធសាសនាមានចំណាស់ជាងគេ ? បើយើងពិនិត្យទៅលើប្រវត្តិសាស្ត្រ និងពិនិត្យលើការជាក់ស្ដែងឃើញថា នៅអាស៊ីអាគ្នេយ៍នេះប្រទេសដែលគោរពព្រះពុទ្ធសាសនាមានចំណាស់ជាងគេ គឺមានតែប្រទេសកម្ពុជាយើងនេះឯង។ ចំពោះបណ្ដាប្រទេសដទៃទៀតឃើញថា មានប្រទេសមួយចំនួនគេគោរពព្រះពុទ្ធសាសនាដូចយើងដែរ តែគេគោរពនោះស្ថិតនៅក្នុងដំណាក់កាលក្រោយយើង។ ឧទាហរណ៍ ដូចជាករណី ប្រទេសថៃ ចាប់ពីស.វទី១រហូតមកដល់ដើមស.វទី៩ ក្នុងពេលដែលប្រទេសយើងបានកសាងជាប្រទេសមានអធិបតេយ្យភាព និងមានវប្បធម៌រឹងមាំរួចទៅហើយនោះ ប្រទេសនេះកំពុងស្ថិតនៅជាកុលសម្ព័ន្ធ ឬជាជនជាតិភាគតិច ឬជាជនជាតិបញ្ចើក្អែកគ្មានឯកភាពនៅក្នុងខេត្តយូណាន នៃប្រទេសចិន ពោលគឺមិនទាន់កើតជារដ្ឋនៅឡើយទេ។ លុះត្រាមកដល់ស.វទី៩ទើបជនជាតិនេះបានជ្រៀតចូលមកក្នុងឥណ្ឌូចិនតាមខ្សែទឹកទន្លេមេគង្គ ធ្វើដំណើរពីជើងចុះមករកទិសខាងត្បូង ដោយដណ្ដើមទឹកដីពីជនជាតិខ្មែរយើងខ្លះ ពីជនជាតិមនខ្លះ... រួចកសាងជារដ្ឋឯករាជ្យរបស់ខ្លួនមួយនៅស.វទី១៣។

ដូចនេះ ជនជាតិថៃពុំបានទទួលព្រះពុទ្ធសាសនា ដោយផ្ទាល់ពីជនជាតិឥណ្ឌាដូចជនជាតិខ្មែរយើងទេ។ ព្រះពុទ្ធសាសនានៅក្នុងប្រទេសថៃនាពេលសព្វថ្ងៃនេះ ត្រូវបាននាំបញ្ចូលពីប្រទេសកម្ពុជា ឬជាសាសនាដែលបានចាក់ឫសនៅលើទឹកដីនោះតាំងពីយូរ ពោលគឺតាំងពីទឹកដីនោះជាទឹកដីរបស់ខ្មែរមុនការចូលមកដល់នៃជនជាតិថៃម្ល៉េះ។

www.budinst.gov.kh www.elibraryofcambodia.org

ចំពោះជនជាតិវៀតណាម ក្នុងតំណាក់កាលពីស.វទី១ ដល់ស.វទី៩ ពុំទាន់រំដោះខ្លួនចេញពីអាណានិគមចិន នៅឡើយដែរ។ លុះមកដល់ស.វទី១០ ទើបជនជាតិនេះបានរំដោះខ្លួនចេញពីអាណានិគមចិនរួចកសាងប្រទេសរបស់ខ្លួន។ ព្រះពុទ្ធសាសនា **មហាយាន** ដែលជនជាតិវៀតណាមគោរពនាពេលសព្វថ្ងៃនេះ ជាសាសនាដែលហូរចូលមកពីប្រទេសចិន តាំងពីនៅក្រោមអាណានិគមចិនម្ល៉េះ។

ចំណែកប្រទេសដទៃទៀត ដែលនៅក្នុងតំបន់នេះ មានប្រទេសខ្លះគោរពព្រះពុទ្ធសាសនាដែរ តែក្នុងដំណាក់កាលក្រោយ ឬគេពុំគោរពពុទ្ធសាសនាតែម្តង ដោយគោរពសាសនាដទៃទៀត។

បើសរុបមកឃើញថា ប្រទេសកម្ពុជាយើងជាប្រទេសមួយមានអធិបតេយ្យភាពចំណាស់ជាងគេ ហើយទទួល និងគោរពព្រះពុទ្ធសាសនាមុតមាំជាងគេ ដែលសក្តិសមជាដែនដីសុវណ្ណភូមិដែលទទួលការផ្សព្វផ្សាយព្រះពុទ្ធសាសនា ដោយផ្ទាល់ពីសំណាក់សមណទូតពីរអង្គព្រះនាម **សោណត្ថេរ** និង **ឧត្តរត្ថេរ** ក្រោមព្រះរាជូបត្ថម្ភនៃព្រះបាទ **ធម្មាសោករាជ** ស.វទី៣ ឬទី២មុនគ.សនេះណាស់។

## ៤. ការវិវត្តនៃលទ្ធិព្រះពុទ្ធសាសនានៅកម្ពុជា

រួចមកហើយយើងឃើញថា ព្រះពុទ្ធសាសនាបានចូលមកដល់ប្រទេសកម្ពុជាយើងតាំងពីស.វទី៣ មុនគ.សម្ល៉េះ សាសនានេះបានចាក់ឫស ព្រមទាំងមានការវិវត្តរបស់ខ្លួនតាំងពីពេលនោះរហូតមក ហើយមកដល់សព្វថ្ងៃនេះនៅតែមានអត្ថិភាព និងមានការរីកចំរើនរបស់ខ្លួនយ៉ាងរឹងមាំ([១៧])។

ការសិក្សាពីការវិវត្តនៃលទ្ធិព្រះពុទ្ធសាសនានៅកម្ពុជា បានធ្វើឱ្យយើងកាន់តែយល់ច្បាស់ពីលទ្ធិនេះនៅក្នុងដំណាក់កាលប្រវត្តិសាស្ត្រនីមួយៗ ព្រមទាំងបានស្គាល់ពីឥទ្ធិពលរបស់សាសនានេះ ទៅលើបណ្តាវិស័យផ្សេងៗនៃសង្គមខ្មែរយើង។ ប៉ុន្តែ ទន្ទឹមនឹងការសិក្សាពីការវិវត្តនៃលទ្ធិសាសនានេះចាំបាច់ក៏យើងត្រូវតែសិក្សាពីការវិវត្តខ្លះៗនៃលទ្ធិព្រហ្មញ្ញសាសនាផងដែរ ព្រោះថាសាសនាទាំងពីរនេះ សុទ្ធតែមានវត្តមាន មានអត្ថិភាព និងការរីកចំរើនស្របៗគ្នា ឬអន់ថយជាងគ្នានៅលាយឡំគ្នាក្នុងសង្គមខ្មែរយើង ពោលគឺពេលខ្លះ ព្រះពុទ្ធសាសនារីកចំរើនជាងពេលខ្លះព្រហ្មញ្ញសាសនារីកចំរើនជាងឬផ្ទុយទៅវិញ។ តែពេលខ្លះ ក៏គេសង្កេតឃើញសាសនាទាំងពីរនេះរលាយចូលគ្នា ឬពេលខ្លះមានទំនាស់នឹងគ្នាយ៉ាងខ្លាំងក្លាក៏មាន។

ខាងក្រោមនេះ យើងសូមលើកយកការវិវត្តនៃលទ្ធិព្រះពុទ្ធសាសនាមកធ្វើការសិក្សា តាមដំណាក់កាលនីមួយៗ ដូចតទៅ :

### ក. សម័យបុរេប្រវត្តិសាស្ត្រ

នៅសម័យបុរេប្រវត្តិសាស្ត្រ មុនស.វទី១ នៃគ.ស ព្រះពុទ្ធសាសនាបានចូលមកដល់ប្រទេសកម្ពុជាយើងហើយ តែការវិវត្ត និងការរីកចំរើនយ៉ាងណានោះយើងពុំអាចដឹងបានច្បាស់លាស់ទេ ព្រោះយើងពុំអាចរកឃើញ

---

[១៧] លោកបណ្ឌិត ឆ សោ **ព្រះពុទ្ធសាសនា និងសង្គមខ្មែរ** ភ្នំពេញ១៩៩៤ ទំព័រ ៩២

www.budinst.gov.kh www.elibraryofcambodia.org

ឯកសារ ឬការកំណត់ណាដែលយើងអាចវាយតំលៃ ឬធ្វើការសន្និដ្ឋានបានឡើយ។ តែទោះយ៉ាងណាក៏យើងអាចយល់ថា ព្រះពុទ្ធសាសនាក្រោយការចូលមកដល់ក្នុងសម័យបុរេប្រវត្តិសាស្ត្រនេះ ជាពន្លកត្រួយទ្រទ្រង់ការវិវត្ត នៃសម័យក្រោយៗមកទៀត។

នៅក្នុងសម័យបុរេប្រវត្តសាស្ត្រ មុនស.វទី១នេះ ជនជាតិខ្មែរយើងគោរពព្រះពុទ្ធសាសនាថេរវាទ (ហីនយាន) បែបហីនយានបុរាណតាមបែបព្រះត្រៃបិដក។

**ខ. សម័យនគរភ្នំ**

ពីស.វទី១រហូតដល់ពាក់កណ្ដាលស.វទី៦ ការវិវត្តនៃលទ្ធិព្រះពុទ្ធសាសនានៅសម័យនេះ យើងបានពឹងផ្អែកទៅលើសិលាចារឹកពុទ្ធបដិមាករ និងឯកសារចិនដែលគេបានមកតាមរយៈកំណត់ហេតុ កត់ត្រារបស់ជនជាតិចិនឈ្មោះ **កាំង** **ថៃ** និង **ជូ** **យីង** ដែលគេបានមកទស្សនប្រទេសកម្ពុជាយើង នៅសម័យនគរភ្នំនេះក្នុងពាក់កណ្ដាលស.វទី៣ នៃគ.ស។

ផ្អែកលើកាកសំណល់ និងរូបបដិមាករដែលគេបានរកឃើញនៅ **កំពង់ផែអូរកែវ** ដែលជាកំពង់ផែដ៏ល្បីល្បាញមួយរបស់ខ្មែរនៅសមុទ្រនៃប្រទេសនគរភ្នំត្រង់ឈូងសមុទ្រថៃសព្វថ្ងៃ។ កំពង់ផែអូរកែវនេះជាកំពង់ផែអន្តរជាតិរបស់ខ្មែរ ដែលមានលក្ខណៈងាយស្រួលក្នុងការស្រូបយកអ្នកដំណើរសមុទ្រពីបណ្ដាប្រទេសជិតឆ្ងាយនៅលើសកលលោក ដែលមានទំនាក់ទំនងពាណិជ្ជកម្មជាមួយបណ្ដាប្រទេសនៅអាស៊ីអាគ្នេយ៍ ជាមួយកំពង់ផែនៅប្រទេស **ឥណ្ឌា** ប្រទេស **អ៊ីរ៉ង់** និងបណ្ដាកំពង់ផែនៅតាមសមុទ្រ **មេឌីទែរ៉ាណេ** ។ ដោយសារភាពងាយស្រួលរបស់កំពង់ផែនេះ ជនជាតិខ្មែរយើងបានទំនាក់ទំនងជាមួយជនជាតិផ្សេងៗ ហើយបានទទួលវប្បធម៌របស់បណ្ដាប្រទេសផ្សេងៗទាំងនោះ។ ដោយសារមូលហេតុនេះ ទើបប្រទេសកម្ពុជាយើងត្រូវបានគេហៅថាគឺជា **ចំណុចប្រជុំនៃសិល្បៈ** (Le Cambodge est le carrefour des Arts)។

វត្ថុតាងដែលគេបានឃើញនៅកំពង់ផែអូរកែវនេះ មានកាកសំណល់ផ្សេងៗ ដូចជាព្រះពុទ្ធរូប រូបិយវត្ថុជាតិរ៉ូម៉ាំង ជាតិឥណ្ឌា និងតួអក្សរព្រាហ្មី។ ផ្អែកលើសិលាចារឹកនៅ**ទុំកាញ់** (ញ៉ាត្រាង) ក្នុងប្រទេសវៀតណាមសព្វថ្ងៃ យើងសង្កេតឃើញថាព្រះពុទ្ធសាសនាបានរីកចំរើនយ៉ាងខ្លាំងក្នុងរាជ្យព្រះបាទ**ហ្វាន់ ម៉ាន** គឺព្រះបាទ **ស្រីមារៈ** នាស.វទី២នៃគ.ស។ តាមអត្ថន័យនៃសិលាចារឹកនេះបញ្ជាក់ថាព្រះរាជាប្រទេសនគរភ្នំក្នុងគ.សទី២ ព្រះនាមស្រីមារៈជាព្រះអគ្គពុទ្ធសាសនូបត្ថម្ភដ៏មហិមាមួយអង្គ។ ព្រះអង្គត្រាស់បង្គាប់ឱ្យចារឹកទុកដើម្បីជាអនុស្សាវរីយ៍។ រាជត្រកូលគឺបរមវង្សជ្រះថ្លាចំពោះព្រះពុទ្ធសាសនាយល់ច្បាស់នូវគោគតិ ដំណើរអន្ទោលស្លាប់នៃសត្វលោកក្នុងវដ្តសង្សារ ទ្រង់ប្រកបដោយមេត្តាករុណាចំពោះសព្វសត្វ ហើយត្រាស់បង្គាប់ឱ្យបរិច្ចាកព្រះរាជទ្រព្យផ្ទាល់ព្រះអង្គធ្វើទានទុកជាសារណប្រយោជន៍។ ទីបំផុតទ្រង់ផ្ដាំទុកថា សូមព្រះរាជាសោយរាជ្យតំណទៅមុខទៀតឱ្យប្រតិបត្តិតាមព្រះរាជប្រកាសនេះ ដើម្បីប្រយោជន៍ធំដល់សត្វលោក។

www.budinst.gov.kh www.elibraryofcambodia.org

តាមឯកសារចិននៃព្រះរាជវង្ស **ឡឺ** (Tsi) បានដំណាលថា ក្នុងគ.សទី១១ នៃគ.សទី៥ មានព្រះរាជានគរភ្នំមួយព្រះអង្គព្រះនាម **កៅ ចេនជុ ឬ ចុ យេធាម៉ុ** (ហៅតាមភាសាចិន) គឺព្រះបាទ **កៅណ្ឌិន្យជ័យវរ្ម័ន** ឬ **កោណ្ឌញ្ញជ័យវរ្ម័ន** ។ កាលដើមឡើយព្រះរាជអង្គនេះគោរពសាសនាព្រាហ្មណ៍ តែក្រោយមកព្រះអង្គទ្រង់គោរពព្រះពុទ្ធសាសនាវិញ។ ព្រះអង្គទ្រង់បានបញ្ជូនភិក្ខុ**សាក្យ នាគសេន** ជាតំណាងឱ្យទៅកាន់ក្រុងចិន ប្រមាណគ.ស ៤៨៤ ដោយមានទាំងដង្វាយទៅថ្វាយស្តេចក្រុងចិនព្រះនាម **ខុ នីជង់** ។ ព្រះសង្ឃអង្គនេះបានថ្វាយពត៌មានដល់ព្រះចៅក្រុងចិនពីស្ថានភាពប្រទេសនគរភ្នំ និងពីសាសនាដែលមានការរីកចំរើននៅក្នុងនគរភ្នំ។ ប្រជាពលរដ្ឋ ខ្មែរគោរពព្រះពុទ្ធសាសនាផង និងព្រហ្មញ្ញសាសនាផង តែព្រះពុទ្ធសាសនារីកចំរើនរុងរឿងណាស់ ដោយមានភិក្ខុសាមណេរយ៉ាងច្រើនក្រៃលែង ហើយការប្រតិបត្តិតាមពុទ្ធវចនៈក៏រឹងតឹង តែប្រពៃណាស់ទៀត។ ពេលព្រះភិក្ខុសាក្យ នាគសេនត្រឡប់មកវិញ ព្រះចៅក្រុងចិនបានសុំផ្ញើដង្វាយជាច្រើនមកថ្វាយព្រះចៅនគរភ្នំវិញ។

លោក **ត្រឹង ងា** ជាសាស្ត្រាចារ្យប្រវត្តិសាស្ត្រខ្មែរម្នាក់ដ៏ជំនាញ បានបញ្ជាក់ឱ្យដឹងថា នៅសម័យនគរភ្នំនេះព្រះពុទ្ធសាសនាមានភាពរុងរឿង ជាពិសេសនៅស.វទី៥-៦ ក្នុងរជ្ជកាលព្រះបាទ **កៅណ្ឌិន្យជ័យវរ្ម័ន** និង **រុទ្រវរ្ម័ន**។ នៅគ.ស៥០៣ព្រះបាទកៅណ្ឌិន្យជ័យវរ្ម័នដែល ទ្រង់បានបញ្ជូនរាជទូតឱ្យយក**ព្រះពុទ្ធរូបធ្វើពីផ្កាថ្មសមុទ្រ** និងវត្ថុផ្សេងៗជាច្រើនទៀត ទៅថ្វាយស្តេចក្រុងចិន ព្រមទាំងបានបញ្ជូនភិក្ខុខ្មែរពីរអង្គទៀត គឺភិក្ខុ**សង្ឃបាល** មួយអង្គ និងភិក្ខុ **មន្ទ្រសេន** មួយអង្គ ដែលជាអ្នកប្រាជ្ញចេះព្រះត្រៃបិដក និងចេះបកប្រែភាសាបរទេសច្រើនភាសាឱ្យទៅប្រែព្រះត្រៃបិដក តាមការនិមន្តឱ្យទៅជួលប្រែរបស់ព្រះចៅក្រុងចិនព្រះនាម **វូ** នៃព្រះរាជវង្ស**លាង**។ ភិក្ខុទាំងពីរអង្គនេះបានជួយទៅប្រែភាសាអស់១៦ឆ្នាំ ហើយបានធ្វើការនៅវិការិយាល័យ ។

ក្នុងគ.ស៥១៤ មានព្រះមហាក្សត្រព្រះនាមរុទ្រវរ្ម័ន ទ្រង់ជ្រះថ្លាក្នុងព្រះពុទ្ធសាសនា បានប្រតិបត្តិតាមពុទ្ធោវាទយ៉ាងហ្មត់ចត់។ ក្នុងរជ្ជកាលនៃព្រះមហាក្សត្រអង្គនេះ ប្រទេសកម្ពុជាមានព្រះកេសធាតុ១អង្គជាទីគោរពសក្ការបូជា ជាមង្គលប្រទេស តែព្រះកេសធាតុនោះតមកបានទៅតំកល់ឯប្រទេសចិន ([១៨])។ ព្រះចៅក្រុងចិនមានការស្ងើចសរសើរយ៉ាងខ្លាំង ព្រមទាំងបានចាត់ទុកថាជាព្រះគ្រូទៀតផង ។

សេចក្តីប្រែរបស់ព្រះថេរៈទាំងពីរព្រះអង្គនេះ មានសេសសល់រហូតមកដល់សព្វថ្ងៃនៃព្រះត្រៃបិដកចិន។ ក្នុងពេលដែលសម្តេចព្រះបាទ **នរោត្តម សីហនុ** ទ្រង់ស្តេចយាងទៅប្រទេសចិនឆ្នាំ ១៩៥៦ សមាគមពុទ្ធសាសនាចិនបានយកគម្ពីរនោះទៅថ្វាយព្រះអង្គទតមើល ដើម្បីបញ្ជាក់ថា មិត្តភាពរាប់អានគ្នារវាងខ្មែរ និងចិនមានអាយុ តាំងពីជាង១៥ស.វមកហើយ ។

ឆ្នាំ១៩៦៦ សម្តេចសង្ឃរាជ **ហួត តាត** បាននិមន្តទៅចូលរួមសន្និបាតនៅទីក្រុង**កូឡុំបូ** ព្រះអង្គបានទទួលសៀវភៅដែលព្រះសង្ឃខ្មែរពីរអង្គបានបកប្រែនៅប្រទេសចិននោះដែរ ([១៩]) ។

---

[១៨] លោក ស៊ន សំណាង ( បណ្ឌិតប្រវត្តិវិទ្យា ) **ប្រវត្តិសាស្ត្រព្រះពុទ្ធសាសនានៅកម្ពុជា** ភ្នំពេញ ១៩៨៨ ទំព័រ ៦៦

[១៩] លោកបណ្ឌិត ធ ឈា **ព្រះពុទ្ធសាសនា និងសង្គមខ្មែរ** ភ្នំពេញ ១៩៩៤ ទំព័រ ៩៧

www.budinst.gov.kh www.elibraryofcambodia.org

សរុបមកយើងឃើញថា នៅសម័យនគរភ្នំ ព្រះពុទ្ធសាសនាមានការវិវត្ត និងមានការរីកចំរើនយ៉ាងច្បាស់លាស់។ តែព្រះពុទ្ធសាសនានៅក្នុងសម័យនោះ គឺព្រះពុទ្ធសាសនាហីនយាន និយមភាសាសំស្ក្រឹតដែលនាំចូលមកតាំងពីស.វទី៣ ឬទី២មុនគ.ស ដោយព្រះភិក្ខុ **សោណត្ថេរ** និង **ឧត្តរត្ថេរ**។ រហូតមកដល់ពាក់កណ្តាលស.វទី៦ នៃការវាយលុករបស់ **ចេនឡា** មកលើអាណាចក្រនគរភ្នំ ព្រះពុទ្ធសាសនាហីនយាននេះនៅរុងរឿងនៅឡើយ។ លុះមកដល់ចុងស.វទី៧ នៃសម័យចេនឡាទើបចុះអានុភាពបន្តិចម្តង១។

នៅក្នុងសម័យនគរភ្នំនេះ យើងសង្កេតឃើញមានសាសនាមួយទៀតមានវត្តមាន និងមានការរីកចំរើនផងដែរដោយពុំគិតពីជំនឿ និងការនិយមនៃវប្បធម៌ដើមរបស់ជនជាតិខ្មែរយើងទេ។ នោះគឺលទ្ធិសាសនាព្រាហ្មណ៍ **កៅណ្ឌិន្យ** ( ហ៊ុន ទៀន)។ សាសនាព្រាហ្មណ៍នេះ ត្រូវបានគេគោរពបូជាចំពោះ**ព្រះឥសូរ** **ព្រះវិស្ណុ** **ព្រះហរិហរៈ** និង**ព្រះព្រហ្ម**។ តែនៅខាងដើមសម័យនគរភ្នំគណៈឥសូរនិយមទំនងជាមានឋានៈជាសាសនាផ្លូវការផង ដោយយោលទៅលើឯកសារចិនដែលបញ្ជាក់ថា ព្រះរាជាតែងយាងឡើងលើភ្នំ **ម៉ូតាន់** ដើម្បីបូជាចំពោះ**ព្រះមហេស្វរៈ** (ព្រះឥសូរ)។ ប៉ុន្តែក្រោយមក មានអធិរាជខ្លះ មានព្រះបាទកៅណ្ឌិន្យជ័យវរ្ម័នជាដើម ដែលដើមឡើយព្រះអង្គគោរពព្រះឥសូរ រួចផ្លាស់មកកាន់ព្រះពុទ្ធសាសនាវិញ។ ចំពោះព្រហ្មញ្ញសាសនានិកាយព្រះវិស្ណុក៏ត្រូវបានគោរពផងដែរ។ ភស្តុតាងដូចជាយើងឃើញមានបដិមាវិស្ណុ និងអវតាររបស់ព្រះវិស្ណុជាច្រើននៅតំបន់**ឱដ្ឋ** អង្គបុរី ខេត្តតាកែវជាដើម។ តែទន្ទឹមនឹងនោះ ក៏គេសង្កេតឃើញមានពុទ្ធរូប និងទេវរូបជាច្រើននៅតំបន់ភ្នំដានោះដែរ។ នេះបញ្ជាក់ថានៅសម័យនគរភ្នំមានសាសនាច្រើន ដែលត្រូវប្រជាពលរដ្ឋខ្មែរយើងគោរពបូជា គ្រាន់តែព្រះពុទ្ធសាសនារីកចំរើនជាងប៉ុណ្ណោះ។

### គ. សម័យចេនឡា

សម័យនេះកើតនៅពាក់កណ្តាលស.វទី៦ដល់ចុងស.វទី៨ ([២០])។ ចេនឡាជាឈ្មោះ សាមន្តរដ្ឋមួយរបស់ចក្រភពនគរភ្នំ ហើយដណ្តើមបានជ័យជំនះ។ ការបះបោរនេះ បានប្រតិបត្តិទៅក្រោមការដឹកនាំរបស់ក្សត្រព្រះនាម **ភវវរ្ម័ន** ជាបុត្ររបស់ **វីរវរ្ម័ន**និងជាចៅរបស់ព្រះបាទ **រុទ្រវរ្ម័ន**។ ក្រោយពេលដែលបានទទួលជ័យជំនះប្រទេសខ្មែរយើងនាពេលនោះបានប្រែឈ្មោះពីចក្រភពនគរភ្នំ មកចេនឡាវិញ។ ក្រោយមកទៀតនៅដើមស.វទី៨ (៧០៦ រដ្ឋចេនឡានេះត្រូវបានបែកបាក់គ្នាជាពីរទៀត គឺ**ចេនឡាទឹកលិច** និង**ចេនឡាដីគោក**។ ចេនឡាទឹកលិចសំរាប់សំគាល់លើទឹកដីដែលនៅខាងក្រោមរាប់ពីល្បាក់ខោនមកដល់មាត់សមុទ្រ។ ចំណែកចេនឡាដីគោកសំរាប់សំគាល់វិសាលភាពទឹកដីដែលស្ថិតនៅខាងលើ គឺនៅខាងជើងភ្នំដងរែក។

នៅក្នុងសម័យចេនឡានេះ ព្រះពុទ្ធសាសនាហីនយាន (ថេរវាទ) ដែលបានរីកចំរើនក្នុងសម័យនគរភ្នំនោះត្រូវបានចុះអនុភាពរបស់ខ្លួនបន្តិចម្តង១ តែពុំសាបសូន្យភ្លាមទេ ដោយគេប្រទះឃើញព្រះពុទ្ធរូបនៅស្រុក ព្រៃ

[២០] លោកការញ៉ែត ជ តេរ **ព្រះពុទ្ធសាសនា និងសង្គមខ្មែរ** ភ្នំពេញ ១៩៩៤ ទំព័រ ៦៧

www.budinst.gov.kh www.elibraryofcambodia.org

កប្បាស ដែលសាងឡើងនៅស.វទី៧ ព្រមទាំងមានសិលាចារឹកជាច្រើនទៀត។ លុះមកដល់ចុងស.វទី៨ ព្រះពុទ្ធសាសនាមហាយាន ឬហៅថាព្រះពុទ្ធសាសនាអាចរិយវាទ ដែលនិយមភាសាសំស្ក្រឹតបានចូលមកដល់ប្រទេសខ្មែរយើង ហើយរីកលូតលាស់មកដល់ស.វទី១៣នៃសម័យអង្គរ។ គេបានរកឃើញសិលាចារឹកមួយផ្ទាំងទៀត ចុះកាលកំណត់៧៩១ នៅប្រាសាទ **តាគៀម** ក្នុងខេត្តសៀមរាប ដែលអាចចាត់ទុកជាសក្ខីភាពមួយចាស់ជាងគេ នៃព្រះពុទ្ធសាសនាមហាយាននៅស្រុកខ្មែរយើង ព្រោះឯកសារនេះ បាននិយាយពីការកសាងបដិមាពោធិសត្វលោកេស្វរៈជាពោធិសត្វមួយព្រះអង្គដែលគេនិយមជាងគេនៅស្រុកខ្មែរយើង។ ក្នុងសិល្បៈចំលាក់បុរាណ សិល្បករខ្មែរយើងច្រើនឆ្លាក់រូបពោធិសត្វនេះ ជារូបបុរសមានវ័យក្មេង មានព្រះហត្ថបួនកាន់ផ្កាឈូក ខ្សែផ្កាំ គម្ពីរ និងដបទឹក (សូមកុំច្រឡំនឹងព្រះវិស្ណុដែលមានព្រះហត្ថបួនដែរ តែកាន់ផ្កាឈូក កងចក្រ គទា និងសង្ខ)។ លក្ខណៈស្រួលចំណាំចំពោះព្រះពោធិសត្វលោកេស្វរៈ គឺនៅលើព្រះសិររបស់ព្រះអង្គមានរូបព្រះពុទ្ធ **អមិតាភៈ**។ ប៉ុន្តែ គេមិនសូវជួបប្រទះរូបបដិមាពោធិសត្វលោកេស្វរៈច្រើនប៉ុន្មានទេ។ គេបានប្រទះឃើញនៅ ក្រមួនសរនៅកម្ពុជាក្រោមមួយទៀត នៅប្រាសាទតាគៀមសៀមរាប និងគេប្រទះឃើញនៅប្រាសាទទន្លេបាទីខេត្តតាកែវ។ ទោះបី ព្រះពុទ្ធសាសនាមហាយាន ដែលជាសាសនាចំណូលថ្មីមានការរីកចំរើនក៏ដោយ ក៏គេនៅតែឃើញមានមន្ត្រី និងប្រជាពលរដ្ឋខ្មែរខ្លះ មួយចំនួនគោរពព្រះពុទ្ធសាសនាហីនយានផងដែរ។

ចំពោះលទ្ធិព្រហ្មញ្ញសាសនាវិញ នៅក្នុងសម័យចេនឡានេះ គេសង្កេតឃើញមានការគោរពបូជាចំពោះគណៈផ្សេងៗដូចជា :

- គណៈសិវៈ មានឋានៈជាសាសនាផ្លូវការ ចំពោះព្រះរាជាទាំងអស់ចាប់តាំងពីព្រះបាទ ភវវរ្ម័នទី១ និងប្អូនជីដូនមួយរបស់ព្រះអង្គ **ចិត្រ សេន** សុទ្ធតែបានធ្វើការកសាងលិង្គព្រះឥសូរសំរាប់ជាទីសក្ការៈបូជា។ គេបានរកឃើញសិលាចារឹកពីរផ្ទាំងរបស់ព្រះបាទ ភវវរ្ម័ន ដែលមួយផ្ទាំង គឺសិលាចារឹកភ្នំបន្ទាយនាងនៅតំបន់**ខ្ពស់ឈមុី** ខេត្តបាត់ដំបង ដែលនិយាយពីការកសាងលិង្គព្រះឥសូរ។ ក្នុងរាជព្រះបាទ ភវវរ្ម័ន ដដែល ព្រះអង្គចិត្រ សេននេះឯងបានកសាងផ្ទាំងសិលាចារឹកសំស្ក្រឹតខ្លីៗជាច្រើននិយាយពីការកសាងលិង្គនៅតាមបណ្តោយទន្លេមេគង្គ ក្នុងខេត្តក្រចេះ ស្ទឹងត្រែង និងនៅខាងលិចបុរីរម្យ។ មកដល់រាជ្យព្រះអង្គផ្ទាល់ ព្រះបាទ ចិត្រ សេន (ព្រះបាទមហេន្ទ្រវរ្ម័ន ៦០០) ព្រះអង្គទ្រង់បានកសាងសិលាចារឹកផ្សេងៗទៀតនៅត្រង់ទន្លេមូន និងនៅសុរិន្ទនិយាយពីការកសាងលិង្គគិរិសៈ និងរូបគោនន្ទិរក្នុងឱកាសដែលព្រះអង្គបានធ្វើសង្គ្រាមវាតទីកដីជាបន្តពីព្រះរៀមឆ្ពោះទៅទិសខាងលិច និងខាងត្បូង។ ក្រៅពីការគោរពបូជាលិង្គនៅមានគណៈមួយទៀតដែលគោរពព្រះឥសូរដែរ គឺគណៈ**បាសុបត**។

- គណៈវិស្ណុមានការគោរពផងដែរ តែមិននិយមច្រើនទេ។ តែគេឃើញមានការគោរពចំពោះគណ**បញ្ចរាត្រ**។

- ព្រះហរិហរៈ (វិស្ណុ សិវៈ) ហរិ = វិស្ណុ ហរៈ = សិវៈ ក៏ត្រូវបានគេគោរពបន្តពីសម័យនគរភ្នំមក។ គេបានឃើញព្រះហរិហរៈមួយព្រះអង្គនៅប្រាសាទអណ្តែត ស.វទី៧យ៉ាងល្អវិចិត្រ ហើយមានរាងសង្ហាថែមទៀត

www.budinst.gov.kh www.elibraryofcambodia.org

- ព្រះហរិហរៈ (វិស្ណុ សិវៈ) ហរិ = វិស្ណុ ហរៈ = សិវៈ ក៏ត្រូវបានគេគោរពបន្តពីសម័យនគរភ្នំមក។ គេបានឃើញព្រះហរិហរៈមួយព្រះអង្គនៅប្រាសាទអណ្ដែត ស.វទី៧យ៉ាងល្អវិចិត្រ ហើយមានរាងសង្ហាថែមទៀត ដែលគេចាត់ទុកជាស្នាដៃឯក នៃសិល្បៈចំលាក់ខ្មែរ។ តែក្រោយមកចាប់ពីពេលនេះតទៅ គេពុំឃើញមានការគោរពព្រះហរិហរៈតទៅទៀតឡើយ។

ក្នុងគ.ស៦៦៤ មានព្រះមហាក្សត្រមួយអង្គព្រះនាម **ជ័យវរ្ម័នទី១** ទ្រង់ជ្រះថ្លាក្នុងព្រះពុទ្ធសាសនា ហើយព្រះអង្គបានបំបួសព្រះរាជបុត្រពីរអង្គជាភិក្ខុក្នុងព្រះពុទ្ធសាសនា ដើម្បីឱ្យបានជាព្រះញាតិព្រះពុទ្ធសាសនា ភិក្ខុមួយរូបព្រះនាម **រតនភាណុ** និងមួយអង្គទៀតព្រះនាម **រតនសិន្ធុះ** ។

រវាងស.វខាងលើនេះ ព្រះពុទ្ធសាសនាបានចំរើនរុងរឿងណាស់ ព្រះពុទ្ធរូបជាព្រះបដិមាកររចនា បានផ្សាយទូទៅក្នុងទីផ្សេងៗ។

សរុបមក យើងសង្កេតឃើញថានៅក្នុងសម័យចេនឡានេះ មានសាសនាច្រើនដែលប្រជាពលរដ្ឋខ្មែរយើងគោរពបូជានៅលាយឡំគ្នាគ្រាន់តែតិចច្រើនជាងគ្នាប៉ុណ្ណោះ។ ដោយឡែកព្រះពុទ្ធសាសនាហីនយាន ដែលជាសាសនាមួយក្នុងចំណោមសាសនាទាំងអស់ ហើយបានចាក់ឫសមុនគេនោះ មានការរីកចំរើននៅសម័យនគរភ្នំនោះបានចុះអនុភាពបន្តិចម្ដងៗនៅសម័យចេនឡា តែពុំមែនសាបរលាបភ្លាមៗនោះទេ។ ក្រោយពេលព្រះពុទ្ធសាសនាហីនយានចុះអនុភាព ព្រះពុទ្ធសាសនាមហាយានបានមកជំនួសវិញម្ដង។

### ឃ. សម័យអង្គរ

សម័យអង្គរត្រូវបានចាប់កំណើតពីគ.ស៨០២ ជាឆ្នាំដែលព្រះបាទ **ជ័យវរ្ម័នទី២** ជាបឋមក្សត្រនៃសម័យអង្គរចូលបង្រួបបង្រួមជាតិ និងកសាងទឹកដីឡើងវិញ បង្កើតជាសម័យអង្គរនោះ រហូតដល់ឆ្នាំ១៤៣១ ជាឆ្នាំចំណាកចោលអង្គរដោយសម្ដេច **ចៅ ពញាយ៉ាត** មកតាំងនៅ **ទួលបសាន** (ស្រីសន្ធរ) និងបន្តមកទៀត នៅរាជធានីចតុមុខ ភ្នំពេញសព្វថ្ងៃនេះ។

ក្នុងតំណាក់កាលដំបូងនៃសម័យអង្គរនេះ ព្រះពុទ្ធសាសនាហីនយាន (ថេរវាទ) ដែលចុះអានុភាពតាំងពីចុងស.វទី៨មកនោះកាន់តែចុះអានុភាពខ្លាំងឡើងៗ តែពុំរលុបរលាយបាត់បង់ទាំងស្រុងនោះឡើយ។ តែគេសង្កេតឃើញព្រហ្មញ្ញសាសនា និងព្រះពុទ្ធសាសនាមហាយាន (អាចរិយវាទ) មានការរីកចំរើន ព្រមទាំងជះឥទ្ធិពលយ៉ាងខ្លាំងដល់ការកសាងប្រទេសជាតិនាសម័យនោះ។ ពេលខ្លះ គេសង្កេតឃើញព្រហ្មញ្ញសាសនា និងព្រះពុទ្ធសាសនាមហាយានមានការរីកចំរើនឆ្លាស់គ្នា ពេលខ្លះចូលគ្នា ពេលខ្លះមានទំនាស់នឹងគ្នាយ៉ាងខ្លាំងក្លា។

នៅសម័យអង្គរនេះ សាសនាមានមុខងារយ៉ាងសំខាន់ក្នុងនយោបាយ ការគ្រប់គ្រង និងការកសាងប្រទេស ប៉ុន្តែ ការគោរពប្រតិបត្តិសាសនារបស់ថ្នាក់ដឹកនាំ ពុំសូវមានការឯកភាពទេ គឺផ្លាស់ប្ដូរទៅតាមចំណូលចិត្តរបស់បុគ្គលម្នាក់ៗ មានព្រះរាជាខ្លះគោរពព្រះពុទ្ធសាសនា ព្រះរាជាខ្លះគោរពព្រហ្មញ្ញសាសនានិកាយឥសូរ មានព្រះរាជាខ្លះគោរពនិកាយព្រះវិស្ណុ និងមានព្រះរាជាខ្លះគោរពព្រះព្រហ្ម។ ដោយលក្ខណៈបែបនេះ គេយល់ថាជាលក្ខណៈដែល

LIBRARY BUDDHIST INSTITUTE

www.budinst.gov.kh www.elibraryofcambodia.org

កើតចេញរចនាសម្ព័ន្ធរបស់សង្គមខ្មែរតែម្តង ហើយប្រៀបបានទឹងទំនិញទិញដូរ ដែលនាំយក ឬជាវប្បធម៌ថ្លៃថ្នូរ សំរាប់ព្រះមហាក្សត្រ មន្ត្រី និងអភិជន។ ចំពោះរាស្ត្រប្រជាក្រីក្រវិញ ហាក់ដូចជាពុំសូវជ្រួតជ្រាបប៉ុន្មានទេ។

ពីស.វទី៩ ដល់ស.វទី១១ ព្រហ្មញ្ញសាសនាគណៈសិវនិយម មានឧត្តមភាពលើគណៈសាសនាឯទៀតៗ ព្រោះព្រះរាជាភាគច្រើន បានចាត់ទុកសាសនានេះជាសាសនារបស់រដ្ឋ ដោយការប្រារព្ធធ្វើពិធីទេវរាជ ដែលព្រះរាជាមានឋានៈស្មើនិងអាទិទេព (ព្រះឥសូរ) ពោលគឺ អាទិទេព គឺស្តេច ហើយស្តេច គឺអាទិទេព ដោយមានសិវលិង្គតំណាងតំកល់ក្នុងប្រាសាទភ្នំ។ តែក្នុងរយៈពេលនេះ ក៏យើងសង្កេតឃើញព្រះរាជាទាំងឡាយនោះ តែងយកព្រះហឫទ័យទុកដាក់ និងជួយឧបត្ថម្ភចំពោះសាសនាឯទៀត ដែលរួមរស់ជាមួយគ្នាយ៉ាងសុខដុមរមនា ដែលក្នុងនោះមានព្រះពុទ្ធសាសនាផងដែរ។

នៅស.វទី១១ ព្រះពុទ្ធសាសនាមហាយាន ដែលបានចូលមកតាំងពីសម័យចេនឡា នាស.វទី៨ ត្រូវបានព្រះបាទ **សុរ្យវរ្ម័នទី១** (១០០២-១០៥០) លើកតំកើងជាសាសនារបស់រដ្ឋ។ តែក្រោយមក នៅស.វទី១២ គណៈវិស្ណុនិយមត្រូវបានព្រះបាទ**សុរ្យវរ្ម័នទី២**គោរពរាប់អានសំបើមណាស់ ក្រោមព្រះរាជូបត្ថម្ភរបស់ព្រះអង្គ **ប្រាសាទអង្គរវត្ត** ដ៏ធំស្កឹមស្កៃបានកសាងឡើងដើម្បីតំកល់វិស្ណុបដិមាសំរាប់ជាទីគោរពបូជា។

បន្តក្រោយមកទៀត ក្នុងរាជក្រោយៗ ជាពិសេសក្នុងរាជព្រះបាទ **ជ័យវរ្ម័នទី៧** ព្រះពុទ្ធសាសនាត្រូវបានគោរពយ៉ាងមុតមាំវិញម្តង។ ព្រះអង្គទ្រង់បានចាត់តាំងកសាង **ប្រាសាទបាយ័ន** មានលក្ខណៈជាប្រាសាទភ្នំសំរាប់តំកល់រូបតំណាងព្រះរាជា គឺពុទ្ធបដិមាជាភស្តុតាង។ ពិធី **ទេវរាជ** ដែលព្រះរាជាពីមុនៗមកបានគោរពបូជា ត្រូវជំនួសដោយពិធី **ពុទ្ធរាជ**។

គ.ស១១៨១ ព្រះបាទ **ជ័យវរ្ម័នទី៧** ទ្រង់រាជសម្បត្តិគង់នៅក្នុងរាជធានី**យសោធរបុរៈ** (នគរភ្នំ) ទ្រង់ជាពុទ្ធសាសនិកដ៏ប្រសើរ ទ្រង់បានកសាងអាគារពីរថ្វាយព្រះសង្ឃ **រាជវិហារ** (តាព្រហ្ម) មួយ និង**ជ័យស្រី** (ព្រះខាន់) មួយ។ ក្នុងរជ្ជកាលនោះ មានសង្ឃជាមហាថេរជាន់ខ្ពស់សុទ្ធសឹងមានគុណឡើចំនួន១៨អង្គ មានមហាថេរជាលំដាប់មកចំនួន២៧៤០អង្គ សុទ្ធតែជាសាស្ត្រាចារ្យជាន់ខ្ពស់។ រាល់ថ្ងៃមានភិក្ខុសង្ឃចំនួន៤៣៩អង្គ ត្រូវនិមន្តទៅក្នុងព្រះបរមរាជវាំងមហានគរ។ល។ ព្រះមហាក្សត្រអង្គនេះ ទ្រង់មានព្រះរាជសទ្ធាជ្រះថ្លាក្នុងព្រះពុទ្ធសាសនាដ៏លើសលុបណាស់ ទ្រង់បានបំពេញព្រះរាជកុសលធ្វើពុទ្ធបូជា ដោយវត្ថុដ៏មានតំលៃយ៉ាងច្រើនអនេក។

អំពើជាព្រះរាជកុសល ទំនុកបំរុងក្នុងព្រះរាជព្រះពុទ្ធសាសនា ដែលព្រះមហាក្សត្រអង្គនេះទ្រង់បានធ្វើនោះ មិនអាចនឹងពិពណ៌នាសរសើរថាដូចម្តេចបានឡើយ យើងគ្រាន់តែនិយាយប្រៀបធៀបថា ព្រះបាទធម្មាសោកមហារាជក្នុងប្រទេសឥណ្ឌា (ជម្ពូទ្វីប) ទ្រង់ឧបត្ថម្ភព្រះពុទ្ធសាសនា។ យ៉ាងណាមិញ ព្រះបាទ ជ័យវរ្ម័នទី៧ ក៏យ៉ាងដូចនោះដែរ យើងអាចទុកព្រះអង្គជាព្រះបាទធម្មាសោកមហារាជរបស់ព្រះរាជាណាចក្រកម្ពុជា។

ក្នុងរជ្ជកាលនៃព្រះមហាក្សត្រអង្គដដែលនេះ មានព្រឹត្តិការណ៍មួយទៀតដែលយើងមិនអាចនឹងបំភ្លេចចោលបាន គឺព្រះអង្គទ្រង់បានបញ្ជូនព្រះរាជបុត្រមួយអង្គ ជាទីពេញព្រះរាជហឫទ័យ ឱ្យចូលមកសិក្សាវិជ្ជាខាងព្រះ

www.budinst.gov.kh www.elibraryofcambodia.org

ពុទ្ធសាសនានៅកោះលង្កាណេហ ហើយព្រះរាជបុត្របានបួសជាភិក្ខុក្នុងវត្តមហាវិហារ នៅគ.ស ១១៩០។ ប្រវត្តិសាស្ត្រនៃប្រទេសភូមា ក៏បានបញ្ជាក់ថា មានព្រះរាជបុត្រនៃព្រះមហាក្សត្រខ្មែរមួយអង្គ ព្រះនាម **លិទ្ធៈ** បានទៅសិក្សាវិជ្ជាខាងព្រះពុទ្ធសាសនា ហើយបានបួសនៅកោះលង្កាជាមួយនិងភិក្ខុមុន៤អង្គ ([២១])។ នេះអាចចាត់ទុកជាសក្ខីភាពនៃសម្ព័ន្ធមេត្រីខាងវប្បធម៌រវាងប្រទេសកម្ពុជា និងប្រទេសស្រីលង្កាពីបុរាណកាល ។

ខាងលើនេះ យើងបានសង្កេតឃើញថា សាសនានៅសម័យអង្គរមានការវិវត្តឆ្លាស់គ្នា។ តែសាសនាទាំងអស់នោះ មានពេលខ្លះមាកការរីកចំរើនស្របៗគ្នាតិចច្រើនជាងគ្នា រលាយចូលគ្នា និងមានទំនាស់គ្នាយ៉ាងស្រួចស្រាវ ។

**១. ការរលាយចូលគ្នានៃបណ្ដាសាសនានៅសម័យអង្គរ** ([២២])

ការរលាយចូលគ្នានៃបណ្ដាសាសនានៅសម័យអង្គរ ដែលអ្នកសិក្សាប្រវត្តិសាស្ត្រខ្មែរ បាននិយមប្រើពុំមែនមានន័យថា សាសនាដែលមានច្រើន ហើយរលាយចូលគ្នានៅសល់តែមួយនោះទេ តែការរួមរស់ជាមួយគ្នា និងមានចិត្តសន្ដោសប្រោសប្រណីទៅវិញទៅមក ដើម្បីជាកំលាំងមួយធ្វើឱ្យសង្គមជាតិរីកចំរើន និងសុខសន្តិភាព។ នៅសម័យអង្គរនេះ គេសង្កេតឃើញក្នុងរាជ្យព្រះរាជាច្រើនព្រះអង្គ ដែលមានសាសនាជាច្រើន តែសាសនាទាំងនោះបានរួមរស់ និងមានការរីកចំរើនរៀងៗខ្លួន ហើយគ្មានការប៉ះទង្គិចរវាងគ្នានឹងគ្នាឡើយ ។ ភស្តុតាងដូចជា :

- ក្នុងរាជព្រះបាទ **ជ័យវរ្ម័នទី២** (គ.ស ៨០២-៨៥០) ដែលមានព្រះរាជធានីនៅ**មហេន្ទ្របព៌ត** ( ភ្នំគូលេន ) ។ ព្រះរាជាកាន់សាសនាព្រាហ្មណ៍ តែមាននាម៉ឺន និងប្រជារាស្ត្រកាន់ព្រះពុទ្ធសាសនាមហាយានផងដែរ ។

- ក្នុងរាជព្រះបាទ **ជ័យវរ្ម័នទី៣** (គ.ស ៨៥០-៨៧៧) ដែលមានព្រះរាជធានីនៅ**ហរិហរាល័យ** នៅតំបន់រលួស ស្រុកប្រាសាទបាគង ខេត្តសៀមរាបសព្វថ្ងៃ។ ព្រះរាជាកាន់សាសនាព្រាហ្មណ៍ តែមាននាម៉ឺន និងប្រជារាស្ត្រគោរពព្រះពុទ្ធសាសនា។

- ក្នុងរាជព្រះបាទ **ឥន្ទ្រវរ្ម័នទី១** (គ.ស ៨៧៧-៨៨៩) ដែលមានព្រះរាជធានីនៅ**ហរិហរាល័យ** ដែរ ។ ព្រះរាជាកាន់សាសនាព្រាហ្មណ៍ តែមាននាម៉ឺន និងប្រជារាស្ត្រគោរពព្រះពុទ្ធសាសនា។

- ក្នុងរាជព្រះបាទ **យសោវរ្ម័នទី១** (គ.ស ៨៨៩-៩០០) ដែលមានព្រះរាជធានីនៅ**យសោធរបុរៈ** អង្គរធំ ក្នុងរាជ្យរបស់ព្រះអង្គ ព្រះពុទ្ធសាសនា និងសាសនាព្រាហ្មណ៍មានសិទ្ធិដូចគ្នា គឺប្រជារាស្ត្រគោរពតាមការស្ម័គ្រចិត្តរបស់ខ្លួន។ ទ្រង់បានកសាងនៅលើច្រាំងខាងត្បូង នៃបារាយយសោធរតដាកនៅអាស្រមជាច្រើនសំរាប់គណៈសាសនាដូចជា :

- ព្រាហ្មណ៍ស្រម សំរាប់អ្នកកាន់សាសនាព្រះឥសូរ

---

[២១] **និក្ខេបបទ** ( ខ្លូត ធីតា ) ការពារថ្នាក់បណ្ឌិត ឆ្នាំ១៩៩៨

[២២] **និក្ខេបបទ** ( ខ្លូត ធីតា ) ការពារថ្នាក់បណ្ឌិត ឆ្នាំ១៩៩៨

www.budinst.gov.kh www.elibraryofcambodia.org

- វៃស្នពវាស្រម សំរាប់អ្នកកាន់សាសនាព្រះវិស្ណុ
- សៅតពាស្រម សំរាប់អ្នកកាន់សាសនាព្រះពុទ្ធ

- ក្នុងរាជព្រះបាទ **ជ័យវរ្ម័នទី៤** (គ.ស ៩២៨-៩៤១) ដែលមានព្រះរាជធានីនៅ**អង្គរធំ** ក្រោយមកផ្លាស់ទៅនៅ**កោះកែរ** ៧០គ.ម ទិសឦសាន្តក្រុងអង្គរ។ ព្រះរាជាអង្គនេះកាន់សាសនាព្រាហ្មណ៍ ឯនាម៉ឺន និងប្រជារាស្ត្រភាគច្រើនគោរពព្រះពុទ្ធសាសនា។

- ក្នុងរាជព្រះបាទ **រាជេន្ទ្រវរ្ម័នទី២** (គ.ស ៩៤៤-៩៦៧) ដែលមានព្រះរាជធានីនៅ**កោះកែរ** បានមួយឆ្នាំ រួចក៏រើមកនៅ**អង្គរធំ**វិញ។ ព្រះរាជាកាន់សាសនាព្រាហ្មណ៍ តែទ្រង់បានប្រោសប្រទានចំពោះពុទ្ធសាសនាផងដែរ។ ព្រះអង្គបានកសាងវត្តអារាមខាងពុទ្ធសាសនា កាន់តែប្រសើរឡើងមកជិតរាជធានី។ ក្នុងរាជ្យព្រះមហាក្សត្រអង្គនេះ សេរីភាពខាងសាសនាបានបើកទូលំទូលាយណាស់។ ព្រាហ្មណ៍សាសនា និងព្រះពុទ្ធសាសនាមានការរាប់អានគ្នាកាន់តែជិតស្និទ្ធថែមទៀត។

- ក្នុងរាជព្រះបាទ **ជ័យវរ្ម័នទី៥** (គ.ស ៩៦៧-១០០១) ដែលមានព្រះរាជធានីនៅ**អង្គរធំ** ។ ព្រះរាជាអង្គនេះ និងពួកមន្ត្រីជាន់ខ្ពស់កាន់សាសនាឥសូរ។ តែមានឯកសារខ្លះថា ព្រះអង្គជាអ្នកកាន់សាសនាព្រះពុទ្ធដ៏មុតមាំ បានធ្វើឱ្យអ្នកដែលពុំធ្លាប់មានសទ្ធាជ្រះថ្លាចំពោះព្រះពុទ្ធសាសនា ក៏ត្រឡប់ជាមានសទ្ធាជ្រះថ្លាតាមព្រះអង្គយ៉ាងច្រើន។ ហើយព្រះអង្គបានកសាងព្រះពុទ្ធរូបមួយអង្គធំ នៅជិតប្រាសាទ **ឆាយ័ន** គឺ**ព្រះពុទ្ធរូបគោតមឬក**។

- ក្នុងរាជព្រះបាទ **សុរ្យវរ្ម័នទី១** (គ.ស ១០០២-១០៥០) ដែលមានព្រះរាជធានីនៅ**អង្គរធំ** ។ ព្រះអង្គជាអ្នកកាន់ព្រះពុទ្ធសាសនាមហាយាន តែព្រះអង្គគោរពព្រះពុទ្ធសាសនាថេរវាទ និងសាសនាព្រាហ្មណ៍ផងដែរ ដោយមិនឱ្យសាសនាទាំងនោះមានការថ្នាំងថ្នាក់នឹងគ្នាឡើយ។

- ក្នុងរាជព្រះបាទ **ហសវរ្ម័ន** (គ.ស ១០៦៦-១០៨០) ដែលមានព្រះរាជធានីនៅ**អង្គរធំ** ។ ព្រះរាជាអង្គនេះប្រកបដោយគតិបណ្ឌិតគ្រប់រាជករណីកិច្ចនៃសាសនា។ ព្រះអង្គគោរពកាន់សាសនាទាំងអស់ស្មើៗគ្នា តាមឋានៈព្រះអង្គជាព្រះមហាក្សត្រ។

- ក្នុងរាជព្រះបាទ **សុរ្យវរ្ម័នទី២** (គ.ស ១១១៣) ដែលមានព្រះរាជធានីនៅ**អង្គរធំ** ។ ព្រះអង្គជាអ្នកកាន់សាសនាព្រាហ្មណ៍ និកាយវិស្ណុ។ ឯនាម៉ឺន និងប្រជារាស្ត្រក៏ត្រូវអនុញ្ញាត្តិឱ្យគោរពព្រះពុទ្ធសាសនាផងដែរ។

ខាងលើនេះយើងសង្កេតឃើញថា ក្នុងសម័យអង្គរចាប់ពីស.វទី៩ រហូតដល់ពាក់កណ្តាលស.វទី១នៃស.វទី១២ សាសនាទាំងអស់នោះ មានការរួមរស់ផ្លាស់ប្តូរគ្នាល្អណាស់ ព្រមទាំងគ្មានទំនាស់មាស់ទាញគ្នាឡើយ។ នេះដែលគេហៅថា **ការលាយចូលគ្នានៃសាសនា** ។ ការលាយចូលគ្នានេះ ពុំមែនស្ថិតស្ថេររៀងរហូតទេ ក្រោយមកគេ

www.budinst.gov.kh www.elibraryofcambodia.org

ឃើញនូវទំនាស់ទាស់ទាញគ្នា ដែលបង្កឡើងដោយព្រហ្មញ្ញសាសនាប្រឆាំងនឹងពុទ្ធសាសនា ឬទំនាស់ដែលបង្កឡើងដោយព្រះពុទ្ធសាសនាប្រឆាំងនឹងព្រហ្មញ្ញសាសនា ដែលមានករណីព្រឹត្តិការណ៍របស់**តាត្រសក់ផ្អែម** ជាអាទិ ។

**ច. ប្រតិកម្មនៃលទ្ធិសាសនាព្រាហ្មណ៍និកាយសិវៈប្រឆាំងនឹងព្រះពុទ្ធសាសនា** (២៣)

រួចមកហើយយើងសង្កេតឃើញថាចាប់ពីស.វទី៩ មកដល់ស.វទី ១២ លទ្ធិព្រហ្មញ្ញសាសនាមានការរីកចំរើនព្រមទាំងមានការរួមរស់ជាមួយនឹងលទ្ធិព្រះពុទ្ធសាសនា។ តែចាប់ពីចុងស.វទី ១២ និងដើមស.វទី១៣មក លទ្ធិព្រហ្មញ្ញសាសនាបានចុះអនុភាពរបស់ខ្លួនបន្តិចម្តងៗ ទន្ទឹមគ្នានឹងការអស់ឥទ្ធិពលនៃលទ្ធិទេវរាជ។ ផ្ទុយនឹងការចុះអនុភាពនៃលទ្ធិសាសនាព្រាហ្មណ៍ព្រះពុទ្ធសាសនាត្រូវបានលើកតំកើង ជាពិសេសចាប់ពីរាជ្យព្រះបាទ **យសោវរ្ម័នទី២** មកដល់រាជ្យព្រះបាទ **ជ័យវរ្ម័នទី៧** និងក្នុងរាជ្យស្តេចក្រោយៗទៀត ព្រះពុទ្ធសាសនាមានការរីកចំរើនខ្លាំងជាង ព្រមទាំងមានអនុភាពទៅលើប្រជាពលរដ្ឋភាគច្រើនផង។ ហេតុនេះ បានធ្វើឱ្យគណៈសង្ឃនៃលទ្ធិសាសនាព្រាហ្មណ៍មានការមិនសប្បាយចិត្ត និងមានការប្រតិកម្មយ៉ាងខ្លាំងប្រឆាំងនឹងពុទ្ធសាសនា។ គេសង្កេតឃើញមានការកោសលុបរូបចំលាក់ព្រះពុទ្ធសាសនានៅលើជញ្ជាំង និងលើសសរប្រាសាទ ហើយសាងសង់ជំនួសវិញដោយលិង្គព្រះឥសូរ ឬតាបសតាំងសីល។ តពីរាជ្យរបស់ព្រះបាទ **ជ័យវរ្ម័នទី៧** ក្នុងរាជ្យស្តេចក្រោយៗ គេសង្កេតឃើញមានសិលាចារឹកកសាងឡើងដោយពួកព្រាហ្មណ៍ដែលចង់ប្រស់ប្រពៃណីព្រាហ្មណ៍ ដែលមានតាំងពីស.វមុន១ឱ្យរស់រវើកឡើងវិញក្រោយពីត្រូវបាត់ឈ្មោះបោះសំឡេងក្នុងរជ្ជកាលរបស់ព្រះបាទ **ធរណីន្ទ្រវរ្ម័នទី២** ព្រះបាទ **ជ័យវរ្ម័នទី៧** និងអគ្គមហេសីរបស់ព្រះអង្គ។ ក្នុងរជ្ជកាលរបស់ព្រះបាទ **ជ័យវរ្ម័នទី៨** ( ពាក់កណ្តាលទី ២ នៃស.វទី ១៣ ) ពួកព្រាហ្មណ៍បានទទួលអនុគ្រោះសារជាថ្មីឡើងវិញ ។ មហេសីរបស់ព្រះអង្គមួយរូប គឺព្រះនាង**ចក្រវ័ត្តិរាជទេវី** ត្រូវជាកូនស្រីរបស់ព្រាហ្មណ៍ **ឫសោធិត ឬឈាសិកេស** ដែលបានមកពីប្រទេសភូមាក្នុងរជ្ជកាលព្រះបាទ **ជ័យវរ្ម័នទី៧** ហើយដែលបានទទួលឋានន្តរនាមជា **ជ័យមហាប្រធាន**។ ប្អូនថ្លៃស្រីរបស់ព្រាហ្មណ៍នោះ បានរៀបការជាមួយព្រាហ្មណ៍ម្នាក់ទៀតឈ្មោះ **ជ័យមង្គលាទ៌** ។ នាងមានកូនម្នាក់ ឈ្មោះដូចគ្នានឹងព្រាហ្មណ៍ឪពុកដែរ ។ ព្រះបាទ **ជ័យវរ្ម័នទី៨** ទ្រង់បានផ្តល់កិត្តិយសដ៏ធំធេងចំពោះជយមង្គលាថ៌ជាកូននេះ រហូតបានបញ្ជាឱ្យស្ថាបនាប្រាសាទមួយនៅឆ្នាំ១២៩៥ ដើម្បីឧទ្ទិសដល់វិញ្ញាណក្ខន្ធនៃបុរសរូបនេះដែលបានទៅជាបងប្អូនជីដូនមួយរបស់ព្រះអគ្គមហេសីព្រះអង្គ។ នេះបញ្ជាក់ពីការនិយមឡើងវិញ ចំពោះសាសនាព្រាហ្មណ៍នៅក្នុងរាជ្យព្រះបាទ**ជ័យវរ្ម័នទី៨**នេះ ។

តែទោះបី មានប្រតិកម្មប្រឆាំងពីសំណាក់ពួកព្រាហ្មណ៍ ដូចបានរៀបរាប់ខាងលើក៏ដោយ ក៏គេឃើញព្រះពុទ្ធសាសនាដែលនាំចូលតាមរយៈព្រះអង្គម្ចាស់ **តាមលិន្ទ** ជាព្រះរាជបុត្ររបស់ព្រះបាទ **ជ័យវរ្ម័នទី៧** បានផ្សព្វផ្សាយចូលមកដល់ប្រទេសខ្មែរយើង ហើយត្រូវបានប្រជាពលរដ្ឋនិយមគោរពកាន់តែច្រើនឡើងៗហើយដែរ ។

---

(២៣) មហាគបញ្ញ៉ែត ធ ឈា **ព្រះពុទ្ធសាសនា និងសង្គមខ្មែរ** ភ្នំពេញ១៩៩៤ ទំព័រ ៧០

www.budinst.gov.kh www.elibraryofcambodia.org

ក្រោយពីប្រតិកម្មប្រឆាំងរបស់សាសនាព្រាហ្មណ៍ ក្នុងរាជ្យព្រះបាទ **ជ័យវរ្ម័នទី៨** មក ក្នុងរាជ្យរបស់ព្រះមហាក្សត្រក្រោយៗមក យើងសង្កេតឃើញមានការគោរពសាសនាឆ្លាស់គ្នាវិញ នេះពុំមែនមានន័យថាការចុះសំរុងគ្នាទេ តែបញ្ជាក់ពីអស្ថេរភាព និងទំនាស់សាសនា ហើយទន្ទឹមនឹងនោះដែរ ស្ថានភាពរបស់សង្គមជាតិកាន់តែចុះដុនដាបទៅៗ។

ឧទាហរណ៍ ដូចជា :

- ក្នុងរាជព្រះបាទ **ស្រីន្ទ្រវរ្ម័ន** ឬ **ឥន្ទ្រវរ្ម័នទី៣** (១២៩៥-១៣០៧) ព្រះអង្គជាអ្នកគោរពព្រះពុទ្ធសាសនា។ គេសង្កេតឃើញ មានសិលាចារឹកជាភាសាបាលីជាលើកដំបូង និយាយពីការស្ថាបនាព្រះវិហារមួយ និងព្រះពុទ្ធបដិមាមួយនៅក្នុងឆ្នាំ១៣០៩ គឺ២ឆ្នាំក្រោយដែលព្រះអង្គដាក់រាជ្យ ផ្ទេរទៅឱ្យព្រះរាជវង្សទាយាទ ដើម្បីព្រះ អង្គយាងទៅសាងផ្នួសក្នុងព្រៃ។

- ក្នុងរាជ្យព្រះបាទ **ស្រីន្ទ្រជ័យវរ្ម័ន** (១៣០៧-១៣២៧ ) ព្រះអង្គទ្រង់ចាត់ឱ្យតុបតែងបន្ថែមនូវប្រាសាទដែលបានកសាងឡើងក្នុងរជ្ជកាលព្រះបាទ **ជ័យវរ្ម័នទី៨** ដើម្បីឧទ្ទិសចំពោះព្រាហ្មណ៍ **ជ័យមង្គលាទី**។

- ក្នុងរាជ្យព្រះបាទ **ជ័យវម៌ាទិបរមេស្វរៈ** ឬ **ជ័យវរ្ម័នទី៩** (១៣២៧-?) គេសង្កេតឃើញមានសិលាចារឹកបាយ័នសរសេរជាភាសាខ្មែរ និងសិលាចារឹកអង្គរវត្ត សរសេរជាភាសាសំស្ក្រឹត ជាស្នាដៃរបស់ព្រាហ្មណ៍ **វិទ្យេសធីមន្ត** ដែលជាស្នាដៃចុងក្រោយបំផុត ដែលទាក់ទងនឹងសាសនាព្រាហ្មណ៍មានអត្ថន័យពោរពេញទៅដោយគំនិតសិវនិយម។

ដោយសារការរីកចំរើននៃព្រាហ្មណ៍សាសនាឡើងវិញនេះហើយ ដែលធ្វើឱ្យមានប្រតិកម្មពីសំណាក់ពុទ្ធសាសនាវិញម្តង។

**ច. ព្រឹត្តិការណ៍របស់នាយត្រសក់ផ្អែម**

កន្លងមកយើងសង្កេតឃើញថា ព្រះពុទ្ធសាសនា និងព្រាហ្មណ៍សាសនាជាសាសនាពីរដែលមានអត្ថិភាព ព្រមទាំងមានការរីកចំរើនទៅក្នុងសង្គមកម្ពុជាយើង ដែលពេលខ្លះមានការរីកចំរើនស្របៗគ្នា រលាយចូលគ្នា និងប្រតិកម្មរបស់ព្រាហ្មណ៍សាសនាប្រឆាំងនឹងព្រះពុទ្ធសាសនា។

ខាងក្រោមនេះ យើងសូមលើកយកព្រឹត្តិការណ៍របស់នាយត្រសក់ផ្អែមមកសិក្សា។ ព្រឹត្តិការណ៍នេះ ជាព្រឹត្តិការណ៍មួយសំខាន់នៃប្រវត្តិសាស្ត្រខ្មែរ ដែលអ្នកសិក្សាប្រវត្តិសាស្ត្រ ក៏ដូចជាអ្នកសិក្សាអក្សរសាស្ត្រ និងសង្គម

www.budinst.gov.kh www.elibraryofcambodia.org

វិទូបានយល់ថាជាបដិវត្តន៍មួយរបស់សង្គមនាសម័យនោះ។ ព្រឹត្តិការណ៍នាយត្រសក់ផ្អែមនេះ មានរឿងដំណាលដូចតទៅ :

- មានបុរសម្នាក់ដាំត្រសក់មានរសជាតិផ្អែមខុសប្លែកពីត្រសក់នានា។ នាយបានបេះត្រសក់យកទៅថ្វាយព្រះមហាក្សត្ររាល់ថ្ងៃ ហើយត្រូវបានព្រះរាជាប្រទានលំពែងមួយ សំរាប់ការពារចំការរបស់គាត់។

- យប់មួយ ព្រះមហាក្សត្របានចូលទៅលួចបេះត្រសក់ ដោយសាកល្បង តើនាយត្រសក់ផ្អែមអាចការពារចំការត្រសក់ឬទេ ? នាពេលនោះដោយពុំដឹងថាជាព្រះមហាក្សត្រ នាយត្រសក់ផ្អែមក៏បោះពួយនឹងលំពែងត្រូវព្រះមហាក្សត្រសុគតនៅពេលនោះទៅ។

- ដោយគ្មានព្រះមហាក្សត្រ នាម៉ឺនសព្វមុខមន្ត្រីបានមូលមតិគ្នាលើក នាយត្រសក់ផ្អែម ឱ្យឡើងសោយរាជ្យ ព្រមទាំងបានបុត្រីស្តេចធ្វើជាមហេសីទៀតផង។

ព្រឹត្តិការណ៍របស់នាយត្រសក់ផ្អែម ឬគេហៅថាតាត្រសក់ផ្អែមដូចបានរៀបរាប់ខាងលើនេះ ត្រូវបានអ្នកប្រវត្តិសាស្ត្រយល់ថា ជាព្រឹត្តិការណ៍បដិវត្តន៍មួយក្នុងប្រវត្តិសាស្ត្រខ្មែរ ទាំងវិស័យនយោបាយផង និងវិស័យសាសនាផង។ បដិវត្តន៍នយោបាយក៏ជាបដិវត្តន៍ដែលផ្ទេរពីការគ្រប់គ្រងប្រទេស ដែលយកលទ្ធិទេវរាជធ្វើជាមាគ៌ាក្នុងការដឹកនាំប្រទេស មកគោរពលទ្ធិពុទ្ធរាជដែលនិយមតាមលទ្ធិពុទ្ធសាសនាសំរាប់ដឹកនាំប្រទេសវិញ។ លទ្ធិទេវរាជដែលព្រះបាទ **ជ័យវរ្ម័នទី២** បានបង្កើតឡើងតាំងពីដើមស.វទី៩មានឥទ្ធិពលយ៉ាងខ្លាំងក្លារហូតដល់ចុងស.វទី១២ ដើម្បីជាមធ្យោបាយសំរាប់ការបង្រួបបង្រួមជាតិ និងកសាងប្រទេសជាតិ។ តែចាប់ពីស.វទី១៣មក ពិធីទេវរាជនេះត្រូវចុះសាបរលាបបន្តិចម្តង១ ទន្ទឹមគ្នានឹងមានទំនាក់ទំនងយ៉ាងញឹកញាប់ជាមួយព្រះពុទ្ធសាសនា។ នៅសម័យចុងនៃសម័យអង្គរ ទំនាស់សាសនាកាន់តែស្រួចស្រាវឡើង។ ព្រឹត្តិការណ៍តាត្រសក់ផ្អែមនេះ គេអាចចាត់ទុកជាបដិវត្តន៍សាសនា ពីព្រាហ្មណ៍សាសនាមកព្រះពុទ្ធសាសនា។ អាស្រ័យហេតុនេះហើយទើបយើងសង្កេតឃើញថាចាប់ពីរាជ្យ **តាត្រសក់ផ្អែម**នេះមក ព្រហ្មញ្ញត្រូវបោះបង់ចោលទាំងស្រុង ហើយព្រះពុទ្ធសាសនាហីនយានត្រូវបានមកជំនួសវិញ។ ចាប់ពីពេលនោះហើយ ដែលព្រះពុទ្ធសាសនាហីនយានចាប់រីកចំរើនរហូតមកដល់សម័យក្រោយ១ទៀត និងរហូតមកដល់បច្ចុប្បន្ន។

### ឌ. ក្រោយសម័យអង្គរ រហូតមកដល់សព្វថ្ងៃ ([២៨])

ចាប់ពីចំណោកចោលអង្គរ ១៤៣១ រហូតមកដល់សព្វថ្ងៃនេះ សង្គមកម្ពុជាយើងបានឆ្លងកាត់របបសង្គមជាច្រើនដែលមាននិន្នាការនយោបាយខុស១គ្នា។

- ពីចុងស.វទី១៥ ដល់ស.វទី១៧ **សម័យលង្វែក**
- ពីដើមស.វទី១៧ ដល់ឆ្នាំ ១៨៦៣**សម័យឧត្តុង្គ**

[២៨] លោកបណ្ឌិត ឆ ណោ **ព្រះពុទ្ធសាសនា និងសង្គមខ្មែរ** ភ្នំពេញ១៩៩៨ ទំព័រ ៧៦

www.budinst.gov.kh www.elibraryofcambodia.org

- ពីឆ្នាំ ១៨៦៣ ដល់ឆ្នាំ ១៩៥៤ **សម័យអាណានិគមបារាំង**
- ពីឆ្នាំ ១៩៥៥ ដល់ឆ្នាំ ១៩៧០ **សម័យសង្គមរាស្ត្រនិយម**
- ពីឆ្នាំ ១៩៧០ ដល់ឆ្នាំ ១៩៧៥ **សម័យរបបសាធារណរដ្ឋខ្មែរ**
- ពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ **សម័យរបបកម្ពុជាប្រជាធិបតេយ្យ**
- ពីឆ្នាំ ១៩៧៩ ដល់ឆ្នាំ ១៩៩៣ **សម័យរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា និងរដ្ឋកម្ពុជា**
- ពីឆ្នាំ ១៩៩៣ រហូតមកជារបបរាជានិយមដែលប្រទេសយើងមានឈ្មោះថា **ព្រះរាជាណាចក្រកម្ពុជា** ។

ចាប់ពីពេលនោះរហូតមកដល់សព្វថ្ងៃនេះ មានរយៈពេលជាង៩ស.វហើយ ដែលមានព្រះមហាក្សត្រសោយរាជ្យ៤៦ព្រះអង្គ។ ក្នុងរយៈកាលនេះ លើកលែងតែក្នុងរយៈពេលនៃ**សម័យរបបកម្ពុជាប្រជាធិបតេយ្យ** (១៩៧៥-១៩៧៩) របបទាំងអស់សុទ្ធតែគោរពព្រះពុទ្ធសាសនាហីនយានទាំងអស់។ ចំពោះព្រហ្មញ្ញសាសនា និងព្រះពុទ្ធសាសនាមហាយានដែលចុះសាបរលាបតាំងពីចុងសម័យអង្គរមកនោះ ក៏កាន់តែអស់ទៅៗរហូតដល់គ្មានតែម្តង។ ទីកន្លែងវត្តអារាមរបស់សាសនាទាំងពីរត្រូវបានព្រះពុទ្ធសាសនាហីនយានចូលកាន់កាប់ ហើយប្រែក្លាយទៅជាវត្តអារាមសំរាប់គោរពបូជារបស់ពុទ្ធសាសនិកថេរវាទវិញ។

ឧទាហរណ៍ : ដូចជា **វត្តអង្គសេរី វត្តអង្គ វត្តឈើទាលក្រើល វត្តតាំងស្វាយ វត្តតាំងគោក វត្តបាសាយ** ....។ល។ យើងគួរកត់ចំណាំថា វត្តអារាមដែលមានឈ្មោះថា **អង្គ តាំង ឈើទាល បា** ...។ល។ នៅខាងដើមជាវត្ត ដែលដើមឡើយជាវត្តខាងព្រហ្មញ្ញសាសនា។

នៅសម័យលង្វែកក៏ដូចជាក្នុងសម័យឧត្តុង្គដែរ ព្រះពុទ្ធសាសនាហីនយានបានរីកចំរើនយ៉ាងខ្លាំងក្លា ព្រមទាំងមានតួនាទីសំខាន់ក្នុងសង្គមកម្ពុជាយើង។ ជាពិសេសនៅសម័យឧត្តុង្គ ព្រះពុទ្ធសាសនាហីនយានត្រូវបានលើកតំកើង ដែលមានព្រះមហាក្សត្រខ្មែរគ្រប់ព្រះអង្គ ជាពុទ្ធសាសនូបត្ថម្ភយ៉ាងជ្រាលជ្រៅជាទីបំផុត។ ជាពិសេស ក្នុងរាជ្យ **ព្រះហរិរក្សរាមាធិបតីព្រះអង្គឌួង** (១៨៤០-១៨៥៩) ព្រះអង្គជាអ្នកធ្លាប់សិក្សារៀនសូត្រក្នុងសំណាក់ព្រះពុទ្ធសាសនា។ ព្រះអង្គសព្វព្រះរាជហឫទ័យឱ្យសាមណេរ ឧបាសក ឧបាសិកា យុវជនបានទៅសិក្សាវិជ្ជាគ្រប់បែបយ៉ាង មានអក្សរសាស្ត្រខ្មែរ កាព្យសាស្ត្រ និងទស្សនវិជ្ជាព្រះពុទ្ធសាសនា។ នៅក្នុងសម័យឧត្តុង្គ គ្រាន់តែនៅក្នុងក្រុងឧត្តុង្គមានវត្តអារាមដល់ទៅ ៥០០ វត្ត។

ក្នុងសម័យអាណានិគមនិយមបារាំង (១៨៦៣-១៩៥៤) ថ្វីត្បិតតែពួកបារាំងមានបំណងចង់លុបបំបាត់ចោលវប្បធម៌ អក្សរសាស្ត្រខ្មែរយ៉ាងណាក៏ដោយ ក៏ព្រះពុទ្ធសាសនាហីនយាននៅតែរីកចំរើន ព្រមទាំងមានតួនាទីរឹតតែខ្លាំងក្លាឡើងនៅក្នុងសង្គមជាតិ។ ព្រះមហាក្សត្រខ្មែរមានជាអាទិ ព្រះបាទ **នរោត្តម** ព្រះបាទ **ស៊ីសុវត្ថិ** ព្រះបាទ **ស៊ីសុវត្ថិមុនីវង្ស** សុទ្ធតែជាអ្នកគោរពព្រះពុទ្ធសាសនាយ៉ាងមុតមាំ។ ជាអាទិក្នុងរជ្ជកាលព្រះបាទ **នរោត្តម** (១៨៥៩-១៩០៤) ព្រះអង្គទ្រង់បានកសាង**ព្រះវិហារ ព្រះកែវមរកត** នៅខាងត្បូងជាប់ព្រះបរមរាជ

www.budinst.gov.kh www.elibraryofcambodia.org

វាំង ដើម្បីជាទីសក្ការៈបូជា និងឧទ្ទិសចំពោះព្រះពុទ្ធសាសនាហីនយាន។ ប៉ុន្តែ ក្នុងរជ្ជកាលរបស់ព្រះអង្គនេះ គេសង្កេត ឃើញមានការចូលមកដល់នូវព្រះពុទ្ធសាសនាហីនយានមួយប្រភេទទៀត គឺព្រះពុទ្ធសាសនាហីនយានគណៈធម្មយុត្តិនិកាយក្នុងប្រមាណឆ្នាំ ១៨៥៤។ ដូចនេះ ចាប់ពីពេលនោះមក ព្រះពុទ្ធសាសនាហីនយាននៅក្នុងប្រទេសយើងមានពីរនិកាយ គឺ **មហានិកាយ** និង **ធម្មយុត្តិកនិកាយ** ។ និកាយទាំងពីរនេះពុំមានទំនាស់រវាងគ្នានឹងគ្នាឡើយ។ តែផ្ទុយទៅវិញ និកាយទាំងពីរនេះបានក្លាយទៅជាកំលាំងមួយដ៏សំខាន់ ជះឥទ្ធិពលដល់ប្រជាពលរដ្ឋខ្មែរយើងឱ្យមានកំលាំងសាមគ្គីភាព ឯកភាពជាតិ និងការកសាងទឹកដីក្នុងរាជ្យព្រះមហាក្សត្រក្រោយៗទៀត ព្រោះប្រជាពលរដ្ឋម្នាក់ៗមាន សិទ្ធិ សេរីភាពក្នុងជំនឿរបស់ខ្លួន ដោយពុំមានការបង្ខិតបង្ខំ និងការប្រកាន់បក្សពួកឡើយ។ ចូលមកដល់រាជ្យព្រះបាទ **ស៊ីសុវត្ថិ** (១៩០៤-១៩២៧) ព្រះអង្គជាពុទ្ធសាសនិកមួយអង្គដ៏ឆ្នើម ដែលបានកសាង **រាជបណ្ណាល័យ មន្ទីរពុទ្ធសាសនបណ្ឌិត** និង **សាលាបាលីជាន់ខ្ពស់** ។ មកដល់រជ្ជកាលព្រះបាទ **ស៊ីសុវត្ថិមុនីវង្ស** (១៩២៧-១៩៤១) ព្រះអង្គទ្រង់សព្វព្រះរាជហឫទ័យចំពោះសង្ឃឱ្យមានសណ្តាប់ធ្នាប់ត្រឹមត្រូវទៅតាមព្រះត្រៃបិដក។ ព្រះអង្គជាពុទ្ធសាសនូបត្ថម្ភនៃឧត្តមសង្គីតិ (ឧត្តមសង្គាយនា) បង្កើតឱ្យមានក្រុមជំនុំផ្ទៀងផ្ទាត់ព្រះត្រៃបិដក ហើយប្រែពីបាលីមកភាសាជាតិ មានរយៈពេលពីឆ្នាំ ១៩២៩ ដល់ឆ្នាំ ១៩៣៩ ។ រយៈពេល១០ឆ្នាំបានបោះពុម្ពជាសៀវភៅ បន្តៗតាំងពីពេលនោះ រហូតមកដល់ឆ្នាំ១៩៦៩ ទើបចប់សព្វគ្រប់ ដែលមានសៀវភៅចំនួន ១១០ក្បាល។

មកដល់រជ្ជកាលព្រះបាទ **នរោត្តម សីហនុវរ្ម័ន** ក្នុងពេលដែលព្រះអង្គឡើងសោយរាជ្យលើកទី១ (១៩៤១-១៩៥៥) ព្រះអង្គបានបន្តប្រពៃណីរបស់ព្រះមហាក្សត្រមុនៗ។ ព្រះអង្គទ្រង់បានប្រោសព្រះរាជទានរដ្ឋធម្មនុញ្ញ ដល់ប្រជារាស្ត្ររបស់ព្រះអង្គ ដែលមានក្នុងរដ្ឋធម្មនុញ្ញ ត្រង់ប្រការ៨ដោយបញ្ជាក់ថា **ព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋ** ។ ត្រង់នេះបញ្ជាក់ថាឱ្យឃើញនូវព្រះរាជហឫទ័យយកព្រះទ័យទុកដាក់ចំពោះព្រះពុទ្ធសាសនាក្នុងឋានៈព្រះអង្គជាអគ្គសាសនូបត្ថម្ភមួយព្រះអង្គដ៏ឆ្នើម។ មិនតែប៉ុណ្ណោះ ព្រះអង្គទ្រង់បានចំណាយព្រះរាជទ្រព្យផ្ទាល់ដើម្បីកសាងវត្តអារាម ព្រះចេតិយ និងព្រះរាជកុសលផ្សេងៗ មានកសាងពុទ្ធិកវិទ្យាល័យជាដើម។ ហើយទ្រង់បានសាងផ្នួស ជាភិក្ខុក្នុងសំណាក់ព្រះពុទ្ធសាសនាអស់រយៈពេល៣ខែទៀត ដើម្បីបំពេញព្រះរាជករណីកិច្ចតាមព្រះរាជប្រវេណី ដែលព្រះរាជវង្សានុវង្សធ្លាប់បំពេញមកផង និងដើម្បីទ្រង់បានសិក្សាច្បាប់ព្រះពុទ្ធសាសនាឱ្យបានជ្រាបច្បាស់លាស់ផង ឱ្យបានសមជាព្រះរាជឋានៈរបស់ព្រះអង្គ ជាព្រះអគ្គពុទ្ធសាសនិក។

ក្រោយពេលសម្តេចព្រះបាទ **នរោត្តម សីហនុវរ្ម័ន** ព្រះអង្គទ្រង់ដាក់រាជ្យថ្វាយព្រះវរបិតា ព្រះនាមព្រះបាទ **ព្រះនរោត្តម សុរាម្រិត** (១៩៥៥) ព្រះអង្គកាន់តែយកព្រះហឫទ័យទុកដាក់ចំពោះព្រះពុទ្ធសាសនាកាន់តែខ្លាំងឡើងៗ។

ក្នុងរាជ្យព្រះបាទសម្តេច **ព្រះនរោត្តម សុរាម្រិត** (១៩៥៥) ព្រះអង្គទ្រង់បានយកព្រះហឫទ័យទុកដាក់ចំពោះព្រះពុទ្ធសាសនាដូចព្រះមហាក្សត្រមុនៗដែរ។ ព្រះអង្គជាអគ្គពុទ្ធសាសនូបត្ថម្ភគ្រប់វិស័យព្រះពុទ្ធសាសនា

www.budinst.gov.kh www.elibraryofcambodia.org

ធ្វើឱ្យសាសនានេះមានការរីកចំរើនក្រៃលែងដូចក្នុងរជ្ជកាលព្រះបាទ**នរោត្តម សីហនុវរ្ម័ន** ជាព្រះរាជបុត្ររបស់ព្រះអង្គ។ ព្រះអង្គទ្រង់បានរៀបចំពិធីបុណ្យពាក់កណ្ដាលសាសនា (ពុទ្ធសករាជ២៥០០) និងបុណ្យសម្ពោធ **ព្រះសក្យមុនីចេតិយ** បញ្ចុះ**ព្រះបរមសារីរិកធាតុ** នៅមុខ **ស្ថានីយ៍រថភ្លើងយាន**រាជធានីភ្នំពេញ។

ក្រោយពេលសម្តេច **ព្រះនរោត្តម សុរាម្រិត** ទ្រង់សោយទិវង្គតទៅ ព្រះមហាក្សត្រិយានី **ស៊ីសុវត្ថិ កុសមៈនារីរតន៍** ជាព្រះរាជមាតានៃព្រះបាទ **នរោត្តម សីហនុវរ្ម័ន** ក្នុងនាមជាព្រះមហាក្សត្រ ព្រះអង្គមិនខុសពីមហាក្សត្រមុនៗ ព្រះអង្គជាព្រះអគ្គសាសនូបត្ថម្ភឡើកតំកើងព្រះពុទ្ធសាសនាមិនឱ្យសាបរលាបឡើយ។ ព្រះអង្គទ្រង់សព្វព្រះរាជហឫទ័យ ចាត់តាំងឱ្យរះរើសង់ជាថ្មីនៅ **ព្រះវិហារ ព្រះកែវមរកត** និង **វែទពន្ធជំពិញ ព្រះវិហារ** ដែលចាស់ហើយនោះឡើងវិញ។ ព្រះអង្គទ្រង់បានឧបត្ថម្ភទំនុកបំរុង **មន្ទីរពេទ្យព្រះកុសមៈ ពេទ្យព្រះសង្ឃ** សំរាប់ព្យាបាលអាពាធរបស់ព្រះសង្ឃ។ តាមស្ថិតិឆ្នាំ ១៩៦១ ក្នុងប្រទេសកម្ពុជាយើងទាំងមូលមានវត្តអារាមចំនួន២៥៨០វត្ត។ ចំណែកព្រះសង្ឃដែលអាស្រ័យក្នុងវត្តនេះមានចំនួន ៥៣៥០៩អង្គ។ តែបើគិតក្នុងឆ្នាំ ១៩៦៩ វត្តអារាមមានចំនួន ៣៣៦៩វត្ត ពីវត្តគណៈមហានិកាយមាន ៣២៣០វត្ត និងគណៈធម្មយុត្តិនិកាយមានចំនួន ១៣៩វត្ត។ ចំណែកព្រះសង្ឃមានចំនួន ៦៥០៦២អង្គ គឺខាងមហានិកាយ ៦២៦៧៨ និងធម្មយុត្តិ ២៣៨៤ អង្គ។ នេះបញ្ជាក់ឱ្យឃើញថា នៅសម័យនេះព្រះពុទ្ធសាសនាមានភាពរុងរឿងណាស់។

**ជ. សម័យសាធារណរដ្ឋខ្មែរ : ១៩៧០-១៩៧៥** ([២៥])

ថ្ងៃទី១៨ មិនា ឆ្នាំ១៩៧០ ជាថ្ងៃរដ្ឋប្រហារខុសច្បាប់របស់លោក **លន់ នល់** ទំលាក់ **សម្តេចព្រះនរោត្តម សីហនុ** ដែលជាប្រមុខរដ្ឋកម្ពុជា។ កម្ពុជាបានចូលដល់របបថ្មីមួយគឺ របបសាធារណរដ្ឋខ្មែរក្រោមខ្សែញាក់នៃចក្រពត្តិអាមេរិក ។

ក្នុងសម័យនេះ ព្រះពុទ្ធសាសនាដែលមានពីមុនមកមិនសាបសូន្យទេ តែក៏មិនរីកចំរើនដែរ។ វត្តអារាមដែលជាទីសក្ការៈរបស់ប្រជាពលរដ្ឋខ្មែរ ត្រូវកងទ័ពរបស់លោក **លន់ នល់** ចូលបោះទីតាំងជាច្រើនកន្លែង។ ព្រះវិហារ រូបបដិមា កុដិ ចេតិយ គម្ពីរសាសនាទាំងឡាយ ត្រូវទទួលការបំផ្លិចបំផ្លាញក្រោមទំងន់គ្រាប់ផ្លោង គ្រាប់ទំលាក់ពីយន្តហោះ ពោលគឺគ្មានវត្តណាមួយ ដែលនៅស្រុកស្រែគេចផុតពីគ្រាប់កាំភ្លើងគ្រប់ប្រភេទបានឡើយ។ ចំពោះព្រះសង្ឃក៏ទទួលនូវការគំរាមកំហែងជាញឹកញាយដែរ ពីសំណាក់កងទ័ពព្រៃ និងកងទ័ពស្រុកដែលម្ខាងៗមានបំណងប្រមូលយកទៅជាកងកំលាំងរបស់ខ្លួន។

**ឈ. របបកម្ពុជាប្រជាធិបតេយ្យ : ១៩៧៥-១៩៧៩**

ក្រោយឆ្នាំ១៩៧៥ ប្រទេសកម្ពុជាបានឈានចូលទៅក្នុងសម័យមួយដ៏ខ្មៅងងឹតអន្ធការ ខ្មោចផ្សារឈើចាប់គ្មានពេលល្ហែ ឃើញតែភ្នំឆ្អឹង ស្ទឹងឈាម សមុទ្រទឹកភ្នែកដែលតំរូវឱ្យប្រជារាស្ត្រកម្ពុជាទូទាំងប្រទេសត្រូវហែលឆ្លង

---

[២៥] លោកបណ្ឌិត ធ សោ **ព្រះពុទ្ធសាសនា និងសង្គមខ្មែរ** ភ្នំពេញ១៩៩៤ ទំព័រ ៨០

www.budinst.gov.kh www.elibraryofcambodia.org

កាត់។ សមុទ្រដ៏ធំធេងនេះ បណ្ដាលឱ្យប្រជារាស្ត្រយើងត្រូវស្លាប់យ៉ាងវេទនាអស់ជាងបីលាននាក់ ហើយអ្នកដែលនៅសល់ពីស្លាប់ស្ទើរតែពុំមែនជាមនុស្ស ឃើញតែរូបរាងកាយស្គមស្គាំង ស្បែកជ្រីវជ្រួញ... ។ល។ ទាំងនោះ នាំមកនូវក្ដីឈឺចាប់ ខ្លោចផ្សារ និរាសព្រាត់ប្រាស់ ជីវិតគ្មានលំនឹងនៅសល់តែបាតដៃទទេ។

នៅលើវិស័យសាសនា ពួកគេមានបំណងលុបបំបាត់សាសនាចោលតែម្ដង មិនថាសាសនាណាជាសាសនាណាទេ។ ពួកគេបានជន្លៀសព្រះសង្ឃចេញពីវត្តអារាម ធ្វើគតព្រះសង្ឃ ធ្វើទារុណកម្មព្រះសង្ឃ គ្មះតេះដៀលដោយប្រការផ្សេងៗ ប្រមាថមើលងាយដល់ព្រះសង្ឃ និងពុទ្ធសាសនិកខ្មែរយើង។ ពួកគេបានប្រែក្លាយទីកន្លែង ដែលជាទីសក្ការៈបូជារបស់ព្រះសង្ឃទៅជាទីវាលពិឃាត មន្ទីរឃុំឃាំង ...។ល។ ពេលខ្លះទៀត គេបានវាយបំបាក់ចោលព្រះពុទ្ធបដិមា ព្រះវិហារ កំទេចគ្រឿងសក្ការៈបូជាទាំងឡាយ ដើម្បីប្រែក្លាយទីនោះធ្វើជាក្រោលគោ ឬកន្លែងចិញ្ចឹមសត្វជាដើម។

ដូច្នេះយើងឃើញថា ព្រះពុទ្ធសាសនាហ៊ីនយាន ដែលប្រជារាស្ត្រយើងធ្លាប់គោរពបូជាជាយូរយារណាស់មក ហើយនោះត្រូវធ្លាក់ចុះយ៉ាងខ្លាំងស្ទើរតែរលត់បាត់ឈ្មោះបាត់ស្រមោល។

**ញ់- ព្រះពុទ្ធសាសនាក្រោយឆ្នាំ ១៩៧៩ មកដល់សព្វថ្ងៃ**

ក្រោយថ្ងៃ៧ មករា ១៩៧៩ មកព្រះពុទ្ធសាសនាត្រូវបានរស់ឡើងវិញជាសន្សឹមៗ ត្រឹមត្រូវតាមច្បាប់រដ្ឋនៃមាត្រារដ្ឋធម្មនុញ្ញថែមទៀតផង។

បន្ទាប់ពីមានការបោះឆ្នោតដោយសេរី និងត្រឹមត្រូវនៅថ្ងៃ ២៣ ឧសភា ១៩៩៣ សង្គមកម្ពុជាយើងបានឈានដល់គំណោក់កាលមួយថ្មី ដោយមានការឯកភាពរវាងគណបក្សធំ១ជាប់ឆ្នោតពីរគឺ **គណបក្សហ្វ៊ុនស៊ិនប៉ិច** និង **គណបក្សប្រជាជនកម្ពុជា** បានកសាងនូវរបបមួយដែលមានលក្ខណៈត្រឹមត្រូវ ស្របច្បាប់តាមបំណងប្រាថ្នារបស់ប្រជារាស្ត្រខ្មែរ គឺរបបរាជានិយម អាស្រ័យរដ្ឋធម្មនុញ្ញ បែបប្រជាធិបតេយ្យសេរីពហុបក្ស ក្រោមមាគ៌ាដឹកនាំរបស់ **សម្ដេចឪ** យកតាមពន្លឺ **សង្គមរាស្ត្រនិយម** ដែលព្រះអង្គបានដឹកនាំរួចមកហើយ ហើយមានការរីកចំរើនឡើងគ្រប់វិស័យរួមទាំងព្រះពុទ្ធសាសនានេះផងដែរ ដោយព្រះអង្គជាអ្នកគោរព និងប្រកាន់យកលទ្ធិព្រះពុទ្ធសាសនាបែបហ៊ីនយានយ៉ាងខ្ជាប់ខ្ជួនតាំងពីមុនមក។

ព្រះអង្គបានប្រកាសជាលាយលក្ខណ៍អក្សរ ឱ្យបញ្ចូលព្រះពុទ្ធសាសនា ជាសាសនារបស់រដ្ឋនៅក្នុងរដ្ឋធម្មនុញ្ញខ្មែរយើងបច្ចុប្បន្ន។ លើសពីមុនទៅទៀតនៅក្នុងចរចនានៃព្រះរាជាណាចក្រកម្ពុជាយើង ក៏ឃើញមានសាសនានៅក្នុងនោះដែរគឺ **ជាតិ សាសនា ព្រះមហាក្សត្រ** ។

តាមប្រសាសន៍លោក **អ៊ុង សំអឹន** អនុប្រធានមន្ទីរធម្មការ និងសាសនារាជធានី កាលពីល្ងាចថ្ងៃអាទិត្យទី២១ ខែកញ្ញា ឆ្នាំ១៩៩៧ នៅតាមកញ្ចក់ទូរទស្សន៍រាជធានីភ្នំពេញប៉ុស្តិ៍លេខ៣បញ្ជាក់ច្បាស់ថា ៖

**ក- មន្ទីរធម្មការក្រុងមានការិយាល័យ៤**

១- ការិយាល័យរដ្ឋបាលទទួលបន្ទុករៀបលិខិតចេញចូល ...។ល។

www.budinst.gov.kh www.elibraryofcambodia.org

២- ការិយាល័យធម្មការនិងកិច្ចការសាសនា

៣- ការិយាល័យសាសនសិក្សា

៤- ការិយាល័យធម្មការសាសនខ័ណ្ឌ

**១. វត្ត សាលា ព្រះសង្ឃ ដូនជី សិស្ស និស្សិត**

១- គណៈមហានិកាយ

- វត្ត : ៨៣. ភិក្ខុសាមណេរ : ៣២១៩អង្គ. ដូនជី : ៨៧៨នាក់. សិស្សនិស្សិត : ១៥៩៦នាក់។
- សាលាពុទ្ធិកសិក្សា : ១៦. សាលាធម្មវិន័យ : ៣
- ពុទ្ធិកវិទ្យាល័យ១ និងពុទ្ធិកវិទ្យាល័យ២ត្រូវបានក្រសួងធម្មការគ្រប់គ្រងផ្ទាល់

២- គណៈធម្មយុត្តិកៈ

វត្ត :២. ព្រះសង្ឃ : ៧៥អង្គ. សិស្សនិស្សិត : ១១៥នាក់. ដូនជី : ៧នាក់. សាលាធម្មវិន័យ : ១ ។

ជាងនេះទៅទៀតព្រះពុទ្ធសាសនានៅមានកិច្ចការផ្សេងៗទៀតសំរាប់សង្គមខ្មែរ ។

www.budinst.gov.kh www.elibraryofcambodia.org

# ផ្នែកទី២

## ការរីកចំរើននៃព្រះពុទ្ធសាសនាក្នុងជីវិតខ្មែរ

(វិស័យអប់រំពុទ្ធសាសនានៅកម្ពុជា ព្រះពុទ្ធសាសនា និងច្បាប់រដ្ឋធម្មនុញ្ញ ប្រវត្តិពុទ្ធសាសនាហីនយាន ប្រវត្តិព្រះសក្យមុនីចេតិយ ប្រវត្តិព្រះវិហារព្រះកែវមរកត ប្រវត្តិវត្តបុទុមវតីរាជវរារាម ប្រវត្តិវត្តឧណ្ណាលោម )

# ជំពូកទី១

## វិស័យអប់រំព្រះពុទ្ធសាសនានៅកម្ពុជា

### ១. គណៈមហានិកាយ

គណៈមហានិកាយនេះ គឺចូលមកប្រតិស្ឋាននៅប្រទេសកម្ពុជាយូរណាស់មកហើយ តាំងពីស.វទី១៣មកម្ល៉េះ។ ប្រទេស**ភូមា** និង **មន** បានទទួលពួកភិក្ខុពីស.វទី៤។ ប្រទេសទាំងពីរនេះពីដើមកាន់លទ្ធិមហាយានរួចបានបកដល់ស.វទី១១ ប្រែទៅកាន់ព្រះពុទ្ធសាសនាហីនយានវិញ។

ប្រទេស**ភូមា** បានទទួលព្រះត្រៃបិដកបាលីតាំងពីស.វទី៦ ហើយបានប្តូរមកព្រះរាជាណាចក្រ **មន** ( **នគរសអុំអែន** ) **ទ្វារវតី**។

នៅស.វទី១២ ប្រទេស**សៀម** ក៏បានទទួលឥទ្ធិពលហីនយានពីប្រទេសភូមាតមក លទ្ធិហីនយាននៃប្រទេសសៀម បានផ្សាយចូលមកប្រទេសកម្ពុជា ( [26] )។

### ២. គណៈធម្មយុត្តិ

គណៈធម្មយុត្តិកើតឡើងដោយ **ព្រះសុគន្ធមានបុណ្យ** ឬ **ព្រះសុគន្ធាធិបតី** ព្រះនាម **ប៉ាន** លោកបាននិមន្តទៅសិក្សារៀនសូត្រធម៌ និងវិន័យខាងព្រះពុទ្ធសាសនានៅទីក្រុង**បាងកក** ( ប្រទេសថៃ ) លោកបាននាំនិកាយនេះចូលមកប្រតិស្ឋានក្នុងប្រទេសកម្ពុជាពីគ.ស ១៨៦៤ ( [27] )។ ក្រោយពេលមួយឆ្នាំនៃអំណាចគ្រប់គ្រងប្រទេសបារាំង ( ១១ សីហា ១៨៦៣ )។

#### ក. កំណើតធម្មយុត្តិនៅប្រទេសថៃ

អនុជរបស់ព្រះបាទ **រាមាទី៣** ឬ ព្រះ **Nang Klao** ស្តេច **Mongkut** ក្នុងរយៈពេលដែលសាងព្រះផ្នួស២៧ព្រះវស្សា ព្រះអង្គឈ្លាសវៃក្នុងការពិចារណារកខុសត្រូវក្នុងគម្ពីរព្រះពុទ្ធសាសនា។ ព្រះអង្គបានវែកញែកការយល់ដឹងក្នុងគម្ពីរព្រះត្រៃបិដក ( **Tripritaka** )។ ទង្វើរបស់ព្រះពុទ្ធបានអប់រំមនុស្សឱ្យយល់ដឹងច្រើន ហើយក៏ក្លាយទៅ

---

[26] លោក វ៉ាយ ប៊ុក **ព្រះពុទ្ធសាសនានៃកម្ពុជា** ភ្នំពេញ១៩៥៧ ទំព័រ ៣

[27] លោក វ៉ាយ ប៊ុក **ព្រះពុទ្ធសាសនានៃកម្ពុជា** ភ្នំពេញ១៩៥៧ ទំព័រ ៧

www.budinst.gov.kh www.elibraryofcambodia.org

ជាក្រុមដែលប្លែកពីវិន័យរបស់ព្រះសង្ឃក្រុមផ្សេងនោះ ទើបហៅថា ក្រុមធម្មយុត្តិ ព.ស ២៣៦៧. ធម្មយុត្តិ ( **Dhammayut** ) ខុសគ្នាពីក្រុមមហានិកាយ ( **Mahanikaya** ) ( [២៨] ) ។

**ខ. កំណើតធម្មយុត្តិនៅប្រទេសកម្ពុជា**

ព្រះរាជប្រវត្តិនៃសម្តេច **ព្រះសុគន្ធា** សង្ឃរាជាធិបតី លោកប្រសូត្រនៅព.ស ២៣៦៥ នៅឃុំ **ខ្មែរគង្គារស្តេច** ខេត្ត **បាត់ដំបង** ។ មាតាបិតាមានស្រុកកំណើតនៅភូមិ ស្មោង ស្រុក ស្មោង ខេត្ត កំពង់ធំ លោករស់នៅ បាត់ដំបង ដោយចលនា **គេខាំខែន** ។ ពេលសម្តេចព្រះសង្ឃប៉ានមានព្រះជន្មបាន១២វស្សា ព្រះអង្គបួសជាសាមណេរនៅវត្តពោធិ ឃុំសង្កែ ខេត្តបាត់ដំបង។ បួសបានមួយវស្សាទើបព្រះអង្គចូលស្នាក់នៅវត្ត **សះកេត** ក្រុង **ទេព** សិក្សាគម្ពីរព្រះត្រៃបិដក ពីព្រះជន្ម ១៣ លុះដល់ព្រះជន្ម ២១វស្សា។ បួសតាមលទ្ធិមហានិកាយបាន ៤ វស្សាទ្រង់ព្រះបរិយត្តិ និងព្រះកម្មដ្ឋានបានចេះចប់ចំណេះ អាចារ្យបានរៀនខាងផ្លូវសូត្រសូត្របទបមហានិកាយគ្រប់យ៉ាង។ ក្រោយមកសុំក្រុមម៉ឺន **គុចឱុន** សម្តេចព្រះចមក្លាវទៅសិក្សាសិក្ខាវិន័យក្នុងសំណាក់ ចៅឃុន ព្រះញាណរក្ខិត ចៅវត្តបរមនិវាស ក៏បានឃើញច្បាស់ថា វិន័យធម្មយុត្តិកៈនេះប្រព្រឹត្តបរិសុទ្ធត្រឹមត្រូវតាមផ្លូវធម្មវិន័យពិត។ ព.ស ២៣៩២ សម្តេចប៉ាន បានចូលក្នុងសំណាក់សម្តេចព្រះ**ចម-ក្លាវ**។ សម្តេច ចម-ក្លាវ ជាព្រះឧបជ្ឈាយ៍ ចៅឃុនព្រះញាណរក្ខិត និងព្រះអមរាភិរក្ខិត "កើត" ជាឧបសម្បទាចារ្យ។ ញត្តិ ចតុត្ថកម្មត្រឹមត្រូវតាមវិធីជាធម្មយុត្តិកៈ ទទួលនាមក្នុងសាសនាជាបញ្ញា **សីលោ** ហើយចេញទៅគង់វត្តបរមនិវាសវិញ។ បញ្ញា **សីលោប៉ាន** បានសុំស្នាក់នៅសំណាក់ចៅឃុន ព្រះញាណរក្ខិតជាអាចារ្យ។ សម្តេច **ប៉ាន** បានសិក្សាយ៉ាងត្រឹមត្រូវបំផុតនូវធម៌វិន័យ មានព្រះវិន័យ ៥ គម្ពីរព្រះសូត្រ ៥ គម្ពីរ ព្រះអភិធម្ម ៧ គម្ពីរ។

ពេលចេញវស្សា សម្តេចប៉ានបាននិមន្តទៅប្រែគម្ពីរ នៅវត្តកែវហ្វូង ក្នុងក្រុងទេពបាន ៤ ប្រយោគ ទើបបានឡើងសមណសក្តិ ជាមហាទ្រង់គ្រឿង មានបៀវត្ស ៤៨ បានក្នុងមួយឆ្នាំ។

លុះ ព.ស ២៣៩៧ ឆ្នាំខាល ទើបព្រះបាទសម្តេចព្រះហរិរក្សរាមាឥស្សរាធិបតី ព្រះចៅប្រទេសកម្ពុជា ព្រះអង្គឱ្យគេទៅសុំវិន័យធម្មយុត្តិកៈមកឧទ្ធានទៅកម្ពុជា ( [២៩] ) ។

ព្រះ**ចម-ក្លាវ** ជ្រាបហើយ ទើបយល់ព្រមហើយថ្វាយព្រះគម្ពីរ ៨០ ក្បាលហើយអារាធនាចៅឃុនព្រះអមរាភិរក្ខិតឱ្យជូនព្រះមហាប៉ាន និង ព្រះសង្ឃ ៦ អង្គមកតាំងវិន័យធម្មយុត្តិកៈក្នុងក្រុងឧដុង្គមានជ័យ ។

សម្តេចព្រះសុគន្ធាសង្ឃរាជាធិបតី បានចំលងយករតនកថា និងបុព្វសិក្ខាសង្ខេបរបស់ចៅឃុនអមរាភិរក្ខិតជាអក្សរសៀម រៀនទាំងអក្សរបុរាណចេះចាំស្ទាត់ទាំងគតិលោក គតិធម៌ ។ សម្តេចប៉ាន បាននិមន្តពីបាងកកតាមផ្លូវកំពត ព្រមទាំងព្រះសង្ឃ ៦អង្គមានព្រះ ពោធិវង្សច័ន្ទទ៍ជាដើម ឧបាសក ៤នាក់ មានព្រះទិព្វអក្សរមៈផ្លាស់ជាដើម ។

---

[២៨] Montri Umanijani BUDDHISM IN THAI LIVE Bangkok, Thai, 1981 page 12

[២៩] ព្រះទិព្វអក្សរមៈ ផ្លាស់ : ធម្មយុត្តិ ៖ តាមព្រះរាជប្រវត្តិមហាសាសនវង្ស ៖ទំព័រ ព.ភ.ម.ឍ

ព្រះបាទសម្ដេច ព្រះហរិរក្សរាមាឥស្សរាធិបតី ព្រះអង្គសប្បាយព្រះទ័យណាស់ ហើយត្រាស់ឱ្យគង់នៅវត្តសាលាគួហើយថ្វាយបច្ច័យឧបត្ថម្ភជានិច្ចដល់សម្ដេចព្រះសិរីលោចន៍ជាធិបតី។ ព្រះសុគន្ធាសង្ឃរាជាធិបតី ទ្រង់គង់ជាគណាចារ្យនៃធម្មយុត្តិវង្សប្រដៅសាសនាឱ្យប្រទព្រឹត្តទៅតឹងតែងក្នុងធម្មវិន័យជានិច្ច។ ក្នុងវស្សាជាបឋមបានឡើងសមណសក្តិជាព្រះអរិយវង្ស។ លុះគំរប់ពីរជាព្រះវិមលធម្ម គំរប់បីជាព្រះមហាវិមលធម្ម គំរប់បួនបានអភិសេកជាស្ដេចសង្ឃ។

សម្ដេចព្រះសុគន្ធាសង្ឃរាជាធិបតី ព្រះអង្គជាឧបជ្ឈាយ៍ដំបូងក្នុងវិន័យវង្សធម្មយុត្តិកៈនៅក្នុងកម្ពុជា។ ព្រះអង្គមានប្រាជ្ញាឈ្លាសវៃទាំងគតិលោក គតិធម៌ ចេះភាសាសំស្ក្រឹត មគធៈ សៀម ឡាវ ភូមា មន លង្កា ខេមរបុរាណបានរៀបរៀងប្រែច្រើនសំរាប់អ្នកសិក្សា។ លុះឆ្នាំឆ្លូវ ចល្លសករាជ១២២៧ ព្រះបាទសម្ដេចព្រះនរោត្តម បរមទេវាវតារ ព្រះចៅកម្ពុជរដ្ឋ ស្ដេចមកតាំងក្រុងភ្នំពេញ ហើយបានសាងវត្តបុទុមវតីរាជវរារាម មានមហាសីមាទំហំ១៦០ម៉ែត្រ បណ្ដោយ២០០ម៉ែត្រ ព្រះពោធិវង្សគង់នៅវត្តស្វាយពពែ។ កិច្ចការរាជការស្ដេចប៉ាន បាននិមន្តទៅក្រុងទេពជាមួយឧកញ៉ា ប្រសើរសូរ្យវង្ស ហើយអញ្ជើញស្ដេចព្រះអង្គ ឃៃ ព្រះអង្គយាងមកក្រុងភ្នំពេញ។ ស្ដេចប៉ានបានពន្យល់ភាសាខេមរបុរាណដល់លោក អេម៉ូទីញ៉េរ ( លោកអេម៉ូញ៉េបានកត់ត្រាបោះពុម្ពនៅទីក្រុងប៉ារីសរហូតសព្វថ្ងៃ ) ។ ហើយព្រះអង្គបានសូមព្រះរាជអនុញ្ញាត្តិឱ្យព្រះសិរីកជេនធម្មចាប និងព្រះសង្ឃ៤អង្គនាំសក្ការៈទៅផ្សៀងសាសនាឯលង្កាទ្វីប ព្រះសុភូតិមហាថេរ រាមញ្ញវង្ស បានឱ្យព្រះរតនសារត្ថេរសង្ឃលង្កាជូនសក្ការៈវិញ គឺព្រះបរមសារីរិកធាតុមួយព្រះអង្គ ព្រះអរហន្តមួយព្រះអង្គ កូនពោធិព្រឹក្សមួយដើម ទ្រង់បានដាំនៅមុខវត្តបុទុមវតីនៅថ្ងៃអង្គារ ១០រោច ខែអាសាធ ឆ្នាំកុរ ព.ស២៤៣០ និងគ.ស ១៨៨៧។ ព្រះសេលោប៉ាន កំពុងប្រារព្ធឱ្យសាងចេតិយធំមួយ ពេលនោះព្រះអង្គលើកសៀតព្រះឧទរ ហើយសោយទីវង្គតនៅថ្ងៃសៅរ៍ ៤រោច ខែអាសាធ ឆ្នាំម្សាញ់ ព.ស២៤៣៦ គ.ស១៨៩៣ រវាងជន្មាយុ៦៨វស្សា ទ្រង់ព្រះផ្នួសបាន៤៨វស្សា។ ឯចេតិយធំនោះ ត្រូវបានសម្ដេចមង្គលទេពាចារ្យ អៀម ជាសិស្សផ្ទាល់ឋានន្តរសក្តិជាសម្ដេចសង្ឃនាយកទី២ គ្រប់គ្រងបន្តនៅវត្តបុទុមវតី។ សម្ដេច អៀមសាងសង់សក្សមុនីចេតិយ ហើយបញ្ចុះព្រះបរមសារីរិកធាតុ១ ព្រះអរហន្ត១និងព្រះធាតុសម្ដេចព្រះគន្ធាសង្ឃរាជាធិបតីនៅឯថ្ងៃពុធ ១រោច ខែភទ្របទ ព.ស២៤៥២ ត្រូវនឹងថ្ងៃទី ៨ ខែឧសភា ឆ្នាំ១៩០៩។

នេះជាជីវិតខ្មែរ ពោរពេញទៅដោយការងារពុទ្ធសាសនា ដែលជនជាតិខ្មែរបានគោរពស្រលាញ់ពេញចិត្តពេញថ្លើម ជាក់ស្ដែងតាំងពីសម័យនគរភ្នំមកម្ល៉េះ។ ប៉ុន្តែ ហេតុដែលខ្មែរទាញប្រយោជន៍ពីព្រះពុទ្ធសាសនាមកបំរើជាតិមិនបានត្រឹមត្រូវតាមដំបូន្មានរបស់ព្រះពុទ្ធនោះ ព្រោះខ្មែរបានបាត់ស្មារតីច្រើនណាស់ ខ្មែរជ្រុះគុណធម៌ ជ្រុះសុខភាព និងសមត្ថភាពច្រើនណាស់។

សម័យសង្គមរាស្ត្រនិយមគ.ស១៩៥៥ ព្រះរាជាណាចក្រកម្ពុជាបានបង្កើតពុទ្ធិកៈវិទ្យាល័យព្រះសីហនុរាជ។ ដំណោលគ្នានេះដែរ មានកើត ទង់ ត្រា ទស្សនាវដ្ដីនៃព្រះពុទ្ធសាសនា។

www.budinst.gov.kh www.elibraryofcambodia.org

- ទង់ពុទ្ធសាសនា ជាទង់មាន៦ពណ៌ តំរូវតាមឆព្វណ្ណរង្សីរបស់ព្រះសម្មាសម្ពុទ្ធទុកជាមូលដ្ឋានហើយសព្វថ្ងៃ ពុទ្ធសាសនិកពិភពលោកបានទទួលស្គាល់ប្រើប្រាស់ក្នុងផ្ទៃអន្តរជាតិ ហើយខ្មែរហៅថា **ទង់សាសនា** ។
- ត្រា : ត្រាសាទិស គឺជាត្រាប្រចាំអង្គការរបស់ព្រះពុទ្ធសាសនា ជាធម្មចក្រមាន៨កាំ តំណាងអរិយមគ្គមាន៨អង្គ ។
- ទស្សនាវដ្តីពន្លឺកងចក្រ : មានប្រជុំសង្ឃមហាសន្និបាតរាល់ឆ្នាំ... ដើម្បីដឹងពត៌មាន និងផ្តល់ពត៌មានពីក្រុងដល់ខេត្ត ស្រុក ក្រោមអធិបតីសម្តេចសង្ឃរាជ និងការរីចំរើនអន់ថយ ឬឧបសគ្គយ៉ាងណាខ្លះ ( [៣០] ) ។

ចំណុចទាំងអស់ខាងលើនេះ គឺធាតុនៃវប្បធម៌ខ្មែរ ។ ដោយសារ ព្រះពុទ្ធសាសនាមានលក្ខណៈច្រើន ទាក់ទងដល់វប្បធម៌ជាតិ ដល់ចរិតលក្ខណៈរបស់ជាតិទើបទីវត្តអារាមមានតួនាទីមួយទៀត ជាតំណាងអត្តសញ្ញាណជាតិ និងជាព្រលឹងនៃវប្បធម៌ជាតិ ។ មានវត្តអារាមនៅកន្លែងណា បញ្ជាក់ថានៅកន្លែងនោះមានមនុស្សខ្មែរធ្លាប់រស់នៅ ។

នៅសម័យមហានគរយើងមានប្រាសាទបុរាណ មានសិលាចារឹក ដែលជាភស្តុតាងបញ្ជាក់ថា ប្រជាជនខ្មែរធ្លាប់រស់នៅទីណាខ្លះ ក្នុងឧបទ្វីបអាស៊ីអាគ្នេយ៍នេះ ។ ឯសម័យកណ្តាល វត្តអារាមក៏មានបញ្ជាក់បន្ថែមទៀត លើប្រាសាទបុរាណទាំងនោះថែមទៀត ។

ព្រះពុទ្ធសាសនា ព្រះសង្ឃ វត្តអារាម ជារបស់ប្រជាជនខ្មែរកសាងដោយប្រជារាស្ត្រខ្លួន និងដើម្បីបំរើផលប្រយោជន៍របស់ខ្លួន ។ ដូច្នេះ មានតែប្រជារាស្ត្រខ្លួនឯងទេ ដែលជាអ្នកកំណត់ជោគវាសនារបស់ជាតិខ្លួន ។

ពិសេសទៅទៀត ពុទ្ធសាសនិកជនទាំងឡាយ គួរត្រូវយកចិត្តទុកដាក់ចំពោះអ្នកក្រីក្រ និងអ្នកទន់ខ្សោយទាំងខាងជីវភាព ទាំងខាងស្មារតីសមស្របសំរាប់ទៅតាមគោលធម៌ព្រះពុទ្ធសាសនា និងស្របតាមតថភាពបច្ចុប្បន្ន ។

[៣០] សម្តេចសង្ឃរាជ ជួន ណាត **ទស្សនាវដ្តីពុទ្ធចក្រ** ភ្នំពេញ លេខ២៩/១៩៦៨

www.budinst.gov.kh www.elibraryofcambodia.org

# ងារនៃមន្ត្រីសង្ឃ

នៅក្នុងនិកាយនីមួយៗ ក្រុមនីមួយៗនៃរាជាគណៈ មានចំនួនមន្ត្រីសង្ឃជាកំណត់ ហើយមានមុខងារផ្សេងៗគ្នា ប៉ុន្តែមានឋានៈស្មើរគ្នាទៅវិញទៅមក ។

ក្រុមដែលខ្ពស់ជាងគេ ពោលគឺក្រុមមួយ (ហៅថា ថ្នាក់ឯក) មានសមាជិក៣រូប សំរាប់គណៈមហានិកាយ និងមានតែសមាជិក២រូបសំរាប់គណៈធម្មយុត្តិ ។

ងាររបស់គណៈទាំងពីររៀងៗខ្លួន មានដូចតទៅ:

**មហានិកាយ**

១.ព្រះធម្មលិខិត

២.ព្រះពោធិវង្ស

៣.ព្រះវន័រ័ត្ន

**ធម្មយុត្តិ**

២. ព្រះមង្គលទេពាចារ្យ

២.ព្រះពុទ្ធាចារ្យ

រាជានៃក្រុមទាំងពីរ (ហៅថា ថ្នាក់ទោ) មានចំនួនសមាជិកប្រាំមួយរូបសំរាបគណៈមហានិកាយ និងសមាជិកបីរូបសំរាប់គណៈធម្មយុត្តិ :

**មហានិកាយ**

១.ព្រះមហាវិមលធម្ម

២.ព្រះពុទ្ធឃោសាចារ្យ

៣.ព្រះធម្មឃោសាចារ្យ

៤.ព្រះឃោសធម្ម

៥.ព្រះសាសនមុនី

៦.ព្រះមុនីកុសល

**ធម្មយុត្តិ**

១.ព្រះមហាព្រហ្មមុនី

២.ព្រះធម្មឧត្តម

៣.ព្រះអរិយកស្សប

រាជាគណៈនៃក្រុមទាំងបី (ហៅថា ថ្នាក់ត្រី) មានចំនួនសមាជិកប្រាំមួយរូប សំរាប់មហានិកាយ និង មានសមាជិកបួនរូបសំរាប់ធម្មយុត្តិ :

**មហានិកាយ**

១.ព្រះសិរីសម្មតិវង្ស

២.ព្រះពុទ្ធវង្ស

៣.ព្រះសាក្យវង្ស

៤.ព្រះឧបាលិវង្ស

៥.ព្រះញាណវង្ស (ថ្មី)

៦.ព្រះសុមេធវង្ស (ថ្មី)

**ធម្មយុត្តិ**

១.ព្រះអរិយវង្ស

២.ព្រះញាណវង្ស

៣.ព្រះធម្មតិវង្ស

៤.ព្រះមហាវីរវង្សាចារ្យ

www.budinst.gov.kh www.elibraryofcambodia.org

TABLE I.
Number of Wats. Monks in Cambodia 1979-1995

| Year | Active Wats | # of Monks | of which: Novices | Nuns (Don chee) | Temple boys | Remarks/Source |
|---|---|---|---|---|---|---|
| 1969 | 3,369 | 65,062 | n/a | n/a | n/a | |
| 1979 | n/a | 12 | n/a | n/a | n/a | DRA |
| 1980 | n/a | 770 | n/a | n/a | n/a | DRA |
| 1981 | <br>740 | 2,610<br>4,930<br>3,000<br>2,000 | <br><br><br>1,500 | n/a | n/a | DRA<br>C.E.<br>WCRP Report on Kampuchea 5/5/81 quoting Tep Vong<br>FEER 24/4/81 |
| 1982 | <br>1,321 | 2,735<br>7,000<br>2,311 | n/a | n/a | n/a | DRA<br>Buddhist General Assembly cited in C.E.<br>CS Quarterly 14(3)1990 citing official report |
| 1983 | n/a | 2,778 | n/a | n/a | n/a | DRA |
| 1984 | <br>1,395 | 3,200 | n/a | n/a | n/a | DRA<br>H.Löschmann, Asien 7/91 |
| 1985 | [illegible] | 3,709 | n/a | n/a | n/a | DRA |
| 1986 | n/a | 4,100<br>6,000 | n/a | n/a | n/a | DRA<br>H.Löschmann,Asien 7/91 |
| 1987 | n/a | 4,349 | n/a | n/a | n/a | DRA |
| 1988 | n/a | 4,740 | n/a | n/a | n/a | DRA |
| 1989 | <br>2,300 | 14,062<br>8,000 | n/a | n/a | n/a | DRA<br>FEER 3/8/89 quoting Tep Vong |
| 1990 | <br>2,728<br>2,567 | 22,330<br>19,191<br>14,000 | n/a | <br>1,346 | n/a | DRA<br>DRA 30 June 1990 (Mey Yam)<br>H.Löschmann,Asien 7/91 |
| 1991 | <br>2,613 | 24,757<br>21,316 | n/a | n/a | n/a | DRA<br>Report B.Maat/COEPR 4 Feb 91 |
| 1992 | 7,069 | 26,237 | n/a | n/a | n/a | DRA |
| 1993 | [illegible] | 27,475* | n/a | n/a | n/a | DRA, [illegible] |
| 1994 | n/a | 36,408 | n/a | n/a | n/a | DRA |
| 1995 | [illegible]<br>(311)* | 40,916<br>(1,095)* | [illegible]<br>(522)* | n/a | n/a | DRA, [illegible] |
| 1996 | n/a | 61,349<br>(1,147)* | n/a | n/a | n/a | DRA |

Source: Center for Advanced Study and Ministry of Cults &Religious Affairs, 1996
Notes: n/a = not available; (*) Dhammayuttika order only; DRA = Dept.of Religious Affairs; WCRP = World Council on Religion & Peace; FEER = Far Eastern Economic Review; CS = Cultural Survival; C.E. = Chhom Ean paper (1995)

www.budinst.gov.kh www.elibraryofcambodia.org

រាជាគណៈនៃក្រុមទីបួន (ហៅថា ថាក់ចត្វា) មានចំនួនសមាជិកម្ភៃរូបសំរាប់គណៈមហានិកាយ និងមានចំនួនសមាជិកដប់ពីររូបសំរាប់គណៈធម្មយុត្តិ :

**មហានិកាយ**

១.ព្រះធម្មវិបស្សនា
២.ព្រហសម្មាធិធម្ម
៣.ព្រះញាណកោសល
៤.ព្រះសិរីសង្គាមមុនី
៥.ព្រះសិរីវិសុទ្ធិ
៦.ព្រះធម្មវង្សា
៧.ព្រះញាណសំវរៈ
៨.ព្រះធម្មសំវរៈ
៩.ព្រះឥន្ទមុនី
១០.ព្រះទេពមុនី
១១.ព្រះវិន័យមុនី
១២.ព្រះទេពសត្ថា
១៣.ព្រះសីលសំវរៈ
១៤.ព្រះគម្ពីរត្ថេរ
១៥.ព្រះអរិយមគ្គញាណ
១៦.ព្រះវិភទ្ទញាណ
១៧.ព្រះបវរសត្ថា
១៨.ព្រះញាណវិសុទ្ធិវង្ស
១៩.ព្រះធម្មវិសុទ្ធិវង្ស
២០.ព្រះបិដកធម្ម

**ធម្មយុត្តិ**

១.ព្រះបទុមវង្ស
២.ព្រះធម្មមុនី
៣.ព្រះធីរមេធា
៤.ព្រះអរិយមុនី
៥.ព្រះទេពមោលី
៦.ព្រះធម្មត្ថេរ
៧.ព្រះអមរាភិរក្ខិត
៨.ព្រះមហារាជធម្ម
៩.ព្រះរតនៈមុនី
១០.ព្រះធម្មត្រ័យលោកាចារ្យ
១១.ព្រះធម្មវរោត្តម
១២.ព្រះញាណវីរិយៈ

ឋានានុក្រម ក៏ជាឋានៈក្រោមបន្ទាប់នៃឋានៈរបស់ក្រុមក្រោយគេ (ហៅថា ថ្នាក់ចត្វា) នៃរាជាគណៈ មានងារ ហៅថាព្រះគ្រូ , ធាឡាត់ , វិន័យធម្ម , វិន័យធរ , សមុហ៍ , បៃឋិការ (ងារសៀម) និងលេខាធិការ ។ ពួកនេះត្រូវសម្តេចសង្ឃនាយកតែងតាំង ដោយសេចក្តីយល់ព្រមពីរដ្ឋមន្ត្រីក្រសួងធម្មការ ។

## សភាសង្ឃ

មានសភាសង្ឃបីប្រភេទ :

១.មានសភាជាន់ខ្ពស់ឬថេរសភាពីរ : ថេរសភា មួយសំរាប់និកាយនីមួយៗ ហើយស្ថិតនៅរមសង្ឃនាយកនៃគណៈរៀងៗខ្លួន ។

www.budinst.gov.kh www.elibraryofcambodia.org

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ស្ថិតិវត្ត និងព្រះសង្ឃ ឆ្នាំ ១៩៩៨-៩៩

—*—

| ល.រ | ឈ្មោះខេត្ត-ក្រុង | វត្ត | | ព្រះសង្ឃមហានិកាយ | | សរុបមហានិកាយ | ព្រះសង្ឃធម្មយុត្តិ | | សរុបធម្មយុត្តិ | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|---|
| | | មហានិកាយ | ធម្មយុត្តិ | ភិក្ខុ | សាមណេរ | | ភិក្ខុ | សាមណេរ | | មេគុណ |
| 1 | ភ្នំពេញ | 84 | 03 | 1.732 | 1.387 | 3.119 | 50 | 17 | 67 | ពន់ ខែត |
| 2 | កណ្ដាល | 342 | 20 | 1.497 | 2.735 | 4.232 | 57 | 144 | 201 | ឈួន យង់ |
| 3 | កំពង់ចាម | 509 | 11 | 1.730 | 4.076 | 5.806 | 80 | 72 | 152 | យ៉ែម ស៊ុខ |
| 4 | ព្រៃវែង | 423 | 14 | 1.435 | 2.230 | 3.665 | 87 | 77 | 164 | ឈុន ជីម |
| 5 | បាត់ដំបង | 207 | 08 | 1.385 | 2.311 | 3.696 | 18 | 38 | 56 | ឈួយ ហឿង |
| 6 | សៀមរាប | 202 | 02 | 1.592 | 2.400 | 3.596 | 06 | 05 | 11 | ពុម ម៉ុល្លា |
| 7 | តាកែវ | 290 | 16 | 965 | 2.143 | 3.108 | 21 | 94 | 115 | ធាំ ស៊ូស |
| 8 | កំពត | 189 | 05 | 778 | 1.765 | 2.543 | 13 | 15 | 28 | អែម តឿង |
| 9 | កំពង់ស្ពឺ | 198 | 07 | 1.700 | 2.435 | 4.135 | 27 | 60 | 87 | ស្វាយ ដុង |
| 10 | កំពង់ធំ | 211 | គ្មាន | 909 | 2.607 | 3.516 | 00 | 00 | 00 | រោង ផៃ |
| 11 | ស្វាយរៀង | 212 | គ្មាន | 769 | 1.271 | 2.040 | 00 | 00 | 00 | ខេត មិន |
| 12 | បន្ទាយមានជ័យ | 180 | 04 | 856 | 1.963 | 2.819 | 40 | 31 | 71 | ស៊ី ញ៉ុញ |
| 13 | ពោធិ៍សាត់ | 118 | 04 | 480 | 1.546 | 2.026 | 10 | 07 | 17 | អ៊ុក ឌុំ |
| 14 | កំពង់ឆ្នាំង | 172 | គ្មាន | 654 | 1.592 | 2.246 | 00 | 00 | 00 | សួន ហាន |

www.budinst.gov.kh www.elibraryofcambodia.org

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| 15 | ក្រចេះ | 90 | 02 | 260 | 569 | 829 | 06 | 05 | 11 | [illegible] |
| 16 | កោះកុង | 36 | 01 | 210 | 168 | 378 | 02 | 02 | 04 | [illegible] |
| 17 | ក្រុងព្រះសីហនុ | 20 | គ្មាន | 151 | 244 | 395 | 00 | 00 | 00 | [illegible] |
| 18 | ស្ទឹងត្រែង | 3[illegible] | គ្មាន | 140 | 185 | 325 | 00 | 00 | 00 | [illegible] |
| 19 | ព្រះវិហារ | 32 | គ្មាន | 98 | 247 | 345 | 00 | 00 | 00 | [illegible] |
| 20 | [illegible]គិរី | 13 | គ្មាន | 57 | 110 | 167 | 00 | 00 | 00 | |
| 21 | មណ្ឌលគិរី | 05 | គ្មាន | 07 | 16 | 23 | 00 | 00 | 00 | [illegible] |
| 22 | ក្រុងកែប | 08 | គ្មាន | 34 | 54 | 88 | 00 | 00 | 00 | |
| | សរុប | 3.588 វត្ត | 97 វត្ត | 17.439 អង្គ | 31.658 អង្គ | 49.097 អង្គ | 417 អង្គ | 567 អង្គ | 984 អង្គ | |

សរុប[illegible]វត្តមហានិកាយ និងធម្មយុត្តិ : 3.685 វត្ត

★ សរុបព្រះ[illegible] មហានិកាយ និងធម្មយុត្តិ : 5.0081 អង្គ

www.budinst.gov.kh www.elibraryofcambodia.org

៩ . វិស័យសិក្សាធិការ :

ក . សាលាបាលីជាន់ខ្ពស់ ( ឥឡូវគេហៅថាពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត ) សាលាបាលីរង ( ហៅពុទ្ធិកបឋមសិក្សា ) :

អ្វីជាភាសាបាលី ? មូលហេតុ ដែលកើតភាសាបាលី ! ។ ភាសាបាលីកើតនៅប្រទេសឥណ្ឌា ។ កាលមុននិងជំនាន់ពុទ្ធកាលភាសានេះ គ្មានរបៀបវេយ្យាករណ៍ទេ ដូចគម្ពីរបាលីព្រះត្រៃបិដក ដែលយើងមើលនិងបោះពុម្ពនៅប្រទេសយើងឃើញពាក្យ " ស្រមដែល " ជាច្រើន ។ បើអ្នកប្រាជ្ញសម័យថ្មី អាចកាត់ពាក្យ " ស្រមដែល " នេះចោលចេញបាន គម្ពីរព្រះត្រៃបិដក នោះជាមានសភាពខ្លីៗ ស្រួលអាន ស្រួលស្តាប់ ទាំងលេលិតផង ។

តាមសេចក្តីក្នុងសន្និសីទរបស់ឯកឧត្តម វ៉ាយ ណុក អតីតរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ឧស្សាហកម្មធ្វើក្នុងនាមជាសមាគមមិត្តសាលាបាលី ពីថ្ងៃទី ៦ មេសា ១៩៥១ ថា " ការរៀនភាសាបាលីនេះ មិនមែនទើបនឹងមានទេ " ។ តាមប្រវត្តិសាស្ត្រ ភាសាបាលីបានចូលមកក្នុងប្រទេសយើងតាំងពីសតវត្សទី ១៧ ( ព.ស ) ( គ.ស. ទី ១២ ) ម្ល៉េះ កាលព្រះពុទ្ធសាសនាប៉ែកខាងមហាយានបានចូលមកក្នុងប្រទេសយើងជាដំបូង ។ ដល់មកក្នុងទី ២០ នៃ ព.ស ( គ.ស.ទី ១៥ ) ព្រះពុទ្ធសាសនាថេរវាទហីនយាន បានចូលមកប្រទេសយើងទៀត ភាសាបាលីក៏ចេះតែប្រើលាយសំមិនឡើងជាលំដាប់ ។ យើងឃើញការរៀនសូត្របាលីមានរបៀបរាបទាបក្រាស់ តាំងពីក្នុងរជ្ជកាលព្រះបាទសម្តេចព្រះហរិរក្ស រាមាឥស្សរាធិបតី ( ព្រះអង្គដួង ) គឺតាំងពីក្នុងសតវត្សទី ២៤ នៃព.ស. ។ ដល់មកទៀត ក្នុងសតវត្សទី ២៥ នៃព.ស. ក្នុងរជ្ជកាលព្រះបាទសម្តេចព្រះនរោត្តម យើងឃើញមានពិធីវេញប្រយោគ ប្រែបាលី ។ បន្ទាប់មកទៀត ក្នុង ព.ស. ២៤៥២ ( គ.ស. ១៩០៩ ) មាន បង្កើតសាលាបាលីនៅនៃវត្ត ។ ក្រោយពីនោះមកទៀត ក្នុងព.ស. ២៤៥៧ ( គ.ស. ១៩១៤ ) សាលាបាលីជាន់ខ្ពស់របស់យើងសព្វថ្ងៃ បានបង្កើតឡើងជាដំបូងសាលាបាលីនៅនៃវត្ត គឺសាលាបាលីជាន់ខ្ពស់នេះ មានអាយុ ៣៧ ឆ្នាំ ហើយ ។ បន្ទាប់តមក តាំងពី ព.ស. ២៤៧៦ ( គ.ស. ១៩៣៣ ) រហូតដល់សព្វថ្ងៃ គឺក្នុងរយៈវេលា ១៧ ឆ្នាំ ប៉ុណ្ណោះ បានបង្កើតសាលាបាលីរងក្នុងព្រះរាជាណាចក្រមានចំនួន ១៨៤ សាលា មានសិស្សរៀនចេញចូលរៀងៗ ជាង ១០០០ រូប (៣៩) ។

សរុបសេចក្តីថា ក្នុងកម្ពុជរដ្ឋមានវត្តចំនួន ២៦៨០ ( ១៩៥៣ មានវត្ត ២៧៦៣ ) សាលាបាលីរងចំនួន ២៨៤ ( ១៩៥៣ មានជាង ៣០០ ) មានភិក្ខុសង្ឃ ចំនួនប្រហែល ៣៥០០០ រូប ជាអ្នកបញ្ចប់ក្នុងរៀនសូត្របាលី រៀនសូត្រព្រះពុទ្ធសាសនា ភាសាខ្មែរឱ្យបានជ្រៅជ្រះ ... ។

សាលាបាលីជាន់ខ្ពស់ ដែលជាក្រុមសាលាគោរពរួមតែមួយ បានផ្ទេរសាលានោះមកឱ្យរដ្ឋាភិបាលខ្មែរនៅថ្ងៃទី ៣១ ខែ ធ្នូ ១៩៤៧ ។

ខ . ពុទ្ធសាសនបណ្ឌិត (៤០) :

ពុទ្ធសាសនបណ្ឌិត កើតឡើង គ.ស. ១៩៣០ ដោយមានតែព្រះរាជក្រឹត្យប្រកាសបញ្ញត្តិច្បាប់ ដែលបានស្ថាបនាតាមព្រះរាជប្រកាស ១៩២១ ។ តាំងពីនោះមក ពុទ្ធសាសនបណ្ឌិត ដែលមានលោកស្រី ស៊ុយ៉ង់ កាព៉ឺឡែស ជាអគ្គលេខាធិការ ការងារបានរីកចម្រើនជាលំដាប់ ។

---

(៣៩) លោក វ៉ាត បុក ប្រវត្តិព្រះពុទ្ធសាសនានៅកម្ពុជា ភ្នំពេញ ១៩៩៧ ទំព័រ ១៦-១៨

(៤០) លោក វ៉ាត បុក ប្រវត្តិព្រះពុទ្ធសាសនានៅកម្ពុជា ភ្នំពេញ ១៩៩៧ ទំព័រ ១៨-២៣

www.budinst.gov.kh www.elibraryofcambodia.org

ពុទ្ធសាសនបណ្ឌិត្យ មានកិត្យានុភាពក្រោយរក្សាទុកនូវគម្ពីរវែងសំខាន់ៗ នៃពិភពលោក ព្រមទាំងគម្ពីរតេករនានាធម៌បុរាណ ។ ក្រុមនេះ គឺស្ថាបនាដោយស្នាព្រះហស្ថនៃព្រះប្រមុខមហាក្សត្រប្រទេសកម្ពុជា និងជាវិទ្យាស្ថានតមកពីសាលាបាលីជាន់ខ្ពស់ និងព្រះរាជបណ្ណាល័យ ។ វិទ្យាស្ថាននេះ ពីដើមគេហៅថា " វិទ្យាស្ថានរបស់ការសិក្សាខាងព្រះពុទ្ធសាសនាហីនយាន " មានបេសកកម្មគ្រប់គ្រងណែនាំ និងរៀបចំអង្គការនៃការសិក្សាព្រះពុទ្ធសាសនាហីនយាន ។ នៅខែ កុម្ភៈ ១៩៤៣ វិទ្យាស្ថានបានប្រែនាមថា វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ ហើយបានទទួលពីព្រះរាជបណ្ណាល័យនូវសៀវភៅ និងឯកសារជាច្រើន មានអក្សរសាស្ត្រ សាសនា ប្រវត្តិសាស្ត្រ បុរាណសាស្ត្រ ព្រមទាំងបោះពុម្ពសៀវភៅព្រះរាជបណ្ណាល័យ និងសាលាបាលីជាន់ខ្ពស់ថែមទៀត ។ ពិតមែនតែមានមហាសង្គ្រាមលោកលើកទី ២ និងកងទ័ពជប៉ុនចូលមកប្រទេសកម្ពុជា ពុទ្ធសាសនបណ្ឌិត្យនៅតែមានដំណើរទៅខាងមុខ ។

ក្រុមជំនុំព្រះត្រៃបិដក បានស្ថាបនាឡើង តាមព្រះរាជប្រកាសលេខ ១០៦ ចុះថ្ងៃទី ១៤ ធ្នូ ១៩២៩ (៣០) ការបោះពុម្ពព្រះត្រៃបិដក ក៏បានចាប់ផ្តើមធ្វើតមក ។ ព្រះត្រៃបិដកជាស្នាដៃ ឬកក្រុមជំនុំព្រះត្រៃបិដក ដែលមានសម្តេចព្រះធម្មលិខិត ល្វី ឯម (ជោតញ្ញាណោ) ការបោះជាព្រះអភិធម្មបិដក តាមរយៈសាលាបាលីជាន់ខ្ពស់ជាអធិបតី ព្រមទាំងការព្យាយាមនៃព្រះសមុទ្ទប៉ុន ឌី ឌី និងសម្តេចព្រះមហាសុមេធាធិបតីសង្ឃនាយក ជួន ណាត (ជោតញ្ញាណោ) កាលនៅជាព្រះសមុស្សា ។ ព្រះត្រៃបិដកមាន ១១០ ក្បាល បើរាប់ទាំងព្រះសូត្រ ព្រះវិន័យ និងព្រះអភិធម្ម ។

វចនានុក្រមខ្មែរ បាននាំទៅកាន់អត្ថ នៃពុទ្ធសាសនបណ្ឌិត្យផ្សាយទៅពាសពេញភូមិ និងជនបទ ខេត្ត ព្រមទាំងបណ្តាសៀវភៅផ្សេងៗ លោកក្រៅប្រទេស ។ តែឥឡូវនេះ ដោយសារសន្តិសុខ វចនានុក្រមនោះ ក៏ត្រូវផ្អាកបណ្តោះអាសន្ន រឹតបានត្រូវទៅលើសាធារណៈ របាំងពេលការពារទៅថ្ងៃក្រោយ ។

ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ ដោយមានលោកស្រី ឌឺ ម៉ាស៊ី សមាជិកវិទ្យាស្ថានបូព៌ាប្រទេសជាអ្នកណែនាំ ក៏បានដំណើរការទៅតែក្នុងនេះវិញទេតែពាក់កណ្តាល បានរក្សាទុកឯកសារជាច្រើន ។ ឆ្នាំ ១៩៤៩ មានឯកសារ ៣៦០០ ដែលបានផ្ទុក ។ ឆ្នាំ ១៩៥០ មានឯកសារ ៤០០០ ។

បណ្ណាល័យពុទ្ធសាសនបណ្ឌិត្យ មានសៀវភៅប្រមាណជាង ១០០០០ ក្បាល ព្រមទាំងសាស្ត្រាស្លឹករឹត ។ សន្និពិព្ធណ៍ មានចាស់ចាប់ ៣០០ ។ ការបោះពុម្ពទស្សនាវដ្តី " កម្ពុជសុរិយា " ក៏បានធ្វើជាប៉ោរ៉ាប់តមក ។ សារមន្ទីរផ្សេងៗ ដែលមានព្រះពុទ្ធរូប ឆ្លាក់ គំនូរ និងបូរាណវត្ថុ ដែលមានសារមន្ទីរគិមេថ៍ បានធ្វើអំណោយខ្លះ មានក្បាច់ចំលាក់សិល្បៈជាដើម ដែលនាំចំណូលទៅប្រទេស និងចិន្តាបូព៌ាប្រទេស លោយឲ្យផ្លាទៅជាសកម្មភាពដ៏ប្រសើរ ។

បើតាមពិតធ្វើឲ្យល្បីឈ្មោះ ពុទ្ធសាសនបណ្ឌិត្យជាស្នាដៃរបស់លោកស្រី ស៊ុយ សាន ការប៉ឺឡេស លោក លុី វ៉ែរ ហ្វីណូ លោក ហ្សក សឺដេស លោក វ៉ិក្ទ័រ ហ្គោឡូប៊ឺ ចិន ដែលបានព្យាយាមរចនាវិទ្យាស្ថាននេះ ទៅជាវិទ្យាស្ថានវិទ្យាសាស្ត្រសម័យថ្មី មានកិត្តិនាមល្បីល្បាញក្នុងពិភពលោក ។

ពុទ្ធសាសនបណ្ឌិត្យ ដែលជាក្រុមនៃរាជការសាសនា ត្រូវបានផ្ទេរមកឱ្យស្ថិតក្រោមក្រសួងពីថ្ងៃទី ១៤ តុលា ១៩៥០ ដោយអនុក្រឹត្យលេខ ៨ ខែ តុលា ១៩៥៩ និងកិច្ចព្រមព្រៀងចុះថ្ងៃទី ១៩ មិថុនា ១៩៥០ ។

៩. សាលាធម្មវិន័យ ៖

សាលាធម្មវិន័យ ជាកន្លែងបង្រៀនព្រះពុទ្ធសាសនា ដោយមានកំរិតសិក្សាខាងព្រះវិន័យ ព្រះសូត្រ និងព្រះអភិធម្ម ដើម្បីនឹងបញ្ជ្រាបពុទ្ធិតាម ។

www.budinst.gov.kh www.elibraryofcambodia.org

## ឃ . សមាគម :

### ឃ.១ . សមាគមមិត្តពុទ្ធិកវិទ្យាល័យ ([៣៣])

សមាគមមិត្តពុទ្ធិកវិទ្យាល័យ ( មិមុនហៅថា សមាគមមិត្តសាលាបាលី )នេះ កើតឡើងដោយលោក ម៉ៅ ទី ឈោះក្យាស់ ក្រសួងមហាផ្ទៃជាអ្នកផ្តើមគំនិត បានណាត់ពេលប្រជុំលើកដំបូងនៅក្នុងថ្ងៃទី ២០ កុម្ភៈ ១៩៤៩ ដើម្បីនឹងតាំងគណៈកម្មាធិការមណ្ឌលព្រះរាជសង្ឃ និងធ្វើសេចក្តីព្រាងនៃលក្ខន្តិកៈសមាគមនេះ ។ លុះលក្ខន្តិកៈសម្រេចហើយ បានធ្វើមហាសន្និបាតបោះឆ្នោតលើកទី ១ ដើម្បីរើសក្រុមអភិបាល និងបើកបន្ទីសំណាក់ការ ដែលមានដំណើរការរហូតដល់សព្វថ្ងៃនេះ ។

### ឃ.២ . ពុទ្ធិកសមាគមពិភពលោកមជ្ឈមណ្ឌល តំបន់ភាគកម្ពុជរដ្ឋ :

ពុទ្ធិកសមាគម ពិភពលោកមជ្ឈមណ្ឌលភូមិភាគកម្ពុជរដ្ឋ សមាគមនេះបានដំណើរការ មកទល់នឹងមហាសង្គ្រាមលោកលើកទី ២ ទើបផុតផាយកំលាំងរួចរឹតាសសាបសូន្យ ។

. ទើបមកដល់សព្វថ្ងៃទី ១៤ ខែ កញ្ញា ១៩៥២ ក្រោយពីសម្តេចព្រះមហាសុមេធាធិបតីសង្ឃនាយក ជួន ណាត និមន្តត្រឡប់ពីប្រជុំសមាជពុទ្ធសាសនាសាកលនៅទីក្រុងកូឡុំបូ ( ប្រទេសស៊ីឡង់ ) ពីខែមិថុនា ១៩៥០ សមាគមក៏ផ្តួចផ្តើមឡើងដោយសម្តេចជាអ្នកជួយឧបត្ថម្ភមាននាមថា : ពុទ្ធិកសមាគម ពិភពលោកមជ្ឈមណ្ឌលភូមិភាគកម្ពុជរដ្ឋ ។ សមាគមនេះ បានជ្រើសរើសក្រុមអភិបាលមណ្ឌលព្រះរាជសង្ឃក្នុងពេលនោះ រួចបានរើសជាស្ថាពរនៅក្នុងថ្ងៃទី ២៨ ធ្នូ ១៩៥២ ។

សមាគមនេះ មានដំណើរការមក បានបញ្ជូនសិស្សពីររូប ឱ្យទៅរៀនឯអាណាការាម ក្នុងសំណាក់ព្រះភិក្ខុ ហម្មុង ( ធម្មរាមោ ) ជិតទីក្រុងនៃប្រទេសឥណ្ឌា ។

### ឃ.៣ . សមាគមគិលានសង្គ្រោះ :

ចំពោះព្រះសង្ឃ សមាគមនេះ ស្ថាបនាពីថ្ងៃ ២៨ ធ្នូ ១៩៤៩ ហើយបានសាងមន្ទីរពេទ្យព្រះសង្ឃ ហើយបានសម្ពោធពីថ្ងៃទី ២១ កុម្ភៈ ១៩៥៦ ។

### ឃ.៤ . ការតមនាគមនឹង ជាមួយប្រទេសដទៃខាងផ្លូវពុទ្ធសាសនា ([៣៤])

. សមាជសាកលពុទ្ធសាសនានៃទីក្រុងកូឡុំបូ ( ប្រទេសស៊ីឡង់ ឬស៊ីលង្កា )

សមាជនេះ ធ្វើនៅក្នុងឆ្នាំ ( លើកទី១ ) ដោយសេចក្តីណែនាំពីសមាគមពិភពលោក នៅទីក្រុងនេះ ដែលមានមហាក ឌ.ក.មលលស អេរកេរ៉ះ ជាប្រធាន មានប្រទេសក្នុងពិភពលោកជាច្រើន ( ប្រហែលជាង ៤០ ) បានទៅប្រជុំក្នុងពេលនោះ ។

. សមាជសកលពុទ្ធសាសនានៅទីក្រុង តូក្យូ ( ប្រទេសជប៉ុន ) លើកទី ២ :

សមាជនេះ បានធ្វើនៅវត្ត ហុង្គាន់ ( ក្រុងតូក្យូ ) ពីថ្ងៃ ២៥ កញ្ញា ដល់ថ្ងៃទី ១៣ តុលា ១៩៥២ ។ ប្រទេសទាំងឡាយ មានប្រទេសឥណ្ឌា ថៃឡង់ ភូមា កម្ពុជា វៀតណាម ចិន ជប៉ុន ជាដើម មានចំនួន ៤០ ប្រទេស មានទាក់ប្រតិភូទៅរួមប្រជុំសមាជនៅពេលនោះ មានចំនួន ១៧០ នាក់ ។

---

[៣៣] លោក ភិក្ខុ ហ៊ុត ព្រះពុទ្ធសាសនានៃកម្ពុជា ភ្នំពេញ ១៩៩៧ ទំព័រ ២៣

[៣៤] លោក ... ព្រះពុទ្ធសាសនានៃកម្ពុជា ភ្នំពេញ ១៩៩៧ ទំព័រ ២៤-២៥

www.budinst.gov.kh www.elibraryofcambodia.org

# ជំពូកទី ២

## ព្រះពុទ្ធសាសនា និងច្បាប់រដ្ឋធម្មនុញ្ញ

" មាត្រា ៨ នៃច្បាប់រដ្ឋធម្មនុញ្ញបានថ្លែងថា " ព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋ " មែនពិត សម្ដេចព្រះឧបយុវរាជ កាលទ្រង់ជាព្រះមហាក្សត្រិយ៍ប្រទេសកម្ពុជា ទ្រង់ជ្រាបច្បាស់នូវសន្ដានចិត្តជនជាតិខ្មែរ បានជាទ្រង់ប្រកាសក្នុងមាត្រា ៨ ខាងលើនេះថា ព្រះពុទ្ធសាសនា ជាសាសនានៃជនជាតិខ្មែរទាំងមូល ជាសាសនាដ៏វិសេសពេញលក្ខណៈ ជាសាសនាស្របទៅតាមលទ្ធិប្រជាធិបតេយ្យ " ( [៣៥] ) ។

លទ្ធិប្រជាធិបតេយ្យ ជាលទ្ធិរបស់រាស្ត្រ ធ្វើដោយរាស្ត្រ ដោយអង្គប្រជារាស្ត្រ ដើម្បីប្រយោជន៍ប្រជារាស្ត្រមានបំណងចង់បំបាត់នូវសេចក្ដីលំបាកវេទនា ប្រជារាស្ត្រគង់ធ្វើអនាគតប្រជារាស្ត្រ ដោយយកសមភាព សេរីភាព ភាតរភាព សាមគ្គីភាព ផ្សេងៗជាមូលដ្ឋាននៃការប្រតិបត្តិ ។ លទ្ធិនេះនៅបច្ចុប្បន្ន រឺ អតីតកាលដែលមិនទាន់កើតមាន ដោយជឿជាក់ថា សេចក្ដីព្យាយាមរបស់មនុស្សក្នុងកិច្ចការទាំងឡាយ ដោយយុត្តិធម៌ជាមូលដ្ឋាន ឬជាប្រយោជន៍រាស្ត្រ ជាវត្ថុបំណង នឹងបានសំរេចបានដល់ប្រយោជន៍ទាំងនោះ ។ ចំណែកឯព្រះពុទ្ធសាសនា ជាលទ្ធិវិធានាប្រាប់អោយយើងនូវសីលធម៌ គុណធម៌ ពេះវាចា ផ្លូវដែលអាចនឹងអោយយើងរំលត់ទុក្ខផ្សេងៗ មានជាតិ ជរា ព្យាធិ មរណៈ រហូតដល់ព្រះនិព្វាន ។ ដូច្នេះ ព្រះពុទ្ធសាសនាមិនសំរេចរកសុខចំពោះខ្លួនឬ ? ។

ព្រះពុទ្ធសាសនាមិនមែនដូច្នេះទេ ព្រះពុទ្ធសាសនាទូន្មានប្រយ័ត្ន : ត្រូវរកសុខចំពោះខ្លួនអោយឃើញសិន ទើបរកសុខជូនអ្នកដទៃបាន ។

បើតាមព្រះពុទ្ធសាសនា និងលទ្ធិប្រជាធិបតេយ្យមានបំណងធ្វើអោយមនុស្សបានសុខ ព្រោះលោកអោយធម៌ជាគ្រូ ។ លទ្ធិទាំងពីរ ជាជាតិដែលបង្រៀនអោយមនុស្ស និងលោកអោយចំរើនទៅរកសន្តិភាព ធ្វើអោយមនុស្សលោកអោយមានសន្តិភាព ភាតរភាព សេរីភាព សមគ្គីភាព វឌ្ឍនភាព ជាគ្រឿងអោយរាំងប្រមើលមើលទុក្ខផ្សេងៗបំបាត់មនុស្សអោយបានរួចផុតនូវទុក្ខសោក ។ តែព្រះពុទ្ធសាសនាខុសពីលទ្ធិប្រជាធិបតេយ្យ ។

ព្រះពុទ្ធសាសនាអោយមនុស្សប្រតិបត្តិតាមធម៌ ដើម្បីធ្វើបាប និងរួចរាស់ខ្លួនអោយអស់ លោភៈ ទោសៈ មោហៈ ។ ធ្វើអោយមានការសម្រេចសុខចំពោះខ្លួនឯង ហើយទៅរកសុខជូនអ្នកដទៃជាក្រោយ ។ លទ្ធិប្រជាធិបតេយ្យ ពុំបានបង្រៀនអោយធ្វើអោយមានចិត្តស្អាតនៃគុណធម៌ ពុំបង្រៀនអោយរួចផុតពីអាសវៈ តើហើយឱ្យទៅរកប្រយោជន៍ដើម្បីសង្គមជាតិ មនុស្សធម៌ ស្មើភាពពីព្រោះលោកទាំងឡាយដែរ ។ បើចិត្តរបស់ខ្លួនមិនបានស្ងប់ ធ្វើម្ដេចអាចសង្គមជាតិ មនុស្សធម៌ លោកស្ងប់ទៅបាន ? បើពុំព្រះពុទ្ធសាសនាមិនបានស្ដាប់តែ ៥ តែ ៨ សោះ តើការគោរពព្រះពុទ្ធសាសនា ទទួលបានយ៉ាងណា ?

ព្រោះហេតុដូច្នេះហើយ ព្រះពុទ្ធសាសនា " គឺលោកតាំងពុកតែងបួសក្នុងធម្មា គាត់ឥតកាយបួសចិត្តទាំងអស់ ទាំងកាយវាចាចិត្តរបស់ព្រះអង្គពុំមាន ។ លទ្ធិប្រជាធិបតេយ្យ គឺលោកមុខមុខក្នុងធំនៅថាជាច្បាប់ព្រះធម៌ ហើយលោកទើបមិនមែនអាចនឹងនាំទៅរកសុខបាន ។ លទ្ធិប្រជាធិបតេយ្យ

[៣៥] លោក រ៉ែល ប៊ុក ព្រះពុទ្ធសាសនានៅកម្ពុជា ភ្នំពេញ ១៩៧៣ ទំព័រ ៧៥

www.budinst.gov.kh www.elibraryofcambodia.org

ចរកឃ្លងទៅត្រើយកាលណានោះ ពីព្រោះតែនឹកនាំវេលាវេលា តែគល់វានៅ លុះមានទឹកភ្លៀងធ្លាក់ចុះពីអាកាសធាតុម្ដងទៀតមក ក៏គល់នោះដុះឡើងជាថ្មី កញ្ចប់ព្រៃជាវិញនៃដែលកាត់ចោល ក៏កើតជារុក្ខជាតិមួយដើមថ្មីទៅទៀត ។ បើខ្លួនមានចិត្តពេញដោយរាគៈ ទោសៈ មោហៈ ម្ដងនឹងធ្វើអោយខ្លួនវង្វេងក្នុងវិលទៅវិញ ម្ដងនឹងធ្វើអោយរលោភចំពោះទៅរកសន្តិភាពបាន ! (៣៦)

បើដូច្នេះ លទ្ធិព្រហ្មញ្ញសាសនា និងលទ្ធិពុទ្ធសាសនាមានសភាពមិនខុសគ្នាស្រឡះទៅហើយឬ ? មិនមែនលទ្ធិព្រហ្មញ្ញសាសនា ជាលទ្ធិសំរាប់អនុវត្តន៍ទៅខាងលោកិយចក្រ គឺ សំរាប់រចនាបុគ្គលអោយមានស្រលាញ់ជាតិ ញ៉ាំងសង្គមអោយចំរើនរុងរឿងឡើងតាមលំដាប់ ធ្វើអោយមានមនុស្សធម៌ ។ អោយចំរើនទៅរកសេចក្ដីសុខជាតិវិជ្ជាភាពទៅ ធ្វើលោកអោយឡើងទៅកាន់ វឌ្ឍនភាព សម្បូណ៌ភាព ។ ចំណែកឯលទ្ធិសាសនា ជាលទ្ធិសំរាប់អនុវត្តទៅខាងសាសនាចក្រ ឬពុទ្ធចក្រ គឺសំរាប់រចនាបុគ្គលអោយមានគុណធម៌ សីលធម៌ ញ៉ាំងសង្គមអោយចំរើន អោយលះបង់នូវទុក្ខវេទនា លោភៈយ៉ាងណាក៏ដោយ ញ៉ាំងបុគ្គលខ្លួនអោយរួចរស់ទៅ ពីជាតិ ជរា ព្យាធិ មរណៈ អោយអស់ជាទៅ ធ្វើឲ្យសង្គមអោយរលត់លោភជាលំដាប់ មនុស្សធម៌អោយផុតពីទុក្ខ តែម្រែរការពារបរទេសពីទុក្ខ គឺបុគ្គល សង្គម មនុស្សធម៌ លោកអោយបានដល់ព្រះនិព្វាន ជាស្ថានបរមសុខជាគត់ ។

លទ្ធិព្រហ្មញ្ញសាសនា និងលទ្ធិពុទ្ធសាសនានាំមនុស្សទៅរកសុខផ្សេងគ្នា ព្រោះតែលទ្ធិព្រហ្មញ្ញនាំមនុស្សទៅកាន់លោកិយ ឬសាមិស គឺសុខជាលោកិយ ឬសុខប្រកបដោយអាមិសទៅកាន់ឋានទេវលោក ឯលទ្ធិពុទ្ធសាសនាដែលនាំមនុស្សទៅកាន់លោកុត្តរ ឬ សុខប្រាសចាកអាមិស សុខដ៏បរិសុទ្ធផុតពីទុក្ខទាំង ១៣ ពង សុខក្នុងព្រះនិព្វាន ។

# ជំពូកទី ៣

## ព្រះពុទ្ធសាសនាផ្នែកហីនយាន ព្រះសក្យមុនីចេតិយ ព្រះវិហារព្រះកែវមរកត វត្តបទុមវតី រាជវរារាម វត្តឧណ្ណាលោម ព្រះស្រគាលេញ មុនីសេនរាជ

១ . ការស្ដារព្រះពុទ្ធសាសនា ផ្នែកហីនយាន ដែលបានចូលមកក្នុងប្រទេសកម្ពុជា តាមព្រះរាជនិពន្ធនៃសម្ដេចព្រះសង្ឃរាជ " ទៀង " និងសម្ដេចព្រះសុគន្ធាធិបតី " ប៉ាន " (៣៧)

ការផ្សព្វផ្សាយពុទ្ធសាសនាតែ ៥០០ ឆ្នាំ ឆ្នាំ ... [illegible] ... ព្រះពុទ្ធរូប និងព្រះវិហារ ... ព្រះពុទ្ធសាសនានៅក្នុងទៅ ។ ដោយព្រះធាតុ ... [illegible] ... ព្រះអង្គបានទ្រង់ ... ។ ព្រះភិក្ខុ ... [illegible] ... ទៅដល់ក្នុងព្រះបរមរាជវាំង ... ។ ព្រះរាជាទ្រង់ ... [illegible]

៣៦ លោក ... ព្រះពុទ្ធសាសនានៃកម្ពុជា ភ្នំពេញ ១៩៧៧ ទំព័រ ៧៦

៣៧ ... ទៀង ... ប៉ាន ... [illegible] ... ទំព័រ ១៣ ១៨

" អាត្មាភាពមានចិត្តប្រាថ្នាកែវមណីជោត និងយកមកសាងព្រះពុទ្ធរូប " ។ ខណៈនោះ សម្តេចអម្រិន្ទ្រាធិរាជ ទទួលយករាជសារថា " ចូលព្រះបង្គំជាខ្ញុំបាននិមន្តថ្វាយ " ។ ទើបព្រះឥន្ទ្រាធិរាជ ព្រះអង្គត្រាស់ប្រើព្រះវិស្សុកម្មទេវបុត្តថា " ម្នាលអ្នក ចូរអ្នកទៅសុំយកកែវមណីជោតនោះអំពី យក្សគុម្ភណ្ឌ នៅឯភ្នំវេបុល្លបព៌តមក " ។ ព្រះវិស្សុកម្មទេវបុត្ត ក៏ក្រាបទូលថា " ដែលនឹងទៅសុំយកកែវមណីជោតនោះឃើញថា ពួកយក្សគុម្ភណ្ឌពុំប្រគល់ឲ្យឡើយ សូមអញ្ជើញធូលីព្រះបាទទៅផងទើបបាន " ។

ក្នុងខណៈនោះ សម្តេចព្រះអម្រិន្ទ្រាធិរាជ និងមាតលីទេវបុត្តក្រាបថ្វាយបង្គំលា. សម្តេចព្រះនាគសេនថេរនោះ ទៅដល់ ភ្នំព្រះសុមេរុ ។ ពួកយក្សដែលរក្សាកែវមណីនោះ ចេញមកទទួលក្រាបទូលសួរថា " ព្រះអង្គស្តេចមកនេះ មានប្រាថ្នាអ្វី " ? សម្តេចអម្រិន្ទ្រាធិរាជតបវិញថា " យើងមកសុំកែវមណីជោត និងយកទៅសាងជាព្រះពុទ្ធរូប " ។ ពួកយក្សទូលថា " ទ្រង់ប្រាថ្នាយកកែវមណីជោតនោះ ពួកទូលព្រះបង្គំជាខ្ញុំ និងថ្វាយពុំបានឡើយ ដ្បិតកែវមណីជោតនេះមានតែមួយព្រះអង្គ ទុកសំរាប់រាជ្យស្តេចមហាចក្រ ហើយស្តេចមហាចក្រកើតឡើងកាលណា ទារកែវមណីជោតនោះពីពួកទូលព្រះបង្គំជាខ្ញុំៗនឹងបាន ពីណាថ្វាយ ។ បើទ្រង់ប្រាថ្នាកែវមរកតនោះថ្វាយបាន ដ្បិតកែវមរកតនោះ មាន ៣ ព្រះអង្គ ទុកសម្រាប់ស្តេចចក្រពត្រ ។ សម្តេចអម្រិន្ទ្រាធិរាជទ្រង់ជ្រាបហើយក៏ព្រមតាម ។ ពួកយក្សក៏ទៅយកកែវមរកតនោះ មកក្រាបទូលថ្វាយសម្តេច អម្រិន្ទ្រាធិរាជ ក៏ទទួលយកកែវមរកតនោះ នាំមកប្រគេនថ្វាយសម្តេចមហានាគសេនថេរ ។ លំដាប់នេះ ព្រះអង្គនិងព្រះមាតលី ក៏ស្តេចត្រឡប់ ទៅឯឋានត្រៃត្រឹង្សមហាវិមានវិញ ។

សម្តេចព្រះនាគសេនថេរ ព្រះអង្គពុំចេះនឹងកសាងព្រះកែវមរកតនោះ ទើបនិមន្តព្រះវិស្សុកម្មទេវបុត្តដែលជាងទេព មកទទួលយកសាងព្រះកែវមរកតនោះជាព្រះពុទ្ធរូប ។ សម្តេចព្រះមហានាគសេនថេរ ព្រះអង្គក៏ព្រមឲ្យសាង ។ ទើបព្រះវិស្សុកម្មទេវបុត្ត ដែលជាជាងទេពធ្វើការសាងសង់ព្រះកែវមរកតនោះ គឺសាងនៅព្រះវស្ស ពុំបានសាងឆ្ងាយ ប្រាសាទ ឬតាមអាគារណាផ្សេងទៀត ។ ព្រះអង្គសាងអស់ ៧ យប់ ៧ ថ្ងៃ ទើបកើតឡើងជាព្រះពុទ្ធរូបមានរូបព្រះអង្គគំរស់ ប្រពៃលាភ្ញាសណ្ឋាន ហើយបញ្ចុះព្រះសារីរិកធាតុ ៧ ព្រះអង្គ ក្នុងព្រះកេសា ១ ព្រះអង្គ ក្នុងព្រះហស្តទាំងពីរ ១ ព្រះអង្គ ។ ក្នុងព្រះបាទទាំងពីរ ១ ព្រះអង្គ ។ ក្នុងព្រះឱរាទាំងសងខាងពីរព្រះអង្គសារីរិកធាតុលើ ព្រះកែវមរកតនោះ ក៏ចាំងតាំងពីការឡើងក្តុងពីសមាធិ ហើយត្រឡប់មកវិញ ។ រស្មីមហាជនទាំងឡាយ ក៏ចាត់ស្ងប់ស្ងៀមព្រះកែវនោះអស់ប្រមាណ ។ សម្តេចព្រះមហានាគសេនថេរ ព្រះអង្គទាយទុកថា ព្រះកែវមរកតនេះ ពុំគ្រាន់តែនៅតែក្នុងនគរ ប្រទេសនេះឡើយ គឺនឹងត្រូវយាងនៅក្នុងនគរផ្សេងៗ តែ ៣៥ ឆ្នាំទៀត ហើយទៅនៅនគរបាតលីបុត្ត ៤៥០ ឆ្នាំ ទៅនៅ លង្កាទ្វីប ២០៥ ឆ្នាំ ទៅនៅក្រុងអង្គរ ២០៧ ឆ្នាំ រួចទៅនៅក្រុងអយុធ្យាទៀត ។ ព្រះអង្គព្រះពុទ្ធ ធម៌រាជសាសនា កើតមានក្នុងទីនោះទៀត ។

ពុទ្ធសករាជ ៤៥០ ម.ស. ៣០០ ម.ស. ២២១ ឆ្នាំ ម៉ែ ឯកស័កនោះ ទ្រង់ចាតលីបុត្តបាត់គ្រាបតំណក់ព្រះធម៌ កើតចលាចល ។ ខណៈនោះ ព្រះចៅក្រុងបាតលីបុត្តឲ្យនាំគ្នាទៅអញ្ជើញ សុំអញ្ជើញព្រះកែវថ្វាយព្រះចៅក្រុងបាតលីបុត្ត

កាលព្រះពុទ្ធអង្គគង់មាននៅឡើយ បានតំកល់ព្រះពុទ្ធសាសនាក្នុងនគរលង្កានេះយ៉ាងមាំមួន ឥឡូវព្រះកែវមរកតកើតក្នុងនគរបាតលីបុត្រ ហើយនឹងទុកតំកល់នៅទីនេះ មិនគួរនឹងព្រះពុទ្ធអង្គដែលប្រតិស្ឋានមុកនេះ ។ ឥឡូវនេះ សូមទូលចំពោះព្រះពុទ្ធដីកានៃព្រះជិនមានបុណ្យ និងព្រះរាជហេតុរបស់យើង សូមអញ្ជើញព្រះកែវមរកតទៅតំកល់ទុកក្នុងលង្កាទ្វីប ឱ្យត្រូវនឹងព្រះពុទ្ធដីកានៃព្រះបរមគ្រូ ។ ព្រះចៅក្រុងបាតលីបុត្រ ព្រះអង្គជំនុំប្រមរសេនាមុខមន្ត្រីហើយថា ព្រះចៅក្រុងលង្កាមានសុភអក្សរមកនេះជាគួរនឹងព្រះពុទ្ធដីកាព្រះបរមរាជគ្រូពីកាល់ ហើយកាលព្រះមហានាគសេន ក៏សាងព្រះកែវមរកតនេះសោតបានទាយទុកថា ព្រះអង្គកែវមរកតនេះ នឹងនិមន្តទៅបំភ្លឺក្នុងទ្វីបលង្កា និងក្នុងព្រះមហានគរឥន្ទបត្តបុរី និងនគរក្រុងស្រីអយុធ្យានោះដែរ ។ ព្រះចៅក្រុងបាតលីបុត្រ ទ្រង់មេត្តាប្រណី ព្រះរាជបញ្ញានុវង្ស អញ្ជូលមហាសមាគមន៍ប្រណី ហើយត្រាស់បង្គាប់ព្រះមុខក្រសួង ឱ្យរៀបចំមនុស្សបុក និងចាំម៉ាលាយមង់សែនប្រាជ្ញាទ្រៀមសំរាប់ហែនោះ អញ្ជើញព្រះកែវមរកតចុះទៅតំកល់លើសំពៅព្រះទីនាំង មានសំពៅបារមីរាងហែទាំងហែក្រោយ អ្នកស្ដៅទាំងមន្ត្រីតូចធំ មហាសេនា ក៏ចេញពីកំពង់ទៅ ។ លុះទៅដល់កំពង់ក្រុងលង្កាហើយ ព្រះចៅក្រុងលង្កាឱ្យរៀបមនុស្សបុកនិងភ្លេងភ្លាត់មន្ត្រីតូចធំ ត្រៀមហែរឡើងទៅតំកល់ក្នុងព្រះមហាប្រាសាទ ។ ក្នុងថ្ងៃដែលព្រះកែវមរកតទៅដល់នោះ សេចក្ដីអស្ចារ្យ បានបញ្ចេញឱ្យភ្លឺពណ៌រស្មីចំអាកាស ៧ ពណ៌ ខាងក្រឡាលោហប្រថពី ៧ ពណ៌ផ្ទុកគ្នា ។

មហាជនទាំងពួង ក៏នាំគ្នាទូលបង្គំប្រគេនផ្កាធ្វើសក្ការបូជា មិនដែលខានរាល់វេលាឡើយ ។ ព្រះកែវមរកតឋិតក្នុងលង្កាទ្វីបនោះអស់ ៤៥០ ឆ្នាំ រួមព្រះពុទ្ធសករាជបាន ១៣០០ ឆ្នាំ ។ ព.ស. ១៣០០ គ.ស. ៧៥៧ ម.ស. ៦៧៩ ច.ស. ១៣៤ ឆ្នាំ ជូត ចត្វាស័ក ព្រះបាទអនុរុទ្ធ ព្រះចៅក្រុងពុកាមជាធំ រីព្រះចៅក្រុងមន មានឫទ្ធិអានុភាពប្រើនាគង់ព្រះទីនាំងអស្សដែលហោះហើរលើអាកាសបាន ។ ថ្ងៃមួយនោះ ទ្រង់នឹកក្នុងព្រះរាជហឫទ័យចង់បានព្រះត្រៃបិដកទាំង ៣ ទៅទុកតំកល់ក្នុងព្រះនគរ ទើបត្រាស់សួរសេនាថា ព្រះត្រៃបិដកនោះ ព្រះធម៌ណាទៅត្រឹមត្រូវជាង ទើបអស់នាម៉ឺនសព្វ មុខមន្ត្រី អ្នកប្រាជ្ញ រាជបណ្ឌិត ក្រាបបង្គំទូលថា ព្រះត្រៃបិដកទាំង ៤ នោះ នៅក្នុងលង្កាទ្វីបត្រឹមត្រូវជាង ហើយឮផងថាបានទាំងព្រះកែវមរកត ដែលសម្ដេចព្រះនាគសេនប្រតិស្ឋានសាងតាំងពីព្រះពុទ្ធសករាជ ៥០០ ឆ្នាំនោះ យកទៅតំកល់ទុកថែមទៀតផង ។ ទើបព្រះអង្គត្រាស់សួរថា ព្រះកែវមរកតនោះ មានឫទ្ធិអានុភាពដូចម្ដេច ? កាលកសាងនោះដូចម្ដេចខ្លះ ? មន្ត្រីក្រាបទូលថា ព្រះកែវមរកតនោះ មិនជាតែរូបប្រក្រតីឡើយ ចំពោះសម្ដេចព្រះឥន្ទ្រាធិរាជទេវតាំងតែកែវពូកពាណ់យក ដែលទេវតាទុកនៅភ្នំវិបុលបញ្ជូលមកដោយសម្ដេចព្រះនាគសេនរៀន ៖ ព្រះវិស្សកម្មទេវបុត្រ ក៏បានទៅសូមអារាធនាសាងដោយព្រះបង្គំរស់ ៧ យប់ ៧ ថ្ងៃ ទើបរួចស្រេច ហើយបញ្ចុះព្រះបរមសារីរិកធាតុ ៧ ព្រះអង្គក្នុងព្រះកែវមរកតនោះផង ។

កាលព្រះពុទ្ធសករាជ ៨០៥ នោះ ក្រុងបាតលីបុត្រកើតការយុទ្ធចំបាំងខ្លាំង ដោយកិច្ចកាត់ទឹកដីនឹងស្រុកក្នុងស្រុកលង្កានោះ ព្រះក្រុងលង្កាក្រែងអន្តរាយព្រះកែវមរកតនោះ បានទាក់ទាញឱ្យទៅសូមបញ្ជូនព្រះកែវមរកតនោះ ទៅតំកល់ទុកក្រុងលង្កាបាន ៤៥០ ឆ្នាំ ។

ព្រះបាទអនុរុទ្ធបានទ្រង់ជ្រាបហេតុប្រការដូច្នេះ រឹតតែមានព្រះរាជហឫទ័យចង់បានព្រះកែវមរកតនោះណាស់ ប្រមាណទើបព្រះអង្គឱ្យរៀបសំពៅព្រះទីនាំងគត់មួយ និងព្រះទីនាំងអស្ស រួចបាត់សម្ដេចព្រះពុទ្ធឃោសា និងព្រះមហាថេរ ៤

www.budinst.gov.kh www.elibraryofcambodia.org

ព្រះអង្គ ព្រមទាំងបរិវារសំរាប់សំពៅឱ្យទៅលង្កាទ្វីប ៣ ខែមុន ។ លុះនឹងដល់ទៅហើយ ទើបព្រះអង្គទ្រង់ត្រៀមព្រះមហាក្សត្រទ្រង់នូវព្រះខ័នកែវរតនមង្គល ហើយទៀតកត់យកព្រះទីនាំសេះស្តួរហោះទៅតាមផ្លូវអាកាស ។ លុះដល់ទៅក្រុងលង្កាហើយព្រះអង្គយាតចូលទៅគាល់ព្រះចៅក្រុងលង្កាក្រាសទោយផ្លូវព្រះរាជមេត្រីសុំចំលងព្រះត្រៃបិដកទាំង ៤ ព្រមទាំងសុំព្រះកែវមរកតផង ។ ព្រះចៅក្រុងលង្កា បានឃើញព្រះបាទអនុរុទ្ធហោះបានដូច្នោះ គិតខ្លាចអំណាចបារមី ក៏ក្រាបទូលថា សុំឱ្យមន្ត្រីក្រមព្រះរាជបណ្ឌិតចំលងថ្វាយ ព្រមទាំងព្រះកែវមរកតផង តាមសព្វព្រះរាជហឫទ័យ ។ ទើបព្រះបាទអនុរុទ្ធត្រាស់ថា " អរព្រះគុណនឹងព្រះមហាមិត្តណាស់តែចំលងតាមក្បួនលង្កានោះ ពុំកបើកិតមិត្តឃើញទៀយ សុំឱ្យក្រមព្រះរាជបណ្ឌិតធ្វើតយើងខារចំលងវិញ " ។ ព្រះចៅក្រុងលង្កាក៏ព្រមទើបព្រះបាទអនុរុទ្ធក្រាបទូលសម្តេចព្រះពុទ្ធឃោសាចារ្យ សូមព្រះអង្គឱ្យចំលងព្រះត្រៃបិដកទាំង ៤ ស្រេចកាលណាកាឱ្យអញ្ជើញទាំងព្រះកែវមរកតទៅដាក់ក្នុងសំពៅត្រឡប់ទៅវិញផង ។ ឯខ្លួនយើងមុនទៅព្រះដំណើរមុន ។ សម្តេចព្រះពុទ្ធឃោសា ក៏ចាត់ការឱ្យព្រះថេរៈ ៨ អង្គនិងក្រមព្រះរាជបណ្ឌិតចារចំលងព្រះត្រៃបិដកនោះលោកសរសេរសព្វស្រេចតែការនោះ មិនរួចកន្លងទេ ។ ការចារនេះអស់ ៧ ខែ រួចជាស្រេច ។

ព.ស ១៣០១ គ.ស ៧៥៨ ម.ស ៦៨៥ ច.ស ១២៨ ឆ្នាំជូតបញ្ចស័កនោះ ព្រះបាទ ធម្មិកសុរិយាវង្សដែលគ្រងរាជ្យនៅឥន្ទបត្តបាន ២២ ឆ្នាំ ព្រះជន្ម ៥០ ឆ្នាំ ។ ក្នុងគ្រានោះ ព្រះពុទ្ធឃោសា ព្រះអង្គអញ្ជើញព្រះវិន័យបិដកមួយចប់ ព្រះអភិធម្មបិដកមួយចប់ ព្រះកែវមរកតមួយ និងព្រះឧណ្ហីសជាតុព្រះគោតមស្សរៈ ១១ ព្រះអង្គកែវព្រះភ្លើង ១ ព្រះអង្គដាក់សំពៅជាមួយនឹងព្រះអង្គគង់ ព្រមទាំងមហាថេរ ៥ អង្គផង ហើយអញ្ជើញព្រះសុត្តន្តបិដក ១ ចប់ ព្រះនិរុត្តបិដក ១ ចប់ ព្រមទាំងព្រះមហាថេរ ៣ ព្រះអង្គ ដាក់ក្នុងសំពៅមួយទៀតដែរ ហើយបើកចេញពីក្រុងលង្កាទ្វីបទៅ ។ នោះជាបុណ្យរបស់ព្រះរាជបូរីនគរក្រុងកម្ពុជាធិបតី សំពៅមួយដែលដាក់ព្រះសុត្តន្តបិដកនិងព្រះនិរុត្តបិដកនោះ ខ្យល់បក់ជាត់ទៅកាន់នគរ...វិញ ។ សំពៅមួយដែលដាក់ព្រះកែវមរកត និងកែវព្រះភ្លើង ព្រះឧណ្ហីសជាតុ និងវិន័យបិដក ព្រះអភិធម្មបិដកនោះ ខ្យល់បក់ជាត់ទៅកាន់នៅកោះគោកធ្លក ក្នុងកម្ពុជាធិបតី ។ សំពៅនោះទៅកប៉ាល់បន្តដល់ការប្តូរព្យុះធ្លាយអស់ទៅ ហើយលិចនៅត្រង់កោះគោកធ្លក ។

សម្តេចព្រះពុទ្ធឃោសា ៥ ព្រះអង្គ និងអ្នកក្នុងសំពៅនោះនាំគ្នាហែលទៅដល់ច្រាំង គង់នៅលើកោះគោកធ្លកនោះ ។ ពួកអ្នកស្រុកឃើញ ព្រះថេរៈមានអានុភាពប្រសើរ ហើយអញ្ជើញព្រះត្រៃបិដក ព្រះធាតុ ព្រះឧណ្ហីសជាតុ និងព្រះកែវព្រះភ្លើង ព្រមទាំងកែវមរកតផង ក៏ចូលទៅរាយការណ៍ថ្វាយព្រះមហាក្សត្រ ។

គ្រានោះសម្តេចព្រះពុទ្ធឃោសា ព្រះអង្គសាងព្រះអារាម ១ ដាក់ព្រះត្រៃបិដកឱ្យហៅថាវត្តលង្កា ឱ្យសាងព្រះអារាម ១ ទៀត ដាក់ព្រះធាតុនិងព្រះឧណ្ហីសជាតុ ឱ្យហៅថាវត្ត ឧណ្ណាលោម ឱ្យសាងព្រះអារាម ១ ទៀត ដាក់ព្រះកែវព្រះភ្លើងឱ្យហៅថាវត្ត កែវព្រះភ្លើង ឱ្យសាងព្រះអារាម ១ ទៀត សម្រាប់ព្រះអង្គគង់សាងព្រះ...

អតីតនៃស្រុកបាត់ដំបងហៅថា ព្រះពុទ្ធឃោសា ឱ្យសាងព្រះអារាម ១ ទៀតសំរាប់ព្រះកែវមរកតដាក់នាមហៅថា វត្តព្រះពុទ្ធ ម.នបុណ្យគឺតាមនាមព្រះអង្គ និងព្រះកែវមរកត ដែលបានបុណ្យនោះ ។ សេចក្តីដែលព្រះពុទ្ធឃោសាមកតាំងអារាម គឺគល់ព្រះពុទ្ធសាសនានេះ បានឱ្យរីកសុះសាយណាស់ ។

សម្តេចពាន់ល្បាក់ចារក្សត្រ ចៅហ្វាយស្រុកបូស៊ីកែវ មានសំរាប់ច្បាំងសុំឱ្យរស់ក្រមជីវិត នាំយកសេចក្តីក្រាបបង្គំ ទូលព្រះចៅទេវរាជបរមបពិត្រ ជាម្ចាស់ជីវិតលើត្បូង សូមទ្រង់ប្រោសប្រោសប្រណី ។ ព្រះមហាក្សត្រិយ៍ទ្រង់ព្រះអំណរណាស់ ព្រះរាជបញ្ជាឱ្យមុខងារក្រសួងព្រះសង្ឃឱ្យបញ្ជូនព្រះនាង ព្រះបានពិធីបង្គុំអបអរ ស្តេចឡើងគង់ព្រះទីនាំងរួមលើករស់ រាជាធិការ ទៅចូលគាល់ព្រះអារាមទាំង ៥ នោះ ។ ចំណែកផ្នែកធ្វើការ ព្រះអង្គកែងសំឡូអក្សរទៅថយក្រុមមិថិលា សុំជាងចំនួន ១០០ នាក់ តាំងភិក្ខុមួយឱ្យនៅធ្វើការ ។ ចិភិក្ខុនោះមានឈ្មោះថា ភូមិ ចិនជំរែក ទៀបមកដល់សព្វថ្ងៃ ។ ទ្រង់ឱ្យសាងព្រះអារាមនោះអស់ ៣ ឆ្នាំ ទ្រង់ប្រោសប្រោសប្រទាន ធ្វើបុណ្យឆ្លងរោងជាធំដុំឱ្យរីក ចំណាយព្រះរាជទ្រព្យ ក្នុងព្រះភិក្ខុសង្ឃ និងព្រះរាជអង្គទាំងពួងឱ្យរីក ។ អស់កាលតាំងពីនោះមក នានាកេរ្តិ៍ឈ្មោះល្បីល្បាញសុខស្រួលបញ្ចប់ [illegible] ។

ព.ស.១៣០៨ គ.ស.៧៦៥ ម.ស.៦៨៧ ច.ស.១០៧ ឆ្នាំថោះ ឆស័ក ព្រះបរមនាថបពិត្រ ក្រាបទូល សម្តេចព្រះពុទ្ធឃោសាថា សូមនិមន្តព្រះអង្គ និងព្រះត្រៃបិដក ព្រះកែវមរកតមួយទៅលង្កាទ្វីបព្រះនគរ ។ ទើបសម្តេចព្រះពុទ្ធឃោសា ព្រះអង្គក៏ត្រាស់តាមព្រះរាជបណ្ឌិត ហើយព្រះអង្គតាំងព្រះមហាថេរទាំង ៥ ព្រះអង្គ ជាព្រះរាជាគណៈ ចំនួន ឱ្យនៅថែរក្សាចាត់ចែងកិច្ចការព្រះអារាមទាំង ៥ នោះ ។ ទើបព្រះអង្គឱ្យ ម្រៀបចំព្រះនាវាសំពៅមុខ អភិរម្យសែនខ្ពង់ខ្ពស់ មុតមរកត ទុកដាក់ព្រះត្រៃបិដក និងព្រះកែវនោះ ព្រមដោយនូវគ្រឿងក្ដាត់ គួរក្រោយប្រាក់ចំណីក កងរែងចូលក្នុងព្រះនគរ ហើយព្រះអង្គបង្ហោយនាវានោះ ជាអន្តរាយសម្តេចព្រះពុទ្ធឃោសា ប្រតិបត្តិរក្សាព្រះត្រៃបិដកនោះ ។ ទ្រង់តាំងសម្តេចព្រះពុទ្ធឃោសា ជាសម្តេចព្រះសុគន្ធាធិបតី ជាមេឡនាយកឱ្យសំរេចរាជក្រសួងសង្ឃទាំងឡាយ ហើយព្រះអង្គនៅព្រះរាជវាំង ជាមាត្យទៅតាំងនៅការងារនេះវិញ ។ ព្រះត្រៃបិដកទាំងឡាយនោះ ព្រះអង្គឱ្យដាក់បេតងាក់និងស៊ីកឹល ១ គប់ ស៊ីក្រូចាំ ១ គប់ ស្លឹកមាស ១ គប់ ពិតរបទុកក្នុងតូប ។ ព្រះអង្គឱ្យសាងព្រះសាទ ១ ពីធ្ ក៏ធ្វើអង្គាស់ខ្ទង់ជាថ្មីវិញ ហើយតំកល់ ព្រះកែវមរកត ចាត់ឱ្យក្រុមព្រះរាជវង្ស ថែរក្សាតាមរបៀបថ្មី ។ ព្រះរាជការទ្រង់ព្រះអំណរហើយ ព្រះអង្គប្រជុំភាគពលរាជ ព្រមទាំងរាជមកធ្វើបុណ្យសម្ពោធ ព្រះត្រៃបិដក និងព្រះកែវមរកតនោះ ជាអស្ចារ្យឱ្យរីក សម្រេចបានប្រមាណជាង ៧ ខែ ទើបសំរេចបុណ្យនោះ ។

២- ប្រវត្តិនៃព្រះសក្យមុនីចេតិយ :

ព្រះចេតិយនេះ បានមាននាមថា "ព្រះសក្យមុនីចេតិយ" ព្រោះជាព្រះចេតិយដែលព្រះពុទ្ធបរិស័ទបានកសាងទុក ជាទីរម្លឹក និងជាទីគោរព បំពេញផ្ទៃដែលព្រះបរមសារីរិកធាតុនៃព្រះសក្យមុនីសម្មាសម្ពុទ្ធ និងព្រះសារីរិកធាតុនៃព្រះសារីបុត្រ ព្រះមោគ្គល្លានជាអគ្គសាវ័កទាំងពីរ បាននិមន្តពីប្រទេសសិរីលង្កាមកប្រជាប់នៅក្នុងព្រះរាជធានីភ្នំពេញ អស់រយៈវេលា ៧ ថ្ងៃ ៧ យប់ គឺពីថ្ងៃ អាទិត្យ ទី ៥ ដល់ ថ្ងៃ សៅរ៍ទី ១១ តុលា ព.ស.២៤៩៦ គ.ស.១៩៥២ ទើបបាននិមន្តត្រឡប់ទៅប្រទេសសិរីលង្កាវិញ ។

www.budinst.gov.kh www.elibraryofcambodia.org

ក្នុងកាលដែលព្រះបរមសារីរិកធាតុនៃព្រះសម្មាសម្ពុទ្ធ និងព្រះសារីរិកធាតុនៃព្រះសារីបុត្រព្រះមោគ្គល្លាន ជាអគ្គសាវកទាំងពីរ និមន្តមកដល់នោះ ពុទ្ធបរិស័ទនៅប្រទេសកម្ពុជាទាំងព្រះរាជា ទាំងប្រជារាស្ត្រ មានសេចក្តីជ្រះថ្លាបរិមាកក្រៃកើតរំពើកទូទាំងប្រទេស នាំគ្នាច្រើនម៉ឺននាក់ មកធ្វើសក្ការបូជាដោយមហោឡារសក្ការៈគ្រប់យ៉ាង មានមាសប្រាក់ជាដើម ។ បណ្ណាសក្ការៈទាំងនោះ ធំណែកខាងប្រាក់បានមូលរួម ប្រាំមួយសែន ប្រាំមួយម៉ឺន ប្រាំពីរពាន់ បីរយ ប្រាំបួនរៀល ម្ភៃមួយសេន (១.៦៦៧ ៣០៩' ២១ ) ។

គ្រានោះគណៈកម្មការបុណ្យ បានចែករំលែកចំនួនប្រាក់នោះជាចំណែកផ្សេងៗ តាមស្ថានដែលត្រូវចែកទាំងក្នុងប្រទេសទាំងក្រៅប្រទេស រីក្នុងប្រទេសជាអាទិ៍ គឺមួយចំណែក ចំនួនកៅសិបម៉ឺនរៀល (៩.០០.០០០') ជាតំការសាងមន្ទីរពេទ្យព្រះសង្ឃពុទ្ធសាសនិក នៅក្រុងភ្នំពេញ ។ មួយចំណែកទៀត ចំនួនម្ភៃម៉ឺនរៀល (២០០.០០០') ជាតំការសាងព្រះសម្មាសម្ពុទ្ធចេតិយានៈ សំរាប់តំកល់ព្រះបរមសារីរិកធាតុ ។

នៅជុំវិញនៃទួលព្រះសម្មាសម្ពុទ្ធចេតិយ មានរូបចំលាក់រឿងពុទ្ធប្រវត្តិ គ្រប់កាលដែលទ្រង់ប្រសូត ទ្រង់ចេញសាងព្រះផ្នួស ទ្រង់សំដែងព្រះធម្មចក្រ ទ្រង់បរិនិព្វានជាមុខចតុរស្សន្ធាន ជាប្រាសាទសំរាប់ជាទីធ្វើសក្ការបូជា ។

នៅវេលាធ្វើបុណ្យឆ្លងព្រះសម្មាសម្ពុទ្ធចេតិយានេះ ពុទ្ធបរិស័ទបានរៀបចំតំកល់ព្រះបរមសារីរិកធាតុ ក្នុងព្រះចេតិយមាស. តំកល់ព្រះចេតិយមាសក្នុងព្រះស្តូបសិរីធ្ងន់ ១០០ គីឡូក្រាមដែលបានដាក់នាមថា " ព្រះសម្មាសម្ពុទ្ធចេតិយ " ហើយបានតំកល់ព្រះស្តូបសិរីនោះ នៅក្នុងព្រះសម្មាសម្ពុទ្ធចេតិយ ដែលធ្វើអំពីថ្មកែវមានកំពស់ ១៥ ម៉ែត្រ ទទឹង ៧ ម៉ែត្រ ។

បុណ្យនេះ ជាបុណ្យធំក្រៃលែងរបស់កម្ពុជរដ្ឋ រាជរដ្ឋាភិបាលបានចាត់ចែងធ្វើឡើងក្នុង ព្រះបរមរាជូបត្ថម្ភនៃព្រះករុណាជាម្ចាស់ជីវិតលើត្បូងធ្វើអស់ពេលវេលា ៧ ថ្ងៃ គឺតាំងពីថ្ងៃ នៅថ្ងៃអាទិត្យ ១៤ កើត ខែ ពិសាខ ឆ្នាំរកាឯកស័ក ព.ស.២៥០០ ត្រូវនឹងថ្ងៃទី ១២ ឧសភា គ.ស.១៩៥៧ ដល់ថ្ងៃសៅរ៍ ៤ រោច ខែពិសាខ ត្រូវនឹងថ្ងៃទី ១៨ ខែ ឆ្នាំដដែលជាថ្ងៃផុតបុណ្យ ។

បុណ្យនេះមានទិសៈ ២ ផ្នែក គឺ :

១ _ បុណ្យ ព.ស. ២៥០០ ឬបុណ្យកន្លះពុទ្ធកាលនៃពុទ្ធសាសនា ។

២ _ បុណ្យឆ្លងព្រះសម្មាសម្ពុទ្ធចេតិយតំកល់ព្រះបរមសារីរិកធាតុ ។ បុណ្យទាំង ២ ផ្នែកនេះ ប្រព្រឹត្តទៅត្រង់ព្រះសម្មាសម្ពុទ្ធចេតិយត្រង់មុខស្ថានីយ៍រទេះភ្លើង ក្រុងភ្នំពេញ ។

នៅឱកាសបុណ្យទាំង ២ ផ្នែក ព្រះរាជធានីភ្នំពេញបានផ្លាស់ទេសភាព និងបរិយាកាសថ្មីស្រស់ស្អាត ហើយនៅពិធីការជុំវិញព្រះសម្មាសម្ពុទ្ធចេតិយដែលជាទីប្រជុំនៃការបុណ្យនោះ មានការលេងល្បែងសប្បាយៗ ល្ខោន ល្ខោន ។ ល ។

[illegible] ព្រះសម្មាសម្ពុទ្ធចេតិយសំដែងរឿងដោយរបាំជាតិ ចំរៀងខ្មែរ និងភ្លេងខ្មែរ [illegible] ផ្សេងៗ ។ ល ។ [illegible] ប្រជាជននានា និងពុទ្ធបរិស័ទ ទាំងបព្វជិត ទាំង [illegible] ទាំងក្នុង និងអំពីប្រទេស ពុទ្ធសាសនិកនានា ពីក្រៅប្រទេស [illegible] [illegible] [illegible] និងប្រតិភូព្រះសង្ឃនានា [illegible]

[illegible] ។

www.budinst.gov.kh www.elibraryofcambodia.org

ក្រៅពីការរៀបរៀងដោយរបៀបដូចខាងលើនេះ មានភាពរុងរឿងដោយក្បួនហែយ៉ាងធំអស្ចារ្យ ៤ កើតទៀត គឺក្បួនហែជើងគោកជុំវិញរាជធានីភ្នំពេញ និងក្បួនហែជើងទឹកតាមដងទន្លេ ដូចមានចែងដោយពិស្តារក្នុងពិធីបុណ្យឯមហាភាពសព្វគ្រប់រួចស្រាប់ ។

នៅថ្ងៃ ១៥ កើត ខែ ពិសាខ ជាថ្ងៃពេញបូណ៌មី ពុទ្ធបរិស័ទ ទាំងបព្វជិត ទាំងគ្រហស្ថ តែងនាំគ្នាទៅប្រជុំថ្វាយគ្រឿងសក្ការបូជាផ្សេងៗ ធ្វើកិច្ចនមស្ការចំពោះព្រះសក្យមុនីចេតិយ ហើយធ្វើទានដាក់បាត្រដល់ព្រះសង្ឃជាច្រើនអង្គ ក្រោមព្រះរាជូបត្ថម្ភដ៏ខ្ពង់ខ្ពស់នៃសម្តេចព្រះមហាក្សត្រិយានី និងសម្តេចព្រះប្រមុខរដ្ឋជារៀងរាល់ឆ្នាំ ដែលមានចែងទុកក្នុងព្រះរាជក្រឹត្យលេខ ៧៣ ន.ស. ចុះថ្ងៃទី ២៤_១_៥៨ ។

អប្បមាទោ អមតំ បទំ
បមាទោ មច្ចុនោ បទំ
ការមិនធ្វេសប្រហែស ជាផ្លូវមិនស្លាប់
ការធ្វេសប្រហែស ជាផ្លូវនាំឱ្យស្លាប់

## ៣_ ប្រវត្តិព្រះឧបោសថរតនារាម ( ព្រះវិហារព្រះកែវមរកត ) :

ភាគជ័យឧក្ខទស្សិកតែ

ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តមបរមទេវតា ព្រះចៅក្រុងកម្ពុជាធិបតី ព្រះសុវណ្ណកោដ្ឋ ទ្រង់មានព្រះសទ្ធាជ្រះថ្លា ជឿជាក់យ៉ាងមុតមាំក្នុងព្រះពុទ្ធសាសនា ទ្រង់មានព្រះតំរិះយល់ឃើញថា វិហារទានជាផលានិសង្សដ៏ខ្ពង់ខ្ពស់ ព្រមទាំងជាកុសលផង ។ ហើយមានប្រយោជន៍ពិសេស ជាគោលចារឹកយ៉ាងមាំ ទុកឱ្យអនុជនក្នុងអនាគតយល់ថា ប្រទេសកម្ពុជាយើង ជាប្រទេសកាន់ព្រះពុទ្ធសាសនាដោយពិតប្រាកដណាស់ ទាំងប្រជាជាតិ និងព្រះមហាក្សត្រ ។

ដោយមានព្រះបញ្ញាញាណដូច្នេះ ទ្រង់បានឱ្យប្រជុំសេនាបតី មន្ត្រីគ្រប់ជាន់ខាងគ្រហស្ថ និងខាងព្រះសង្ឃមានសម្តេចព្រះសង្ឃនាយកទាំងពីរគណៈជាដើម ឱ្យមកចូលជុំចំពោះព្រះភក្ត្រ ហើយទ្រង់បានថ្លែងព្រះរាជបំណងនេះ ប្រទានដល់ក្រុមជំនុំដោយសព្វគ្រប់ លុះក្រុមជំនុំថ្វាយសេចក្តីយល់ព្រមតាមព្រះរាជបំណងហើយ ទ្រង់ត្រាស់ឱ្យចាប់ផ្តើមកសាងព្រះវិហារ

www.budinst.gov.kh www.elibraryofcambodia.org

នៅក្នុងឆ្នាំ រោង ចត្វាស័ក ព.ស.២៤៣៦ គ.ស.១៨៩២ រៀងរហូតមកដល់ ព.ស.២៤៤៦ គ.ស.១៩០៣ ហើយជាស្រេច ។ ទើបតំកល់ព្រះពុទ្ធរូបព្រះកែវមរកត ដែលជាសំណាក និងតំកល់ព្រះពុទ្ធរូប ទ្រង់តំកល់ព្រះសណ្ឋិតសាងអំពីមាសសុទ្ធទំងន់មួយហាបមួយចុង ។ ព្រមទាំងសាងមន្ទីរសំរាប់តំកល់ព្រះត្រៃបិដក តំកល់ព្រះពុទ្ធបាទ និងមន្ទីរព្រះសុធម្មផង ដោយទ្រង់ធ្វើបុណ្យឆ្លងបញ្ចុះសីមារួចជាស្រេច ក្នុងឆ្នាំដែលសាងព្រះវិហារហើយ ( [៣៨] )

៩. វត្តបទុមវតីរាជវរារាម :

វត្តបទុមវតីរាជវរារាមសព្វថ្ងៃនេះ ជាកេរ្តិ៍ដំណែលវត្តចាស់បុរាណមាននាមហៅថា វត្តខ្ទមតាយ៉ង កើតមានជាយូរអង្វែងជាង ៤០០ ឆ្នាំមកហើយ ។

កាលព្រះបាទសម្តេចព្រះបរមរាជា ពញាយ៉ាត ទ្រង់មកសាងក្រុងភ្នំពេញជាដំបូង ក្នុងឆ្នាំថោះ សប្តស័ក ព.ស. ១៩៧៩ គ.ស.១៤៣៥ ។ គ្រានោះ ព្រះអង្គទ្រង់ត្រាស់បង្គាប់ឱ្យចឹកព្រែក លើកថ្នល់ ទ្រង់ឱ្យសាងវត្តជាច្រើននៅក្នុងក្រុង មានវត្ត ខ្ទមតាយ៉ង ដែលស្ថិតនៅទិសខាងត្បូងព្រះបរមរាជវាំងចតុមុខ គឺវត្តបទុមវតីរាជវរារាមសព្វថ្ងៃនេះជាដើម ។ វត្តនេះទ្រង់ឱ្យគេសាងក្នុងឆ្នាំកុរ បញ្ចស័ក ព.ស.១៩៨៦ គ.ស.១៤៤៣ ( [៣៩] )

## អំពីវត្តខ្ទមតាយ៉ង

ដើមហេតុដែលឱ្យឈ្មោះថាវត្ត ខ្ទមតាយ៉ង ព្រោះដីវត្តនោះ កាលដើមឡើយជាដីចំការរបស់តាយ៉ង ហើយគាត់បានចឹកខ្ទមមួយនៅខាងត្បូងចំការនោះបានឱ្យឈ្មោះវត្ត ខ្ទមតាយ៉ង ។

## អំពីវត្តបទុមវតីរាជវរារាម

ដើមហេតុដែលបានប្រែនាមវត្ត ខ្ទមតាយ៉ងមកថា វត្តបទុមវតីរាជវរារាមវិញនោះ មានសេចក្តីអធិប្បាយដូចតទៅនេះ :

ចំណេរកាលពីព្រះបាទសម្តេចព្រះបរមរាជា ពញាយ៉ាតមក មានព្រះមហាក្សត្រជាច្រើនអង្គ គង់នៅក្រុងភ្នំពេញនេះជាប់រៀងរហូតមកដល់ព្រះបាទសម្តេចព្រះស្រីសុគន្ធបទ ។ ក្រោយមក ទ្រង់បោះបង់ចោលទីក្រុងភ្នំពេញទៅសាងទីក្រុងថ្មីនៅទួល បាសាន ខេត្តស្រីសន្ធរ ដំណេរពីនោះមក ព្រះមហាក្សត្រអង្គក្រោយៗ បានផ្លាស់ទីក្រុងទៅសាងក្នុងខេត្តផ្សេងៗទៀតជាច្រើនរហូតមកដល់សាងទីក្រុងឧដុង្គមានជ័យ ។ ចំណេរកាលពីនោះមកទៀត ព្រះបាទសម្តេច ព្រះនរោត្តមបរមរាមទេវតា ទ្រង់បានបោះបង់ទីក្រុងឧដុង្គមានជ័យ មកសាងទីក្រុងនៅភ្នំពេញវិញជាគ្រាទីពីរ ក្នុងឆ្នាំឆ្លូវ សប្តស័ក ព.ស.២៤០៨ និង គ.ស.១៨៦៥ ។ គ្រានោះព្រះបាទសម្តេចព្រះ នរោត្តម ទ្រង់បាននិមន្តសម្តេចព្រះសុគន្ធាសង្ឃរាជាធិបតី ព្រះនាមបញ្ញាសិលោ "ទៀង" ពី វត្តព្រះរាជទ្រព្យ "វត្តអំពិលបី" ក្រុងឧដុង្គមានជ័យឱ្យមកគង់នៅវត្តខ្ទមតាយ៉ង ដែលជាវត្តបទុមវតីរាជវរារាមសព្វថ្ងៃនេះឯង ។

---

[៣៨] ឧកញ៉ា បញ្ញាធិបតីអ៊ុក ម៉ុក ទស្សនាវដ្ដីកម្ពុជសុរិយា លេខ ៧/១៩៦២ ទំព័ ៣៧

[៣៩] សម្តេចព្រះសុធម្មាធិបតី ភុល ទេស ទស្សនាវដ្ដីកម្ពុជសុរិយា លេខ ៧/១៩៦២ ទំព័ ៣៨

www.budinst.gov.kh www.elibraryofcambodia.org

គ្រានោះ វត្តខ្ពបតាយ៉ង ដែលជាវត្តចាស់បុរាណ ពុំមានកុដិ សាលា វិហារជា ទៅក្ដីដែលចាស់ណាស់សល់ទេ ទាំងភិក្ខុ សាមណេរ សូម្បីតែមួយអង្គក៏គ្មានដែរ ។ វត្តចាស់នេះ ក្លាយទៅជាទីមានព្រៃស្បាតសុទ្ធសាធទៅវិញ ព្រោះគេបានបោះបង់ចោលជាច្រើនរយឆ្នាំមកហើយ ។ ប៉ុន្តែគេដឹងថា កន្លែងនេះជាវត្តចាស់បុរាណ ដោយគេបានឃើញក្នុងច្បាប់ព្រះរាជពង្សាវតារផង គេបានសង្កេតឃើញដីទួលមួយខ្ពស់ជាងគេ ដែលអាចសន្និដ្ឋានបានថា ជាទីព្រះវិហារផង ហើយលើដីទួលនោះ មានរោងប្រក់ស្លឹកមួយតូច នៅក្នុងរោងនោះ មានព្រះបដិមាតូចមួយព្រះអង្គ មានថែនថ្មសន្លឹកសីមាមួយផ្ទាំងនិងថ្មភោលមូលៗជាច្រើនជុំនៅលើទួលនោះទៀតផង ។ នៅទិសខាងកើតមុខទួលនោះ មានខ្ពបតូចមួយដែរ នៅទិសខាងត្បូងមានខ្ពបមួយធំជ្រៅដែលបង្ហោចតាយ៉ង កាត់ទឹកសំរាប់យកទឹកស្រោចដំណាំកាត់ ។ ឯទឹកនោះ មានទាំងរដូវប្រាំងវស្សា ពុំដែលរីងស្ងួតទេហើយថ្លាស្អាតផង ។ អ្នកស្រុកតែងដងទឹកនោះយកទៅប្រើប្រាស់ធម្មតាបាន ។

គ្រានោះ ព្រះបាទសម្ដេចព្រះនរោត្តម ទ្រង់ត្រាស់បង្គាប់ឱ្យមេការដឹកជញ្ជូនឈើ ព្រះរាជទ្រព្យពីក្រុងឧដុង្គមានជ័យ មកសាងកុដិ សាលា វិហារ នៅលើដីទួលនោះ ទ្រង់ឱ្យចៅកូ "ស្វាមភ្លោះ" ជាមេចាំង ខាងលើ ជីកខ្ពបចាស់នេះឱ្យជ្រៅថែមទៀតដើម្បីយកដីទៅចាក់បំពេញទីទួល និងរៀបចំទីទួលនោះឱ្យធំទូលាយឡើង ហើយទ្រង់ឱ្យនាំពុកក្លុងស្វាមភ្លោះទាំងនោះ ។ លុះរៀបចំវត្តបានរួចសព្វគ្រប់ហើយ ទ្រង់ក៏ត្រាស់ធ្វើពិធីបុណ្យបញ្ចុះសីមា ឆ្លងព្រះវិហារ កុដិ សាលា ។ ពេលនោះហើយ ដែលបានប្រែនាមវត្តខ្ពបតាយ៉ងមកជា វត្តបុទុមវតីរាជវរារាមវិញ ប្រែជាវត្តមានឈ្មោះជាងមុន ជាអារាមដ៏ប្រសើររបស់ព្រះរាជា រាប់រហូតមកដល់សព្វថ្ងៃនេះ ។

សម្ដេចព្រះសុគន្ធាសង្ឃរាជាធិបតី ព្រះនាមបព្វជិតជា "ពាន" ជាសង្ឃរាជទី ១ នៃព្រះសង្ឃខាងគណធម្មយុត្តិកនិកាយ និងមានព្រះឋានៈជាចៅអធិការទី ១ នៃវត្តនេះ សម្ដេចបានញ៉ាំងពុទ្ធបរិស័ទឱ្យមានសទ្ធាជ្រះថ្លាណាស់ក្នុងធម្មវិន័យ ដោយការបំពេញព្រះបរិយត្តិធម៌ ព្រមទាំងប្រតិបត្តិធម៌ ជាគំរូជាប់រៀងមក ។ លុះដល់មកឆ្នាំ កុរ នព្វស័ក ព.ស ២៤៣០ គ.ស.១៨៨៧ ព្រះបាទសម្ដេចព្រះនរោត្តម ទ្រង់បានបញ្ជាការឱ្យដាំដើមព្រះពោធិព្រឹក្សមួយដើមនៅខាងមុខព្រះវិហារ ដែលសមណទូតលង្កាទ្វីប បាននាំពីលង្កាទ្វីបមកថ្វាយព្រះអង្គ ជាមួយនឹងព្រះបរមសារីរិកធាតុ និងព្រះអរហន្តធាតុ ។ បន្ទាប់ពីនោះមក សម្ដេចព្រះសុគន្ធាសង្ឃរាជាធិបតី ទ្រង់បានបញ្ជាការឱ្យស្ថាបនាព្រះមហាចេតិយមួយនៅខាងត្បូងព្រះវិហារ ដើម្បីបញ្ចុះព្រះបរមសារីរិកធាតុ និងព្រះអរហន្តធាតុនោះទៀត ។ ប៉ុន្តែ ទ្រង់នឹងព្យាបាលសាងឡើង ក៏ទ្រង់មានអាពាធចូលព្រះនិព្វានទៅ ទើបសម្ដេចព្រះមង្គលទេពាចារ្យ ព្រះនាម "កង្កុ អៀម" ដែលបានទទួលឋានន្តរស័ក្តិ ជាសម្ដេចព្រះសង្ឃនាយកទី ២ បានបញ្ជាការស្ថាបនាតទៅទៀត ដោយរួបរួមជាមួយព្រះវង្សានុវង្ស ព្រមទាំងពុទ្ធបរិស័ទទាំងឡាយជាច្រើន បានសំរេចសព្វគ្រប់ ។ ព្រះមហាចេតិយនេះ មានកំពស់ពីគ្រឹះរហូតដល់ស្ដូបកំពូល ៣៣ ម៉ែត្រ សណ្ឋានបុទុមផ្ទុំ (១៧ x ៤ = ៦៨ ម៉ែត្រ) មានចេតិយតូចៗជាបរិវារ អមព្រុំជ្រុងទាំង ៤ អង្គមួយៗកំពស់ ៦ ម៉ែត្រ នៅត្រង់ចន្លោះអង្គចេតិយតូចនិមួយៗនោះ មានច្រកចូលទាំង ៤ ជ្រុង បែរចេញទៅតាមទិសទាំងបួន ។

www.budinst.gov.kh www.elibraryofcambodia.org

លុះដល់ឆ្នាំ រកា ឯកស័ក ព.ស.២៤៥២ គ.ស.១៩០៩ ព្រះបាទសម្តេចព្រះស៊ីសុវត្ថិ និងសម្តេចព្រះមង្គលទេពាចារ្យ "កុង យ៉ុក" ទ្រង់បានធ្វើបុណ្យបញ្ចុះព្រះសារីរិកធាតុ និងព្រះអដ្ឋិធាតុនៅផ្នែកខាងលិច ព្រមទាំងអដ្ឋិធាតុសម្តេចព្រះសុគន្ធាធិបតីនៅផ្នែកខាងត្បូង ។

លុះដល់ឆ្នាំ ឆ្លូវ សប្តស័ក ព.ស.២៤៨០ គ.ស.១៩៣៧ ព្រះបាទសម្តេចព្រះស៊ីសុវត្ថិមុនីវង្ស និងសម្តេចព្រះមង្គលទេពាចារ្យព្រះនាម "ចន្ទ្រាធិតេព្យ" ដែលជាសម្តេចព្រះសង្ឃនាយកទី ៣ ទ្រង់បានចាត់ការឱ្យរុះរើព្រះវិហារចាស់ចេញ ហើយសាងឡើងជាថ្មីដោយបេតុង និងស៊ីម៉ង់ត៍វិញ ដោយមានពុទ្ធបរិស័ទ ប្រជាពលរដ្ឋគ្រប់ជាន់ថ្នាក់ បានចូលរួមបច្ច័យក្នុងការកសាងនោះជាមួយនឹងព្រះអង្គផង ។

លុះដល់ឆ្នាំ រោង ចត្វាស័ក ព.ស.២៤៩៦ គ.ស.១៩៥២ ពុទ្ធបរិស័ទទាំងឡាយ មានឯកឧត្តម ញឹក ទួច ជាប្រធាន បានកសាងសាលាបរិយត្តិធម្មមួយខ្នងដែលមានពីរជាន់ និងសាងថាវរវត្ថុផ្សេងៗពីរកើតទៀតជាច្រើន មានសាលាភិក្ខុ សាលាទីធាតា និងកុដិភិក្ខុជាដើម ក្នុងរជ្ជកាលព្រះបាទសម្តេចព្រះនរោត្តមសីហនុវរ្ម័ន និងក្នុងសម័យសម្តេចព្រះសុគន្ធាធិបតី ព្រះនាម "ពុទ្ធទារោ រឿង ស្រី" ដែលជាសម្តេចព្រះសង្ឃនាយកទី ៤ ។

វត្តបទុមវតីរាជវរារាមនេះ ជាវត្តតំណាងគណៈធម្មយុត្តិកនិកាយ ក្នុងព្រះរាជាណាចក្រកម្ពុជា ប្រកបដោយសង្ឃដ៏សោភា និងមនុស្សារីជោផ្ទាន ២ ខាង គួរជាទីត្រេកត្រអាលនៃពុទ្ធបរិស័ទទាំងឡាយ និងជាទីគង់នៅនៃព្រះមហាថេរ ជាប្រធាននៃសង្ឃមណ្ឌលគណៈធម្មយុត្តិ មានសមណស័ក្តិជា សម្តេចព្រះសង្ឃនាយកដែលព្រះមហាក្សត្រជាព្រះរាជាធិបតីទ្រង់តែងតាំងឡើង ដោយមានព្រះរាជក្រឹត្យ និងតាមពិធីផងដែរ ។ តាំងពីដើមរៀងមក មាន ៥ ព្រះអង្គហើយ គាត់ទាំង ៥ ព្រះអង្គ និងសម្តេចសង្ឃនាយកដែលមានងារសក្តិជា សម្តេចព្រះសុគន្ធាធិបតីព្រះនាម "..." ក្នុងសម័យបច្ចុប្បន្ននេះ ។

## អតីតមហាសីមា

វត្តបទុមវតីរាជវរារាមនេះ មានមហាសីមាទំហំទទឹង ៥ ស៊ិន ពី ១៦០ ម៉ែត្រ បណ្តោយ ៥ ស៊ិន ពី ២០០ ម៉ែត្រ ដែលសម្តេចព្រះកត្តាសង្ឃរាជាធិបតី ទ្រង់បានបញ្ចុះនៅថ្ងៃ អង្គារ ទី ១៤ កើត ខែ ពេស ឆ្នាំ មមែ ព.ស.២៤១៤ ក្នុងរាជ្ជកាលសម្តេចព្រះនរោត្តមបរមរាមទេវាវតារ ដូចមានសិលាចារឹក ដែលបានតម្កល់ទុកនៅក្នុងព្រះវិហារវត្តបទុមវតីរាជវរារាម នោះស្រាប់ ។

វត្តនេះ កាលនៅជាវត្តឧបោសថារាម គិតពីត្រឹមឆ្នាំ កុរ សប្តស័ក ព.ស.២៣២៨ គ.ស.១៧៨៥ ដែលព្រះបាទសម្តេចព្រះមហារាជា "អង្គចន្ទ" ទ្រង់សាងឡើងមកដល់ឆ្នាំ ឆ្លូវ សប្តស័ក ព.ស.២៤០៨ គ.ស.១៨៦៥ ហើយបាន ៨០ឆ្នាំ ជាសម័យកាលនៃអាយុវត្តឧបោសថារាម ។ គិតពីត្រឹមឆ្នាំឆ្លូវ សប្តស័ក ព.ស. ២៤០៨ គ.ស. ១៨៦៥ ដែលព្រះបាទសម្តេចព្រះនរោត្តម ទ្រង់បានសាងឡើង និងបានប្រែនាមជាវត្តបទុមវតីរាជវរារាម មកដល់ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥០៤ គ.ស. ១៩៦១ ហើយបាន ៩៦ ឆ្នាំ ជាសម័យកាលនៃអាយុវត្តបទុមវតីរាជវរារាម ។ បើគិតអាយុវត្តនេះ តាំងពីដើមនៅជាវត្តឧបោសថារាមរហូតដល់ ១៧៦ ឆ្នាំ គឺតាំងពីឆ្នាំ ព.ស. ២៣២៨ រហូតមកដល់ ព.ស. ២៥០៤ គ.ស. ១៩៦១ ជាសម័យកាលនៃអាយុវត្តនេះ ដែលបានប្រតិស្ឋានមក ។

www.budinst.gov.kh www.elibraryofcambodia.org

## ៩ - ប្រវត្តិនៃវត្តឧណ្ណាលោម (៤០) :

ប្រវត្តិនៃវត្តឧណ្ណាលោម មានការទាក់ទងគ្នានឹងព្រះរាជពង្សាវតារនៃប្រទេសកម្ពុជាខ្លះ បើស្រង់យករឿងក្នុងពង្សាវតារកម្ពុជាដោយសង្ខេបខ្លះ មករៀបរៀងតទៅ ប្រវត្តិនៃវត្តឧណ្ណាលោម អាចផ្ដល់នូវសេចក្ដីភ្លឺច្បាស់ឡើងបាន ។ លើកលែងតែព្រឹត្តិការណ៍ខ្លះ ពិតពិតកាលយូរអង្វែងហើយ ដូចយ៉ាងកំណើតនៃមហាចេតិយឧណ្ណាលោមជាដើម ដែលមិនដឹងជាកើតក្នុងសម័យណា ព្រោះព្រះរាជពង្សាវតារពុំបានចែងត្រង់ ។

ក្នុងព្រះរាជពង្សាវតារនៃប្រទេសកម្ពុជា មានសេចក្ដីថ្លែងថា ព្រះបាទសម្ដេចព្រះធម្មរាជា (ពញាយ៉ាត) ទ្រង់គ្រប់គ្រងរាជសម្បត្តិគង់នៅក្នុងព្រះបរមរាជវាំងមហានគរ (នគរធំ) បាន២៥ ឆ្នាំ លុះដល់ឆ្នាំទី ១៦ នៃរជ្ជកាលរបស់ព្រះអង្គ មើលទ្រង់មានព្រះរាជបរិយាយថា នឹងទ្រាំនៅក្នុងមហានគរនេះតទៅទៀតពុំកើត ក៏មានព្រះរាជបញ្ជាឱ្យកសាងព្រះរាជវាំងនៅទួលបាសាន ក្នុងខណ្ឌស្រីសឈរ ពីក្នុងស្រុកស្រីសន្ធរ ខេត្តកំពង់ចាមសព្វថ្ងៃនេះ ។

នៅថ្ងៃ ១៣ រោច ខែ មិគសិរ ឆ្នាំ ជូត ឆស័ក ព.ស ១៩៧៦ ចុល្លសករាជ ៧៩៤ គ.ស. ១៤៣២ ព្រះបាទសម្ដេចព្រះធម្មរាជា (ពញាយ៉ាត) ទ្រង់សម្ដេចយាងចេញចាកមហានគរ មុខមន្ត្រីដោយរាជសេវកាមាត្យ មានម៉ឺនសព្វមុខមន្ត្រីជាដើម ដោយព្រះពីធីនាំទៅតាមផ្លូវមាគ៌ាទឹក ។ លុះថ្ងៃ ១៤ កើតខែ បុស្ស ឆ្នាំ ជូត ឆស័ក [illegible] ព្រះអង្គមានព្រះរាជបញ្ជាឱ្យសម្ដេចចៅពញា [illegible] [illegible] ដែលស្គាល់ពីមានជាកន្លែង ឱ្យទៅពិនិត្យមើលទីនៅជិតភ្នំដូនពេញ [illegible] មានសេចក្ដី ព្រះអង្គក៏មានព្រះរាជបញ្ជាឱ្យកសាងព្រះរាជវាំងថ្មីត្រង់ទីនោះ ។ នៅថ្ងៃ [illegible] ព.ស. ១៩៧៧ ច.ស. ៧៩៦ គ.ស. ១៤៣៤ ព្រះបាទសម្ដេចព្រះធម្មរាជា (ពញាយ៉ាត) [illegible] នៅថ្ងៃ ១៥ កើត ខែ [illegible] ព្រះរាជវាំងថ្មី នៅជិតភ្នំដូនពេញ ។

នៅថ្ងៃ ១១ រោច ខែ [illegible] ឆ្នាំ ខាល ឆស័ក ព.ស. ១៩៨១ ច.ស. ៧៩៩ គ.ស. ១៤៣៧ [illegible] ព្រះអង្គ [illegible] ។ [illegible] ព្រះអង្គមានព្រះរាជបញ្ជាឱ្យ [illegible] (ស្រី) [illegible] ។ [illegible] ។ [illegible] ដែលជាកន្លែង [illegible] ពីទីនេះ [illegible] ព្រមទាំងព្រះរាជបញ្ជាឱ្យ [illegible] ១ [illegible] ។ [illegible] នៅខាងកើតព្រះសក្យមុនីចេតិយសព្វថ្ងៃនេះ ។ [illegible] ។

---

(៤០) [illegible] កម្ពុជសុរិយា ក្នុងលេខ ៩/១៩៦២ ទំព័រ ២០-៣០

www.budinst.gov.kh www.elibraryofcambodia.org

ព្រះបាទសម្តេចមហារាជា ( អង្គឌួង ) ទ្រង់មានព្រះរាជបញ្ជា ឱ្យកសាងវិហារលើទីដីខ្ពស់ដែលជាកន្លែងទ្រង់គង់ចាំការពារវាយសត្រូវ ឱ្យកសាងចេតិយធំមួយពីខាងក្រោយ វិហារ ។ ល ។ ទ្រង់បញ្ញត្តិឱ្យហៅវត្តនេះថាវត្តព្រះចេតិយបរិពារ ( ព្រះចំណេញពោធិ៍ ) មហាជនហៅវត្តនេះថាវត្តភ្នំទ្រងជើងម្តង អ្នកខ្លះហៅថាវត្តភ្នំទ្រង់ជាប់រៀងមក ។ ទ្រង់មានព្រះរាជបញ្ជាឱ្យកសាងវត្ត ៦ វត្តទៀត គឺ វត្តព្រះអារាម នៅត្រង់ទិសខាងកើត ទៀបអាត្មយភ្នំម្ចាស់ ។ វត្តសន្ធរ នៅត្រង់ទិសខាងកើត ទៀបភ្នំព្រះរាជទ្រព្យ ។ វត្តព្រះពុទ្ធឃោសា នៅត្រង់ខាងត្បូងព្រែកចិននិងព្រែក នាទិសខាងកើតភ្នំម្ចាស់ ។ ការជាទ្រង់ព្រះរាជទាននាមវត្តទាំង ៣ ជាផ្ទះ ដើម្បីឱ្យសមនឹងចំណេះរឿងដែលថា ព្រះពុទ្ធឃោសាចារ្យនាំគម្ពីរពីលង្កាទ្វីប ។ វត្តតាមុទ្ធ នៅខាងទិសអាគ្នេយ៍ភ្នំម្ចាស់ ពីតជាប់នឹងមាត់ព្រែក ឱកញ៉ាឌួង ឆ្ងាយបន្តិចពីវត្តនោះ ។ ព្រះពុទ្ធរូបធាតុ ដែលតំកល់ក្នុងវិហារវត្តពោធិ៍នេះ មានព្រះនាមថា ព្រះត្រៃកាលញ្ញ ព្រោះគេនិមន្តមកតាមសមុទ្រពីប្រទេសស្រីលង្កា ។ វត្តខ្ពង់ព្រះពុទ្ធ ដែលមាននាមនេះ ព្រោះព្រះរាជាមកពីស្រុកស្រីលង្កា ដែលគេសាងចំណេញព្រះចេតិយទាំង ៥ នៅខាងលិចវិហារវត្តព្រះអង្គតាមសព្វថ្ងៃនេះ ។ វត្តព្រះអង្គស ដោយមានគេនាំព្រះពុទ្ធរូប ៣៦ អង្គមកតម្កល់ ព្រះចំណេញកាលតពីមកខាងមុខរហូតមកដល់ វត្តបានពីសព្វថ្ងៃនេះ ។

ថ្ងៃ ១១ កើត ខែ ពិសាខ ឆ្នាំ ខាល អដ្ឋស័ក ព.ស. ១៩៨៦ ច.ស. ៨០៤ គ.ស. ១៨៤២ ព្រះបាទសម្តេចមហារាជា ( អង្គឌួង ) ព្រមទាំងខ្ញុំរាជការក្រសួងទាំងពីរ និងពពួកសង្ឃ មានសម្តេចព្រះសុគន្ធាធិបតី នាមដើមសម្តេចទេព ប្រមុខបានធ្វើបុណ្យបញ្ចុះសីមាក្រង់វត្តទាំង ៧ មានវត្តព្រះចេតិយបរិពារជាដើម និងព្រះរាជពិធីជាកុសលផ្សេងៗ ។ល។

## វត្តឧណ្ណាលោមក្នុងសម័យតមក

ឧណ្ណាលោមជាពាក្យបាលី ពាក្យសំស្ក្រឹតជាឩណ៌ាលោម ប្រែថា រោមក្រញាញ់ គឺរោមដែលដុះត្រង់ចន្លោះចិញ្ចើមទាំងពីរឡើងពីរោមចិញ្ចើមក្រញាញ់ ។ ក្នុងព្រះរាជពង្សាវតារថា ព្រះបាទសម្តេចព្រះមហារាជា ( អង្គឌួង ) ទ្រង់ប្រទាននាមវត្តនេះតាមនាមដើមស្រាប់ ជានាមនៃចេតិយដែលបញ្ចុះព្រះឧណ្ណាលោមនៃព្រះអរហន្តមហាកស្សប ។ រឿងនេះ សម្តេចព្រះមហាសង្ឃរាជនាម ទៀង ( សុវណ្ណកេសរ ) មានព្រះបន្ទូលថា ចេតិយនេះ និងព្រះពុទ្ធរូបថ្មធំដែលប្រតិស្ឋានក្នុងខឿនក្រោយនៃមហាចេតិយនោះ មានពាក្យបណ្តាំតៗមកថា កសាងតាំងពីក្នុងសម័យដែលព្រះពុទ្ធសាសនាផ្សាយចូលមកក្នុងប្រទេសកម្ពុជា នេះជាចំណុចមួយ ទីដីដែលគេសាងចេតិយធំនេះ កាលពីដើមជាដីខ្ពស់ជាងដីឯទៀត ក្នុងតំបន់នេះដូចជាកោះតូចមួយ ។ ត្រង់ដែលថា បញ្ចុះព្រះឧណ្ណាលោមនៃព្រះអរហន្តមហាកស្សបនោះ សម្តេចព្រះសង្ឃរាជ មានព្រះបន្ទូលថា ជាពាក្យបណ្តាំតៗមកដែរ ពុំមែនជាព្រះអរហន្តមហាកស្សបនោះ ក្នុងរឿងរាវព្រះធម្មបទអដ្ឋកថា ក្នុងសម័យពុទ្ធកាល ទាំងចេតិយធំ និងព្រះពុទ្ធរូបថ្មនោះ ក៏ពុំមែនជាព្រះមហាកស្សបបុរាណ ប្រហែលអាចជា ព្រោះរឿងតាមពាក្យតៗនោះទេ ។

www.budinst.gov.kh www.elibraryofcambodia.org

គួរអស់លោកអ្នកអានប្រវត្តិនេះ សង្កេតពិនិត្យមើលសណ្ឋានទ្រង់ទ្រាយចេតិយចំកណ្ដាល ដែលហៅថា ចេតិយឧណ្ណាលោមក៏គង់អាចប្រាប ព្រមទាំងស្មានបានផងទៀតថា ក្នុងប្រទេសកម្ពុជាទាំងមូល ឬទាំងក្នុងប្រទេស ពុទ្ធសាសនាឯទៀតក៏ដោយ មានតែចេតិយឧណ្ណាលោមមួយនេះឯង ដែលមានរូបរាំងកំផែងពីរ ។ ចំណែកខាងព្រះពុទ្ធរូបថ្មអង្គធំ ដែលស្ថិតស្ថានចំកណ្ដាលរូងខាងក្រោមនៃចេតិយធំនេះ ក៏មានទ្រង់ទ្រាយដូចគ្នានឹងព្រះពុទ្ធរូបថ្មទាំងឡាយ ក្នុងសម័យបុរាណកាលឯណោះដែរ ។ ប្រវត្តិនៃវត្តឧណ្ណាលោម មានរឿងពាក់ព័ន្ធខាងដើមដូចពណ៌នាមកនេះឯង ។ នោះចំណែកការតទៅមុខ ដើម្បីប្រវត្តិនៃវត្តនេះ មានរូបរាងគួរថ្លែងបានតាមលំដាប់កាល ដូចមានសេចក្ដីរៀបរាប់តទៅនេះ ៖

លុះដល់មក ព.ស.ទី ២៣ គឺកាលពីឆ្នាំ ច ឆស័ក ព.ស. ២២៣៨ ម.ស. ១០៦០ គ.ស. ១៦៩៤ ក្នុងរជ្ជកាលនៃព្រះបាទសម្ដេចព្រះជ័យជេដ្ឋា ក្នុងព្រះរាជពង្សាវតារខ្មែរ មានថេរៈមួយព្រះនាមថា ព្រះ ភោធិវង្ស ( ឯក ) ចៅអធិការវត្តឧណ្ណាលោម និងព្រះ ស្រីសង្ឃមុនី ( អ៊ី ) ចៅអធិការវត្តព្រះចេតិយបព៌ត បានថ្វាយព្រះពរព្រះរាជាថា ទីដីទួលព្រះស្រីនេះចង្អៀតណាស់ ពុំសមគួរនឹងកសាងព្រះរាជវាំងតាមព្រះរាជបំណងនោះទេ បើសព្វព្រះរាជហឫទ័យនឹងកសាងព្រះរាជវាំងថ្មីទុកជាទីរំលឹកដល់ ការមានជ័យ ឈ្នះបច្ចាមិត្តនោះ គួរកសាងនៅទីជិតចេក វិស្រុក រីញ ព្រោះមានទីដីទួលរាបស្មើល្អ ។ ព្រះបាទសម្ដេចព្រះជ័យជេដ្ឋា ក៏សព្វព្រះរាជហឫទ័យយល់ស្របតាម ហើយព្រះអង្គមានព្រះរាជបញ្ជាឱ្យកសាងព្រះវាំងមួយនៅជិតបឹងស្រែង ហៅថាព្រះរាជវាំង ចិនស្រេង នៅខាងទិសពាយ័ព្យ នៃក្រុងភ្នំពេញសព្វថ្ងៃនេះ ។ ប៉ុន្តែសព្វថ្ងៃនេះ ព្រះរាជវាំងនេះរលំរលាយបាត់បែកធាតុចង់ទៅហើយ ។ ក្នុងរជ្ជកាលនេះ ព្រះភោធិវង្ស ( ឯក ) នោះជាទីប្រឹក្សាក្នុងការរៀបផ្ទាត់ច្បាប់សំរាប់តុលាការ ដែលចាស់ៗហៅថា ក្រមច្បាប់ព្រះជ័យជេដ្ឋានោះផង ចាត់ចែងកិច្ចការព្រះពុទ្ធសាសនា ក៏បានពិនិត្យផ្ទៀងផ្ទាត់ពីរបីគម្ពីរផងដែរ ។

សរុបសេចក្ដីមកឃើញថា តាំងពីក្នុងរជ្ជកាលនៃព្រះបាទសម្ដេចព្រះបរមរាជា ( ញ៉ាងកាំង ) រៀងរហូតមកដល់សម័យបច្ចុប្បន្ន វត្តឧណ្ណាលោមរាំងចែងតែការកិច្ចសព្វគ្រប់ ដែលជាធម្មតា ប្រាកដតែពុំច្បាស់ថា គឺលោកចៅអធិការពីមួយមកមួយទៀតៗគ្នារៀងមក តើមានប៉ុន្មានគណរហើយ ? មាននាមអ្វីខ្លះ ? សុទ្ធតែបានសមណស័ក្តិជាអ្វីខ្លះ ? ឬក៏ខ្លះពុំមានសមណស័ក្តិជាអ្វីទេ ? ពុំឮព្រះឯង ។ ក្នុងព្រះរាជពង្សាវតារកត់ត្រាបានត្រឹមតែ ព្រះភោធិវង្ស ( ឯក ) ប្រហែលប៉ុណ្ណោះ ក្នុងរជ្ជកាលនៃព្រះបាទ ព្រះជ័យជេដ្ឋា ព.ស ២២៣៨ ម.ស ១០៦០ គ.ស ១៦៩៤ ក៏តែមយល់ ( ឯក ) មុខប្រហែលប៉ុណ្ណោះ ក្នុងរជ្ជកាលនៃព្រះបាទ ព្រះជ័យជេដ្ឋា ព.ស ២៥០៩ នេះ ឃើញបាន ២៦៧ ឬ ២៦៨ ឆ្នាំហើយ ។ លុះដល់មករជ្ជកាលនៃព្រះបាទសម្ដេចព្រះនរោត្តម ( ព.ស ... ) ទើបព្រះអង្គ ស្ដេចបានចេញបញ្ជាឱ្យមានចំណាត់ការក្នុងក្រុងភ្នំពេញ ដើម្បីប្រវត្តិនៃវត្តឧណ្ណាលោមរាងការទៅវិញ ... ជាក់ច្បាស់តាមពិតជាបំពេញរៀបរាប់តទៅ ។

## វត្តឧណ្ណាលោមក្នុងបច្ចិមសម័យ

នៅថ្ងៃ ព្រហស្បតិ៍ ៩ កើត ខែ ចេត្រ ឆ្នាំ ជូត សប្តស័ក ព.ស. ២៤០៨ ម.ស. ១៧៨៧ ច.ស ១២២៧ គ.ស. ១៨៦៥ វេលាម៉ោង ៩ ព្រឹក ព្រះបាទសម្តេចព្រះនរោត្តម ( ហរិរក្សរាមាឥស្សរាធិបតី ... ) ស្តេចយាងចេញចាកព្រះបរមរាជវាំងក្រុងសាររ ពើយុទ្ធក្រុងឧដុង្គមានជ័យមកគង់ប្រចាំក្រុងភ្នំពេញ តាមបុរាណទក្រុកាដ៏ ២ តពីក្រាដី ១ ក្នុងរជ្ជកាលនៃព្រះបាទសម្តេចបរមរាជា ( ពញាយ៉ាត ) ។ល។ សម្តេចព្រះមហាសង្ឃរាជព្រះនាម ទៀង និងព្រះរាជាគណៈថានានុក្រមច្រើនរូប មានព្រះមហាវិមលធម្ម នាម ភុម និងព្រះលោកសាសា នាម ខ្មាក់ ជាដើម ក៏ចេញចាកវត្តប្រាង្គ ក្រុងឧដុង្គមានជ័យមកគង់នៅវត្តឧណ្ណាលោមនោះ ។

វត្តឧណ្ណាលោម មានចៅអធិការស្រាប់មក មាននាមថា លោកគ្រូ គង់ តមក មានសមណស័ក្តិជារាជាគណៈជាព្រះធម្មវិបស្សនា គេច្រើនហៅលោកថា លោកតា គង់ ព្រះធម្មវិបស្សនា លោកមានកុដិប្រក់ស្បូវ ១ ខ្នង ជាលំនៅរបស់លោកនៅត្រង់ទិសខាងជើងព្រះចេតិយឧណ្ណាលោម ។ លុះសម្តេចព្រះមហាសង្ឃរាជមកគង់នៅវត្តនេះ លោកលោកតាក៏សូមថ្វាយឋានៈចៅអធិការវត្តឧណ្ណាលោមដល់សម្តេច ប៉ុន្តែ សម្តេចមិនព្រមទទួល ។ លុះចំណេរកាលតមក លោកព្រះធម្មវិបស្សនាគង់ ទទួលអនិច្ចធម្មទៅ ឋានៈចៅអធិការវត្តឧណ្ណាលោម ក៏ធ្លាក់មកលើសម្តេចព្រះមហាសង្ឃរាជ ព្រោះសម្តេចជាប្រមុខនៃសង្ឃស្រាប់ ។

## តំណពងចៅអធិការវត្តឧណ្ណាលោម ក្នុងបច្ចិមសម័យ

ចាប់ដើមតាំងពីព្រះបាទសម្តេចព្រះនរោត្តម ស្តេចមកគង់នៅក្រុងភ្នំពេញរៀងរហូត មកដល់សម័យបច្ចុប្បន្ននេះ វត្តឧណ្ណាលោមមានចៅអធិការ ៥ អង្គគឺ :

១ . ព្រះធម្មវិបស្សនា គង់

២ . សម្តេចព្រះមហាសង្ឃរាជ ព្រះនាម ទៀង សុវណ្ណកេសរ ...

៣ . សម្តេចព្រះធម្មលិខិត ព្រះនាម អ៊ុក ជាព្រះសង្ឃនាយកគណៈមហានិកាយ

៤ . ព្រះមហាវិមលធម្ម ថៃ ពក់ ជាមន្ត្រីសង្ឃពិសេសក្នុង

៥ . ព្រះពុទ្ធឃោសាចារ្យ ជួន ណាត ជោតញ្ញាណោ ។ តមក មានសមណស័ក្តិជាព្រះពោធិវង្ស ជាចាងហ្វាងសាលាបាលីជាន់ខ្ពស់ផង ជាអធិបតីនៃថេរសភាគណៈមហានិកាយផង តមកទៀត មានសមណស័ក្តិជាព្រះមហាសុមេធាធិបតីសង្ឃនាយក តពីនោះមក ជាសម្តេចព្រះមហាសុមេធាធិបតីសង្ឃនាយកគណៈមហានិកាយ ( នៃប្រទេសកម្ពុជា ) រួមភាគីពាលសភាភិក្ខុ បានសុំតាំងតាមពុទ្ធបញ្ញត្តិ តមកបានសុំតាំងឱ្យឡើងជា អភិធម៌ មហាបណ្ឌិត ជាសមណស័ក្តិខ្ពស់បំផុតសំរាប់ប្រទេសកម្ពុជា ។

www.budinst.gov.kh www.elibraryofcambodia.org

## បរិមាណនៃទីដីវត្តឧណ្ណាលោម

វត្តឧណ្ណាលោមមានផ្ទៃដីខ្នាតបន្តិច ពុំស្មើភាគទេ ដូចខាងក្រោមនេះ ៖

១ - ផ្នែកខាងត្បូង ពីទីបំផុតកំពែងខាងកើត ដល់ទីបំផុតខាងលិច ១៤៥ ម៉ែត្រ ។

២ - ផ្នែកខាងលិច ពីទីបំផុតកំពែងខាងត្បូង ដល់ទីបំផុតខាងជើង ១៦៥ ម៉ែត្រ ( វែងលើសផ្នែកទី ១_៣_៤ ចំនួន ២០ ម៉ែត្រ ) ។

៣ - ផ្នែកខាងជើង ពីទីបំផុតកំពែងខាងលិច ដល់ទីបំផុតខាងកើត ១៤៥ ម៉ែត្រ ។

៤ - ផ្នែកខាងកើត ពីទីបំផុតកំពែងខាងជើង ដល់ទីបំផុតខាងត្បូង ១៤៥ ម៉ែត្រ ។

កាលពីដើមទីដីខាងមុខវត្តនោះ តាំងពីព្រៃវត្តរហូតដល់មាត់ទន្លេ ( ម្សៅត្រានិងព្រៃវត្ត ) ជាដីអធិករណ៍សង្ឃ គឺជាដីសំរាប់វត្តឧណ្ណាលោមទាំងអស់ហៅថា ឈាកសីមា ព្រៃចំណីវត្ត ។ ប៉ុន្តែ គេពុំដែលបានធ្វើលិខិតបញ្ជាក់អ្វីបន្តិចបន្តួចដល់វត្តឧណ្ណាលោមទេ ។ លុះចំណេរកាលតមក ទីដីខាងមុខវត្តនោះ ក៏ក្លាយជាដីរបស់ក្រុងភ្នំពេញ ។ លុះដល់មកសម័យប្រទេសកម្ពុជាឯករាជ្យសម្បូរណ៍ រាជការក្រុងភ្នំពេញបានបង្វែរទីដីមាត់ទន្លេខាងមុខវត្ត ប្រវែង ២០ ម៉ែត្រ ឱ្យជាដីកំពង់សំរាប់វត្តឧណ្ណាលោម ។ ល ។

## ការរៀបចំវត្តឧណ្ណាលោម

ដើម្បីកុំឱ្យប្រវត្តិនៃវត្តឧណ្ណាលោម មានសេចក្តីវែងឆ្ងាយពេក យើងនាំដកនៅត្រឹមនេះ សូមពណ៌នាដោយសង្ខេប ព្រោះក្នុងសម័យបច្ចុប្បន្ននេះ អស់លោកអ្នកអានប្រវត្តិនេះសុទ្ធតែបានឃើញ បានជ្រាបអស់ហើយ ។

កាលដែលសម្តេចព្រះមហាសង្ឃរាជព្រះនាម ទៀង មកគង់ក្នុងវត្តឧណ្ណាលោម វត្តនេះ មានទីដីក្រហោងក្រហែង ខ្វះខាត ទាលុះ ពុំទាន់ស្អាតសមរម្យនៅឡើយទេ លុះចំណេរកាលតមក វត្តឧណ្ណាលោមក៏បានសភាពដ៏បរិបូណ៌ដោយជាប់តាមលំដាប់ដោយសម្តេចនេះ ៖

១ - ក្រោយពីពេលដែលព្រះករុណាជាម្ចាស់ជីវិត ព្រះបាទសម្តេចព្រះនរោត្តម យាង ទៅគង់ឯព្រះបរមរាជវាំងចតុមុខ គឺព្រះបរមរាជវាំងសព្វថ្ងៃនេះ ព្រះបាទសម្តេចព្រះនរោត្តម ទ្រង់មានព្រះរាជបញ្ជាឱ្យលោកមេការរុះរើព្រះវិហារកាត់នៅព្រះរាជវាំងភាគីត ( ព្រះរាជវាំងសំបត ) នៅខាងជើងវត្តឧណ្ណាលោមឱ្យយកមកសង់ជាវិហារកាត់ឈើមានជាន់ ២ ថ្វាយសម្តេចព្រះមហាសង្ឃរាជ គឺ កុដិមួយខ្នងនៅខាងជើងរាជ្យព្រះវិហារ ( កុដិនេះព្រះពុទ្ធឃោសាចារ្យ ជឹម ប៉ុណ្ណ នៅក្រោយក្នុងសព្វថ្ងៃនេះ ) ។ លុះតមក ព្រះពុទ្ធឃោសាចារ្យ ជឹម ប៉ុណ្ណ បានជួសជុលឡើងជាថ្មី ធ្វើឱ្យមានផ្លូវចូលពីខាងជើងវិញ ។

២ - សម្តេចព្រះមហាសង្ឃរាជ និងពុទ្ធបរិស័ទបានកសាងវិហារ ទំហំ ៤ ក្បៀងតាមភ្ជានិង ឧណ្ណាលោម ព្រមទាំងបានឱ្យជាងធ្វើតំរៀតដាក់ពីមុខនៃវិហារផងដែរ ។ ល ។

៣ - បានទំកល់ព្រះបរមសារីរិកធាតុ នៃព្រះសម្មាសម្ពុទ្ធបរមគ្រូ ដែលលោកលោកយកពីប្រទេស ស្រីលង្កា ជាចំណោមនៃសម្តេចព្រះសង្ឃព្រះនាម សិរីសុមេធ ៖ នៅវត្ត ទីរង្សារាម ក៏បានក្រុងលង្កាព្រឹត្តិជាមួយយកមកជាចំណោមនៃសម្តេចព្រះសង្ឃព្រះនាម ទៀង ព្រះបាទសម្តេចព្រះនរោត្តមសេង ទោះជាសូមធ្វើជាអង្គរបិទផ្ទាំងខាងកើត នៃវិហារឧណ្ណាលោមជាកស្លុតាយុក្រាប់ ។

www.budinst.gov.kh www.elibraryofcambodia.org

ក្នុងរូងនៃចេតិយទាំង ៥ ខឿនព្រហ្មហារចេតិយ ដែលតំកល់ព្រះបរមសារីរិកធាតុនោះ សុទ្ធតែមានព្រះពុទ្ធរូបមួយអង្គៗ រួចទីបព្រះពុទ្ធរូបថ្មពីបុរាណ ដែលស្ថិតនៅក្នុងរូងកណ្ដាលផងជា ៦ អង្គ ។ ល ។

៤ _ ឯចេតិយទាំងឡាយនៅទីទិសខាងក្រោម ខឿនព្រហ្មហារចេតិយនោះ សុទ្ធតែពុទ្ធបរិស័ទបានកសាងតំកល់ ឬបញ្ចុះអដ្ឋិធាតុនៃអ្នកមានគុណរបស់ខ្លួន ដោយបានអនុញ្ញាតពីសម្ដេចព្រះមហាសង្ឃរាជ ។ ល ។

៥ _ ចំពោះកាលមក លោកឧកញ៉ាអគ្គមហាសេនា ( ម៉ុក ) ជាប្រមុខនៃពុទ្ធបរិស័ទ បានសុំអនុញ្ញាតសម្ដេចព្រះមហាសង្ឃរាជ ហើយបានផ្ដួចផ្ដើមវិហារថ្មី ជំនួសវិហារចាស់ ស្រោបគ្រឿងឈើប្រក់ក្បឿងពពក ប៉ុន្តែចំហៀងវិហារទុកឱ្យនៅឡើយដើម ។ ល ។

៦ _ ក្នុងកាលនៃព្រះតេជព្រះគុណ ( កែវ ឯក ) ជាចៅអធិការសេនាសនៈផ្សេងៗ មានឧបដ្ឋានសាលា និងសាលាឆាន់ជាដើម បានកើតមានឡើងក្នុងវត្តឧណ្ណាលោម ។ វត្តនេះមានការលូតលាស់រីកចំរើនរៀងៗ មករាល់ឆ្នាំតាមពេលវេលា ។ សាលាធំមួយខ្នងនៅទិសខាងលិចទល់មុខព្រះវិហារ ដែលលោកអ្នកឧកញ៉ាអគ្គមហាសេនា ( ម៉ុក ) កាលនៅជាគ្រូឧណ្ណាលោម បានកសាងនិងសាលាតូចមួយខ្នងទៀត នៅជាប់ទីលំនៅសម្ដេចព្រះមហាសង្ឃរាជ ដែលលោកឧកញ៉ាប្រឹក្សាហោរា ( សៅរ៍ ) បានកសាង ក៏បានត្រូវរុះរើគ្រឿងសំភារៈមកផ្សំ ធ្វើជាសាលាឆាន់ម៉ែង និងសេនាសនៈដទៃខ្លះទៀត ឱ្យបានល្អរកតរៀងទៅ ។ ល ។

៧ _ ពុទ្ធបរិស័ទបានកសាងកុដិថ្មពីរខ្នងជាប់គ្នា មហាកុដិនៅខាងជើងវិហារ ។ អ្នកឧកញ៉ាអគ្គរាជទេព ( កាន់ម៉ាក់ ) ពេលស្ម័គ្រចិត្តផ្ដាច់ស៊េរីសាលាសមាធិស្ថាន ( ពិសេសកាលពីណោះ ) សំរាប់វត្តឧណ្ណាលោម ដោយចៅអធិការបច្ចុប្បន្ន គឺ ស.ស.ម.ណ ដោយល្ហល្ហើរ ការអនុញ្ញាតថ្ងៃ បានសុំព្រះបរមរាជានុញ្ញាត ព្រះករុណាជាម្ចាស់ជីវិត ហើយបានកសាងសាលាធម្មស្ថានពីរជាន់ ដែលព្រះករុណាជាម្ចាស់ជីវិតទ្រង់យាងមកសោយទេវាស្ថានក្រោមនោះ ដោយពុទ្ធបរិស័ទមានភាពច្រើន បានជួយកសាងផែជាច់ផ្សេងៗ និងគ្រឿងបរិក្ខារផ្សេងៗផង ។ ល ។

៨ _ ដោយចៅអធិការបច្ចុប្បន្ន គឺ ស.ស.ម.ណ ចោតញ្ញាណកា និងពុទ្ធបរិស័ទភាគច្រើនមានមហាកថា ខ្ទង់ជាដើម យល់ឃើញថា វិហារវត្តឧណ្ណាលោមនេះខាងចំពុក និង គីឡានកាន់តែច្រើនចុះទ្រុឌទ្រោមភាពស៊ាំទៀត និងដំណក់ បណ្ដោយជាដើម ទុកឱ្យនៅយូរទៅទៀតពុំកើត ក៏ព្រមព្រៀងគ្នាបានសុំព្រះបរមរាជានុញ្ញាតព្រះករុណាជាម្ចាស់ជីវិត ហើយរុះរើវិហារចាស់បាន កសាងវិហារថ្មីសព្វថ្ងៃនេះឡើង ។ ល ។

www.budinst.gov.kh www.elibraryofcambodia.org

## ចិរកាលនៃវត្តឧណ្ណាលោម

វត្តឧណ្ណាលោម បើនិយាយពីប្រវត្តិនៃមហាចេតិយកណ្តាលខាងលិចវិហារសព្វថ្ងៃនេះ និង ព្រះពុទ្ធរូបថ្មអង្គធំក្នុងរូងមហាចេតិយនោះ ពុំមែនជាកើតមាននៅពីក្នុងរជ្ជកាលនៃព្រះមហាក្សត្រិយ៍អង្គណា ពីក្នុងពុទ្ធសករាជទីប៉ុន្មានទេ ។ ប៉ុន្តែ បើនិយាយពីត្រឹមរជ្ជកាល នៃព្រះបាទសម្តេចព្រះបរមរាជា ( ពញាយ៉ាត ) ដែលព្រះអង្គមានព្រះរាជបញ្ជាឱ្យកសាងវត្តនេះឡើងវិញទៀត ហើយទ្រង់ធ្វើបុណ្យបញ្ចុះសីមានៅថ្ងៃ ១១ កើត ខែ ពិសាខ ឆ្នាំ ម សប្តស័ក ព.ស. ១៩៨៦. គិតពីឆ្នាំនោះមកដល់ឆ្នាំខាល ចត្វាស័ក ព.ស. ២៥០៥ នេះ ឃើញថាមានចិរកាល ៥១៩ ឆ្នាំ ឬ ៥២០ ឆ្នាំហើយ ។

### ចំពោះយុវជន

ហៃពួកយុវជនអ្នកកំសត់
បើកុំបានវត្តប្រកអាស្រ័យ
សមអ្នកនឹងតកតបានកំរៃ
យប់ថ្ងៃហួសទៅកើតប្រយោជន៍ ។
គួរអ្នកកុំភ្លេចវត្តលំនៅ
ទោះអ្នកចេញទៅឆ្ងាយស្រឡាច
គួរដឹងគុណវត្តកុំបង្ខាច
ប្រយោជន៍និងផលគួរលុំខាន ។
បើមានគេសួរពីកាលរៀន
ចំណេះចេះរៀនទាំងប៉ុន្មាន
អ្នកកុំនិយាយបង្វែងផាន
ត្រូវប្រាប់ថាបានចេះព្រោះវត្ត ។
កុំពោលបន្តុកពួក រឿង
ត្រូវស្តីតាមត្រង់កុំបំភ្លាត់
បំផ្លែងបំភ្លើសបំភ្លេចវត្ត
ព្រោះទោសទាញទាត់ឱ្យវិនាស។
ដាយវត្តជាអាចធំមានព្រលឹង
គួរនឹករំពឹងកុំទើសទាស
នាំប៉ុនបន្តិមកពីរាស្ត្រ
ពីរាស្ត្រឡើងទៅជាមន្ត្រី ។
ដាយផ្ទះជាយវត្តដូចជាផ្កា
ចំណែកអាត្មាបានពីរ
រីឯកាលហើយរៀនស្រុកមេះខ្មែរទី
មុនីកើតមាននៅលោកសាវ័ ។
សាធុ ! សូមឱ្យអ្នកបានសុខ
និរទុក្ខនិរភ័យកើតក្រុង
ជាជនសប្បុរសរបស់វត្ត
មាននិរោគមានបរប្រសើរហោង !

www.budinst.gov.kh www.elibraryofcambodia.org

៦ - ព្រះបដិមាព្រះស្រគាលេញ (៤១) :

ព្រះស្រគាលេញអង្គនេះកើត ដែលទៅពញាកង្ហីសង្គ្រាម " ហុក " បានបំពមានកើតលើព្រះស៊ីញាញបាននៅ ពោរណមួតស្វាធារដែលហោ ជុតទ័ពអង្គរលោកតេជៈគុ ទៅកាន់ព្រះរាជាក្សត្រ សម្ដេចព្រះរាជាធិរាជ ៩៨៦នាទ នៃសម្ដេច ព្រះបរមរាជា ឱ្យបានជួសជុលព្រះពុទ្ធរូបនៃវត្តតាម្រោងរាជធានី នៅវត្តស្រគាលេញ ២៣ ។ លុះចំណេរកាលមកខាងក្រោយ ព្រះពុទ្ធរូប ស្រគាលេញអង្គនេះបានមកប្រតិស្ឋានក្នុងវត្តឧណ្ណាលោម គឺព្រះពុទ្ធរូបអង្គធំក្នុងវិហារវត្តឧណ្ណាលោម សព្វថ្ងៃនេះ ដែលគេបានត្រូវជួសជុលអស់វារៈ ៣ ដងហើយ ព្រោះនាមថា ស្រគាលេញនោះ ក៏លេបបាត់ទៅពុំមានលេចឮឡើង ។

៧ - វិសាខបូជា (៤២) :

ពាក្យថា សក្ការៈ មកពី សក្កៈ សំស្ក្រឹតថា កតៈ កោតសរសើរគោរពៈ និងបូជៈ " ដូច "មានសេចក្ដីថា ការ កំណត់កាលថ្នាំ ការគោរពតាំងពីព្រេងព្រឹទ្ធមក ដោយយកបុប្ផាធូបទៀន ឬវត្ថុអ្វីមួយជាគ្រឿង ។ ក្នុងជំនាន់ដើម គេប្រើត្រឹមតែសក្ការៈបុណ្ណោះ ។ លុះសម័យក្រោយមកប្រមាណក្នុងសម័យឧត្តុង្គ ទើបបានប្រែជាសក្ការបូជារហូតដល់សព្វថ្ងៃនេះ ។

សក្ការបូជាមានបួនយ៉ាង គឺ :

១ - ពុទ្ធសក្ការៈ

២ - ព្រឹក្សសក្ការៈ

៣ - ចេតិយសក្ការៈ

៤ - ធម្មសក្ការៈ

## ប្រវត្តិពុទ្ធសក្ការៈ

ពុទ្ធសក្ការៈ គឺសក្ការៈដែលគេធ្វើចំពោះព្រះពុទ្ធ ៤ ឆ្នាំ គិតពីថ្ងៃ ខួប ១ រោច ខែ ពិសាខ ឆ្នាំ ម្សាញ់ ក្រោយថ្ងៃដែលព្រះសម្ពុទ្ធចូលបរិនិព្វាន ទៅតាមលំដាប់ថ្ងៃរៀងមក ។ ព្រះមហាក្សត្រ បានកំណត់ទុកនៅថ្ងៃអង្គារ ១៥ កើត ខែ ពិសាខ ឆ្នាំ ម្សាញ់ ។

---

៤១ ព្រះរាជពិធីមាស ព្រះស្រគាលេញ ខេមរៈនិស្សិតពុទ្ធសាសនា លេខ ៧/១៩៦២ ទំព័រ ៣៩

៤២ ព្រះមហាឧត្តម ជួនថាច់ សៀវភៅ ធម្មបូជា ភ្នំពេញ ១៩៥១ ទំព័រ ៦-៨

www.budinst.gov.kh www.elibraryofcambodia.org

ហេតុនេះបានជារាប់ត្រឹមថ្ងៃ ១ រោច ខែ ឆ្នាំ ជាបួយនោះ មកជាកំណត់ ពុទ្ធសករាជសរសេរកាត់ថា ព.ស ។

## ប្រវត្តិគ្រិស្តសករាជ

គ្រិស្តសករាជកើតឡើងក្រោយពុទ្ធសករាជចំនួន ៥៤៣ ឆ្នាំ ដោយសាស្តាម្នាក់ឈ្មោះ យេស៊ូ ឬសេសិគ្រិស្តជាអ្នកបង្កើតលទ្ធិសាសនាគ្រិស្ត ឬគ្រិស្ត កើតនៅប្រទេសអ៊ីតាលី ( ខ្លះថាប្រទេសប៉ាឡេស្ទីន ) ក្នុងសតវត្សទី ៦ នៃពុទ្ធសករាជ ( ព.ស. ៥៤៣ ) ទទួលមរណភាពក្នុងព.ស. ៥៧៦ ក្នុងគំរប់អាយុ ៣៣ ឆ្នាំ ។ គ្រិស្តសករាជសរសេរអក្សរកាត់ថា គ.ស. ។

## ប្រវត្តិមហាសករាជ

មហាសករាជ កើតឡើងក្នុងរាជព្រះបាទសកៈ ឬសាលិវាហនៈ នៅក្នុងប្រទេសឥណ្ឌា ក្នុងរវាង ព.ស. ៦២១ ដោយព្រោះឮយកជ័យជំនះយ៉ាងសំបើម របស់ក្សត្រិយអង្គនេះជាកំណត់ ។ ប៉ុន្តែ ក្នុងជំនាន់មុនហៅត្រឹមតែស័ក ឬសករាជប៉ុណ្ណោះ ។ លុះខាងក្រោយមក មានសករាជថ្មីកើតឡើងទៀត ទើបហៅថាសករាជព្រះចៅសាលិវាហនៈ មហាសករាជ ។ សរសេរអក្សរកាត់ថា ម.ស ។

ក្នុងព្រះរាជពង្សាវតារខ្មែរថា ព្រះបាទសម្តេចព្រះអរិយ្យកិល ( ពញាក្រែក ) បានតាំងសករាជមួយក្នុង ១១៨១ ឆ្នាំ ។

ក្នុងពង្សាវតារតានករសៀមរៀប ( លាវ ) ថាព្រះបាទពន្ទុមតី ក្នុងប្រទេសលង្កា ទ្រង់តាំងមហាសករាជនេះឡើង តែបើសមតាមពិតនោះ គឺ ព្រះបាទសាលិវាហនៈ ទ្រង់តាំងឡើងហើយព្រះបាទពន្ទុមតី គ្រាន់តែយកទៅប្រើក្នុងប្រទេសខ្លួនប៉ុណ្ណោះ ។

## ប្រវត្តិចុល្លសករាជ

ក្សត្រភូមាទ្រង់ព្រះនាមសប្បរាជ ឬហៅថា បុប្ផសោហេន៍ ជាក្សត្រិយ៍ទី ១៦ ក្នុងវង្សសម្មុទ្ទឫទ្ធិ ទ្រង់តាំងឡើង ( ក្នុងឆ្នាំកុរ ហើយរាប់ឆ្នាំជាឯកស័ក ) ក្នុងព.ស ១១៨២ ដោយយកសុរិយគតិ គឺពេលប្រជុំបង្គួននៃព្រះអាទិត្យ ដែលគោចរចេញអំពីមេសរាសី ហើយត្រឡប់ចូលមេសរាសីវិញជាកំណត់ ។

ឯការណ៍ដែលប្រើពាក្យថា ឯកស័ក ទោស័ក ត្រីស័ក ជាដើម ប្រកបនឹងឈ្មោះឆ្នាំ ក៏កើតឡើងក្នុងវេលាដែលកើតចុល្លសករាជនេះដែរ ។

ទំនៀមទំលាប់ចូលឆ្នាំ ក្នុងខែ ចេត្រ ( អាប្រិល ) ។

www.budinst.gov.kh www.elibraryofcambodia.org

### ច. ឥទ្ធិពលព្រះពុទ្ធសាសនាក្នុងសង្គមខ្មែរ

ដោយឥទ្ធិពលព្រះពុទ្ធសាសនាចាក់គ្រឹះយ៉ាងមាំក្នុងចិត្តគំនិតខ្មែរ សង្គមខ្មែរ ទំនៀមខ្មែរ មនោគមខ្មែរ តាំងពីយូរអង្វែងណាស់មកហើយ។ មានវត្តអារាមជាច្រើនប្រកបទៅដោយព្រះវិហារ កុដិ សាលាដ៏ល្អៗជាច្រើនដែលពុទ្ធបរិស័ទមានសទ្ធាជ្រះថ្លា បានកសាងធ្វើជាសេនាសនៈ សំរាប់ព្រះសង្ឃគង់នៅដែលនិមន្តមកពីទិសទាំង៤ និងជាទីសំរាប់ធ្វើបុណ្យសុន្ទរ៍ ទាន ស្មាទាន រក្សាសីលជាដើម។ ប្រជាជនខ្មែរទាំងប្រុស ទាំងស្រីភាគច្រើនតែជាឧបាសក ឧបាសិកា អ្នកកាន់ព្រះពុទ្ធសាសនា ធ្វើបុណ្យ ឱ្យទាន រក្សាសីល៥ សីល៨ សីល១០ ធ្វើសមាធិកម្មដ្ឋានជាដើម។ កាលសម័យបុរាណក្មេងៗ កូនចៅអ្នកស្រុកតែងបានចូលទៅសិក្សា រៀនសូត្រអក្សរសាស្ត្រ សិល្បៈ គុនដំបង គុនដាវជាដើម នៅក្នុងវត្តអារាមដែលមានព្រះសង្ឃជាគ្រូបាធ្យាយ។ អ្នកខ្លះក៏បានសាងផ្នួសបួសជាសាមណេរ ឬជាភិក្ខុសិក្សា រៀនសូត្រធម៌អាថ៌ ក្នុងព្រះពុទ្ធសាសនា។

ជាពិសេសឥទ្ធិពលព្រះពុទ្ធសាសនាបានចូលស៊ប់សួនចាក់ឫសយ៉ាងមាំក្នុងសង្គមខ្មែរ ទំនៀមខ្មែរ មនោគមខ្មែរ ព្រលឹងខ្មែរតាំងតែពីច្រើនស.វណាស់មកហើយ ដែលមានជាអាថ៌ដោយខ្មែរពេញចិត្ត ពេញថ្លើមពេក ទើបខ្មែរបញ្ចូលអ្វីៗទៅក្នុងការបង្ហាញព្រះពុទ្ធសាសនាសឹងតែទាំងអស់ ដូចបានជំរាបខ្លះៗរួចមកហើយ។

#### គ. ជំនឿ Croyance

ឥទ្ធិពលព្រះពុទ្ធសាសនាបានបណ្តាលឱ្យមាន :

- ជំនឿបុណ្យបាប
- ជំនឿកម្មផល
- ជំនឿសច្ចៈ សុចរិត យុត្តិធម៌

ដែលបានជាកត្តាដ៏ធំមួយ ជួយរុញច្រានសង្គមខ្មែរ មនុស្សខ្មែរឱ្យមានសីលធម៌ មនុស្សធម៌ ស្គាល់បុណ្យបាប ហើយខំប្រឹងធ្វើ ខំប្រឹងកសាងអំពើល្អៗ គ្រប់ៗគ្នា។

#### ខ. ប្រពៃណី ទំនៀមទំលាប់ Coufume Moeurs

មានប្រពៃណី ទំនៀមទំលាប់ជាច្រើន ស្ទើរតែគ្រប់មែកធាងវប្បធម៌ អរិយធម៌ សុទ្ធតែមានទំនាក់ទំនងនិងព្រះពុទ្ធសាសនាដូចជា :

- ពិធីចំរើនជន្មាយុ ( ចំរើនអាយុ )
- ពិធីរាពាហ៍ពិពាហ៍
- ពិធីបូជាសព ហែរសព
- ពិធីកោរជុក
- ពិធីអភិសេកព្រះពុទ្ធរូប

www.budinst.gov.kh www.elibraryofcambodia.org

និងមានប្រពៃណីខ្លះទៀត ជាបែបព្រះពុទ្ធសាសនាសុទ្ធៗ ដូចជា :

- ពិធីចូលព្រះវស្សា
- ពិធីចេញព្រះវស្សា
- ពិធីបុណ្យកឋិនទាន
- ពិធីបុណ្យផ្កា
- ពិធីភ្ជុំបិណ្ឌ
- ពិធីបុណ្យបច្ច័យបួន
- ពិធីបុណ្យឆាក មហាបង្សុកូល
- ពិធីបុណ្យទេសនាមហាជាតក ។ល។

ប៉ុន្តែ ដោយហេតុថា ខ្មែរបានទទួលឥទ្ធិពលសាសនាព្រាហ្មណ៍ផង ព្រះពុទ្ធសាសនាផង ម្លោះហើយក្នុងប្រពៃណី ទំនៀមទំលាប់ខ្មែរ ក៏មានលាយចំរុះដោយធាតុទាំងពីរ ព្រាហ្មណ៍និយម ព្រះពុទ្ធនិយម ជាមួយនិងខ្មែរនិយម។

ហេតុនេះ ពិធីបុណ្យទានផ្សេងៗ ដែលជាប្រពៃណីច្រើនតែមានធាតុទាំងពលាយឡំដូចជា :

- ពិធីចំរើនព្រះបរិត្ត គេនិមន្តព្រះសង្ឃចំរើនព្រះបរិត្តផង ធ្វើស្លាធមិបាយសី ឬស្លាធមិដូងផងតាមបែបបុរាណ។
- ពិធីស្រោចទឹករំដោះ គេនិមន្តព្រះសង្ឃសូត្រមន្តផង ធ្វើពិធីរំដោះគ្រោះ (បែបព្រាហ្មណ៍ គឺមានសែនព្រេនជាដើម) ផង។

ប្រពៃណី ទំនៀមទំលាប់ណាដែលគេធ្វើហើយ មានតំកល់ព្រះពុទ្ធជាទីសក្ការៈបូជា មានចំរើនព្រះបរិត្តទេសនាជាដើម គឺជាបែបព្រះពុទ្ធនិយម ក្នុងប្រពៃណី ទំនៀមទំលាប់ខ្មែរ។

សូត្រធម៌ កូនក្មេងអាណាថា ត្រាច់ចរសុំទានតាមផ្សារ ច្រកល្ហកនៃភូមិ ឃុំ ស្រុក ខេត្ត ... ។

ក្រៅពីនេះនៅមានបញ្ហាយុវជនទៀត ដែលត្រូវអប់រំឱ្យបានពេញលេញ ដើម្បីជាជំនួយដល់ពួកយុវជនតទៅអនាគត ក្នុងការផ្សព្វផ្សាយព្រះពុទ្ធសាសនា និងការជួយប្រទេសជាតិមាតុភូមិ។

### គ. ការបួសមាន២ គឺ :

#### ១. ពិធីបួសជាសាមណេរដោយសង្ខេប

កុលបុត្រណាមានអាយុយ៉ាងតិច១១ឆ្នាំគត់ មានសំដីវាចារច្បាស់លាស់ ព្រមទាំងពុំមានការប៉ះពាល់លើទោសកំហុស ដែលព្រះវិន័យ និងច្បាប់បញ្ញត្តិហាមឃាត់សំរាប់ប្រទេស កុមារនោះអាចបួសជាសាមណេរបាន។

www.budinst.gov.kh www.elibraryofcambodia.org

លំដាប់តមក កុលបុត្រត្រូវចូលមកថ្វាយបង្គំ ព្រះថេរអ្នកបួសនោះ ហើយអង្គុយប្រហោង ប្រណម្យអញ្ជលិ ក្នុងទីជិតចំពោះមុខលោកសូត្រសូមសរណគមន៍ ព្រមទាំងសីល១០ ([៤៣]) ។

## ២. ពិធីបួសសាមណេរឱ្យឡើងជាភិក្ខុដោយសង្ខេប

ក្រោយពីសាមណេរបានសុំនិស្ស័យពីឧបជ្ឈាយ៍ ហើយគ្រូឧបសម្បទាចារ្យ ( លោកគ្រូសូត្រ ) ចាត់ការពិធីរាប់បាត្រ និងចីវរជាដើម រួចលោកគ្រូសូត្រចេញពីក្នុងជំរុំសង្ឃ ទៅប្រៀនប្រដៅឧបសម្បទាបេក្ខៈ ឱ្យចេះឆ្លើយ មានសួរពីអន្តរាយិកធម៌ គឺបានដល់អាពាធ៥យ៉ាង និងបុគ្គលដែលមានពុទ្ធបញ្ញត្តិ ហាមមិនឱ្យបំបួស ។

ឧបសម្បទាបេក្ខៈ ត្រូវត្រឡប់ចូលថ្វាយបង្គំជំនុំសង្ឃ រួចហើយអង្គុយប្រហោង ប្រណម្យ អញ្ជលិ សូត្រសូមឧបសម្បទាចំពោះសង្ឃ រួចសូត្របញ្ញត្តិចតុត្ថកម្មវាចាជាអវសាន ពេលនោះឧបសម្បទាបេក្ខៈ ហើយបានឡើងទៅកាន់ជាភិក្ខុដោយបរិបូរណ៍ ក្នុងខណៈនោះឯង ។ បន្ទាប់ពីនោះឧបជ្ឈាយ៍ត្រូវប្រាប់អ្នកបួសថ្មីនូវអនុសាសនៈ៨យ៉ាង ពន្យល់បំភ្លឺឱ្យយល់ជាក់ច្បាស់ ([៤៤]) ។

## ៣. ករណីកិច្ចនៃបព្វជិត

ចំនែកកម្មវិធីសិក្សាខាងបព្វជិត មានកម្មវិធីខាងសាលាបាលីរង សាលាធម្មវិន័យ ពុទ្ធិកវិទ្យាល័យព្រះសុរាម្រិត ពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជ ក៏ត្រូវបញ្ចូលអត្ថបទខ្លះនៃកម្មវិធីសិក្សាទាំងពីរផ្នែកឱ្យមានតុល្យភាពនឹងគ្នា គឺដើម្បីឱ្យចេះដឹងខាងផ្លូវលោក ផ្លូវធម៌ជាហេតុញ៉ាំងអាណាចក្រ និងសាសនចក្រឱ្យវិលទៅព្រម១គ្នា។ នេះបញ្ជាក់ជូនតួនាទី និងភារកិច្ចនៃព្រះពុទ្ធសាសនានៅប្រទេសយើង ។ ចុះដូចម្ដេចបានជាលទ្ធផលជាផ្លែផ្កាយើងទទួលត្រូវឃ្លាតឆ្ងាយពីច្បាប់ដើមម្ល៉េះ ? នេះមិនជាការពិបាកយល់ទេឱ្យតែយើងទាំងអស់គ្នាឯកភាព ទទួលស្គាល់ការពិត ។ ប្រសិនបើយើងឯកភាពគ្នាទទួលស្គាល់នូវសារជាតិនៃវិបត្តិនេះ និងតំរូវការអំពីអភិសមាចារមួយដែលមាននិរន្តភាពខាងបច្ចេកទេសមានច្រើនដែរ ។ សាលាច្រើនបានរួមវិភាគទានជាមួយបច្ចេកទេសដ៏ច្រើនសន្ធឹកសន្ធាប់ ដើម្បីដល់សង្គមដែលពិសេសដោយការកំណត់ឱ្យនៃវិបត្តិដែលកើតមានឡើងក្នុងបច្ចុប្បន្នឈរលើមូលដ្ឋាននៃទ្រឹស្តីព្រះពុទ្ធសាសនា ការធ្វើសមាហរណកម្មនៃគំលៃអភិសមាចារ របស់ព្រះពុទ្ធសាសនានៅក្នុងគំរោងអប់រំនៅប្រទេសយើង ។ រួមទាំងការអភិវឌ្ឍទស្សនៈព្រះពុទ្ធសាសនា និងការតំរង់ទិសឆ្ពោះទៅរកធម្មជាតិ ចិត្តសាស្ត្រសង្គម និងទស្សនៈវប្បធម៌ អរិយធម៌ និងរបៀបរបបត្រឹមត្រូវប្រកបដោយនិរន្តភាព ក៏ដូចជាបញ្ហាទាក់ទងនឹងវិស័យផ្សេងៗផងដែរ ។

## ៤. តួនាទីសង្ឃក្នុងការការពារព្រះពុទ្ធសាសនា

ព្រះសង្ឃទាំងពីរគណៈ ( ធម្មយុត្តិ និងមហានិកាយ ) សង្ឃមានតួនាទីត្រឹមត្រូវតាមវិន័យបញ្ញត្តិរក្សាអប្ប

---

[៤៣] លោក កែវ ប៊ុក **ព្រះពុទ្ធសាសនានៃកម្ពុជា** ភ្នំពេញ ១៩៩៧

[៤៤] លោក កែវ ប៊ុក **ព្រះពុទ្ធសាសនានៃកម្ពុជា** ភ្នំពេញ ១៩៩៧

www.budinst.gov.kh www.elibraryofcambodia.org

មាគធម៌បានពេញលេញ សំដែងធម៌ទេសនា ពន្យល់ពុទ្ធបរិស័ទឱ្យបានយល់ច្បាស់ពីប្រតិកម្មព្រះពុទ្ធសាសនា។ ព្រះសង្ឃមានតួនាទីព្យាយាមរៀនសូត្រធម៌ គោរពវិន័យយ៉ាងមុតមាំ កាន់ចរិយាសមរម្យតាមពុទ្ធានុញ្ញត្តិរបស់ព្រះពុទ្ធ។ ព្រះសង្ឃ គឺលោកប្រតិបត្តិសីល សមាធិ បញ្ញាបរិបូរ បំពេញគន្ថធុរៈ និងវិបស្សនាធុរៈឱ្យបានពេញលេញ។ ព្រះសង្ឃលោកធ្វើតាមពុទ្ធឱវាទ។

## ៥. ជីវភាពភិក្ខុសាមណេរក្នុងវត្តអារាម

ព្រះសង្ឃមានពីរគណៈ គឺសង្ឃគណៈមហានិកាយ និងគណៈធម្មយុត្តិ។ គណៈមហានិកាយមានវត្ត និងមានព្រះសង្ឃច្រើនជាងគណៈធម្មយុត្តិ។

ព្រះភិក្ខុសាមណេរនឹងតើនឡើងនៅម៉ោង៤ ឬ៥ ជិតបែកបច្ចូស។ សម័យលោកក៏មន្តទៅសូត្រធម៌ថ្វាយបង្គំព្រះរតនត្រ័យក្នុងព្រះវិហារ រួចក៏ទ្រង់និមន្តទៅបិណ្ឌបាត្រ គ្រប់ច្រកល្ហក វិថី តាមផ្លូវក្នុងភូមិ ឃុំ ស្រុក ខេត្ត និងក្រុង...។ ឧបាសក ឧបាសិកា ក៏ក្រោកពីព្រលឹមដាំបាយដាក់បាត្រ។ ដល់ថ្ងៃឧបោសថសីល ព្រះសង្ឃសំបូរចង្ហាន់ ព្រោះឧបាសក ឧបាសិកាដែលសុំសីល គេយកម្ហូបបាយចំណីគ្រប់យ៉ាងទៅប្រគេនដល់ចៅអធិការវត្ត ដើម្បីបែងចែកទៅភិក្ខុសាមណេរគ្រប់អង្គក្នុងវត្តនីមួយៗ។ ដល់ពេលឆាន់រួចលោកក៏សំរាកមួយស្របក់ ទើបនិមន្តទៅរៀនសូត្រ ព្រះសាមណេរក្នុងក្រុងនិមន្តទៅរៀនសូត្រសាលាបាលីរង សាលាធម្មវិន័យ។ លុះដល់ពេលល្ងាចព្រះសង្ឃមិនឆាន់អាហារទេ ឆាន់បានតែទឹកតែ ស្ករ ទឹកក្រូចជាដើម លើកលែងតែសុរា និងមេរ័យ។ ក្នុងពេលឆាន់សង្ឃត្រូវចំរើនបច្ចវេក្ខណៈ ពិចារណានោះឱ្យទៅជាអាហារបដិកូលសញ្ញាទើបឆាន់បាន។

ពេលយប់ត្រូវរៀនសូត្រធម៌វិន័យ ក្បួនច្បាប់ព្រះពុទ្ធសាសនាឱ្យចេះចាំស្ទាត់ មានព្រះបរិត្តជាដើម រួចថ្វាយបង្គំព្រះទើបសឹងបាន។ សង្ឃត្រូវបំពេញនូវសង្ឃកម្ម តាមពុទ្ធានុញ្ញត្តិមានការសំដែងនូវអាបត្តិជាដើម។ មួយទៀតព្រះសង្ឃត្រូវនៅចាំព្រះវស្សាអស់ត្រីមាសក្នុងវត្តណាមួយ តាំងពីថ្ងៃចូលវស្សា រហូតដល់ចេញវស្សា លើកលែងតែមានការមមាញឹកជាដើម ដូចជា : មាតាបិតាមានជំងឺ ឬគ្រូឧបជ្ឈាយាចារ្យមានរោគាពាធ តែព្រះសង្ឃក្នុងពេលនោះមិនត្រូវចេញពីវត្តដែលខ្លួនចាំវស្សាលើសពីមួយសប្តាហ៍បានឡើយ។ មុននឹងនិមន្តទៅលោកត្រូវអធិដ្ឋានថា : លោកនឹងនិមន្តមកកាន់វត្តវិញតាមកំនត់កាល។ ក្រៅពីនោះដោយសេចក្តីនិមន្តនៃឧបាសក ឧបាសិកាជើងវត្តក្នុងកិច្ចចំរើនព្រះបរិត្តសំដែងធម្មទេសនាលោកអាចនិមន្តទៅបាន។

ជួនកាលដោយមានហេតុអ្វីមួយ មានរោគាព្យាធិជាដើម សង្ឃណាមិនអាចចូលព្រះវស្សាបានក្នុងករណីនេះលោកត្រូវចូលវស្សានៅថ្ងៃទី១ នៃខែស្រាពណ៍។ បើព្រះសង្ឃនៅក្នុងវត្តអារាមចង់និមន្តចេញពីទីវត្តត្រូវឱ្យដំណឹងទៅដល់ចៅអធិការវត្តដែលលោកបំរុងនឹងគង់នៅ។

## ៦. ជីវភាពភិក្ខុសាមណេរក្នុងការងារព្រះពុទ្ធសាសនា

ព្រះសង្ឃ គឺសំដៅយកព្រះសង្ឃទាំងពីរគណៈ (គណៈមហានិកាយ និងគណៈធម្មយុត្តិ) សូមព្រះសង្ឃទាំង

www.budinst.gov.kh www.elibraryofcambodia.org

ពីរគណៈរួបរួមសាមគ្គីគ្នា ដើម្បីផ្សព្វផ្សាយព្រះពុទ្ធសាសនាឱ្យរីកចំរើនពេញព្រះរាជាណាចក្រកម្ពុជាទាំងមូល ។

ព្រះសង្ឃ គឺព្រះភិក្ខុ សាមណេរ ត្រូវប្រព្រឹត្តិឱ្យបានត្រឹមត្រូវតាមវិន័យបញ្ញត្តិ រក្សាអប្បមាទធម៌ សំដែងធម៌ទេសនា ពន្យល់ពុទ្ធបរិស័ទឱ្យយល់ជាក់ច្បាស់នូវវិធីប្រតិបត្តិព្រះពុទ្ធសាសនា ព្យាយាមរៀនសូត្រធម៌វិន័យឱ្យបានមុតមាំ កាន់ចរិយាឱ្យជនសមរម្យទៅតាមពុទ្ធានុញ្ញត្តិ ទើបព្រះពុទ្ធសាសនារីកចំរើនរុងរឿងតទៅអនាគត ។ ព្រះសង្ឃត្រូវប្រព្រឹត្តិសីល សមាធិ បញ្ញាឱ្យបរិបូរណ៍ បំពេញគន្ថធុរៈ និងវិបស្សនាធុរៈ ឱ្យបានពេញលក្ខណៈ ធ្វើតាមឱវាទព្រះពុទ្ធ មានសព្វបាបស្សអករណំមិនឱ្យធ្វើបាបទាំងពួង កុសលស្សូបសម្បទាញុំាងកុសលឱ្យដល់ព្រម១ ជំរះចិត្តរបស់ខ្លួនឱ្យផូរផង់មួយ ធ្វើធម៌អរិយសច្ចៈឱ្យជាក់លាក់ក្នុងសណ្ដានចិត្តឡើងញុំាងលោកធម៌ទាំង៨ឱ្យអស់ទៅតំកល់ឡើងកាន់លោកុត្តរធម៌៩តាមលំដាប់ពិចារណានូវវឌ្ឍនធម៌ និងអន្តរាយធម៌ ដើម្បីការពារកុំឱ្យព្រះពុទ្ធសាសនាវិនាសទៅអនាគត ([៤៥]) ។

ព្រះសង្ឃជាស្រែបុណ្យ សំរាប់ឧបាសក ឧបាសិកា សាបព្រួសនូវពូជ បើស្រែនោះមានជីវជាតិល្អ ពូជដែលសាបព្រួសនោះក៏មានផលល្អដែរ ។ ហេតុនេះ ឧបាសក ឧបាសិកាត្រូវប្រតិបត្តិឱ្យបានជ្រះថ្លា ទើបគេខុស្សាហ៍សាបព្រួសនូវបុណ្យកុសល ។ ព្រះសង្ឃជាសាវ័កនៃព្រះសង្ឃដ៏មានព្រះភាគ លោកបានប្រតិបត្តិហើយដោយប្រពៃ គឺប្រតិបត្តិតាមសីលសមាធិបញ្ញា សង្ឃណាដែលគ្មានសីល សមាធិបញ្ញានៅក្នុងខ្លួនមិនប្រព្រឹត្តិតាមសិក្ខាបទ២២៦ នោះគេមិនហៅថា **សង្ឃ** ឡើយ ។ ដូច្នេះ ត្រូវព្យាយាមធ្វើកាយវិចារចិត្តឱ្យមានរបៀបរៀបរយញុំាងចិត្តឱ្យស្អាតបរិសុទ្ធ វិបស្សនាប្រាជ្ញាឱ្យមានឡើងតាមជាលំដាប់ ព្រះសង្ឃនោះជាទីគោរពនៃពុទ្ធសាសនិកជនទាំងឡាយ ។

ព្រះសង្ឃនេះជាគ្រឿងដ៏ណែលមួយសំរាប់រក្សា ព្រះពុទ្ធសាសនា ប្រមូលប្រជារាស្ត្រខ្មែរឱ្យខិតខំព្យាយាមការពារព្រះពុទ្ធសាសនាឱ្យបានស្ថិតស្ថេរចិរកាលតទៅអនាគត ។ បង្កើនសាមគ្គីភាពឱ្យចំរើនដុះដាលឡើងនៅក្នុងសណ្ដានចិត្តពុទ្ធសាសនិកជនគ្រប់ៗរូប ដើម្បីវាតសកម្មភាពព្រះពុទ្ធសាសនាឱ្យមានវឌ្ឍនភាពតាមការគួរ ញុំាងចិត្តប្រជាជនឱ្យមានចិត្តជ្រះថ្លាចំពោះព្រះពុទ្ធសាសនា ដោយពន្យល់បំភ្លឺខាងវិធីប្រតិបត្តិព្រះពុទ្ធសាសនា ឱ្យបានរុងរឿងជាអរិយភាព ។

ព្រះសង្ឃនេះជាមគ្គុទេសក៍ដ៏ឆ្នើមសំរាប់ដឹកនាំប្រជាជនឱ្យចូលទៅក្រេបទឹកអម្រឹត គឺអមតមហានិព្វាន និងជាសុវណ្ណភេត្រា សំរាប់ដឹកនាំសត្វពីអាកាសធាតុទៅនិព្វានធាតុ ។ លោកជាប្រទីបសំរាប់បំភ្លឺសព្វសត្វឱ្យយល់ផ្លូវខុសផ្លូវត្រង់ គំនិតសង្ឃាធិបតេយ្យ ៥២២៦ ព្រះបាទធម្មិក សង្ឃប្រែថាក្រុម ។ ក្នុងនេះបានដល់ការសំរេចចិត្តមួយគប្បីស្តាប់មតិ និងការយល់ព្រមពីក្រុម ។ ជាន័យអនុវត្តក្នុងសង្គម បានដល់គំនិតប្រជាធិបតេយ្យ គឺយករាស្ត្រជាធំ ស្តាប់យោបល់រាស្ត្រ ។ អ្នកដឹកនាំជាអ្នកបំរើរាស្ត្រ មិនមែនជាចៅហ្វាយរាស្ត្រដូចយើងចូលចិត្តនោះទេ ។ សង្ឃាធិបតេយ្យប្អូរបបប្រជាធិបតេយ្យជារបបគំរូក្នុងសង្គមសាសនា ដែលព្រះសម្មាសម្ពុទ្ធបានតាំងឡើង ។

---

[៤៥] លោក វ៉ាយ ប៉ុក **ព្រះពុទ្ធសាសនានៃកម្ពុជា** ភ្នំពេញ ១៩៧៣

## ផ្នែកទី៣ទស្សនៈអត្ថនិពន្ធ :

ព្រះសង្ឃព្រះអង្គប្រតិបត្តិសីល សមាធិ បញ្ញាបរិបូរបំពេញគន្ថធុរៈ និងវិបស្សនាធុរៈឱ្យបានពេញ លេញ។ ព្រះសង្ឃលោកធ្វើតាមឱវាទព្រះពុទ្ធ។

### ១. ជីវភាពភិក្ខុសាមណេរក្នុងវត្តអារាម :

ព្រះសង្ឃមានពីរគណៈ គឺសង្ឃគណៈមហានិកាយ និងសង្ឃធម្មយុត្តិ ។គណៈមហានិកាយមានវត្ត និងព្រះសង្ឃច្រើនជាងគណៈធម្មយុត្តិ។

ព្រះភិក្ខុសាមណេរ លោកក្រោកឡើងម៉ោង ៤ ឬ៥ ជិតភ្លឺបែកបច្ចូស។ សម័យលោកក៏និមន្តទៅសូត្រធម៌ថ្វាយបង្គំព្រះរតនត្រ័យក្នុងព្រះវិហារ រួចក៏និមន្តទៅទ្រង់បិណ្ឌបាតតាមច្រកល្ហក វិថីតាមផ្លូវក្នុងភូមិ ឃុំ ខេត្ត និងក្រុង..។ ឧបាសក ឧបាសិកាក៏ក្រោកពីព្រលឹមដាំបាយដាក់បាត។ ដល់ថ្ងៃឧបោសថសីលព្រះសង្ឃសំបូរចង្ហាន់ ព្រោះឧបាសិកាដែលសុំសីល គេយកបាយម្ហូបចំណីគ្រប់យ៉ាងទៅប្រគេនចៅអធិការ ដើម្បីបែងចែកទៅព្រះភិក្ខុសាមណេរគ្រប់អង្គតាមវត្តនីមួយៗ។ ដល់ពេលឆាន់រួច លោកសំរាកមួយស្របក់ ទើបនិមន្តទៅរៀនសូត្រ ព្រះសាមណេរក្នុងក្រុងក៏និមន្តទៅរៀនសូត្រឯសាលាបាលីរង សាលាធម្មវិន័យ។ លុះដល់ពេលល្ងាច ព្រះសង្ឃមិនឆាន់អាហារ តែឆាន់បានតែទឹកតែ ស្ករ ទឹកក្រូចជាដើម លើកលែងតែសុរានិងមេរ័យ។ ក្នុងពេលឆាន់ សង្ឃត្រូវចំរើនបច្ចវេក្ខណៈពិចារណាម្ហូបអាហារនោះ ឱ្យទៅជាអាហារបដិកូលសញ្ញា ទើបឆាន់បាន។

ពេលយប់ត្រូវរៀនសូត្រធម៌ ក្បួនច្បាប់ព្រះពុទ្ធសាសនាឱ្យចេះចាំស្ទាត់ មានព្រះបរិត្តជាដើម រួចថ្វាយបង្គំព្រះទើបសឹងបាន។ ព្រះសង្ឃត្រូវបំពេញនូវសង្ឃកម្មតាមពុទ្ធានុញ្ញាត្តិ មានការសំដែងនូវអាបត្តិជាដើម ។មួយទៀតសង្ឃត្រូវចាំព្រះវស្សាអស់ត្រីមាសក្នុងវត្តណាមួយ តាំងពីថ្ងៃចូលវស្សារហូតដល់ចេញវស្សា លើកលែងតែមានការមមាញឹកជាដើម ដូចជា: មាតាបិតាមានជំងឺ ឬគ្រូឧបជ្ឈាយាចារ្យមានរោគាពាធ តែព្រះសង្ឃក្នុងពេលនោះមិនត្រូវចេញពីវត្តដែលខ្លួនចាំវស្សាលើសពីមួយសប្តាហ៍បានឡើយ។ មុននឹងនិមន្តទៅ លោកត្រូវអធិដ្ឋានថា: លោកនឹងនិមន្តមកកាន់វត្តវិញពេលកាលកំណត់។ ក្រៅពីនោះ ដោយសេចក្តីនិមន្តនៃឧបាសក ឧបាសិកាដើម្បីវត្តក្នុងកិច្ចចំរើនព្រះបរិត្តសំដែងធម្មទេសនាលោកអាចនិមន្តបាន។

ជួនកាលដោយមានហេតុអ្វីមួយ មានរោគាពាធជាដើម សង្ឃណាមិនអាចចូលវស្សាបានក្នុងករណីនេះលោកត្រូវចូលវស្សានៅថ្ងៃទី១ នៃខែស្រាពណ៍ ។បើព្រះសង្ឃនៅក្នុងវត្តអារាម ចង់និមន្តចេញពីវត្តត្រូវឱ្យដំណឹងដល់ចៅអធិការវត្តមិនទៅ ឬវត្តឯទៀត ហើយនិមន្តមកគង់នៅវត្តមួយផ្សេងពីលំនៅដើម ត្រូវសុំអនុញ្ញាតពីចៅអធិការវត្តដែលលោកបំរុងនឹងគង់នៅ។

www.budinst.gov.kh www.elibraryofcambodia.org

## ២. ជីវភាពភិក្ខុសាមណេរក្នុងការថែរក្សាព្រះពុទ្ធសាសនា :

ព្រះសង្ឃគឺសំដៅយកព្រះសង្ឃទាំងពីរគណៈ ( គណៈមហានិកាយ និងគណៈធម្មយុត្តិ ) សូមព្រះសង្ឃទាំងពីររូបរួមសាមគ្គីគ្នា ដើម្បីផ្សព្វផ្សាយព្រះពុទ្ធសាសនាឱ្យរីកចំរើនពេញព្រះរាជាណាចក្រទាំងមូល ។

"ព្រះសង្ឃគឺព្រះភិក្ខុ សាមណេរគួរប្រព្រឹត្តឱ្យបានត្រឹមត្រូវតាមវិន័យបញ្ញត្តិ រក្សាអប្បមាទធម៌ សំដែងធម៌ទេសនា ពន្យល់ពុទ្ធបរិស័ទឱ្យយល់ជាក់ច្បាស់នូវវិធីប្រតិបត្តិព្រះពុទ្ធសាសនា ព្យាយាមរៀនសូត្រធម៌ វិន័យឱ្យបានមុតមាំកាន់ចរិយាឱ្យជនសមរម្យទៅតាមពុទ្ធានុញ្ញាត ទើបព្រះពុទ្ធសាសនាចំរើនរុងរឿងតទៅអនាគត ។ ព្រះសង្ឃត្រូវប្រព្រឹត្តសីល សមាធិ បញ្ញាឱ្យបរិបូរ បំពេញគន្ថធុរៈ និងវិបស្សនាធុរៈឱ្យពេញលក្ខណៈ ធ្វើតាមឱវាទរបស់ព្រះពុទ្ធ មានសព្វបាបស្សអករណំមិនឱ្យធ្វើបាបទាំងពួងមួយកុសលស្សូបសម្បទាញុំាងកុសលឱ្យដល់ព្រមជំរះចិត្តរបស់ខ្លួនឱ្យផូរផង់មួយ ធ្វើធម៌អរិយសច្ចៈឱ្យជាក់លាក់ក្នុងសន្តានចិត្តឡើងកាន់លោកុត្តរធម៌ប្រាំបួនតាមលំដាប់សន្តានចិត្តឡើង ញុំាងលោកធម៌ទាំងប្រាំបីឱ្យអស់ទៅ ពំកល់ចិត្តឡើងកាន់លោកុត្តរធម៌តាមលំដាប់ពិចារណានូវវឌ្ឍធម៌ និងអន្តរាយិកធម៌ ដើម្បីកុំឱ្យព្រះពុទ្ធសាសនាវិនាសទៅអនាគត" ។

ព្រះសង្ឃជាស្រែបុណ្យ សំរាប់ឧបាសកឧបាសិកា សាបព្រោះនូវពូជ បើស្រែនោះមានជីវជាតិល្អ ពូជដែលសាបព្រោះក៏បានផលល្អដែរ ។ ហេតុនេះឧបាសក ឧបាសិកា ត្រូវប្រតិបត្តិឱ្យបានជ្រះថ្លាទើបគេឧស្សាហ៍សាបព្រោះនូវបុណ្យកុសល ។ ព្រះសង្ឃជាសាវ័កនៃព្រះដ៏មានព្រះភាគ លោកបានប្រតិបត្តិហើយដោយប្រពៃគឺប្រតិបត្តិតាមសីលសមាធិបញ្ញា សង្ឃណាដែលគ្មានសីល សមាធិបញ្ញានៅក្នុងខ្លួនមិនប្រព្រឹត្តតាមសិក្ខាបទ២២៦នោះគេមិនហៅថាសង្ឃទេ ។ ដូច្នេះត្រូវព្យាយាមធ្វើកាយ វិចាចិត្ត ឱ្យមានរបៀបរៀបរយ ញុំាងចិត្តឱ្យស្អាតបរិសុទ្ធ វិបស្សនាប្រាជ្ញាឱ្យមានឡើងតាមលំដាប់ទើបសង្ឃនោះជាទីគោរពនៃព្រះពុទ្ធសាសនិកជនទាំងឡាយ ។

ព្រះសង្ឃនេះជាកំលាំងមួយសំរាប់រក្សាកេរតំណែលព្រះពុទ្ធសាសនា ប្រមូលប្រជារាស្ត្រខ្មែរឱ្យខិតខំព្យាយាម ការពារព្រះពុទ្ធសាសនា ឱ្យបានស្ថិតស្ថេរចិរកាលតទៅអនាគត ។ បង្កើនសាមគ្គីភាពឱ្យចំរើនដុះដាលឡើងនៅក្នុងសន្តានចិត្តពុទ្ធសាសនិកគ្រប់ៗរូប ដើម្បីវាតព្រះពុទ្ធសាសនាឱ្យមានវឌ្ឍនភាពតាមការគួរ ញុំាងចិត្តប្រជាជនឱ្យមានសទ្ធាជ្រះថ្លាចំពោះព្រះពុទ្ធសាសនា ដោយពន្យល់បំភ្លឺខាងវិធីប្រតិបត្តិព្រះពុទ្ធសាសនាឱ្យបានរុងរឿងជាអរិយភាព ។

" ព្រះសង្ឃនេះជាមគ្គុទេសដ៏ឆ្នើមសំរាប់ដឹកនាំប្រជាជនឱ្យចូលទៅក្រេបទឹកអម្រឹត គឺអមតមហានិព្វានដ្ឋនិងជាសុវណ្ណភេត្រាសំរាប់ដឹកនាំពីអាកាសធាតុទៅនិញ្វន្តធាតុ ។ លោកជាប្រទីបសំរាប់បំភ្លឺសព្វសត្វ ឱ្យយល់ផ្លូវខុសផ្លូវត្រូវ គំនិតសង្ឃាធិបតេយ្យ" ៩២២៦ ព្រះបាទធម្មិកសង្ឃ ប្រែថាក្រុម ។ ក្នុងនេះបានដល់ការសំរេចចិត្តមួយ គប្បីស្តាប់មតិ និងការយល់ព្រមពីក្រុម ។ ជាន័យអនុវត្តក្នុងសង្គម បានដល់គំនិតប្រជាធិបតេយ្យគឺយករាស្ត្រជាធំ ស្តាប់យោបល់រាស្ត្រ អ្នកដឹកនាំជាអ្នកបំរើរាស្ត្រមិនមែនជាចៅហ្វាយរាស្ត្រដូចយើងចូលចិត្តនោះទេ ។ សង្ឃាធិបតេយ្យឬ

www.budinst.gov.kh www.elibraryofcambodia.org

ប្រជាធិបតេយ្យរាស្ត្រ អ្នកដឹកនាំជាអ្នកបំរើរាស្ត្រមិនមែនជាចៅហ្វាយរាស្ត្រដូចយើងចូលចិត្តនោះទេ។ សង្ឃាធិបតេយ្យឬប្រជាធិបតេយ្យជារបបគំរូក្នុងសង្គមសាសនាដែលព្រះសម្មាសម្ពុទ្ធបានតាំងឡើង ។

## ៣. ព្រះពុទ្ធសាសនា និងពហុសាសនានៅកម្ពុជា :

តាំងពីសម័យនគរភ្នំមក ព្រះពុទ្ធសាសនាបានប្រើប្រាសជាមួយសាសនាព្រាហ្មណ៍ សម័យចេនឡាពុទ្ធសាសនាមហានិកាយបានចូលមកទៀត សម័យលង្វែកថែមត្រីសាសនា។ បច្ចុប្បន្ននេះក៏មានសាសនាជាច្រើនដែរដូចជា : ព្រះពុទ្ធសាសនា ឥស្លាមសាសនា មហាយាន និងកៅដាយ សាសនាម៉ុសឹក សាសនាគង់ស៊ុអ៊ុម សាសនាចិនក្នុងស្រុក ..... ត្រូវបានប្រើប្រាស់សំយោគសាសនាក្រៅស្រុកជាមួយសាសនាម្ចាស់ស្រុក អ្នកដូនអ្នកតា ក៏ពុំដែលលេចចេញបាតុភូតទំនាស់អ្វីដែរ។

## ៤. ការប្រើបញ្ញត្តិព្រះពុទ្ធសាសនាមួយចំនួនមិនត្រឹមត្រូវបណ្តាលឱ្យមានការស្រុតចុះសីលធម៌នៅកម្ពុជា :

ចាប់ពីដើមឆ្នាំ ១៩៧៩មក អ្វីៗដែលបាត់បង់នោះ ក៏បានរស់ឡើងវិញ ខ្លះរស់និងរីកចំរើនជាបន្តបន្ទាប់ ខ្លះបានវិវត្តរីកចំរើនទៅរកទិសមួយផ្សេងដែលផ្តល់ផលតិចដល់ការពង្រីកអត្តសញ្ញាជាតិ។

ទន្ទឹមនឹងនោះ មានភិក្ខុសង្ឃដែលប្រកបដោយមនសិកាជាតិខ្ពស់ បានរួមចំណែកស្តារ និងកសាងសង្គម យ៉ាងសកម្ម ហើយទុកជាស្ពានតភ្ជាប់ប្រពៃណីដ៏ប្រសើររបស់ព្រះសង្ឃ និងពុទ្ធសាសនិកយើង តាំងពីជាង២០០ឆ្នាំមកហើយ។ សកម្មភាពដែលលេចធ្លោនោះ គឺការរួមចំណែកស្តារឡើងវិញនូវវិស័យអប់រំ ការកសាងផ្លូវ ស្ពាន កសិកម្ម ព្រមទាំងវិស័យខាងស្មារតី ដែលផ្តល់ផលដ៏ប្រសើរដល់ការប្រមូលផ្តុំសាមគ្គីភាពជាតិ និងឯកភាព ជាតិ។

ប៉ុន្តែ វាក៏នៅមានបាតុភូតអវិជ្ជាមានច្រើនផងដែរ ក្នុងចំនោមព្រះសង្ឃពុទ្ធសាសនិកយើងដោយបណ្តាលមកពីការពុំទាន់មានការភ្ញាក់រលឹក មោះមុត និងការសំរេចចិត្តដ៏អង់អាច ដើម្បីប្រោងផ្តល់ទង់ពុទ្ធសាសនា និងរួមចំណែកស្តារ កសាងសង្គមខ្មែរឡើងវិញ។

ហេតុនេះ ដើម្បីជំរះបាតុភូតអវិជ្ជមានច្រើនទាំងនោះ ព្រះសង្ឃ ពុទ្ធសាសនិកជនទាំងអស់ គួរតែទទួលយកការអប់រំសមស្របក្នុងការបណ្តុះព្រហ្មវិហារធម៌ និងមនសិការ ភ្ញាក់រលឹកកំរិតខ្ពស់ចំពោះសង្គមជាតិ។ ជាក់ស្តែងកាលពីសិក្ខាសាលាលើកទី១ នៅថ្ងៃទី២១-២៣ វិច្ឆិកា ១៩៩៤ អ្នកយល់ដឹងខាងព្រះពុទ្ធសាសនាជាច្រើន បានប្តូរយោបល់យ៉ាងល្អិតល្អន់ អំពីគោលបំណងកែលំអ គោលការណ៍នៃការប្រើប្រាស់ព្រះពុទ្ធសាសនានៅប្រទេសកម្ពុជាយើង ដូចពុទ្ធដីកាខាងក្រោមនេះ :

ត្រូវតែបានទទួលស្គាល់ការពិតថា ពេលនេះគឺជាចុងស.វទី២០ ឈានចូលទី២១ ហើយអ្វីៗមិនដូចពីមុនទេ។ នេះជាសម័យវិទ្យាសាស្ត្រ សម័យកុំព្យូទ័រ សម័យដែលត្រូវការហេតុផលជាក់ស្តែង សម័យដែលទាមទារការប្រណាំងប្រជែងដើម្បីរស់ ដូចពាក្យរបស់អ្នកប្រាជ្ញអឺរ៉ុបថា : អ្នកណាខ្លាំងជាងគេបំផុត អ្នកនោះអាចរស់តទៅទៀត

www.budinst.gov.kh www.elibraryofcambodia.org

បាន (The strong the survival)។ ការដេញចាប់ រឿងពុទ្ធប្រវត្តិ និងលេងល្ខោនបាសាក់អប់រំក្មេង សក្តិសមណាស់សំរាប់ ៣០ ឬ ៤០ឆ្នាំមុន។ តែឥឡូវនេះ ទាល់តែហ្គីតា និងល្ខោននិយាយ ឬវីឌីអូ ទើបអាចទាក់ទាញឱ្យក្មេងចង់ស្តាប់ ចង់មើលបាន។

ត្រូវប៉ាននកាប់ឆ្ការនូវមែកស្វិតណា ដែលដុះលូតលាស់ដោយឥតគេប្រដៅ ជៀសវាងកុំឱ្យទៅជាកូនព្រៃរបោះ ដែលប្រើការមិនសូវបានផល ដោយទុកតែដើមណារឹងមាំឱ្យលូតលាស់ទៅជាដើមរុក្ខជាតិ នឹងគេឡើង មែកស្វិតណាដែលមានជំងឺ ឬមានបញ្ញើរកែ្អក ក៏គួរកាប់ចោល ជៀសវាងឱ្យអន់ដើមផ្លែមិនត្រូវចាំន់។

នេះបញ្ជាក់ឱ្យឃើញថា ទំនាស់មួយត្រូវបានរួមដោយកត្តាជាច្រើន។ ដើម្បីដោះស្រាយទំនាស់មួយ ឬកែលំអផ្នែកមួយ ត្រូវរកហេតុច្រើន ហើយបំពេញឱ្យហេតុទាំងនោះ ទើបទំនាស់ត្រូវបានដោះស្រាយ។

ព្រះពុទ្ធសាសនានៅប្រទេសយើង ដូចគ្នានឹងដើមពោធិ៍ដួលហើយលាស់ឡើងវិញអញ្ចឹង តែគ្មានអ្វីជាគោលអាង ខ្វះការសិក្សា។ បញ្ហាអប់រំទន់ខ្សោយ បញ្ហាសិក្សាមិនគ្រប់គ្រាន់ បញ្ហាការប្រតិបត្តិរយីករយាក បញ្ហាបន្តពូជដោយមានជំងឺ បញ្ហាសេដ្ឋកិច្ចឥតទីពឹង គឺជាតួបង្ហាញ(Indicators) ពីសភាពការណ៍មិនភ្លឺស្វាងមួយរបស់ព្រះពុទ្ធសាសនាខ្មែរនាពេលបច្ចុប្បន្ន (ទុក្ខអរិយសច្ចៈ) និងក៏ជាតួកំណត់(Determiners) ដែលមានអានុភាពអវិជ្ជមានដល់អនាគតនៃព្រះពុទ្ធសាសនាយើង ដោយជៀសមិនបានឡើយ (ទុក្ខសមុទយអរិយសច្ចៈ)។

តើយើងមានយុទ្ធសាស្ត្រអ្វីខ្លះទេ (ទុក្ខនិរោធគាមិនីបដិបទាអរិយសច្ចៈ) ដើម្បីដោះស្រាយមូលបញ្ហាទាំងនេះ ? បើដោះស្រាយហើយ ព្រះពុទ្ធសាសនាយើងមានលក្ខណៈ មុខមាត់បែបណា (និរោធអរិយសច្ចៈ) ផ្លូវប្រាកដជាមាន តែថានឹងមានអ្នកពេញចិត្តដើរតាម ឬយ៉ាងណានោះ មិនមែនជាកំហុសរបស់អ្នកធ្វើផ្លូវទេ សូមទោសសូមលើកឱ្យអស់ទៅចុះ វត្តមួយមានកឋិន២ បើព្រះលោកគង់នៅ ប្រហែលជាទ្រង់ព្រះសំរួលអស់សំណើចជាពុំខានឡើយ។

មានន័យថា ជំរំវិញការអប់រំខាងព្រះពុទ្ធសាសនា នៅមានសេសសល់បញ្ហាច្រើនណាស់ ហើយក៏គួរឱ្យចាប់អារម្មណ៍ដែរ ព្រោះព្រះសង្ឃសុទ្ធសឹងជាទីប្រឹក្សា ជាទីទុកចិត្តរបស់ពុទ្ធបរិស័ទ។ ព្រះភិក្ខុ**មន្នី មិន្តា** មានពុទ្ធដីកាថា : តាមផ្នែកគ្រហស្ថវិញ យើងគ្មានអង្គការសំរាប់ពុទ្ធបរិស័ទសោះ តែមានតាមបែបបុរាណ ដូចជាអាចារ្យ និងគណៈកម្មាការជាដើម ដែលមានមុខនាទីមិនច្បាស់លាស់ និងគ្មានរបៀបរៀបរយឱ្យទៅជាអង្គការដែលមានប្រសិទ្ធភាព។

ជាឧទាហរណ៍ អ្នកខ្លះឃើញអញ្ចេះ អ្នកខ្លះក៏នឹកឃើញអញ្ចុះក្នុងពិធីតែមួយជាដើម។

បញ្ហាបួស ក្នុងសង្គមខ្មែរយើង កិត្តិយស និងការសងគុណដែលកូនស្រីអាចជូនដល់គ្រួសារ ជាពិសេសមាតាបិតា គឺការរៀបមង្គលការដោយត្រឹមត្រូវ។ ឯកូនប្រុសវិញ កិត្តិយស និងការសងគុណចំពោះមាតាបិតា គឺការបាន

www.budinst.gov.kh www.elibraryofcambodia.org

ទៅបួសក្នុងព្រះពុទ្ធសាសនា។ បើសំឡឹងមើលឱ្យជ្រៅ ចំពោះចេតនារបស់សង្គមខ្មែរយើង ចំពោះករណីនេះ អាចហ៊ាននិយាយថា គឺជាផែនការបន្ត។

កូនស្រីរៀបមង្គលការ គឺជាការបន្តពូជខាងផ្លូវកាយ ឯកូនប្រុសទៅបួសក្នុងព្រះពុទ្ធសាសនា គឺជាការបន្តពូជខាងផ្លូវវិញ្ញាណ។ នេះជាឥទ្ធិពលរបស់ព្រះពុទ្ធសាសនា តាមរយៈទស្សនវិជ្ជាដែលអធិប្បាយថា : មនុស្សផ្សំឡើងដោយកាយ និងចិត្ត។ ដូច្នេះ ការបួសក្នុងព្រះពុទ្ធសាសនា គឺជាការបន្តពូជខាងព្រលឹងវិញ្ញាណ ទាំងសំរាប់កុលបុត្រដែលចូលមកបួសផង ទាំងសំរាប់សហគមន៍ខ្លួនឯងផង។ បើពូជដែលយកមកហ្នឹងល្អ ថែទាំបានដឹតដល់ បរិយាកាសអំណោយផលពូជនោះនឹងមានផ្លែផ្កាល្អពុំខាន។ តែរយៈកាលកន្លងមក ការបន្តពូជរបស់ព្រះសង្ឃយើងពុំសូវបានគិតគូរដល់រឿងការជ្រើសរើសពូជទេ គឺឱ្យតែមានចេះ តែដាំទៅ ដល់តែពូជមិនល្អ ក៏ពិបាកថែទាំ ស្រោចទឹក ដើម្បីឱ្យរស់មានផ្លែផ្កានោះក៏ពុំមានគុណភាពល្អដែរ។

បញ្ហាបន្តពូជពង្សព្រះអរិយៈ ឬការបួសក្នុងព្រះពុទ្ធសាសនាខ្មែរយើង កំពុងជួបប្រទះនាពេលបច្ចុប្បន្ន គឺ :

- បេក្ខជនដែលបួស ពុំទាន់យល់ពីគោលបំណងនៃការបួសឱ្យច្បាស់
- បេក្ខជនដែលមានកំរិតវប្បធម៌ទាប ភាគច្រើន គឺមកបួសរៀន
- គ្មានច្បាប់ ឬមាត្រាក្នុងការទទួលបេក្ខជនថ្មីឱ្យច្បាស់លាស់ គឺអ្នកណាក៏បានឱ្យតែមានសទ្ធា
- បួសរួចពុំបានទទួលការថែទាំ បង្រៀនឱ្យបានដឹតដល់ពីសំណាក់អាចារ្យ ឬឧបជ្ឈាយ៍

ជំនាន់ព្រះពុទ្ធ ក្នុងរឿង **មុជលិន្ទ** ព្រះអរហន្តដែលមាននាទីរើសអ្នកបន្តពូជបាននិមន្តទៅសុំព្រះបាទ**ខាគសេន** ពីមាតាបិតាលោករបួសដល់ទៅរាប់ឆ្នាំ ព្រោះសំឡឹងឃើញថា ពូជល្អ។

ក្នុងនេះមិនមែនជាការបំពុលសភាពការណ៍ ឬធ្វើឱ្យសភាពការណ៍អាប់អួរខុសពីការពិត ផ្ទុយទៅវិញ បើមានការបំពុលសភាពការណ៍នោះ ពិតជាបានទទួលអ្វីក្រៅពីបន្ទាបបន្ថោកជាតិឯងនោះទេ ហើយថែមទាំងផ្តល់រង្វាន់ដល់សត្រូវទៀតផង។ តឹរិះគន់ស៊ុកដោយសាមគ្គីភាព នោះវានឹងនាំឱ្យអត្ថិភាពសត្រូវកាន់តែថយចុះ។ គំនិតបែបនេះមិនមែនមានន័យថាមិនឱ្យរិះគន់នោះទេ។ ការរិះគន់កសាង(Critique Constructive) ជាកត្តាចាំបាច់សំរាប់រួមចំណែកកសាងជាតិ។

ជាការពិតរាល់វត្ថុ និងធាតុភូតសុទ្ធតែមានទំនាស់ គឺមិនអាចគេចផុតពីទំនាស់បានទេ។ តែយើងគួរមើលឱ្យឃើញទំនាស់នោះ ដើម្បីរកវិធីដោះស្រាយតាមពេលវេលាសមស្រប។ បើមិនដោះស្រាយវាទេ វានឹងដោះស្រាយខ្លួនឯងតាមបែបឯកតងុល ( សភាវគតិ ) ។ ដើម្បីទទួលផលល្អ គឺមានការដោះស្រាយដោយស្មារតីកសាង។

## ៥. ព្រំដែនព្រះពុទ្ធសាសនា

ការប្រើប្រាស់ព្រះពុទ្ធសាសនាត្រឹមត្រូវតាមគោលការណ៍ធម៌ ស្របតាមផ្លូវការសាសនា និងការប្រើប្រាស់មិនត្រឹមត្រូវ សុទ្ធសឹងតែមានព្រំដែនកំណត់របស់វា។ ទស្សនៈព្រះពុទ្ធសាសនា ក៏ដូចជាទស្សនៈរបស់សីលធម៌ដែរ

www.budinst.gov.kh www.elibraryofcambodia.org

មនុស្ស (ប្តី ប្រពន្ធ កូន ឪពុក ម្តាយ មិត្តភក្តិ) គឺសុទ្ធតែមានព្រំដែនទាំងខាងឆន្ទៈ ទាំងខាងសកម្មភាព។ ការគោរពសិទ្ធទៅវិញទៅមក ការស្គាល់ពេលវេលា គឺសុទ្ធបញ្ជាក់ពីការទទួលស្គាល់ព្រំដែនរបស់វា។ ការរំលោភលើព្រំដែនចិត្ត ព្រំដែនសកម្មភាព ពិតជាធ្វើឱ្យមនុស្សជួបផលវិបាកក្នុងជីវិតជាច្រើន។

បច្ចុប្បន្នក្រសួងធម្មការខេត្ត-ក្រុង រាជធានីងកំពុងយកចិត្តទុកដាក់ក្នុងបញ្ហាកែលំអនូវកំហុសឆ្គងនៃការប្រើប្រាស់ព្រះពុទ្ធសាសនាណាស់។ សិក្ខាសាលាលើកទី១ លើកទី២ លើកទី៣ លោកគ្រូអាចារ្យ **មុត សារ៉ាឌុ** ផ្សាយតាមវិទ្យុរាល់ព្រឹក ដែលជាអ្នកប្រាជ្ញខាងសាសនា សុទ្ធតែរួមចំនែកអប់រំ ផ្ទេរចំណេះដឹងផ្នែកព្រះពុទ្ធសាសនាទាំងអស់ដល់លោកអ្នកដែលជាពុទ្ធបរិស័ទ។

មនុស្សខ្មែរ កំពុងប្រើប្រាស់សីលធម៌ព្រះពុទ្ធសាសនាមានការភ័ន្តច្រឡំ ច្របូកច្របល់ច្រើន។ មានន័យថា : អ្នកចេះគម្ពីរធម៌អាចប្រសើរណាស់ តែបើយកទៅប្រតិបត្តិឱ្យបានត្រឹមត្រូវទៀត នោះវិសេសវិសាលណាស់។ តែបើចេះតែទ្រឹស្តីមិនយកមកអនុវត្តតាម តើទ្រឹស្តីនោះមានប្រយោជន៍ឬទេ ? ចេះគម្ពីរ៨៤០០០ធម្មក្ខន្ធ តែមិនបានយកធម៌ណាមួយមកជាមូលដ្ឋាននៃការប្រតិបត្តិ នោះឈ្មោះថាល្ងង់វិញទេ។ អាចារ្យស្លឹករឹត ខ្លះចេះតែទូន្មានប្រៀនប្រដៅអ្នកដទៃ មានវិជ្ជាពេញខួរក្បាល តែយោងខ្លួនឯងមិនផុតពីអបាយមុខទាំង៤ តើមានប្រយោជន៍អ្វី ?

ព្រះពុទ្ធសាសនាដែលពិតនោះ គឺប្រតិបត្តិទៅមិនក្តៅក្រហាយ មិនកើតជំលោះ ទាស់ទែងខ្វែងគំនិត មិនវិវាទនឹងគ្នា មិនឱ្យកើតសង្គ្រាម មិនឱ្យបង្ហូរឈាម និងមិនមានការធ្វើទារុណកម្ម។ ប៉ុន្តែ ប្រទេសយើងជាប្រទេសកាន់ព្រះពុទ្ធសាសនាបែបថេរវាទ (ព្រះសូត្រ ព្រះវិន័យ ព្រះអភិធម្ម) ប្រហែល៩៥% ដែរ តើយ៉ាងណា ?

អ្នកប្រាជ្ញពោលថា : ការចេះពុទ្ធភាសិតមួយម៉ាត់ ហើយប្រតិបត្តិតាមពុទ្ធភាសិតនេះ ប្រសើរជាងអ្នកចេះគម្ពីរ៨៤០០០ធម្មក្ខន្ធ ហើយប្រតិបត្តិតាមសមគួរ បើបុគ្គលយល់ពីធម៌ដែលមានប្រយោជន៍បានតិចតួចក៏ដោយ តែជាអ្នកប្រព្រឹត្តធម៌សមគួរដល់ធម៌ លះបង់លោភៈ ទោសៈ មោហៈ បានជាអ្នកដឹងសព្វគ្រប់ មានចិត្តល្អ មិនប្រកាន់ក្នុងលោកនេះ ឬលោកដទៃរមែងជាអ្នកមានចំណែកនៃសាមញ្ញផល។

មានន័យថា អ្វីៗសុទ្ធតែបញ្ជាក់ពីព្រំដែនរបស់វា។ គ្មានការប្រើប្រាស់ត្រឹមត្រូវ និងមិនត្រឹមត្រូវណាគ្មានព្រំដែននោះទេ។ ប៉ុន្តែ បញ្ហាសំខាន់បំផុត គឺត្រូវចេះប្រើប្រាស់ឱ្យបានសមស្របតាមទេសៈ និងកាល ជាក់ស្តែងទើបទទួលផលល្អ បើប្រើខុសឆ្គងវានឹងនាំឱ្យវិនាសពិត។ បញ្ហាព្រះពុទ្ធសាសនានេះមានមនុស្សជាច្រើនណាស់បានស្គាល់តែសំបកក្រៅ ឱ្យតំលៃលើពិធីផ្សេងៗ ជឿលើភាពសក្តិសិទ្ធនៃពិធីទាំងនោះថា អាចផ្តល់សិរីសួស្តី សុភមង្គល។

គួរអនុវត្តព្រះពុទ្ធសាសនាឱ្យបានត្រឹមត្រូវ :

- ខ្មែរត្រូវរៀន **ធ្វើបុណ្យ** ឱ្យបានត្រឹមត្រូវតាមមាគ៌ាពិតនៃព្រះពុទ្ធសាសនា ទើបអាចរស់ឡើងវិញបានក្នុងសន្តិភាព សេរីភាព សុភមង្គល និងសេចក្តីថ្លៃថ្នូរ។

www.budinst.gov.kh www.elibraryofcambodia.org

- **ធ្វើបុណ្យត្រឹមត្រូវ** គឺរៀនរស់នៅស្របតាមមជ្ឈិមបដិបទា គឺសីល សមាធិ បញ្ញា ដែលជាវិធី ឬកម្មវិធីសំរាប់ ជីវិតដ៏ល្អឥតខ្ចោះ ត្រូវរៀនរស់នៅ និងធ្វើការបំពេញមុខងារក្នុងមេត្តា ករុណាក្នុងសច្ចៈ ខន្តី កតញ្ញូ ។
- **ធ្វើបុណ្យត្រឹមត្រូវ** គឺរៀនធ្វើល្អ ដើម្បីល្អ ល្អទាំងអស់គ្នា សុខចំរើនទាំងអស់គ្នា ប៉ុន្តែមិនចង់រស់ ចង់បាន ចង់មាន ចង់ចេះ ចង់ខ្ពស់ ចង់មានមុខមាត់ តែម្នាក់ឯងទេ ។
- **ធ្វើបុណ្យត្រឹមត្រូវ** គឺរៀនគ្រប់គ្រងសង្គមតាមលទ្ធិប្រជាធិបតេយ្យ ឬធម្មាធិបតេយ្យ ដែលឱ្យតំលៃលើគោលការណ៍ច្បាប់ ធម៌វិន័យ ធម្មនុញ្ញ ស្ថាប័នជាតិ ប្រយោជន៍រួម យុត្តិធម៌ក្នុងសង្គម ប៉ុន្តែ មិនមែនរឿងបុគ្គល អត្តានិយម គ្រួសារ បក្សពួក គូកនទេ ។
- សំរាប់មេដឹកនាំ **ធ្វើបុណ្យត្រឹមត្រូវ** ត្រូវបន្ថែមទសពិធរាជធម៌ ជាធម៌ សីលធម៌ សំរាប់ព្រះមហាក្សត្រ ឬប្រធានាធិបតី ប្រមុខរដ្ឋ នាយករដ្ឋមន្ត្រី ប្រធានបក្ស ប្រធានសហគមន៍ ចៅអធិការវត្ត មេឃុំ គឺរៀនដើរតួជា **ធម្មិក** ដែលមានន័យថា **អ្នកប្រកបដោយធម៌** ។
- **ធ្វើបុណ្យត្រឹមត្រូវ** គឺត្រូវស្គាល់សិទ្ធ និងករណីកិច្ចជាប្រជាពលរដ្ឋ ស្គាល់សេរីភាព និងការទទួលខុសត្រូវ ចេះប្រើសេរីភាព ចេះគោរពសេរីភាពអ្នកដទៃ ។
- **ធ្វើបុណ្យត្រឹមត្រូវ** គឺត្រូវគោរពសិទ្ធមនុស្ស
- **ធ្វើបុណ្យត្រឹមត្រូវ** គឺត្រូវរៀនដោះស្រាយបញ្ហាក្នុងសង្គម ដោយសន្តិវិធី ដោយសំរុះសំរួល **ចេះឯង ឱ្យក្រែងចេះគេ** ។

**សន្និដ្ឋាន**

សង្គ្រាមនៅកម្ពុជាខ្លាំង ខ្សោយ១ជាងពីរទសវត្សចុងក្រោយ ធ្វើឱ្យកម្ពុជាហិនហោចគ្រប់វិស័យ ។ មហាវិនាសកម្មនេះ បណ្តាលឱ្យមានហេតុជាច្រើន ។ ក្នុងចំនោមហេតុទាំងនោះ មានការប្រើប្រាស់ព្រះពុទ្ធសាសនាមិនសូវត្រឹមត្រូវ ជាហេតុមួយសំខាន់ដែរ ។

តាំងពីព្រះពុទ្ធសាសនា មានវត្តមាននៅលើទឹកដីកម្ពុជាមក យើងឃើញថា : មនុស្សខ្មែរដែលប្រើប្រាស់ព្រះពុទ្ធសាសនាមានលក្ខណៈច្បាប់ លក្ខណៈធម្មាធិបតេយ្យមានភាគតិចណាស់ ។

ការជ្រកក្រោមផ្លាកព្រះពុទ្ធសាសនា ប៉ុន្តែ ខ្លឹមសារផ្សេង ជារឿងមួយគួរឱ្យចាប់អារម្មណ៍ ។ ការប្រើប្រាស់ព្រះពុទ្ធសាសនាត្រឹមត្រូវ ឬមិនត្រឹមត្រូវ សុទ្ធតែស្ថិតក្នុងដែនកំណត់ ។ **អ្នកប្រជាធិបតេយ្យ** គឺជាអ្នកកាន់តាមព្រះពុទ្ធសាសនាហ្នឹងឯង ព្រះពុទ្ធសាសនាយកច្បាប់ជាធំ យកធម៌ជាធំ ( ធម្មាធិបតេយ្យ ) យកប្រយោជន៍រួមជាធំ យកសង្ឃជាធំ ។ ខាងគ្រហស្ថ អំណាចគ្រប់យ៉ាងចេញពីរាស្ត្រ ខាងព្រះពុទ្ធសាសនា អ្វី១សំរេចចេញពីសង្ឃ យកសង្ឃជា

www.budinst.gov.kh www.elibraryofcambodia.org

ធំ។ ខាងផ្លូវលោក យករដ្ឋធម្មនុញ្ញរបស់ជាតិជាគោល ក្នុងសង្គមសង្ឃ ត្រូវយកធម៌វិន័យជាគោល ជាមាត្រាទេសក៏ ជាធម្មនុញ្ញរបស់សង្ឃ។ ទម្រង់ គ្រប់គ្រងបែបនេះឯង ជាទំរង់គ្រប់គ្រងបែបប្រជាធិបតេយ្យ។

ហេតុនេះ ដើម្បីផលប្រយោជន៍ជាតិ ផលប្រយោជន៍សហគមន៍ សង្គម គ្រួសារ និងបុគ្គល យើងគួរជួយរួមចំណែកប្រើប្រាស់ព្រះពុទ្ធសាសនាកំរិតណា កុំឱ្យចាកឃ្លាតឆ្ងាយពីធម៌វិន័យ មិនគម្ពីរនិយម អភិរក្ស គឺស្ថិតនៅក្នុងគំនិតមួយសមស្របតាមគោលធម៌ អប់រំខ្ពស់។ ព្រោះតាំងពីដើមក៏ដូចបច្ចុប្បន្នដែរ ព្រះពុទ្ធសាសនាជាបរិដ្ឋានសង្គមខ្មែរយ៉ាងធំធេង។ ផ្ទុយទៅវិញ ការប្រើប្រាស់ខុសឆ្គងមិនផ្អែកលើធម្មៈពិតប្រាកដ ច្បាស់លាស់ ជាអំពើបន្ថោកបន្ទាបខ្លួនឯង ជាតិឯង ជាបុព្វហេតុនាំឱ្យវប្បធម៌រលំ ជាតិរលាយ។ ព្រោះធម្មៈ គឺច្បាប់ :

ការបង្រៀនទាំងអស់របស់ព្រះពុទ្ធ អាចសរុបមកនៅត្រឹមតែពាក្យមួយ គឺ **ធម្មៈ**។ ច្បាប់សុចរិតនេះ មិនគ្រាន់តែអត្ថិភាពនៅក្នុងទឹកចិត្តមនុស្សទេ ថែមទាំងអត្ថិភាពនៅក្នុងសកលលោកផងដែរ។ សកលលោកទាំងមូល គឺជាតំណាង ឬការផ្សាយ និងធម្មៈ។ ច្បាប់ធម្មជាតិ ដែលវិទ្យាសាស្ត្រទំនើបបានរកឃើញ គឺជាការផ្សព្វផ្សាយរបស់ធម្មៈ។

ប្រសិនបើព្រះចន្ទរះ និងលិច គឺដោយសារតែធម្មៈ ព្រោះធម្មៈ គឺជាច្បាប់ដែលស្ថិតនៅក្នុងសកលលោកដែលធ្វើអំពើ នៅក្នុងវិធីសិក្សារូបវិទ្យា សត្វវិទ្យា រុក្ខវិទ្យា និងតារាវិទ្យា។ ធម្មៈអត្ថិភាពនៅក្នុងសកលលោក ដូចដែលធម្មៈអត្ថិភាពនៅក្នុងទឹកចិត្ត មនុស្ស។ ប្រសិនបើ មនុស្សរស់នៅដោយធម្មៈ មនុស្សនឹងគេចផុតពីអាចិកំបាំង និងសំរេចបាននិព្វាន។

Dhamma is the law :

"All the teachings of the Buddha can be summed up in one word : "Dhamma". This law of righteousness, exists not only in man's heart but it exists in the universe also. All the universe is an embodiment or revelation of Dhamma. The laws of nature which modern science have discovered are revelations of Dhamma.

If the moon rises and sets, it is because of Dhamma, for Dhamma is that law residing in the universe that makes matter act in the ways studied in physics, chemistry, zoology, botany and astronomy. Dhamma exists in the universe just as Dhamma exists in the heart of man. If man live by Dhamma, he will escape misery and attain Nibbana".

គួរជៀសវាងពាក្យចាស់ពោលថា : **គ្នាច្រើនអន្សមខ្លោច គ្នាតិចស្រួសមោចអន្សមឆៅ** ។

www.budinst.gov.kh www.elibraryofcambodia.org

# ឯកសារពិគ្រោះ

## ១. ជាភាសាខ្មែរ

១- លោក កាន់ ម៉ន "[illegible]" ភ្នំពេញ ១៩៩៥

២- ព្រះសាសនមុនី ហ៊ិម ហួរ វត្តឧណ្ណាលោម

៣- ព្រះភិក្ខុធម្មបាល ខៀវ ជុំ "សត្តបរិត្ត" ភ្នំពេញ ១៩៧២

៤- លោកស្រី ឡុង ម៉ិច "ពិធីបុណ្យតាមប្រពៃណីខ្មែរ" ឆ្នាំ១៩៩៥

៥- សម្ដេចសង្ឃរាជ ជួន ណាត "ទស្សនាវដ្ដីពុទ្ធចក្រ" លេខ៧ / ១៩៦២

៦- លោកស្រី ត្រឹង ងា "អរិយធម៌ខ្មែរ" ភ្នំពេញ

៧- ព្រះមហាឧត្តមវី ប៉ាំ ផាត់ សំណាង "ធម្មឧបមា" ភ្នំពេញ ១៩៥១

៨- លោក ទេព មៃរុក "ឧបត្ថម្ភអរិយធម៌ខ្មែរសង្ខេប"

៩- ព្រះវិញ្ញូ អក្សរមុះ ឆ្លាស់ : ធម្មសង្គ្រោះ ការប្រែប្រវត្តិមហាសាសនវង្ស

១០- លោក ម៉ ឈោ "ព្រះពុទ្ធសាសនា និងសង្គមខ្មែរ" ភ្នំពេញ ១៩៩៤

១១- លោក ឌិត រ៉ែប "កម្ពុជសុរិយា" លេខ១ ពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ ១៩៥៧

១២- សម្ដេចព្រះសុគន្ធាធិបតី ជាំ "ទស្សនាវដ្ដីពុទ្ធចក្រ" លេខ២៧ / ១៩៦២

១៣- លោកស្រីសាស្ត្រាចារ្យ ហ៊ែន សាវឿន "សាសនាសកលលោក" ភ្នំពេញ ១៩៦៩

១៤- សម្ដេចព្រះសុមេធាធិបតី គុណ ឆេង "ទស្សនាវដ្ដីពុទ្ធចក្រ" លេខ៧ / ១៩៦២

១៥- លោក [illegible] ព្រះពុទ្ធប្រវត្តិ ភ្នំពេញ ១៩៩៧

១៦- សម្ដេចសង្ឃរាជ ទៀង "ទស្សនាវដ្ដីពុទ្ធចក្រ" លេខ២៧ / ១៩៦២

១៧- លោក [illegible] "ប្រវត្តិសង្ខេបព្រះពុទ្ធសាសនានៅកម្ពុជា" ភ្នំពេញ ១៩៩[illegible]

១៨- សម្ដេចព្រះមហាសុមេធាធិបតី [illegible] "កម្ពុជសុរិយា" លេខ[illegible] វត្តឧណ្ណាលោម

## ២. ជាភាសាបរទេស

១- Montri Umanjam "BUDDHISM IN THAI LIVE" Bangkok, Thailand, 1981.

២- Louis Finot "BUDDHISM" Phnom Penh, 1964.


www.budinst.gov.kh www.elibraryofcambodia.org

# ជីវប្រវត្តិ



**ខ្លុត ធីតា** *KHLOT THYDA*

កើតនៅថ្ងៃទី១ ខែមករា ឆ្នាំ១៩៤៦ ស្រុកក្រគរ ខេត្តពោធិ៍សាត់

ឪពុកឈ្មោះ ឡុង ខ្លុត

ម្ដាយឈ្មោះ នូរ យ៉ិន

**កិច្ចការរដ្ឋបាល គ្រប់គ្រង បច្ចេកទេស បង្រៀន...**

១- គិលានុបដ្ឋាយិកា នៅមន្ទីរពេទ្យពោធិ៍សាត់ ឆ្នាំ១៩៦៦-១៩៧០

២- ប្រធានបច្ចេកទេសពិសោធន៍ នៅមន្ទីរពេទ្យពោធិ៍សាត់ ឆ្នាំ១៩៧០-១៩៧២

៣- អ្នកបច្ចេកទេសពិសោធន៍ នៅមន្ទីរពេទ្យព្រះកេតុមាលា ឆ្នាំ១៩៧២-១៩៧៣

៤- អ្នកបច្ចេកទេសពិសោធន៍ នៅវិទ្យាស្ថានជីវសាស្ត្រភ្នំពេញ ឆ្នាំ១៩៧៣-១៩៧៥

៥- កសិករនៅខេត្តបាត់ដំបង ឆ្នាំ១៩៧៥-១៩៧៩

៦- អ្នកបច្ចេកទេសពិសោធន៍ នៅមន្ទីរពិសោធន៍សុខាភិបាល ឆ្នាំ១៩៨១-១៩៨២

៧- សាស្ត្រាចារ្យភូមិវិទ្យា និងសីលធម៌នៅសាកលវិទ្យាល័យភ្នំពេញ ឆ្នាំ១៩៨២-១៩៨៥

៨- សិក្សានៅសាលា ធូឌឹក ព្រៃនគរ ឆ្នាំ១៩៨៥-១៩៨៦

៩- បង្រៀនទ្រឹស្ដី ម៉ាក្សលេនីន នៅសាកលវិទ្យាល័យភ្នំពេញ មហាវិទ្យាល័យពេទ្យ សាលាបច្ចេកទេស
មិត្តភាពកម្ពុជា-សូវៀត សាលាចំការដូង សាលាគរុមធ្យមទី ១ ៧ ។ ឆ្នាំ១៩៨៦-១៩៩០

១០- ថ្នាក់បណ្ឌិត :

- ឯកទេស : ទស្សនវិជ្ជា គ្រឹះស្ថាន : សាកលវិទ្យាល័យ ហាណូយទី១
- ឆ្នាំសិក្សា : ១៩៩១-១៩៩៥ ចំណងជើងនិក្ខេបបទ : "ជំហានដំបូងនៃ ការប្រើប្រាស់ វិទ្យាសាស្ត្រសាសនា ដើម្បីស្វែងយល់ពី តួនាទីព្រះពុទ្ធសាសនានៅកម្ពុជា"
- ទីកន្លែងធ្វើការបច្ចុប្បន្ន : សាកលវិទ្យាល័យភូមិន្ទភ្នំពេញ ។
- មុខងារបច្ចុប្បន្ន : នាយករងដេប៉ាតឺម៉ង់ទស្សនវិជ្ជា

១១- សាស្ត្រាចារ្យបង្រៀននៅ មហាវិទ្យាល័យទស្សនវិជ្ជា

១២- ជាអ្នកប្រជុំវិទ្យាសាស្ត្រក្នុង និងក្រៅប្រទេស (ថ្នាក់ជាតិ និងអន្តរជាតិ) ពិសេសប្រទេសអាស៊ីអាគ្នេយ៍ជិតខាង

www.budinst.gov.kh www.elibraryofcambodia.org